

ឯកសារគម្ពីព្រះត្រៃបិដកស្កានគេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ។ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៕

www.5000-years.org

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ បញ្ចកនិបាត
# បញ្ចមភាគ
# ៤៤

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៤៩៦

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស បញ្ចកនិបាតោ

# បញ្ចមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកោ

## សេក្ខពលវគ្គោ បឋមោ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច បញ្ចិមានិ ភិក្ខវេ សេក្ខពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សេក្ខពលានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ សទ្ធាពលេន សមន្នាគតា ភវិស្សាម

# សុត្តន្តបិដក

# អង្គុត្តរនិកាយ បញ្ចកនិបាត

## បញ្ចមភាគ

---

*សូមថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

## បឋមបណ្ណាសក

## សេក្ខពលវគ្គ ទី ១

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវិរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកបដោយកម្លាំងសទ្ធា

សេក្ខពលេន ហិរិពលេន សមន្នាគតា ភវិស្សាម សេក្ខពលេន ឱត្តប្បពលេន សមន្នាគតា ភវិស្សាម សេក្ខពលេន វីរិយពលេន សមន្នាគតា ភវិស្សាម សេក្ខពលេន បញ្ញាពលេន សមន្នាគតា ភវិស្សាម សេក្ខពលេនាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ (១)

(២) បញ្ចិមានិ ភិក្ខវេ សេក្ខពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ ។ កតមញ្ច ភិក្ខវេ សទ្ធាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាពលំ ។

---

១ ម. ឥតោ បរំ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ បឋមំ ។

ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងហិរិ ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងឱត្តប្បៈដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងវីរិយៈ ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។

(៦) ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាងតើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿ ពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ ដោយវិជ្ជានឹងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាស្មើគ្មាន ជាសារថីទូន្មាននូវបុរស ដែលគួរទូន្មាន ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសទ្ធា ។

កតមញ្ច ភិក្ខវេ ហិរិពលំ ។ ឥធ ភិក្ខវេ អរិយ-
សាវកោ ហិរិមា ហោតិ ហិរិយតិ កាយទុច្ចរិតេន
វចីទុច្ចរិតេន មនោទុច្ចរិតេន ហិរិយតិ បាបកានំ
អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ ភិក្ខវេ
ហិរិពលំ ។ កតមញ្ច ភិក្ខវេ ឱត្តប្បពលំ ។ ឥធ
ភិក្ខវេ អរិយសាវកោ ឱត្តប្បី ហោតិ ឱត្តប្បតិ
កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ឱត្តប្បតិ
បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ
វុច្ចតិ ភិក្ខវេ ឱត្តប្បពលំ ។ កតមញ្ច ភិក្ខវេ
វីរិយពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធ-
វីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ
កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហប-
រក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ឥទំ
វុច្ចតិ ភិក្ខវេ វីរិយពលំ ។ កតមញ្ច ភិក្ខវេ
បញ្ញាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា
ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ
អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា

ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងហិរិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានហិរិអៀនខ្មាស ចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត អៀនខ្មាសចំពោះការប៉ះពាល់នូវអកុសលធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងហិរិ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងឱត្តប្បៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានឱត្តប្បៈ តក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត តក់ស្លុតចំពោះការប៉ះពាល់នូវអកុសលធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវីរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ ដើម្បីញ៉ាំងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីខ្មីឃ្មាតដ៏មាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងវីរិយៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានបញ្ញា បរិបូណ៌ដោយបញ្ញា ដែលអាចកំណត់ដឹងនូវការកើតនឹងការរលត់ (នូវខន្ធ) ជាបញ្ញាដ៏ប្រសើរ សម្រាប់ទំលុះទំលាយ (នូវគំនរកិលេស) ជាបញ្ញាអាចញ៉ាំងវដ្តទុក្ខ ឲ្យអស់ទៅដោយប្រពៃ

ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សេក្ខពលានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ សទ្ធាពលេន សមន្នាគតា ភវិស្សាម សេក្ខពលេន ហិរិពលេន... ឱត្តប្បពលេន... វីរិយពលេន... បញ្ញាពលេន សមន្នាគតា ភវិស្សាម សេក្ខពលេនាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៣] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់ សេក្ខបុគ្គលមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកប ដោយកម្លាំងសទ្ធា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ដោយកម្លាំងហិរិ . . . ដោយកម្លាំងឱត្តប្បៈ . . . ដោយកម្លាំងវីរិយៈ . . . គួរជាអ្នកប្រកបដោយកម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

(៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីតានតឹង ចង្អៀតចង្អល់ ក្រវល់ក្រវាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ជាអ្នកខ្ជិល ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីតានតឹង ចង្អៀតចង្អល់ ក្រវល់ក្រវាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ។

បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខា ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខាតិ ។

(៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តែងនៅជាសុខ មិនមានសេចក្តីតានតឹង មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយក្នុងបច្ចុប្បន្នឡើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ សុគតិនឹងមានប្រាកដ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ មានវីរិយៈប្រារព្ធ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្តីតានតឹង មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្នឡើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ សុគតិនឹងមានប្រាកដ ។

(៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ជាអ្នកខ្ជិល ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង៥យ៉ាងនេះឯង

យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ អារទ្ធវិរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៥) យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ តស្ស ទិដ្ឋេវ ធម្មេ បញ្ច សហធម្មិកា វាទានុបាតា គារយ្ហំ ឋានំ(១) អាគច្ឆន្តិ ។ កតមេ បញ្ច ។ សទ្ធាបិ នាម តេ នាហោសិ កុសលេសុ ធម្មេសុ ហិរិបិ នាម តេ នាហោសិ កុសលេសុ ធម្មេសុ ឱត្តប្បំបិ នាម តេ នាហោសិ កុសលេសុ ធម្មេសុ វិរិយំបិ នាម តេ នាហោសិ កុសលេសុ ធម្មេសុ បញ្ញាបិ នាម តេ នាហោសិ កុសលេសុ ធម្មេសុ ។ យោ ហិ កោចិ ភិក្ខវេ

---

១ ឱ. ម. វាទានុវាទា គារយ្ហា ឋានា ។

នឹងធ្លាក់ទៅកាន់នរក ដូចគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង នឹងទៅកើតកាន់ស្ថានសួគ៌ ដូចគេនាំយកទៅដម្កល់ទុក ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ មានវីរិយៈប្រារព្ធ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតកាន់ស្ថានសួគ៌ ដូចគេនាំយកទៅដម្កល់ទុក ។

(៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុឬភិក្ខុនី លាសិក្ខាត្រឡប់មកកាន់ភេទដ៏ថោកទាប ពាក្យតូចពាក្យធំ សមតាមហេតុ ៤ យ៉ាង រមែងមកកាន់ស្ថាន ដែលគួរតិះដៀលចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ពាក្យតូចពាក្យធំ ៤ យ៉ាង តើអ្វីខ្លះ ។ គឺសូម្បីតែសទ្ធាក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ សូម្បីហិរិក្នុងកុសលធម៌របស់អ្នក ក៏មិនមាន ១ សូម្បីឱត្តប្បៈក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ សូម្បីសេចក្តីខ្មី-ឃ្មាតក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ សូម្បីបញ្ញា (ការចេះដឹង) ក្នុងកុសលធម៌របស់អ្នកក៏មិនមាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ

ភិក្ខុ វា ភិក្ខុនី វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ តស្ស ទិដ្ឋេវ ធម្មេ បញ្ច សហធម្មិកា វាទានុវាទា គារយ្ហំ ឋានំ អាគច្ឆន្តិ ។ យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អស្សុមុខោបិ រុទមានោ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ តស្ស ទិដ្ឋេវ ធម្មេ បញ្ច សហធម្មិកា បាសំសំ ឋានំ[១] អាគច្ឆន្តិ ។ កតមេ បញ្ច ។ សទ្ធាបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ ហិរិបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ ឱត្តប្បំបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ វីរិយំបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ បញ្ញាបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ ។ យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អស្សុមុខោបិ រុទមានោ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ

---

១ ម. បាសំសា ឋានា ។

ភិក្ខុ ឬភិក្ខុនី លាសិក្ខាត្រឡប់មកកាន់ភេទដ៏ថោកទាប ពាក្យតូចពាក្យធំ សមតាមហេតុ ៥ យ៉ាងនេះ រមែងមកកាន់ស្ថាន ដែលគួរតិះដៀល ចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុ ឬភិក្ខុនី មានមុខជោក ដោយទឹកភ្នែក យំយែក ចំប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ទាំងទុក្ខទាំងទោមនស្ស ពាក្យ (សរសើរ) សមតាមហេតុ ៥ យ៉ាង រមែងមកកាន់ស្ថាន ដែលគួរសរសើរចំពោះបុគ្គលនោះ ក្នុងបច្ចុប្បន្ន ។ ពាក្យ (សរសើរ) សមតាមហេតុ ៥ យ៉ាង តើអ្វីខ្លះ ។ គឺសទ្ធាក្នុងកុសលធម៌របស់អ្នកក៏មាន ១ ហិរិក្នុងកុសលធម៌របស់អ្នកក៏មាន ១ ឱត្តប្បៈក្នុងកុសលធម៌របស់អ្នកក៏មាន ១ សេចក្តីខ្មីឃ្មាតក្នុងកុសលធម៌របស់អ្នកក៏មាន ១ បញ្ញា (ការចេះដឹង) ក្នុងកុសលធម៌របស់អ្នកក៏មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាភិក្ខុឬភិក្ខុនី មានមុខជោក ដោយទឹកភ្នែក យំយែក ចំប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ទាំងទុក្ខទាំងទោមនស្ស

តស្ស ទិដ្ឋេវ ធម្មេ ឥមេ បញ្ច សហធម្មិកា បាសំសា ឋានា អាគច្ឆន្តិ ។

[៦] ន តាវ ភិក្ខវេ អកុសលស្ស សមាបត្តិ ហោតិ យាវ សទ្ធា បច្ចុបដ្ឋិតា ហោតិ កុសលេសុ ធម្មេសុ យតោ ច ខោ ភិក្ខវេ សទ្ធា អន្តរហិតា ហោតិ អស្សទ្ធិយំ បរិយុទ្ធាយ (១) តិដ្ឋតិ អថ អកុសលស្ស សមាបត្តិ ហោតិ ។ ន តាវ ភិក្ខវេ អកុសលស្ស សមាបត្តិ ហោតិ យាវ ហិរិ បច្ចុបដ្ឋិតា ហោតិ កុសលេសុ ធម្មេសុ យតោ ច ខោ ភិក្ខវេ ហិរិ អន្តរហិតា ហោតិ អហិរិកំ បរិយុទ្ធាយ តិដ្ឋតិ អថ អកុសលស្ស សមាបត្តិ ហោតិ ។ ន តាវ ភិក្ខវេ អកុសលស្ស សមាបត្តិ ហោតិ យាវ ឱត្តប្បំ បច្ចុបដ្ឋិតំ ហោតិ កុសលេសុ ធម្មេសុ យតោ ច ខោ ភិក្ខវេ ឱត្តប្បំ អន្តរហិតំ ហោតិ អនោត្តប្បំ បរិយុទ្ធាយ តិដ្ឋតិ អថ អកុសលស្ស សមាបត្តិ ហោតិ ។

---

១ ឱ. ម. បរិយុដ្ឋាយ ។ កត្ថចិ បោត្ថកេ អហិរិកំ បរិយុទ្ធាយាតិ ទិស្សតិ ។

ពាក្យ (សរសើរ) សមតាមហេតុ ៥ យ៉ាងនេះឯង រមែងមកកាន់ស្ថានដែលគួរសរសើរ ចំពោះមុខបុគ្គលនោះ ក្នុងបច្ចុប្បន្ននេះ ។

[៦] ម្នាលភិក្ខុទាំងឡាយ សទ្ធាដែលបុគ្គលដំកល់ស៊ប់ ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសលធម៌ ក៏មិនមានត្រឹមណោះ ម្នាលភិក្ខុទាំងឡាយ លុះសទ្ធាសាបសូន្យទៅ អស្សទ្ធិយៈ (ការមិនជឿ) រួបរឹតក្នុងកាលណា ការប៉ះពាល់នូវអកុសលធម៌ មានក្នុងកាលណោះ ។ ម្នាលភិក្ខុទាំងឡាយ ហិរិដែលបុគ្គលដម្កល់ស៊ប់ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសលធម៌ ក៏មិនមានត្រឹមណោះ ម្នាលភិក្ខុទាំងឡាយ លុះហិរិ សាបសូន្យទៅ អហិរិកៈ (សេចក្ដីមិនអៀនខ្មាស) រួបរឹតក្នុងកាលណា ការប៉ះពាល់នូវអកុសលធម៌ ក៏មានក្នុងកាលណោះ ។ ម្នាលភិក្ខុទាំងឡាយ ឱត្តប្បៈ ដែលបុគ្គលដំកល់ស៊ប់ ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសលធម៌ ក៏មិនមានត្រឹមណោះ ម្នាលភិក្ខុទាំងឡាយ លុះឱត្តប្បៈសាបសូន្យទៅ អនោត្តប្បៈ (សេចក្ដីមិនតក់ស្លុត) រួបរឹតក្នុងកាលណា ការប៉ះពាល់នូវអកុសលធម៌ ក៏មានក្នុងកាលណោះ ។

ន តាវ ភិក្ខវេ អកុសលស្ស សមាបត្តិ ហោតិ យាវ វីរិយំ បច្ចុបដ្ឋិតំ ហោតិ កុសលេសុ ធម្មេសុ យតោ ច ខោ ភិក្ខវេ វីរិយំ អន្តរហិតំ ហោតិ កោសជ្ជំ បរិយុដ្ឋាយ តិដ្ឋតិ អថ អកុសលស្ស សមាបត្តិ ហោតិ ។ ន តាវ ភិក្ខវេ អកុសលស្ស សមាបត្តិ ហោតិ យាវ បញ្ញា បច្ចុបដ្ឋិតា ហោតិ កុសលេសុ ធម្មេសុ យតោ ច ខោ ភិក្ខវេ បញ្ញា អន្តរហិតា ហោតិ ទុប្បញ្ញា បរិយុដ្ឋាយ តិដ្ឋតិ អថ អកុសលស្ស សមាបត្តិ ហោតីតិ ។

(៧) យេភុយ្យេន ភិក្ខវេ សត្តា កាមេសុ លឡិតា[១] អសិតព្យាភង្គឹ ភិក្ខវេ កុលបុត្តោ ឱហាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សទ្ធោ បព្វជិតោ កុលបុត្តោតិ អលំ វចនាយ ។ តំ កិស្ស ហេតុ ។ លព្ភា ហិ ភិក្ខវេ យោព្វនេន កាមា តេ ច ខោ យាទិសា វា តាទិសា វា ។

---

១ ឱ. បលាឡិតា ។

ម្នាលភិក្ខុទាំងឡាយ វីរិយៈ ដែលបុគ្គលដម្កល់ស៊ប់ ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសល ក៏មិនមានត្រឹមនោះ ម្នាលភិក្ខុទាំងឡាយ លុះវីរិយៈ សាបសូន្យទៅ កោសជ្ជៈរួបរឹត ក្នុងកាលណា ការប៉ះពាល់នូវអកុសល ក៏មាន ក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ បញ្ញាដែលបុគ្គលដម្កល់ស៊ប់ ក្នុងកុសលធម៌ មានត្រឹមណា ការប៉ះពាល់នូវអកុសល ក៏មិនមានត្រឹមនោះ ម្នាលភិក្ខុទាំងឡាយ លុះបញ្ញាសាបសូន្យទៅ ទុប្បញ្ញា (ការអ័ប្បបញ្ញា) រួបរឹត ក្នុងកាលណា ការប៉ះពាល់នូវអកុសល ក៏មាន ក្នុងកាលនោះ ។

(៧) ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយច្រើនតែ ជាប់ចិត្តក្នុងកាម ម្នាលភិក្ខុទាំងឡាយ បើកុលបុត្តលះបង់កណ្តៀវនិងអង្រែមក ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស គួរហៅថា កុលបុត្តអ្នកមានសទ្ធាចេញបួស ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា កុលបុត្តអ្នកមានវ័យ គួរបាននូវកាមទាំងឡាយ តាមតែបែបណា ។

យេ ច ភិក្ខវេ ហីនា កាមា យេ ច មជ្ឈិមា កាមា យេ ច បណីតា កាមា សព្វេ កាមាត្វេវ សង្ខំ គច្ឆន្តិ ។ សេយ្យថាបិ ភិក្ខវេ ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ ធាតិយា បមាទមន្វាយ កដ្ឋំ វា កឋលំ វា មុខេ អាហរេយ្យ តមេនំ ធាតី សីឃំ សីឃំ មនសិ-ករេយ្យ សីឃំ សីឃំ មនសិករិត្វា សីឃំ សីឃំ អាហរេយ្យ នោ ចេ សក្កុណេយ្យ សីឃំ សីឃំ អាហរិតុំ វាមេន ហត្ថេន សីសំ[១] បរិគ្គហេត្វា ទក្ខិណេន ហត្ថេន វង្កង្គុលំ ករិត្វា សលោហិតំបិ អាហរេយ្យ ។ តំ កិស្ស ហេតុ ។ អត្ថេសោ ភិក្ខវេ កុមារស្ស វិហេសា នេសា នត្ថីតិ វទាមិ ។ ករណីយញ្ច ខោ ឯតំ ភិក្ខវេ ធាតិយា អត្ថកាមាយ ហិតេសិនិយា អនុកម្បិកាយ អនុកម្បំ ឧបាទាយ ។ យតោ ច ខោ ភិក្ខវេ សោ កុមារោ វុឌ្ឍោ ហោតិ អលំបញ្ញោ

---

១ ឱ. ម. សីសំ ។

ម្នាលភិក្ខុទាំងឡាយ ទោះកាមទាំងឡាយណា ជាកទាបក្តី កាមទាំងឡាយណា កណ្តាលក្តី កាមទាំងឡាយណា ឧត្តមក្តី កាមទាំងអស់នោះ ក៏រាប់ថាជាកាមដូចៗគ្នា ។ ម្នាលភិក្ខុទាំងឡាយ ដូចកុមារតូចទន់ខ្ចីដេកផ្ងារ បៀមកំណាត់ឈើ ឬអំបែងក្នុងមាត់ ព្រោះអាស្រ័យសេចក្តីប្រហែសរបស់ស្រីមេដោះៗ (នោះលុះឃើញហើយ) ក៏យកចិត្តទុកដាក់ ដោយប្រញាប់ប្រញាល់ លុះយកចិត្តទុកដាក់ ដោយប្រញាប់ប្រញាល់ហើយ ក៏នាំចេញនូវកំណាត់ឈើ ឬអំបែងនោះដោយប្រញាប់ប្រញាល់ ប្រសិនបើមិនអាចនឹងនាំចេញ ដោយប្រញាប់ប្រញាល់បានទេ ក៏យកដៃឆ្វេងត្រកងដោយរហ័ស ហើយធ្វើម្រាមចង្អុលដៃខាងស្តាំឲ្យខុប ខ្វេះយកចេញដោយទាំងឈាមមកផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ (ខ្វាប) សេចក្តីលំបាកនុ៎ះនឹងមានដល់កុមារ តថាគតមិនពោលថា សេចក្តីលំបាកនុ៎ះមិនមានដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ស្រីមេដោះដែលមានប្រាថ្នា សេចក្តីចំរើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គួរតែធ្វើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ លុះកាលណា កុមារនោះ ចំរើនធំឡើង មានបញ្ញាសមគួរហើយ

អនបេក្ខា បន(១) ភិក្ខវេ ទានី តស្មិំ កុមារស្មិំ ហោតិ អត្តគុត្តោទានិ កុមារោ ទាលំ បមាទាយាតិ ឯវមេវ ខោ ភិក្ខវេ យាវកីវញ្ច ភិក្ខុនោ សទ្ធាយ អកតំ ហោតិ កុសលេសុ ធម្មេសុ ហិរិយា អកតំ ហោតិ កុសលេសុ ធម្មេសុ ឱត្តប្បេន អកតំ ហោតិ កុសលេសុ ធម្មេសុ វីរិយេន អកតំ ហោតិ កុសលេសុ ធម្មេសុ បញ្ញាយ អកតំ ហោតិ កុសលេសុ ធម្មេសុ អនុរក្ខិតព្វោ តាវ មេ សោ ភិក្ខវេ ភិក្ខុ ហោតិ ។ យតោ ច ខោ ភិក្ខវេ ភិក្ខុនោ សទ្ធាយ កតំ ហោតិ កុសលេសុ ធម្មេសុ ហិរិយា កតំ ហោតិ កុសលេសុ ធម្មេសុ ឱត្តប្បេន កតំ ហោតិ កុសលេសុ ធម្មេសុ វីរិយេន កតំ ហោតិ កុសលេសុ ធម្មេសុ បញ្ញាយ កតំ ហោតិ កុសលេសុ ធម្មេសុ អនបេក្ខោ បនាហំ(២) ភិក្ខវេ តស្មិំ(៣) ហោមិ អត្តគុត្តោទានិ ភិក្ខុ ទាលំ បមាទាយាតិ ។

---

១ ឱ. ម. អនបេក្ខាទានិ ។ ២ ឱ. ម. ទានាហំ ។ ៣ ឱ. ម តស្មិំ ភិក្ខុស្មិំ ។

ម្នាលភិក្ខុទាំងឡាយ ទើបស្រីមេដោះ ក៏មិនសូវគយគន់មើល ចំពោះកុមារនោះទេ ដោយនឹកសង្ឃឹមថា ឥឡូវនេះ កុមារបេះរក្សាខ្លួន លែងមានសេចក្តីប្រហែសធ្វេសហើយ សេចក្តីនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុ មិនធ្វើដោយសទ្ធា ក្នុងកុសលធម៌ មិនធ្វើដោយហិរិ ក្នុងកុសលធម៌ មិនធ្វើដោយឱត្តប្បៈ ក្នុងកុសលធម៌ មិនធ្វើដោយវិរិយៈ ក្នុងកុសលធម៌ មិនធ្វើដោយបញ្ញា ក្នុងកុសលធម៌ ដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតត្រូវតែតាមថែរក្សាភិក្ខុនោះ ដរាបនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះកាលណា ភិក្ខុធ្វើដោយសទ្ធា ក្នុងកុសលធម៌ ធ្វើដោយហិរិ ក្នុងកុសលធម៌ ធ្វើដោយឱត្តប្បៈ ក្នុងកុសលធម៌ ធ្វើដោយបញ្ញា ក្នុងកុសលធម៌ហើយ ម្នាលភិក្ខុទាំងឡាយ ទើបតថាគត ក៏មិនសូវគយគន់មើល ចំពោះភិក្ខុនោះទេ ដោយនឹកសង្ឃឹមថា ឥឡូវនេះ ភិក្ខុនេះ បេះរក្សាខ្លួន លែងមានសេចក្តីប្រហែសធ្វេសហើយ ។

(៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ភិក្ខវេ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ អហិរិកោ ភិក្ខវេ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ អនោត្តប្បី ភិក្ខវេ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ កុសីតោ ភិក្ខវេ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ទុប្បញ្ញោ ភិក្ខវេ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ។ កតមេហិ បញ្ចហិ ។ សទ្ធោ ភិក្ខវេ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ហិរិមា ភិក្ខវេ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ឱត្តប្បី ភិក្ខវេ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ

[៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម (សាសនធម៌) ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានសទ្ធា រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានហិរិ រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានឱត្តប្បៈ រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអប្បឥតបញ្ញា រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្មបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបមិនឃ្លាត រមែងតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានហិរិ រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១

អារទ្ធវីរិយោ ភិក្ខវេ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ បញ្ញវា ភិក្ខវេ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេតិ ។

(៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ អហិរិកោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ អនោត្តប្បី ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ កុសីតោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្មបាន ។

(៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានហិរិ មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានឱត្តប្បៈ មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១

ទុប្បញ្ញោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អគារវោ អប្បតិស្សោ ចវតិ នប្បតិដ្ឋាតិ សទ្ធម្មេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ។ កតមេហិ បញ្ចហិ ។ សទ្ធោ ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ហិរិមា ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ឱត្តប្បី ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ អារទ្ធវិរិយោ ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ បញ្ញវា ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអប្បឥតបញ្ញា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង តែងឃ្លាត មិនតាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា មានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានហិរិ មានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ មានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម មានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា មានសេចក្តីគោរព មានសេចក្តីកោតក្រែង

ន ចវតិ បតិដ្ឋាតិ សទ្ធម្មេ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សគារវោ សប្បតិស្សោ ន ចវតិ បតិដ្ឋាតិ សទ្ធម្មេតិ ។

[១០] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អគារវោ អប្បតិស្សោ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ អហិរិកោ ភិក្ខវេ ភិក្ខុ ... អនោត្តប្បី ភិក្ខវេ ភិក្ខុ ... កុសីតោ ភិក្ខវេ ភិក្ខុ ... ទុប្បញ្ញោ ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អគារវោ អប្បតិស្សោ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សគារវោ

រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង រមែងមិនឃ្លាត តាំងនៅស៊ប់ ក្នុងព្រះសទ្ធម្មបាន ។

[១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានហិរិ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានឱត្តប្បៈ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអ័ប្បឥតបញ្ញា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង មិនគួរនឹងដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានសេចក្តីគោរព

សប្បតិស្សោ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ
វេបុល្លំ អាបជ្ជិតុំ ។ កតមេហិ បញ្ចហិ ។ សទ្ធោ
ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ ភព្វោ
ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ
ហិរិមា ភិក្ខវេ ភិក្ខុ... ឱត្តប្បី ភិក្ខវេ ភិក្ខុ...
អារទ្ធវីរិយោ ភិក្ខវេ ភិក្ខុ... បញ្ញវា ភិក្ខវេ ភិក្ខុ
សគារវោ សប្បតិស្សោ ភព្វោ ឥមស្មឹ ធម្មវិនយេ
វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ ឥមេហិ ខោ ភិក្ខវេ
បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សគារវោ
សប្បតិស្សោ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ
វេបុល្លំ អាបជ្ជិតុន្តិ ។

សេក្ខពលវគ្គោ បឋមោ ។

មានសេចក្ដីកោតក្រែង គួរនឹងដល់នូវសេចក្ដីចំរើន ល្អណាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង គួរនឹងដល់នូវសេចក្ដីចំរើន ល្អណាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានហិរិ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឱត្តប្បៈ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម... ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានបញ្ញា ជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែង គួរនឹងដល់នូវសេចក្ដីចំរើន ល្អណាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង គួរនឹងដល់នូវសេចក្ដីចំរើន ល្អណាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។

ចប់ សេក្ខពលវគ្គ ទី ១ ។

## តស្សុទ្ទានំ

សង្ខិត្តំ វិត្ថតំ ទុក្ខំ
ភតំ សិក្ខាយ បញ្ចមំ
សមាបត្តិ ច កាមេសុ
ចវនា ទ្វេ អគារិកា ។

## ឧទ្ទាននៃសេក្ខពលវគ្គនោះ គឺ:

និយាយអំពីកម្លាំងរបស់សេក្ខបុគ្គលយ៉ាងសង្ខេប ១ កម្លាំងរបស់សេក្ខបុគ្គលយ៉ាងពិស្តារ ១ ភិក្ខុមានធម៌ ៥ យ៉ាង តែងនៅជាទុក្ខ ១ ភិក្ខុមានធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ១ ភិក្ខុឬភិក្ខុនីលាសិក្ខា ១ ជាគំរប់ ៥ ការប៉ះពាល់អកុសល ១ សត្វតែងជាប់ចិត្តក្នុងកាម ១ ភិក្ខុឃ្លាតចាកព្រះសទ្ធម្ម ១ ភិក្ខុមិនមានសេចក្តីគោរព ២ លើក ។

# ពលវគ្គោ

(១១) បុព្វាហំ ភិក្ខវេ អននុស្សុតេសុ ធម្មេសុ អភិញ្ញាវោសានបារមិប្បត្តោ បដិជានាមិ បញ្ចិមានិ ភិក្ខវេ តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ បញ្ច ។ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតីតិ ។

# បឋមបណ្ណាសក ពលវគ្គ

(១១) ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាថាជាអ្នកដល់នូវអរហត្ត ជាទីបំផុតនៃអភិញ្ញាទីដ៏ត្រើយនៃអភិញ្ញា ក្នុងធម៌ដែលមិនធ្លាប់ឮមក ក្នុងកាលមុន ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយកម្លាំងទាំងឡាយណា ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺសីហនាទ ក្នុងកណ្តាលបរិស័ទ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ កម្លាំងតថាគតរបស់តថាគតនោះ មាន ៥ យ៉ាងនេះ ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតប្រកបដោយកម្លាំងទាំងឡាយណា ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺសីហនាទ ក្នុងកណ្តាលបរិស័ទ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ កម្លាំងតថាគតរបស់តថាគតនោះ មាន ៥ យ៉ាងនេះឯង ។

(១២) បញ្ចិមានិ ភិក្ខវេ សេក្ខពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សេក្ខពលានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សេក្ខពលានំ ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ បញ្ញាពលំ ។ សេយ្យថាបិ ភិក្ខវេ កូដាគារស្ស ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ កូដំ ឯវមេវ ខោ ភិក្ខវេ ឥមេសំ បញ្ចន្នំ សេក្ខពលានំ ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ បញ្ញាពលំ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ សទ្ធាពលេន សមន្នាគតា ភវិស្សាម សេក្ខពលេន ហិរិពលេន... ឱត្តប្បពលេន... វីរិយពលេន... បញ្ញាពលេន សមន្នាគតា ភវិស្សាម សេក្ខពលេនាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(១២) ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលនេះ មាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងវីរិយៈ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងរបស់សេក្ខបុគ្គលមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្លាំងរបស់សេក្ខបុគ្គលទាំង ៥ នេះ កម្លាំងបញ្ញា ជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្ទុប (នៃកម្លាំងទាំងពួង) ម្នាលភិក្ខុទាំងឡាយ ដូចផ្ទះកំពូលមានកំពូលជារបស់ប្រសើរ ជាទីប្រជុំព្រម ជាទីអបស្ទុប (នៃទព្វសម្ភារៈទាំងពួង) មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្លាំងរបស់សេក្ខបុគ្គលទាំង ៥ យ៉ាងនេះ កម្លាំងបញ្ញា ជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្ទុប (នៃកម្លាំងទាំងពួង) ក៏មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងគួរជាអ្នកប្រកបដោយកម្លាំងសទ្ធា ដែលជាកម្លាំងរបស់សេក្ខបុគ្គល គួរជាអ្នកប្រកបដោយកម្លាំងហិរិ ... កម្លាំងឱត្តប្បៈ ... កម្លាំងវីរិយៈ ... កម្លាំងបញ្ញា ដែលជាកម្លាំងរបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

(១៣) បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានីតិ ។

(១៤) បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ កតមញ្ច ភិក្ខវេ សទ្ធាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាពលំ ។ កតមញ្ច ភិក្ខវេ វីរិយពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហរតិ

(១៣) ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវិរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។

(១៤) ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវិរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិ-គុណរកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថាកម្លាំងសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវិរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម

អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ឥទំ វុច្ចតិ ភិក្ខវេ វីរិយពលំ ។ កតមញ្ច ភិក្ខវេ សតិពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា ឥទំ វុច្ចតិ ភិក្ខវេ សតិពលំ ។ កតមញ្ច ភិក្ខវេ សមាធិពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ

ដើម្បីលះបង់នូវអកុសលធម៌ ដើម្បីញុំាងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីប្រឹងប្រែងដ៏មុតមាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងវីរិយៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសតិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានសតិប្រកបដោយបញ្ញា ដែលមានសតិ ជាដំនួយដ៏ប្រសើរ ជាអ្នករលឹកនឹកឃើញជាក់នូវអំពើដែលធ្វើរួចយូរហើយខ្លះ នូវសំដីដែលពោលរួចយូរហើយខ្លះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសមាធិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ បានដល់បឋមជ្ឈានដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈ វិចារៈ បានដល់ទុតិយជ្ឈាន ជាគុណជាតមានក្នុងសន្តានខ្លួន មានសេចក្តីជ្រះថ្លាមាំគឺសទ្ធា មានសភាព ជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះលះបង់បីតិផង ជាអ្នកព្រងើយកន្តើយផង មានសតិសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង

យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ ភិក្ខវេ សមាធិពលំ ។ កតមញ្ច ភិក្ខវេ បញ្ញាពលំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានីតិ ។

(១៤) បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ តត្ថ ច ភិក្ខវេ សទ្ធាពលំ ទដ្ឋព្វំ ។ ចតូសុ សោតាបត្តិយង្គេសុ ។

កំបានដល់តតិយជ្ឈាន ដែលព្រះអរិយទាំងឡាយ តែងសរសើរថា បុគ្គលដែលបានដល់តតិយជ្ឈាន រមែងជាអ្នកព្រងើយកន្តើយ មានសតិនៅជាសុខ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះអស់សោមនស្សនិងទោមនស្ស ក្នុងកាលមុនផង ក៏បានដល់ចតុត្ថជ្ឈាន ដែលឥតទុក្ខ ឥតសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់ដឹងនូវការកើតនិងការរលត់ ជាបញ្ញាដ៏ប្រសើរ សម្រាប់ទំលុះទំលាយ (នូវគំនរកិលេស) ជាបញ្ញាអាចញុំាងវដ្តទុក្ខ ឲ្យអស់ទៅដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្លាំងបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។

(១៥) ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវីរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងអង្គនៃសោតាបត្តិ ៤ ។

ឯត្ថ សទ្ធាពលំ ទដ្ឋព្វំ ។ កត្ថ ច ភិក្ខវេ វីរិយពលំ ទដ្ឋព្វំ ។ ចតូសុ សម្មប្បធានេសុ ។ ឯត្ថ វីរិយពលំ ទដ្ឋព្វំ ។ កត្ថ ច ភិក្ខវេ សតិពលំ ទដ្ឋព្វំ ។ ចតូសុ សតិប្បដ្ឋានេសុ ។ ឯត្ថ សតិពលំ ទដ្ឋព្វំ ។ កត្ថ ច ភិក្ខវេ សមាធិពលំ ទដ្ឋព្វំ ។ ចតូសុ ឈានេសុ ។ ឯត្ថ សមាធិពលំ ទដ្ឋព្វំ ។ កត្ថ ច ភិក្ខវេ បញ្ញាពលំ ទដ្ឋព្វំ ។ ចតូសុ អរិយសច្ចេសុ ។ ឯត្ថ បញ្ញាពលំ ទដ្ឋព្វំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានីតិ ។

[១៦] បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ពលានំ ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ បញ្ញាពលំ ។ សេយ្យថាបិ ភិក្ខវេ កូដាគារស្ស ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ កូដំ

កម្លាំងសទ្ធា គួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងវីរិយៈ គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងសម្មប្បធាន ៤ ។ កម្លាំងវីរិយៈគួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសតិ គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងសតិប្បដ្ឋាន ៤ ។ កម្លាំងសតិ គួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសមាធិ គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងឈាន ៤ ។ កម្លាំងសមាធិ គួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងបញ្ញា គួរឃើញក្នុងធម៌ណា ។ គួរឃើញក្នុងអរិយសច្ច ៤ ។ កម្លាំងបញ្ញា គួរឃើញក្នុងធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។

(១៦) ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៥ យ៉ាង ។ កម្លាំង ៥ យ៉ាង តើអ្វីខ្លះ ។ គឺកម្លាំងសទ្ធា ១ កម្លាំងវីរិយៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្លាំង ៥ យ៉ាងនេះ កម្លាំងបញ្ញាជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្តូប (នៃកម្លាំងទាំងពួង) ។ ម្នាលភិក្ខុទាំងឡាយ ដូចផ្ទះកំពូល មានកំពូលជារបស់ប្រសើរ ជាទីប្រជុំព្រម ជាទីអបស្តូប (នៃទព្វសម្ភារៈទាំងពួង) មានឧបមាយ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ ឥមេសំ បញ្ចន្នំ ពលានំ ឯតំ
អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាតនិយំ យទិទំ
បញ្ញាពលន្តិ ។

(១៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ
ភិក្ខុ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិ-
តាយ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ
អត្តនា សីលសម្បន្នោ ហោតិ នោ បរំ សីល-
សម្បទាយ សមាទបេតិ អត្តនា សមាធិសម្បន្នោ
ហោតិ នោ បរំ សមាធិសម្បទាយ សមាទបេតិ
អត្តនា បញ្ញាសម្បន្នោ ហោតិ នោ បរំ បញ្ញា-
សម្បទាយ សមាទបេតិ អត្តនា វិមុត្តិសម្បន្នោ
ហោតិ នោ បរំ វិមុត្តិសម្បទាយ សមាទបេតិ
អត្តនា វិមុត្តិញាណទស្សនសម្បន្នោ ហោតិ នោ
បរំ វិមុត្តិញាណទស្សនសម្បទាយ សមាទបេតិ ។
ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ
ភិក្ខុ អត្តហិតាយ បដិបន្នោ ហោតិ នោ
បរហិតាយាតិ ។

ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្លាំង ៥ យ៉ាងនេះឯង កម្លាំងបញ្ញា ជាគុណជាតខ្ពង់ខ្ពស់ ជាទីប្រជុំព្រម ជាទីអបស្មូប (នៃកម្លាំងទាំងពួង) ក៏មានឧបមេយ្យយ៉ាងនោះឯង ។

(១៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបំពេញសីល ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញសីល ១ ជាអ្នកបំពេញសមាធិដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញសមាធិ១ ជាអ្នកបំពេញបញ្ញាដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញបញ្ញា ១ ជាអ្នកបំពេញវិមុត្តិធម៌ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញក្នុងវិមុត្តិធម៌ ១ ជាអ្នកបំពេញវិមុត្តិញាណទស្សនៈដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។

(១៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ន សីលសម្បន្នោ ហោតិ បរំ សីលសម្បទាយ សមាទបេតិ អត្តនា ន សមាធិសម្បន្នោ ហោតិ បរំ សមាធិសម្បទាយ សមាទបេតិ អត្តនា ន បញ្ញាសម្បន្នោ ហោតិ បរំ បញ្ញាសម្បទាយ សមាទបេតិ អត្តនា ន វិមុត្តិសម្បន្នោ ហោតិ បរំ វិមុត្តិសម្បទាយ សមាទបេតិ អត្តនា ន វិមុត្តិញាណទស្សនសម្បន្នោ ហោតិ បរំ វិមុត្តិញាណទស្សនសម្បទាយ សមាទបេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយាតិ ។

(១៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ន សីលសម្បន្នោ ហោតិ

(១៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនបំពេញសីល ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញសីល ១ ជាអ្នកមិនបំពេញសមាធិ ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញសមាធិ ១ ជាអ្នកមិនបំពេញបញ្ញា ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញបញ្ញា ១ ជាអ្នកមិនបំពេញវិមុត្តិធម៌ ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិធម៌ ១ ជាអ្នកមិនបំពេញវិមុត្តិញាណទស្សនៈ ដោយខ្លួនឯង តែបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯង ។

(១៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯង មិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនបំពេញសីល ដោយខ្លួនឯង

នោ បរំ សីលសម្បទាយ សមាទបេតិ អត្តនា ច
សមាធិសម្បន្នោ ហោតិ នោ បរំ សមាធិសម្បទាយ
សមាទបេតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ
នោ បរំ បញ្ញាសម្បទាយ សមាទបេតិ អត្តនា
ច វិមុត្តិសម្បន្នោ ហោតិ នោ បរំ វិមុត្តិសម្បទាយ
សមាទបេតិ អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ
ហោតិ នោ បរំ វិមុត្តិញាណទស្សនសម្បទាយ
សមាទបេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ
ធម្មេហិ សមន្នាគតោ ភិក្ខុ នេវ អត្តហិតាយ
បដិបន្នោ ហោតិ នោ បរហិតាយាតិ ។

(២០) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ
អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ច ។
កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ច សីល
សម្បន្នោ ហោតិ បរញ្ច សីលសម្បទាយ សមាទបេតិ

មិនបបួលអ្នកដទៃ ក្នុងការបំពេញសីល ១ ជាអ្នកមិនបំពេញសមាធិ ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញសមាធិ ១ ជាអ្នកមិនបំពេញបញ្ញា ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញបញ្ញា ១ ជាអ្នកមិនបំពេញវិមុត្តិធម៌ ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិធម៌ ១ ជាអ្នកមិនបំពេញវិមុត្តិញាណទស្សនៈ ដោយខ្លួនឯង មិនបបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ។

[៦០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍អ្នកដទៃផង ។ ប្រកបដោយធម៌៥យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបំពេញសីល ដោយខ្លួនឯងផង បបួលអ្នកដទៃ ក្នុងការបំពេញសីលផង ១ ជាអ្នកបំពេញសមាធិ ដោយខ្លួនឯងផង បបួលអ្នកដទៃ ក្នុងការបំពេញសមាធិផង ១

អត្តនា ច សមាធិសម្បន្នោ ហោតិ បរញ្ច សមាធិសម្បទាយ សមាទបេតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បរញ្ច បញ្ញាសម្បទាយ សមាទបេតិ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ បរញ្ច វិមុត្តិសម្បទាយ សមាទបេតិ អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ បរញ្ច វិមុត្តិញាណទស្សនសម្បទាយ សមាទបេតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។

ពលវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អននុស្សុតកូដញ្ច
សង្ខិត្តំ វិត្ថតេន ច
ទដ្ឋព្វញ្ច បុនកូដំ
ចតុរោបិ ហិតេន ចាតិ ។

ជាអ្នកបំពេញបញ្ញា ដោយខ្លួនឯងផង បបួលអ្នកដទៃ ក្នុងការបំពេញបញ្ញាផង ១ ជាអ្នកបំពេញវិមុត្តិធម៌ ដោយខ្លួនឯងផង បបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិធម៌ផង ១ ជាអ្នកបំពេញវិមុត្តិញាណទស្សនៈ ដោយខ្លួនឯងផង បបួលអ្នកដទៃ ក្នុងការបំពេញវិមុត្តិញាណទស្សនៈផង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍អ្នកដទៃផង ។

ចប់ ពលវគ្គ ទី ២ ។

## ឧទ្ទាននៃពលវគ្គនោះគឺ

សំដែងអំពីព្រះដ៏មានព្រះភាគ ត្រាស់ដឹងសច្ចៈ ៤ ដែលមិនធ្លាប់ឮមក ១ អំពីកម្លាំងបញ្ញាប្រៀបដូចកំពូលផ្ទះ ១ អំពីកម្លាំង ៥ យ៉ាងដោយសង្ខេប ១ ដោយពិស្តារ១ អំពីកម្លាំង ៥ គប្បីឃើញក្នុងទីដូចម្តេច ១ អំពីកម្លាំងបញ្ញាប្រៀបដូចកំពូលផ្ទះម្តងទៀត ១ អំពីភិក្ខុជាអ្នកប្រព្រឹត្ត ដើម្បីប្រយោជន៍មាន ៤ លើក ។

# បញ្ចង្គិកវគ្គោ

(២១) សោ វត ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ អសភាគវុត្តិកោ សព្រហ្មចារីសុ អាភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ អាភិសមាចារិកំ ធម្មំ អបរិបូរេត្វា សេក្ខំ ធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សេក្ខំ ធម្មំ អបរិបូរេត្វា សីលានិ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សីលានិ អបរិបូរេត្វា សម្មាទិដ្ឋឹ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សម្មាទិដ្ឋឹ អបរិបូរេត្វា សម្មាសមាធឹ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ សភាគវុត្តិកោ សព្រហ្មចារីសុ អាភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ អាភិសមាចារិកំ ធម្មំ បរិបូរេត្វា សេក្ខំ ធម្មំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ

# បញ្ចង្គិកវគ្គ

(២១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ប្រព្រឹត្តមិនស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គលសោះ នឹងបំពេញអភិសមាចារិកធម៌ គឺបញ្ញត្តសីលបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសីលហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះ រមែងមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែង ប្រព្រឹត្តស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គល នឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះទើបមាន បើភិក្ខុបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះទើបមាន

សេក្ខំ ធម្មំ បរិបូរេត្វា សីលានិ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ សីលានិ បរិបូរេត្វា សម្មាទិដ្ឋឹ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ សម្មាទិដ្ឋឹ បរិបូរេត្វា សម្មាសមាធឹ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(២២) សោ វត ភិក្ខវេ ភិក្ខុ អគារវោ អប្បតិស្សោ អសភាគវុត្តិកោ សព្រហ្មចារីសុ អាភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ អាភិសមាចារិកំ ធម្មំ អបរិបូរេត្វា សេក្ខំ ធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សេក្ខំ ធម្មំ អបរិបូរេត្វា សីលក្ខន្ធំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សីលក្ខន្ធំ អបរិបូរេត្វា សមាធិក្ខន្ធំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ សមាធិក្ខន្ធំ អបរិបូរេត្វា បញ្ញាខន្ធំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ សគារវោ សប្បតិស្សោ សភាគវុត្តិកោ សព្រហ្មចារីសុ អាភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ អាភិសមាចារិកំ ធម្មំ បរិបូរេត្វា សេក្ខំ ធម្មំ បរិបូរេស្សតីតិ

បើបានបំពេញសេក្ខធម៌ហើយ ទឹងបំពេញសីលបាន ហេតុនុ៎ះទើបមាន បើបានបំពេញសីលហើយ ទឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះទើបមាន ទើបបានបំពេញសម្មាទិដ្ឋិហើយ ទឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះទើបមាន ។

(៦២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ប្រព្រឹត្តមិនស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គលសោះ ទឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញអភិសមាចារិកធម៌ហើយ ទឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសេក្ខធម៌ហើយ ទឹងបំពេញសីលក្ខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសីលក្ខន្ធហើយ ទឹងបំពេញសមាធិក្ខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសមាធិក្ខន្ធហើយ ទឹងបំពេញបញ្ញាខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង ប្រព្រឹត្តស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គលហើយ ទឹងបំពេញអភិសចារិកធម៌បាន ហេតុនុ៎ះទើបមាន បើបានបំពេញអភិសមាចារិកធម៌ហើយ ទឹងបំពេញសេក្ខធម៌បាន

ឋានមេតំ វិជ្ជតិ សេក្ខំ ធម្មំ បរិបូរេត្វា សីលក្ខន្ធំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ សីលក្ខន្ធំ បរិបូរេត្វា សមាធិក្ខន្ធំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ សមាធិក្ខន្ធំ បរិបូរេត្វា បញ្ញាក្ខន្ធំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[២៣] បញ្ចិមេ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។ កតមេ បញ្ច ។ អយោ លោហំ តិបុ សីសំ សជ្ឈំ ។ ឥមេ ខោ ភិក្ខវេ បញ្ច ជាតរូបស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។ យតោ ច ខោ ភិក្ខវេ ជាតរូបំ ឥមេហិ បញ្ចហិ ឧបក្កិលេសេហិ វិមុត្តំ ហោតិ តំ ហោតិ ជាតរូបំ មុទុ ច កម្មនិយំ ច បភស្សរំ ច ន ច បភង្គុ

ហេតុនុ៎ះទើបមាន បើបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលក្ខន្ធ
បាន ហេតុនុ៎ះទើបមាន បើបានបំពេញសីលក្ខន្ធហើយ នឹងបំពេញ
សមាធិក្ខន្ធបាន ហេតុនុ៎ះទើបមាន បើបានបំពេញសមាធិក្ខន្ធហើយ
នឹងបំពេញបញ្ញាខន្ធបាន ហេតុនុ៎ះទើបមាន ។

(២៣) ម្នាលភិក្ខុទាំងឡាយ មាសសៅហ្មង ដោយឧបក្កិលេស
ណា ជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានរស្មីផង
ជារបស់ប្រែះធាផង មិនងាយនឹងប្រកបការដោយស្រួលផង ឯឧបក្កិលេស
នៃមាសនេះមាន ៥ យ៉ាង ។ ឧបក្កិលេសនៃមាស ៥ យ៉ាង តើអ្វីខ្លះ ។
គឺដែក ១ ស្ពាន់ ១ សំណគក់ ១ សំណប៉ាហាំង ១ ប្រាក់ ១ ។
ម្នាលភិក្ខុទាំងឡាយ មាសដែលសៅហ្មង ដោយឧបក្កិលេសណា
ជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានរស្មីផង ជា
របស់ប្រែះធាផង មិនងាយនឹងប្រកបការដោយស្រួលផង ឧបក្កិលេស
នៃមាសមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណា
បើមាសផុតស្រឡះចាកឧបក្កិលេសទាំង ៥ យ៉ាងនេះហើយ មាសនោះ
ទើបជារបស់ទន់ផង គួរដល់ការងារផង មានរស្មីផង មិនប្រែះធាផង

សម្មា ឧបេតិ កម្មាយ យស្ស កស្សចិ បិឡន្ធនវិ-
កតិយា អាកង្ខតិ យទិ មុទ្ទិកាយ យទិ កុណ្ឌ-
លាយ យទិ គីវេយ្យកេន យទិ សុវណ្ណមាលាយ
តញ្ចស្ស អត្ថំ អនុភោតិ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ
ចិត្តស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ
ឧបក្កិលិដ្ឋំ ចិត្តំ ន ចេវ មុទុ ហោតិ ន ច
កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មាស-
មាធិយតិ អាសវានំ ខយាយ ។ កតមេ បញ្ច ។
កាមច្ឆន្ទោ ព្យាបាទោ ថីនមិទ្ធំ ឧទ្ធច្ចកុក្កុច្ចំ វិចិ-
កិច្ឆា ។ ឥមេ ខោ ភិក្ខវេ បញ្ច ចិត្តស្ស ឧបក្កិ-
លេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ចិត្តំ
ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ
បភង្គុ ច ន ច សម្មាសមាធិយតិ អាសវានំ ខយាយ ។
យតោ ច ខោ ភិក្ខវេ ចិត្តំ ឥមេហិ បញ្ចហិ
ឧបក្កិលេសេហិ វិមុត្តំ ហោតិ តំ ហោតិ ចិត្តំ មុទុ ច
កម្មនិយំ ច បភស្សរំ ច ន ច បភង្គុ សម្មាសមាធិយតិ

ងាយនឹងប្រកបការដោយស្រួលផង បុគ្គលណាមួយ ប្រាថ្នាគ្រឿងប្រដាប់ប្លែក ទោះបីចិញ្ចៀន ទោះបីកុណ្ឌល ទោះបីខ្សែក ឬសង្វារមាស ក៏គ្រឿងប្រដាប់ប្លែកៗនោះ តែងសម្រេចប្រយោជន៍ដល់បុគ្គលនោះ (សេចក្តីនេះមានឧបមាដូចម្តេចមិញ) ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចចិត្តដែលសៅហ្មង ដោយឧបក្កិលេសណា ជាធម្មជាតមិនទន់ផង មិនគួរដល់ការនាកម្មផង មិនមានរស្មីផង ជាចិត្តប្រែះឆាផង មិនងាយនឹងដំកល់មាំ ដើម្បីអស់អាសវៈផង ឯឧបក្កិលេសនៃចិត្តនេះមាន ៥ យ៉ាង ។ ឧបក្កិលេសនៃចិត្ត ៥ យ៉ាង តើអ្វីខ្លះ ។ គឺ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលសៅហ្មង ដោយឧបក្កិលេសណា ជាចិត្តមិនទន់ផង មិនគួរដល់ការនាកម្មផង មិនមានរស្មីផង ជាចិត្តប្រែះឆាផង មិនងាយនឹងដំកល់មាំដើម្បីអស់អាសវៈផង ឧបក្កិលេសនៃចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្ត ផុតស្រឡះចាកឧបក្កិលេសទាំង ៥ យ៉ាងនេះហើយ ទើបចិត្តនោះ ជាធម្មជាតទន់ផង គួរដល់ការនាកម្មផង មានរស្មីផង ជាចិត្តមិនប្រែះឆាផង ងាយនឹងដំកល់មាំ

អាសវានំ ខយាយ យស្ស យស្ស ច អភិញ្ញា-
សច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ
អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ
បាបុណាតិ សតិ សតិ អាយតនេ ។ សោ
សចេ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ
ឯកោបិ ហុត្វា ពហុធា អស្សំ ពហុធាបិ ហុត្វា
ឯកោ អស្សំ អាវិភាវំ តិរោភាវំ តិរោកុដ្ដំ
តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆេយ្យំ
សេយ្យថាបិ អាកាសេ បថវិយាបិ ឧម្មុជ្ជនិមុជ្ជំ
ករេយ្យំ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ
គច្ឆេយ្យំ សេយ្យថាបិ បថវិយា អាកាសេបិ
បល្លង្កេន កមេយ្យំ សេយ្យថាបិ បក្ខី សកុណោ
ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ
បាណិនា បរាមសេយ្យំ បរិមជ្ជេយ្យំ យាវព្រហ្ម-
លោកាបិ កាយេន វសំ វត្តេយ្យន្តិ តត្រ តត្រេវ
សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

ដើម្បីអស់អាសវៈផង មួយទៀត បុគ្គលបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញាបាន កាលបើ មានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ចង់បាននូវឥទ្ធិវិធញ្ញាណ ច្រើនប្រការ គឺអាត្មាអញតែម្នាក់ឯង ចង់និម្មិតខ្លួន ឲ្យបានទៅជាមនុស្សច្រើននាក់ក៏បាន មានគ្នាច្រើននាក់ ចង់និម្មិតឲ្យទៅជាមនុស្សម្នាក់ឯងក៏បាន អាត្មាអញដើរទៅមិនជាប់ចំពាក់ នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង នឹងទីក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន អាត្មាអញចង់ងើបឡើងនឹងមុជចុះក្នុងផែនដី ដូចជាងើបមុជក្នុងទឹកក៏បាន អាត្មាអញចង់ដើរទៅលើទឹក ក៏មិនបែកធ្លាយទឹក ដូចដើរលើផែនដីក៏បាន អាត្មាអញចង់ទៅក្នុងអាកាស ទាំងភ្នែន ដូចជាសត្វស្លាបក៏បាន អាត្មាអញចង់យកដៃទៅស្ទាបអង្អែល ចាប់ពាល់ព្រះចន្ទនឹងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន អាត្មាអញចង់ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន កាលបើមានហេតុ មានទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងឥទ្ធិវិធញ្ញាណនោះៗ ។

សោ សចេ អាកង្ខតិ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណេយ្យំ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យំ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានេយ្យំ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានេយ្យំ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានេយ្យំ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានេយ្យំ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានេយ្យំ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានេយ្យំ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានេយ្យំ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានេយ្យំ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានេយ្យំ អមហគ្គតំ វា ចិត្តំ

បឋមបណ្ណាសក បញ្ចង្គិកវគ្គ

បើបុគ្គលនោះ ប៉ុនប៉ងថា អាត្មាអញ (ចង់ឲ្យ) មានសោតធាតុជាទិព្វដ៏បរិសុទ្ធ កន្លងហួសនូវសោតធាតុ របស់មនុស្សធម្មតា ឮនូវសំឡេងពីរប្រការ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលជាសំឡេងឆ្ងាយក៏បាន ជិតក៏បាន កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងសោតធាតុនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ចង់កំណត់ដឹងចិត្ត របស់សត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តប្រកបដោយរាគៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តប្រាសចាកទោសៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តរួញថយក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តរួញថយ ចិត្តរាយមាយក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តជាមហគ្គតៈ គឺរូបាវចរៈនិងអរូបាវចរៈក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តមិនមែនជាមហគ្គតៈក្តី

អមហគ្គតំ ចិត្តន្តិ បជានេយ្យំ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានេយ្យំ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានេយ្យំ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានេយ្យំ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានេយ្យំ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានេយ្យំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិសតសហស្សំបិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី

អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តជាសឧត្តរៈ គឺលោកិយចិត្តក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តជាអនុត្តរៈ គឺលោកុត្តរចិត្តក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តតាំងមាំក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តមិនតាំងមាំក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តមិនតាំងមាំ ចិត្តរួចចាកកិលេសក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តមិនទាន់រួចចាកកិលេសក្តី អាត្មាអញ គប្បីដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស កាលបើមានហេតុ មានទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងបទចិត្តវិជ្ជានោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ចង់រលឹកនូវបុព្វេនិវាស (ជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន) ច្រើនប្រការ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០.០០០ ជាតិខ្លះ សំវដ្តកប្បដ៏ច្រើនខ្លះ វិវដ្តកប្បដ៏ច្រើនខ្លះ សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះ ថា អាត្មាអញ កើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ

ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានេយ្យំ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា

មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញ ច្យុតចាកអត្តភាពនោះហើយ ទៅកើតក្នុងទីឯណោះ អាត្មាអញទៅកើតក្នុងទីនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញ ច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងទីនេះ អាត្មាអញគប្បីរលឹកនូវបុព្វេនិវាសបានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងបុព្វេនិវាសញ្ញាណនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ចង់ឲ្យមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ចង់ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាសត្វតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្ម ជាមិច្ឆាទិដ្ឋិ

តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

សោ សចេ អាកង្ខតិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេតិ ។

សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកាន់កំណើត តិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកខាងសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោ-សុចរិត ជាសត្វមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកាន់សុគតិសួគ៌ ទេវលោក អាត្មាអញ ចង់ឲ្យមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ អាត្មាអញចង់ដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការៈដូច្នេះ កាលបើមានហេតុ មានទំនង បុគ្គលនោះ ក៏ដល់នូវសេចក្ដីជាក់ច្បាស់ ក្នុងទិព្វចក្ខុញាណនោះៗ ។ បើបុគ្គលនោះប៉ុនប៉ងថា អាត្មាអញ ចង់ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រាន្តនៅ កាលបើមានហេតុ មានទំនង បុគ្គលនោះក៏ដល់នូវសេចក្ដីជាក់ច្បាស់ ក្នុងអាសវក្ខយញាណនោះៗ ។

(២៤) ទុស្សីលស្ស ភិក្ខវេ សីលវិបន្នស្ស ហតុបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតុបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតុបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទា-វិរាគវិបន្នស្ស ហតុបនិសំ ហោតិ វិមុត្តិញាណទស្សនំ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ន បារិបូរឹ គច្ឆតិ ផេគ្គុបិ ន បារិបូរឹ គច្ឆតិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ទុស្សីលស្ស សីលវិបន្នស្ស ហតុបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតុបនិសំ ហោតិ យថា-ភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ

(២៤) ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ឈ្មោះថា សមាធិមានឧបនិស្ស័យ[១] ស្លាប់ កាលបើសម្មា-សមាធិមិនមាន យថាភូតញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាក សម្មាសមាធិ ឈ្មោះថា យថាភូតញាណទស្សនៈមានឧបនិស្ស័យស្លាប់ កាលបើយថាភូតញាណទស្សនៈមិនមាន និព្វិទាវិរាគៈ របស់បុគ្គល ដែលវិបត្តិចាកយថាភូតញាណទស្សនៈឈ្មោះថា និព្វិទាវិរាគៈ មាន ឧបនិស្ស័យស្លាប់ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញាណទស្សនៈ មានឧបនិស្ស័យស្លាប់ ម្នាលភិក្ខុទាំងឡាយ ដើមឈើប្រាសចាកមែក និងស្លឹកហើយ ក្រមរនៃឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ក៏មិនសូវបរិបូណ៌ ស្រាយក្តី ក៏មិនសូវបរិបូណ៌ ខ្លឹមក្តី ក៏មិនសូវ បរិបូណ៌ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចសម្មាសមាធិ របស់បុគ្គលទ្រុស្តសីល វិបត្តិចាក សីល ឈ្មោះថា សម្មាសមាធិមានឧបនិស្ស័យស្លាប់ កាលបើសម្មា-សមាធិមិនមាន យថាភូតញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាក សម្មាសមាធិ ឈ្មោះថា យថាភូតញាណទស្សនៈ មានឧបនិស្ស័យស្លាប់

---

១ សំដៅយកសីលដែលជាហេតុឲ្យកើតសមាធិ ៗ ជាហេតុឲ្យកើតយថាភូតញាណទស្សនៈៗ ជាហេតុឲ្យកើតនិព្វិទាវិរាគៈ ៗ ជាហេតុឲ្យកើតវិមុត្តិញាណទស្សនៈ ។

យថាភូតញាណទស្សនវិបន្នស្ស ហតុបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតុបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សីលវតោ ភិក្ខវេ សីលសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ សតិ យថាភូតញាណទស្សនសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បប្បដិកាបិ បារិបូរឹ គច្ឆតិ តចោបិ បារិបូរឹ គច្ឆតិ ផេគ្គុបិ បារិបូរឹ គច្ឆតិ សារោបិ បារិបូរឹ គច្ឆតិ

កាលបើយថាភូតញាណទស្សនៈមិនមាន និព្វិទាវិរាគៈរបស់បុគ្គលដែលវិបត្តិចាកយថាភូតញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈមានឧបនិស្ស័យស្លាប់ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញាណទស្សនៈរបស់បុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញាណទស្សនៈ មានឧបនិស្ស័យស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិ របស់បុគ្គលមានសីល ពេញលេញដោយសីល ឈ្មោះថា សមាធិបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមាន យថាភូតញាណទស្សនៈ របស់បុគ្គលដែលពេញលេញដោយសម្មាសមាធិ ឈ្មោះថា យថាភូតញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញាណទស្សនៈមាន និព្វិទាវិរាគៈរបស់បុគ្គលដែលពេញលេញ ដោយយថាភូតញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈ បរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញាណទស្សនៈ របស់បុគ្គលដែលពេញលេញ ដោយនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមានមែកនិងស្លឹកបរិបូណ៌ ក្រមរនៃឈើនោះក្តី ក៏បរិបូណ៌ សម្បកក្តី ក៏បរិបូណ៌ ស្រាយក្តី ក៏បរិបូណ៌ ខ្លឹមក្តី ក៏បរិបូណ៌

ឯវមេវ ខោ ភិក្ខវេ សីលវតោ សីលសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ សតិ យថាភូតញ្ញាណទស្សនសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនន្តិ ។

(២៥) បញ្ចហិ ភិក្ខវេ អង្គេហិ អនុគ្គហិតា សម្មាទិដ្ឋិ ចេតោវិមុត្តិផលា ច ហោតិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោតិ បញ្ញាវិមុត្តិផលានិសំសា ច ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ សម្មាទិដ្ឋិ សីលានុគ្គហិតា ច ហោតិ សុតានុគ្គហិតា ច ហោតិ សាកច្ឆានុគ្គហិតា ច ហោតិ សមថានុគ្គហិតា ច ហោតិ វិបស្សនានុគ្គហិតា ច ហោតិ ។

មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចសម្មាសមាធិ របស់បុគ្គលមានសីល ពេញលេញដោយសីល ឈ្មោះថា សម្មាសមាធិ បរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានយថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលពេញលេញ ដោយសម្មា-សមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគ.របស់បុគ្គលដែលពេញលេញ ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈ បរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញ្ញាណ-ទស្សនៈ របស់បុគ្គលដែលពេញលេញ ដោយនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ ។

(២៥) ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដែលមានអង្គ ៥ ជួយទំនុកបំរុងហើយ រមែងមានចេតោវិមុត្តិ ជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិ-សង្សផង ។ អង្គ ៥ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ សម្មាទិដ្ឋិដែលសីលជួយទំនុកបំរុង ១ សុតៈជួយទំនុកបំរុង ១ សាកច្ឆាជួយទំនុកបំរុង ១ សមថៈជួយទំនុកបំរុង ១ វិបស្សនាជួយទំនុកបំរុង ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ អង្គេហិ អនុគ្គហិតា សម្មាទិដ្ឋិ ចេតោវិមុត្តិផលា ច ហោតិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោតិ បញ្ញាវិមុត្តិផលានិសំសា ចាតិ ។

(២៦) បញ្ចិមានិ ភិក្ខវេ វិមុត្តាយតនានិ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុប្បាបុណាតិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុនោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី យថា យថា ភិក្ខវេ តស្ស ភិក្ខុនោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី តថា តថា សោ តស្មិំ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមុជ្ជំ ជាយតិ

ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដែលអង្គ ៥ នេះឯង ជួយទំនុកបំរុងហើយ រមែងមានចេតោវិមុត្តិ ជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិសង្សផង ។

[២៦] ម្នាលភិក្ខុទាំងឡាយ វិមុត្តាយតនៈ (ហេតុជាគ្រឿងរួចចាកកិលេស) នេះមាន ៥ យ៉ាង ដែលជាគុណជាតសម្រាប់ភិក្ខុមិនប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានចិត្តស្លុងទៅ (កាន់ព្រះនិព្វាន) ចិត្តដែលមិនទាន់រួចស្រឡះ ក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ ក៏រមែងដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។ វិមុត្តាយតនៈ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ក្នុងសាសនានេះ ជាគរុដ្ឋានីយបុគ្គល (បុគ្គលគួរគោរព) សំដែងធម៌ដល់ភិក្ខុ ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល សំដែងធម៌ដល់ភិក្ខុនោះយ៉ាងណាៗ ភិក្ខុនោះ រមែងដឹងច្បាស់នូវអត្ថកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះៗ កាលបើភិក្ខុនោះដឹងច្បាស់នូវអត្ថកថា ដឹងច្បាស់នូវបាលី បាមោជ្ជៈ (សេចក្តីរីករាយ) រមែងកើតឡើង

បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ ភិក្ខវេ បឋមំ វិមុត្តាយតនំ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ ក ចិត្តំ វិមុច្ចតិ អបរិក្ខីណា ក អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ ក អនុត្តរំ យោគក្ខេមំ អនុប្បាបុណាតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ នហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ ក គរុដ្ឋានិយោ សព្រហ្មចារី អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ យថា យថា ភិក្ខវេ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិ-សំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថ-ប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមុជ្ជំ ជាយតិ

កាលបើមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្ដីសុខ តែងដំកល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ១ ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តស្ទុងទៅ (កាន់ព្រះនិព្វាន) ចិត្តដែលមិនទាន់រួចស្រឡះ ក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ក៏ដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់ដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្ដា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសំដែងធម៌ដល់ភិក្ខុ តែជាសំដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង តាមសមគួរដល់ការសិក្សាដោយពិស្ដារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសំដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារយ៉ាងណា ៗ ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជៈ ក៏កើតឡើង

បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ ភិក្ខវេ ទុតិយំ វិមុត្តាយតនំ យត្ថ ភិក្ខុនោ អប្បមត្តស្ស ។ បេ ។ យោគក្ខេមំ អនុប្បាបុណាតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ នហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី នបិ យថាសុតំ យថា-បរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ យថា យថា ភិក្ខវេ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ តថា តថា សោ តស្មិំ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិ-សំវេទិនោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ

កាលបើមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្ដីសុខ តែងដំកល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ២ ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ ។ បេ ។ ចិត្តដែលមិនទាន់ដល់នូវធម៌ ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្ដា ឬភិក្ខុជាសព្រហ្មចារីណាមួយ ជាគរុដ្ឋានីយបុគ្គល មិនបានសំដែងធម៌ដល់ភិក្ខុទេ ទាំងមិនបានសំដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង តាមសមគួរដល់ការសិក្សា ដោយពិស្ដារទេ គ្រាន់តែធ្វើការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ដោយពិស្ដារយ៉ាងណា ៗ ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះ ៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជៈក៏រមែងកើតឡើង កាលបើមានបាមោជ្ជៈហើយ បីតិក៏កើតឡើង

បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ
សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ
ភិក្ខវេ តតិយំ វិមុត្តាយតនំ យត្ថ ភិក្ខុនោ
អប្បមត្តស្ស ។បេ។ យោគក្ខេមំ អនុប្បាបុណាតិ ។
បុន ចបរំ ភិក្ខវេ ភិក្ខុនោ នហេវ ខោ សត្ថា ធម្មំ
ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី
នបិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ
ទេសេតិ នបិ យថាសុតំ យថាបរិយត្តំ ធម្មំ
វិត្ថារេន សជ្ឈាយំ ករោតិ អបិច ខោ យថាសុតំ
យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ
មនសានុបេក្ខតិ យថា យថា ភិក្ខវេ ភិក្ខុ
យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ
អនុវិចារេតិ មនសានុបេក្ខតិ តថា តថា សោ
តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិ-
សំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិ-
សំវេទិនោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ

កាលបើមានចិត្ត ប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយ ស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្តីសុខ ចិត្តរបស់ភិក្ខុ ដែលប្រកបដោយសេចក្តីសុខ តែងដំកល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ៣ ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ ។ បេ ។ ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈ ក៏រមែងដល់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានិយបុគ្គល មិនសំដែងធម៌ដល់ភិក្ខុ ទាំងមិនបានសំដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ដោយពិស្តារទេ ទាំងមិនធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្តារដែរ គ្រាន់តែត្រិះរិះពិចារណារំពឹងគន់ចិត្ត ដោយចិត្តចំពោះធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះពិចារណារំពឹងគន់ចិត្ត ដោយចិត្តចំពោះធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា យ៉ាងណា ៗ ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះ ៗ កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជៈ រមែងកើតឡើង កាលបើមានបាមោជ្ជៈ បីតិក៏កើតឡើង

បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ ភិក្ខវេ ចតុត្ថំ វិមុត្តាយតនំ យត្ថ ភិក្ខុនោ អប្បមត្តស្ស ។ បេ ។ យោគក្ខេមំ អនុប្បាបុណាតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ ន ហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី អបិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ អបិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ អបិ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ អបិច ខ្វស្ស អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ យថា យថា ភិក្ខវេ ភិក្ខុនោ អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ

កាលបើមានចិត្តប្រកបដោយបីតិ នាមកាយក៏ស្ងប់រម្ងាប់ ភិក្ខុដែលមាននាមកាយស្ងប់រម្ងាប់ ក៏រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្ដីសុខ ក៏រមែងដំកល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតន ទី ៤ ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ ។បេ។ ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈ ក៏រមែងដល់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះសាស្ដា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានិយបុគ្គល មិនបានសំដែងធម៌ដល់ភិក្ខុទេ ទាំងក៏មិនបានសំដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សា ដោយពិស្ដារទេ ទាំងមិនបានធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារទេ ទាំងមិនបានត្រិះរិះពិចារណារំពឹងគន់ចិត្ត ដោយចិត្តចំពោះធម៌ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាទេ តែលោករៀនយកដោយល្អនូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀនយកដោយល្អនូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញា យ៉ាងណា ៗ

តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ ភិក្ខវេ បញ្ចមំ វិមុត្តាយតនំ យត្ថ ភិក្ខុនោ អប្បមត្តស្ស ។ បេ ។ យោគក្ខេមំ អនុប្បាបុណាតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច វិមុត្តាយតនានិ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុប្បាបុណាតីតិ ។

ភិក្ខុនោះក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជៈក៏កើតឡើង កាលបើមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលៈបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្ដីសុខ តែងដំកល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី៥ ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ ។បេ។ ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈក៏រមែងដល់ ។ ម្នាលភិក្ខុទាំងឡាយ វិមុត្តាយតនៈទាំង៥ យ៉ាងនេះឯង ដែលជាគុណជាត សម្រាប់ភិក្ខុមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តស្ទុះទៅ (កាន់ព្រះនិព្វាន) ចិត្តដែលមិនទាន់រួចស្រឡះចាកកិលេស ក៏រួចស្រឡះផង អាសវៈដែលមិនទាន់អស់ទៅក៏ដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់បានដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង ។

[២៧] សមាធឹ ភិក្ខវេ ភាវេថ អប្បមាណំ និបកា បតិស្សតា សមាធឹ ភិក្ខវេ ភាវយតំ អប្បមាណំ និបកានំ បតិស្សតានំ បញ្ច ញាណានិ បច្ចត្តញ្ញេវ ឧប្បជ្ជន្តិ ។ កតមានិ បញ្ច ។ អយំ សមាធិ បច្ចុប្ប-ន្នសុខោ ចេវ អាយតឹ ច សុខវិបាកោតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ អរិយោ និរាមិសោតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ អកា-បុរិសសេវិតោតិ(១) បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ សន្តោ បណីតោ បដិប្បស្សទ្ធិលទ្ធោ

---

១ ម. មហាបុរិសសេវិតោតិ ។

(២៧) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរជាអ្នកប្រកប ដោយប្រាជ្ញាចាស់ក្លាទឹងសតិខ្ជាប់ខ្ជួន ចំរើននូវសមាធិប្រមាណមិនបាន (លោកុត្តរៈ) ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រកបដោយប្រាជ្ញាចាស់ក្លាទឹងសតិខ្ជាប់ខ្ជួន ចំរើននូវសមាធិប្រមាណមិនបាន ញាណ (ការដឹង) ៥ យ៉ាង ក៏រមែងកើតឡើង ចំពោះខ្លួនមិនខាន ។ ញាណ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺញាណ រមែងកើតឡើងចំពោះខ្លួនថា សមាធិនេះ[១] ជាសុខក្នុងបច្ចុប្បន្នផង មានផលជាសុខតទៅផង ១[២] ញាណ រមែងកើតឡើងចំពោះខ្លួនថា សមាធិនេះ ប្រាសចាកអាមិសៈ[៣] ដ៏ប្រសើរ ១ ញាណ រមែងកើតឡើងចំពោះខ្លួនថា សមាធិនេះ បុរសល្អតែងសេពគប់ ១ ញាណ រមែងកើតឡើងចំពោះខ្លួនថា សមាធិនេះ ល្អិតម៉ដ្ឋចត់ ជាគុណនាំឲ្យបុគ្គលបាននូវបដិប្បស្សទ្ធិ (សេចក្តីស្ងប់)

---

១ អរហត្តផលសមាធិ ឬមគ្គសមាធិ ។ សមាធិនោះជាសុខក្នុងបច្ចុប្បន្ន ព្រោះបានសេចក្តីសុខក្នុងខណៈដែលផឹកឬក្រេបអារម្មណ៍ ។ ២ សមាធិដែលមានមុនហើយ ឲ្យផលជាសុខក្នុងខាងមុខតទៅ ព្រោះសមាធិមុននោះ ជាបច្ច័យដល់សមាធិសុខខាងក្រោយ ។ ៣ អាមិសៈមាន៣យ៉ាង គឺ កាមាមិសៈ នុយគឺកាម១ វដ្តាមិសៈ នុយគឺវដ្ត១ លោកាមិសៈ នុយគឺលោក១ ។ អដ្ឋកថា ។

ឯកោទិភាវាធិគតោ ន ច សសង្ខារនិគ្គយ្ហវារិតប្បត្តោតិ(១) បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ សោ ខោ បនាហំ ឥមំ សមាធឹ សតោវ សមាបជ្ជាមិ សតោ វុដ្ឋហាមីតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ ។ សមាធឹ ភិក្ខវេ ភាវេថ អប្បមាណំ និបកា បតិស្សតា សមាធឹ ភិក្ខវេ ភាវយតំ អប្បមាណំ និបកានំ បតិស្សតានំ ឥមានិ បញ្ច ញាណានិ បច្ចត្តញ្ញេវ ឧប្បជ្ជន្តីតិ ។

[២៨] អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស ភាវនំ ទេសេស្សាមិ តំ សុណាថ ។បេ។ កតមា ច ភិក្ខវេ អរិយស្ស បញ្ចង្គិកស្ស សម្មាសមាធិស្ស ភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ

---

១ ឱ. សសង្ខារនិគ្គយ្ហវារិតាវដោតិ ។ ម. សសង្ខារនិគ្គយ្ហវារិវាវដោតិ ។

បាននូវឯកគ្គតារម្មណ៍ តែមិនទាន់បានដល់នូវការសង្កត់សង្កិនឃាត់ហាម កិលេសដោយសេចក្តីព្យាយាមទេ ១ ញាណ រមែងកើតឡើងចំពោះខ្លួនថា អាត្មាអញនោះសោតនឹកលើករួបរួមចូលកាន់សមាធិនេះ នឹកលើករួបរួមចេញចាកសមាធិនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរជាអ្នកប្រកបដោយប្រាជ្ញាចាស់ក្លានឹងសតិខ្ជាប់ខ្ជួន ចំរើននូវសមាធិប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ប្រកបដោយប្រាជ្ញាចាស់ក្លា នឹងសតិខ្ជាប់ខ្ជួន ចំរើនសមាធិប្រមាណមិនបាន ញាណទាំង ៥ ប្រការនេះឯង រមែងកើតឡើងចំពោះខ្លួនឯងមិនខាន ។

(៤៨) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងវិធីចំរើនសម្មា-សមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ចូរអ្នកទាំងឡាយប្រុងស្តាប់សម្មា-សមាធិនោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិធីចំរើនសម្មាសមាធិដ៏ប្រសើរប្រកបដោយអង្គ ៥ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ។ បេ ។ បានដល់បឋមជ្ឈាន ។ ភិក្ខុនោះក៏ញុំាងករជកាយនេះ ឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ មិនមានឡើយ

សេយ្យថាបិ ភិក្ខវេ ទក្ខោ នហាបកោ វា នហាបកន្តេវាសី វា កំសថាលេ នហានិយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ សន្នេយ្យ សាយំ នហានិយបិណ្ឌិ សិនេហានុគតា សិនេហបរេតា សន្តរពាហិរា ផុដា សិនេហេន ន ច បគ្ឃរតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។ អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស អយំ បឋមា ភាវនា ។ បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ

ម្នាលភិក្ខុទាំងឡាយ ដូចអ្នកផ្ងូតទឹកក្ដី បុគ្គលអ្នកជំនួយការនៃអ្នកផ្ងូតទឹកក្ដី ដែលឈ្លាសវៃ រោយលំអិតសម្រាប់ងូត ក្នុងភាជនៈសម្រិទ្ធិ ហើយប្រោះព្រំដោយទឹក រួចហើយក៏សូនជាដុំ លុះដល់វេលាល្ងាច ដុំលំអិតសម្រាប់ងូត (នោះ) ក៏ស្អិតជាប់ចូលគ្នាស្អិតល្អិត ទាំងខាងក្នុងខាងក្រៅ មិនបានពត់ពយខ្ចាយចេញឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលញុំាងករជកាយនេះ ឲ្យជ្រួតជ្រាប ខ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ មិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចំរើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះ ក៏ញុំាងករជកាយនេះ ឲ្យជ្រួតជ្រាប ខ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសមាធិប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសមាធិ មិនមានឡើយ

សេយ្យថាបិ ភិក្ខវេ ឧទករហទោ ឧព្ភិទោទកោ តស្ស នេវស្ស បុរត្ថិមាយ ទិសាយ ឧទកស្ស អាយមុខំ ន បច្ឆិមាយ ទិសាយ ឧទកស្ស អាយមុខំ ន ឧត្តរាយ ទិសាយ ឧទកស្ស អាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្ស អាយមុខំ ទេវោ ច កាលេន កាលំ សម្មាធារំ នានុប្បវេច្ឆេយ្យ អថខោ តម្ហា ច ឧទករហទា សីតា វារិធារា ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង ប្រឡាយជាទីហូរមកនៃទឹក ក្នុងទិសខាងកើតនៃអន្លង់ទឹកនោះ ក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹក ក្នុងទិសខាងលិច ក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹក ក្នុងទិសខាងជើង ក៏មិនមាន ប្រឡាយជាទីហូរមកនៃទឹក ក្នុងទិសខាងត្បូង ក៏មិនមាន ទាំងភ្លៀងក៏មិនបានបង្អុរចុះនូវធារទឹក ដោយស្រួលក្នុងអន្លង់ទឹកនោះ តាមកាលវេលាឡើយ ឯធារទឹកដ៏ត្រជាក់ ក៏ស្រាប់តែជោរឡើង អំពីអន្លង់ទឹកនោះប៉ុណ្ណោះ ហើយក៏ញុំាងអន្លង់ទឹកនោះឲ្យជ្រួតជ្រាបខ្អែតដ៏បរិបូណ៌ ផ្សព្វផ្សាយដោយទឹកដ៏ត្រជាក់ ប្រទេសបន្តិចបន្តួច នៃអន្លង់ទឹកទាំងអស់នោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយទឹកត្រជាក់ មិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងករជកាយនេះ ឲ្យជ្រួតជ្រាប ខ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសមាធិ មិនមានឡើយ ក៏យ៉ាងនោះឯង ។

អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស អយំ ទុតិយា ភាវនា ។ បុន ចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ សេយ្យថាបិ ភិក្ខវេ ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ តានិ យាវ ចគ្គា យាវ ច មូលា សីតេន វារិនា អភិសន្នានិ បរិសន្នានិ បរិបូរានិ បរិប្ផុដានិ នាស្ស កិញ្ចិ សព្វាវតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ

ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចំរើនសម្មាសមាធិ ដ៏ប្រសើរ ប្រកប ដោយអង្គ ៥ ទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះ នឿយណាយចាកបីតិ ។បេ។ បានដល់តតិយជ្ឈាន ។ ភិក្ខុនោះ ក៏ញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយសុខ ឥតមានបីតិ ប្រទេសបន្តិចបន្តួច នៃកាយ ទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលគ្មានបីតិ មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាទីដែល ដុះព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី មានព្រលិត ឬឈូកក្រហម ឬឈូកស ពួកខ្លះ ដែលដុះក្នុងទឹក ចំរើនក្នុងទឹក មិនទាន់លូត ឡើងផុតអំពីទឹក លិចនៅក្នុងទឹក រស់នៅអាស្រ័យទឹក បទុមជាតទាំង នោះ រមែងជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយ ទឹកដ៏ត្រជាក់ តាំងអំពីឫស មើម រហូតដល់ចុង ប្រទេសបន្តិចបន្តួច នៃវារិជាតទាំងអស់ ដែលជាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ឈ្មោះថា មិនបានផ្សព្វផ្សាយ ដោយទឹកត្រជាក់ មិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងកាយនេះ ឲ្យ ជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយ ដោយសុខឥតមានបីតិ

ណាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។ អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស អយំ តតិយា ភាវនា ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ ណាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ សេយ្យថាបិ ភិក្ខវេ បុរិសោ ឱទាតេន វត្ថេន សសីសំ បារុបិត្វា និសិន្នោ អស្ស ណាស្ស កិញ្ចិ សព្វាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ ណាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។ អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស អយំ ចតុត្ថា ភាវនា ។

ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលគ្មានបីតិ មិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចំរើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ។ បេ ។ ក៏បានដល់ចតុត្ថជ្ឈាន ។ ភិក្ខុនោះអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនផ្សាយដោយចិត្តដ៏បរិសុទ្ធផង់ មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកសំពត់ស្អាតមកអង្គុយទទូរអស់ទាំងក្បាល ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់បុរសនោះ ឈ្មោះថា មិនផ្សាយដោយសំពត់ស្អាត មិនមានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ មិនមានឡើយ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិធីចំរើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ៤ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនោ បច្ចវេក្ខណានិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ សេយ្យថាបិ ភិក្ខវេ អញ្ញោ វា អញ្ញំ បច្ចវេក្ខេយ្យ ឋិតោ វា និសិន្នំ បច្ចវេក្ខេយ្យ និសិន្នោ វា និបន្នំ បច្ចវេក្ខេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ បច្ចវេក្ខណានិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ ។ អរិយស្ស ភិក្ខវេ បញ្ចង្គិកស្ស សម្មាសមាធិស្ស អយំ បញ្ចមា ភាវនា ។ ឯវំ ភាវិតេ ខោ ភិក្ខវេ ភិក្ខុ អរិយេ បញ្ចង្គិកេ សម្មាសមាធិម្ហិ ឯវំ ពហុលីកតេ យស្ស យស្ស អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ សេយ្យថាបិ ភិក្ខវេ ឧទកមណិកោ អាធារេ ឋបិតោ បូរោ ឧទកស្ស សមតិត្តិកោ កាកបេយ្យោ តមេនំ ពលវា បុរិសោ យតោ យតោ អាវដ្ជេយ្យ (១) អាគច្ឆេយ្យ ឧទកន្តិ ។

---

១ ឱ. ម. អាវិជ្ជេយ្យ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត បច្ចវេក្ខណនិមិត្ត ភិក្ខុបានរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ ដូចជាមនុស្សដទៃ សំឡឹងមើលបុគ្គលដទៃ ឬអ្នកឈរសំឡឹងមើលអ្នកអង្គុយ ឬក៏អ្នកអង្គុយសំឡឹងមើលអ្នកដេក យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បច្ចវេក្ខណនិមិត្ត ភិក្ខុបានរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញា ក៏យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ នេះជាវិធី ចំរើនសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ដែលភិក្ខុចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណា ៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា កាលបើមានហេតុមានទំនង រមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងធម៌នោះ ៗ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា ម្នាលភិក្ខុទាំងឡាយ ដូចជាពាងទឹកដែលពេញដោយទឹក ពេញស្មើ (ទឹងមាត់) ល្មមសត្វក្អែកឱនផឹកបាន ដែលគេដំកល់ទុកលើជើងទ្រ បុរសដែលមានកម្លាំងលើករំកិលពាងទឹកនោះទៅក្នុងទីណា ៗ តើទឹកគប្បីដោយតាមមកបានដែរឬ ។

ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ ភាវិតេ
អរិយេ បញ្ចង្គិកេ សម្មាសមាធិម្ហិ ឯវំ ពហុលីកតេ
យស្ស យស្ស អភិញ្ញា សច្ឆិករណីយស្ស ធម្មស្ស ចិត្តំ
អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ
សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។
សេយ្យថាបិ ភិក្ខវេ សមេ ភូមិភាគេ បោក្ខរណី
ចតុរស្សា អាលិពទ្ធា បូរា ឧទកស្ស សមតិត្តិកា
កាកបេយ្យា តមេនំ ពលវា បុរិសោ យតោ
យតោ អាលឹ មុញ្ចេយ្យ អាគច្ឆេយ្យ ឧទកន្តិ ។
ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ ភាវិតេ
អរិយេ បញ្ចង្គិកេ សម្មាសមាធិម្ហិ ឯវំ ពហុលីកតេ
យស្ស យស្ស អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស
ចិត្តំ អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ
សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

បពិត្រព្រះអង្គដ៏ចំរើន គប្បីដោយតាមមកបាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ ក៏ដូច្នោះដែរ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកប ដោយអង្គ ៥ ភិក្ខុបានចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណា ៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា កាលបើមានហេតុ មានទំនង រមែងដល់នូវសេចក្តីជាក់ច្បាស់ ក្នុងធម៌ នោះ ៗ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា ។ ម្នាលភិក្ខុទាំង ឡាយ មួយទៀត ដូចជាស្រះបោក្ខរណី ក្នុងភូមិភាគដ៏ស្មើមាន ជ្រុង ៤ មានភ្លឺព័ទ្ធ ជុំវិញ ជាស្រះពេញដោយទឹក ពេញស្មើ (ទឹងមាត់) ល្មមសត្វក្អែកទុនផឹកបាន បុរសអ្នកមានកម្លាំង នឹងបើក នូវភ្លឺនោះចេញត្រង់កន្លែងណា ៗ តើទឹកគប្បីហូរចេញទៅបានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ទឹងហូរចេញទៅបាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ ក៏ដូច្នោះដែរ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកប ដោយអង្គ ៥ ភិក្ខុបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនហើយយ៉ាង នេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណា ៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយ អភិញ្ញា កាលបើមានហេតុ មានទំនង ក៏រមែងដល់នូវសេចក្តីជាក់ ច្បាស់ ក្នុងធម៌នោះ ៗ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា ។

សេយ្យថាបិ ភិក្ខវេ សុភូមិយំ ចាតុម្មហាបថេ អាជញ្ញរថោ យុត្តោ អស្ស ឋិតោ ឱសតប្បតោទោ(១) តមេនំ ទក្ខោ យោគាចរិយោ អស្សទម្មសារថិ អភិរុហិត្វា វាមេន ហត្ថេន រស្មិយោ គហេត្វា ទក្ខិណេន ហត្ថេន បតោទំ គហេត្វា យេនិច្ឆកំ យទិច្ឆកំ សារេយ្យបិ បច្ចាសារេយ្យបិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំ ភាវិតេ អរិយេ បញ្ចង្គិកេ សម្មាសមាធិម្ហិ ឯវំ ពហុលីកតេ យស្ស យស្ស អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ឯកោបិ ហុត្វា ពហុធា អស្សំ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

---

១ ឱ. ឱធស្តបតោទោ ។ ម. ឱធគ្គបតោទោ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ដូចរថសេះអាជានេយ្យ ដែលគេទឹមបញ្ឈរទុក ក្នុងផ្លូវធំ ៤ មានផែនដីរាបស្មើ តែងមានរំពាត់ផ្គងទុក នាយសារថីអ្នកទូន្មានសេះ ជាអាចារ្យអ្នកបង្ហាត់សេះ ស្ទាត់ពង់វៃ ឡើងកាន់រថនោះ យកដៃឆ្វេងកាន់ខ្សែ ដៃស្តាំកាន់រំពាត់ហើយ បរទៅមុខក្តី បរបត់មកក្រោយក្តី តាមផ្លូវ ណាៗ ដែលគេប្រាថ្នា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសម្មាសមាធិដ៏ប្រសើរ ប្រកបដោយអង្គ ៥ ដែលភិក្ខុចំរើនហើយ យ៉ាងនេះ ធ្វើឲ្យច្រើនហើយ យ៉ាងនេះ ភិក្ខុបង្អោនចិត្តទៅរកធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា កាលបើមានហេតុ មានទំនង រមែងដល់នូវសេចក្តីជាក់ច្បាស់ ក្នុងធម៌នោះៗ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា ក៏យ៉ាងនោះឯង ។ បើភិក្ខុនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញ បានសម្រេចឥទ្ធិវិធញ្ញាណច្រើនប្រការគឺអាត្មាអញម្នាក់ឯង និម្មិតខ្លួនឲ្យបានច្រើននាក់ក៏បាន ។បេ។ អាត្មាអញគប្បីធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងឥទ្ធិវិធញ្ញាណនោះៗ ។

សោ សចេ អាកង្ខតិ ទិព្វាយ សោតធាតុយា វិសុទ្ធាយ ។ បេ ។ យេ ទូរេ សន្តិកេ ចាតិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យំ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជា-នេយ្យំ ។ បេ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញ មានសោតធាតុជាទិព្វ ។បេ។ ឮសំឡេងឆ្ងាយក៏បាន ជិតក៏បាន កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងដល់នូវសេចក្តីជាក់ច្បាស់ ក្នុងសោតធាតុនោះៗ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញ កំណត់ដឹងចិត្តរបស់សត្វដទៃ បុគ្គលដទៃ ដោយចិត្ត (របស់ខ្លួន) គឺចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។បេ។ ចិត្តមិនទាន់រួចស្រឡះចាកកិលេសក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះចាកកិលេស កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងដល់នូវសេចក្តីជាក់ច្បាស់ក្នុងបរចិត្តវិជ្ជានោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ គប្បីរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងបុព្វេនិវាសញ្ញាណនោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។បេ។ គប្បីដឹងច្បាស់នូវពពួកសត្វដែលអន្ទោលទៅតាមកម្ម កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ ក្នុងទិព្វចក្ខុញ្ញាណនោះៗ ។

សោ សចេ អាកង្ខតិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេតិ ។

[២៩] បញ្ចិមេ ភិក្ខវេ ចង្កមេ អានិសំសា ។ កតមេ បញ្ច ។ អទ្ធានក្ខមោ ហោតិ បធានក្ខមោ ហោតិ អប្បាពាធោ ហោតិ អសិតំ បីតំ ខាយិតំ សាយិតំ សម្មាបរិណាមំ គច្ឆតិ ចង្កមាធិគតោ សមាធិ ចិរដ្ឋិតិកោ ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចង្កមេ អានិសំសាតិ ។

[៣០] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ឥច្ឆានង្គលំ នាម កោសលានំ ព្រាហ្មណគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។

បើភិក្ខុនោះ ប្រាថ្នាថា សូមឲ្យអាត្មាអញ បានធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន កាលបើមានហេតុ មានទំនង ភិក្ខុនោះរមែងបានដល់នូវសេចក្តីជាក់ច្បាស់ក្នុងអាសវក្ខយញ្ញាណនោះ ៗ ។

[២៩] ម្នាលភិក្ខុទាំងឡាយ អានិសង្ស ក្នុងការចង្ក្រមនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ ១ អត់ធន់ក្នុងការព្យាយាម ១ មិនមានជម្ងឺ ១ ភោជនដែលបរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្សហើយ រមែងរលួយដោយស្រួល ១ សមាធិដែលកើតអំពីការចង្ក្រម រមែងតាំងនៅអស់កាលយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ក្នុងការចង្ក្រម មាន ៥ យ៉ាងនេះឯង ។

[៣០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាច់ដំណើរទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនអង្គ ក៏បានស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈ របស់អ្នកដែនកោសល ។ តាមដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈនោះ ។

អស្សោសុំ ខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ ឥច្ឆានង្គលំ អនុប្បត្តោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ

ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈបានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវនេះ ស្ដេចមកដល់ស្រុកឥច្ឆានង្គលៈ គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឥច្ឆានង្គលៈ ។ កិត្តិស័ព្ទដ៏ពីរោះឮខ្ចរខ្ចាយសុះសាយ ចំពោះព្រះគោតមដ៏ចំរើននោះ យ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្ត ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់កពថ្មីទៀត ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ (នូវព្រះនិព្វាន) ដោយប្រាជ្ញាដ៏ឧត្តមដោយព្រះអង្គ ហើយញ៉ាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញ៉ាំងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹង ព្រះអង្គសំដែងធម៌មានលំអបទដើម បទកណ្ដាល និងបទចុង ព្រមទាំងអត្ថនិងព្យញ្ជនៈ ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ពេញលេញទាំងអស់

សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា តស្សា រត្តិយា អច្ចយេន បហូតំ ខាទនីយំ ភោជនីយំ អាទាយ យេន ឥច្ឆានង្គលវនសណ្ឌោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ពហិទ្វារកោដ្ឋកេ អដ្ឋំសុ ឧច្ចាសទ្ទា មហាសទ្ទា ។ តេន ខោ បន សមយេន អាយស្មា នាគិតោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ នាគិតំ អាមន្តេសិ កេ បន តេ នាគិត ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆេ វិលោបេន្តីតិ ។ ឯតេ ភន្តេ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា បហូតំ ខាទនីយំ ភោជនីយំ អាទាយ ពហិទ្វារកោដ្ឋកេ ឋិតា ភគវន្តញ្ញេវ ឧទ្ទិស្ស ភិក្ខុសង្ឃញ្ចាតិ ។

ក៏ដំណើរ ដែលបានចូលប្រទះ នឹងព្រះអរហន្តទាំងឡាយ មានសភាព យ៉ាងនោះ ជាការប្រពៃពេកណាស់ ៗ គ្រាកាលកន្លងរាត្រីនោះទៅ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ នាំយកខាទនីយ-ភោជនីយាហារ ដ៏ក្រាស់ក្រែល ចូលសំដៅទៅឯដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ក៏ឈរស្រែកហៅនិយាយខ្លាំង នៅខាងក្រៅក្លោងទ្វារ ៗ គាប់ជួនសម័យនោះ ព្រះនាគិតៈដ៏មានអាយុ លោកនៅជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ៗ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរ ព្រះនាគិតៈ ដ៏មានអាយុថា ម្នាលនាគិតៈចុះ ពួកណាស្រែកហៅនិយាយខ្លាំងម្ល៉េះ ហាក់ដូចជាព្រានត្រីដណ្តើមត្រីគ្នា ៗ ព្រះនាគិតៈដ៏មានអាយុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈនុះ នាំយកខាទនីយភោជនីយាហារ ដ៏ក្រាស់ក្រែល មកឧទ្ទិសចំពោះព្រះអង្គផង ចំពោះភិក្ខុសង្ឃផង ឈរចាំនាខាងក្រៅក្លោងទ្វារ ៗ

មាហំ នាគិត យសេន សមាគមំ មា ច មយា យសោ យោ ខោ នាគិត នយិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អកិច្ឆលាភី អកសិរលាភី សោ (១) មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យាតិ ។ អធិវាសេតុ ទានិ ភន្តេ ភគវា អធិវាសេតុ សុគតោ អធិវាសនកាលោ ទានិ ភន្តេ ភគវតោ យេន យេនេវ ទានិ ភន្តេ ភគវា គមិស្សតិ តន្និន្នា ភវិស្សន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច សេយ្យថាបិ ភន្តេ ថុល្លផុសិតកេ ទេវេ វស្សន្តេ

---

១ ឱ. សោ តំ ។ ម. សោហំ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាគិត: តថាគត សូមកុំឲ្យបួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យបួបប្រសព្វនឹងតថាគត ម្នាលនាគិត: បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ (សុខក្នុងផ្នួស) បវិវេកសុខ (សុខក្នុងសេចក្តីស្ងប់ស្ងាត់) ឧបសមសុខ (សុខក្នុងសេចក្តីស្ងប់រម្ងាប់) សម្ពោធសុខ (សុខក្នុងការត្រាស់ដឹង) ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតធ្លាប់បានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល បុគ្គលនោះឯង រមែងត្រេកអរ ចំពោះសេចក្តីសុខកខ្វក់ សុខក្នុងការដេកលក់ សុខក្នុងលាភសក្ការៈ នឹងសេចក្តីសរសើរ ។ ព្រះនាគិត: ក្រាបបង្គំទូលទៀតថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគ ទទួលនិមន្ត សូមព្រះសុគតទទួលនិមន្តចុះ បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរព្រះអង្គនឹងទទួលហើយ បពិត្រព្រះអង្គដ៏ចំរើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍នឹងគហបតី នៅក្នុងនិគមក្តី នៅក្នុងជនបទក្តី នឹងនាំគ្នាតាមទៅក្នុងទីនោះៗ មិនខាន បពិត្រព្រះអង្គដ៏ចំរើន ដូចជាភ្លៀងមានដំណក់ទឹកដ៏ធ្លោស កាលបង្អុរចុះមក

យថានិន្នំ ឧទកានិ បវត្តន្តិ ឯវមេវ ខោ ភន្តេ យេន យេនេវ ទានិ ភគវា គមិស្សតិ តន្និន្នាវ ភវិស្សន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ តំ កិស្ស ហេតុ ។ តថា ហិ ភន្តេ ភគវតោ សីលបញ្ញាណន្តិ ។ មាហំ នាគិត យសេន សមាគមំ មា ច មយា យសោ យោ ខោ នាគិត នយិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អកិច្ឆលាភី អកសិរលាភី សោ មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យ ។

ទឹកទាំងឡាយ តែងហូរចាក់ទៅរកទីទំនាប យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន បើព្រះដ៏មានព្រះភាគ នឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍ នឹងគហបតី នៅក្នុងនិគមក្តី នៅក្នុងជនបទក្តី នឹងនាំគ្នាតាមទៅក្នុងទីនោះ មិនខាន ក៏យ៉ាងនោះឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះព្រះអង្គមានសីលនឹងប្រាជ្ញា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទៀតថា ម្នាលនាគិតៈ តថាគត សូមកុំឲ្យចួបប្រសព្វនឹងយស-បរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យចួបប្រសព្វនឹងតថាគត ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធ-សុខ ដែលតថាគតធ្លាប់បាន ដូចប្រាថ្នា បានដោយងាយ បានដោយស្រួល បុគ្គលនោះឯង រមែងត្រេកអរ ចំពោះសេចក្តីសុខកខ្វក់ សុខក្នុងការដេកលក់ សុខក្នុងលាភសក្ការៈ នឹងសេចក្តីសរសើរ ។

អសិតបីតខាយិតសាយិតស្ស ខោ នាគិត ឧច្ចារ-បស្សាវោ ឯសោ តស្ស និស្សន្ទោ បិយានំ ខោ នាគិត វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិ-ទេវទុក្ខទោមនស្សុបាយាសា ឯសោ តស្ស និស្សន្ទោ អសុភនិមិត្តានុយោគំ អនុយុត្តស្ស ខោ នាគិត អសុភនិមិត្តេ បាដិក្កូល្យតា សណ្ឋាតិ ឯសោ តស្ស និស្សន្ទោ ឆសុ ខោ នាគិត ផស្សា-យតនេសុ អនិច្ចានុបស្សិនោ វិហរតោ ផស្សេ បាដិក្កូល្យតា សណ្ឋាតិ ឯសោ តស្ស និស្សន្ទោ បញ្ចសុ ខោ នាគិត ឧបាទានក្ខន្ធេសុ ឧទយព្វ-យានុបស្សិនោ វិហរតោ ឧបាទានេ បាដិក្កូល្យតា សណ្ឋាតិ ឯសោ តស្ស និស្សន្ទោតិ ។

បញ្ចង្គិកវគ្គោ តតិយោ ។

ម្នាលនាគិតៈ បុគ្គលដែលស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស រមែងមាន ឧច្ចារៈបស្សាវៈ នេះជាអានិសង្សនៃការជ្រោកជ្រាកនោះ ម្នាលនាគិតៈ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្តតែងកើតឡើង ព្រោះប្រែប្រួល ព្រាត់ប្រាស និរាសចាកសត្វសង្ខារជាទីស្រឡាញ់ នេះជាអានិសង្សនៃសេចក្ដីស្រឡាញ់នោះ ម្នាលនាគិតៈ ការខ្ពើមរអើមក្នុងអសុភនិមិត្ត តែងតាំងឡើង ដល់បុគ្គលអ្នកប្រព្រឹត្ត ព្យាយាម ក្នុងអសុភនិមិត្ត នេះជាអានិសង្សនៃសេចក្ដីព្យាយាមនោះ ម្នាលនាគិតៈ ការខ្ពើមរអើម ក្នុងផស្សៈ តែងតាំងឡើងដល់បុគ្គលអ្នកពិចារណារឿយ ៗ ថា មិនទៀង ក្នុងផស្សាយតនៈទាំង ៦ នេះជាអានិសង្សនៃការពិចារណាថា មិនទៀងនោះ ម្នាលនាគិតៈ ការខ្ពើមរអើម ក្នុងឧបាទានក្ខន្ធ តែងតាំងឡើងដល់បុគ្គលអ្នកពិចារណា នូវការកើតឡើង និងការវិនាសទៅ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះជាអានិសង្សនៃការពិចារណាឧបាទានក្ខន្ធនោះ ។

ចប់ បញ្ចង្គិកវគ្គ ទី ៣ ។

# តស្សុទ្ទានំ

ទ្វេគារវូបក្កិលេសា
ទុស្សីលានុគ្គហេន ច
វិមុត្តិ សមាធង្គិកា
ចង្កមោ នាគិតេន ចាតិ

## ឧទ្ទាននៃបញ្ចង្គិកវគ្គនោះ គឺ

និយាយអំពីសេចក្តីមិនគោរព មាន ២ លើក អំពីឧបក្កិលេស ១ អំពីសម្មាសមាធិ របស់បុគ្គលទ្រុស្តសីល ១ អំពីធម៌សម្រាប់ជ្រោមជ្រែងសម្មាទិដ្ឋិ ១ អំពីវិមុត្តាយតនៈ ១ អំពីបុគ្គលអ្នកចំរើនសមាធិ ១ អំពីការចំរើននូវសម្មាសមាធិប្រកបដោយអង្គប្រាំ ១ អំពីអានិសង្ស ក្នុងការចង្ក្រម ១ អំពីនាគិតត្ថេរ ១ ។

# សុមនវគ្គោ

(៣១) អថខោ សុមនា រាជកុមារី បញ្ចហិ រថសតេហិ បញ្ចហិ ច រាជកុមារីសតេហិ បរិវុតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ សុមនា រាជកុមារី ភគវន្តំ ឯតទវោច ឥធស្សុ ភន្តេ ភគវតោ ទ្វេ សាវកា សមសទ្ធា សមសីលា សមបញ្ញា ឯកោ ទាយកោ ឯកោ អទាយកោ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យុំ ទេវភូតានំ បន នេសំ ភន្តេ សិយា វិសេសោ សិយា នានាករណន្តិ ។ សិយា សុមនេតិ ភគវា អវោច យោ សោ សុមនេ ទាយកោ សោ អមុំ អទាយកំ ទេវភូតោ សមានោ បញ្ចហិ ឋានេហិ អធិគណ្ហាតិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ។

# សុមនវគ្គ

(៣១) គ្រានោះ នាងសុមនារាជកុមារី មានរថ៥០០ នឹងរាជកុមារី៥០០អង្គ ហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។ លុះនាងសុមនារាជកុមារី ប្រថាប់ក្នុងទីសមគួរហើយ បានទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សាវកពីររូបរបស់ព្រះដ៏មានព្រះភាគ ក្នុងសាសនានេះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានបញ្ញាស្មើគ្នា ប៉ុន្តែមួយអង្គជាទាយក មួយអង្គមិនមែនជាទាយក សាវកទាំងនោះ ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក បពិត្រព្រះអង្គដ៏ចំរើន សាវកទាំងពីរដែលកើតជាទេវតានោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា សាវកណាជាទាយក សាវកនោះ ដល់កើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ៥យ៉ាង គឺអាយុទិព្វ១ សម្បុរទិព្វ១ សុខទិព្វ១ យសទិព្វ១ អធិបតេយ្យទិព្វ១ ។

យោ សោ សុមនេ ទាយកោ សោ អមុំ អទាយកំ ទេវភូតោ សមានោ ឥមេហិ បញ្ចហិ ឋានេហិ អធិគ្គណ្ហាតីតិ ។ សចេ បន តេ ភន្តេ តតោ ចុតា ឥត្ថត្តំ អាគច្ឆន្តិ មនុស្សភូតានំ បន នេសំ ភន្តេ សិយា វិសេសោ សិយា នានាករណន្តិ ។ សិយា សុមនេតិ ភគវា អវោច យោ សោ សុមនេ ទាយកោ សោ អមុំ អទាយកំ មនុស្សភូតោ សមានោ បញ្ចហិ ឋានេហិ អធិគ្គណ្ហាតិ មានុសកេន អាយុនា មានុសកេន វណ្ណេន មានុសកេន សុខេន មានុសកេន យសេន មានុសកេន អាធិបតេយ្យេន ។ យោ សោ សុមនេ ទាយកោ សោ អមុំ អទាយកំ មនុស្សភូតោ សមានោ ឥមេហិ បញ្ចហិ ឋានេហិ អធិគ្គណ្ហាតីតិ ។ សចេ បន តេ ភន្តេ ឧភោ អគារស្មា អនគារិយំ បព្វជន្តិ បព្វជិតានំ បន នេសំ ភន្តេ សិយា វិសេសោ សិយា នានាករណន្តិ ។ សិយា សុមនេតិ ភគវា អវោច យោ សោ សុមនេ ទាយកោ

ម្នាលនាងសុមនា សាវកណា ជាទាយក សាវកនោះ ដល់ទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះបើទេវតាទាំងពីរនោះ ច្យុតអំពីទេវលោកនោះ មកកើតក្នុងមនុស្សលោកនេះ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលទាំងពីរនោះ ដែលកើតជាមនុស្សហើយ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះ ដល់មកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាង គឺអាយុជារបស់មនុស្ស ១ សម្បុរជារបស់មនុស្ស ១ សុខជារបស់មនុស្ស ១ យសជារបស់មនុស្ស ១ អធិបតេយ្យជារបស់មនុស្ស ១ ។ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះ ដល់មកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះបើអ្នកទាំងពីរនោះ ចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចំរើន បព្វជិតទាំងនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណា ជាទាយក

សោ អមុំ អទាយកំ បព្វជិតោ សមានោ បញ្ចហិ ឋានេហិ អធិគ្គណ្ហាតិ យាចិតោវ ពហុលំ ចីវរំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ បិណ្ឌបាតំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ សេនាសនំ បរិភុញ្ជតិ អប្បំ អយាចិតោ យាចិតោវ ពហុលំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជតិ អប្បំ អយាចិតោ យេហិ ខោ បន សព្រហ្មចារីហិ សទ្ធឹ វិហរតិ ត្យស្ស មនាបេនេវ ពហុលំ កាយកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេន ពហុលំ វចីកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបេន ពហុលំ មនោកម្មេន សមុទាចរន្តិ អប្បំ អមនាបេន មនាបញ្ញេវ(១) ឧបហារំ ឧបហរន្តិ អប្បំ អមនាបំ ។ យោ សោ សុមនេ ទាយកោ សោ អមុំ អទាយកំ បព្វជិតោ សមានោ ឥមេហិ បញ្ចហិ ឋានេហិ អធិគ្គណ្ហាតីតិ ។ សចេ បន តេ ភន្តេ ឧភោ អរហត្តំ បាបុណន្តិ

---

១ ម. មនាបញ្ញេវ ពហុលំ ។

បុគ្គលនោះ លុះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាង គឺបើគេអង្វរ រមែងប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរ ប្រើប្រាស់ចីវរតិច ១ បើគេអង្វរ រមែងបរិភោគបិណ្ឌបាតច្រើន បើគេមិនអង្វរ ក៏បរិភោគបិណ្ឌបាតតិច ១ បើគេអង្វរ រមែងប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់សេនាសនៈតិច ១ បើគេអង្វរ រមែងប្រើប្រាស់គិលានប្បច្ចយ-ភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់គិលានប្បច្ចយភេសជ្ជ-បរិក្ខារតិច ១ បើប្រសិនជានៅ ជាមួយពួកសព្រហ្មចារីណា ពួកសព្រហ្មចារីនោះ រមែងរាប់អានភិក្ខុនោះ ដោយកាយកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច រាប់អានដោយវចីកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច រាប់អានដោយមនោកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ខ្វល់ខ្វាយបំរើ ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ១ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះបើបព្វជិតទាំងពីររូបនោះ បានសម្រេចព្រះអរហត្ត

អរហត្តប្បត្តានំ បន នេសំ ភន្តេ សិយា វិសេសោ សិយា នានាករណន្តិ ។ ឯត្ថ ខោ បនេសាហំ សុមនេ ន កិញ្ចិ នានាករណំ វទាមិ យទិទំ វិមុត្តិយា វិមុត្តិន្តិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវញ្ចិទំ ភន្តេ អលមេវ ទានានិ ទាតុំ អលំ បុញ្ញានិ កាតុំ យត្រ ហិ នាម ទេវភូតស្សបិ ឧបការានិ បុញ្ញានិ មនុស្សភូតស្សបិ ឧបការានិ បុញ្ញានិ បព្វជិតស្សបិ ឧបការានិ បុញ្ញានីតិ ។ ឯវមេតំ សុមនេ ឯវមេតំ សុមនេ អលញ្ហិ សុមនេ ទានានិ ទាតុំ អលំ បុញ្ញានិ កាតុំ ទេវភូតស្សបិ ឧបការានិ បុញ្ញានិ មនុស្សភូតស្សបិ ឧបការានិ បុញ្ញានិ បព្វជិតស្សបិ ឧបការានិ បុញ្ញានីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

បពិត្រព្រះអង្គដ៏ចំរើន បណ្ដាបព្វជិតទាំងពីររូប ដែលបានសម្រេចព្រះអរហត្តហើយនុ៎ះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ម្នាលនាងសុមនា ត្រង់រឿងនុ៎ះ តថាគត មិនសំដែងហេតុផ្សេងគ្នា ត្រង់ចិត្តដែលរួចស្រឡះ ដោយវិមុត្តិនេះទេ ។ បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលគួរឲ្យទានទាំងឡាយមែន គួរធ្វើបុណ្យទាំងឡាយមែន ព្រោះថាបុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើត ជាទេវតាផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការដល់អ្នកបួស (បាននៅយូរ) ផង ។ ម្នាលនាងសុមនា ហេតុនុ៎ះយ៉ាងនេះហើយ ម្នាលនាងសុមនា ហេតុនុ៎ះយ៉ាងនេះហើយ ម្នាលនាងសុមនា បុគ្គលគួរឲ្យទានទាំងឡាយ គួរធ្វើបុណ្យទាំងឡាយ (ព្រោះ) បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើត ជាទេវតាផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើត ជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកបួសផង ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគតបានត្រាស់ពាក្យនេះហើយ ព្រះសាស្តា បានត្រាស់ពាក្យជាគាថានេះតទៅទៀតថា

## បឋមបណ្ណាសកេ សុមនវគ្គោ

យថាបិ ចន្ទោ វិមលោ   គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ   អាភាយ អតិរោចតិ
តថេវ សីលសម្បន្នោ   សទ្ធោ បុរិសបុគ្គលោ
សព្វេ មច្ឆរិនោ លោកេ   ចាគេន អតិរោចតិ ។
យថាបិ មេឃោ ថនយំ   វិជ្ជុមាលី សតក្កកុ
ថលំ និន្នញ្ច បូរេតិ   អភិវស្សំ វសុន្ធរំ
ឯវំ ទស្សនសម្បន្នោ   សម្មាសម្ពុទ្ធសាវកោ
មច្ឆរី អធិគ្គណ្ហាតិ   បញ្ចដ្ឋានេហិ បណ្ឌិតោ
អាយុនា យសសា ចេវ   វណ្ណេន ច សុខេន ច
ស វេ ភោគបរិព្យុឡ្ហោ   បេច្ច សគ្គេ បមោទតីតិ ។

(៣២) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ ចុន្ទី រាជកុមារី បញ្ចហិ រថសតេហិ បញ្ចហិ ច កុមារីសតេហិ បរិវុតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

ព្រះចន្ទមិនមានមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿងលើសជាងពួកផ្កាយទាំងអស់លើអាកាស ដោយពន្លឺ (របស់ខ្លួន) យ៉ាងណាមិញ បុរសបុគ្គលមានសទ្ធាបរិបូណ៌ ដោយសីល រមែងរុងរឿងជាងពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោកដោយចាគៈក៏យ៉ាងនោះដែរ ។ កាលភ្លៀងប្រកបដោយផ្គរបន្ទោររងំផ្ទៀលផ្លាត់បរិបូណ៌ ដោយភ្នំទឹកដ៏ច្រើន បង្អុរចុះមកបំពេញផែនដី ដែលខ្ពស់ទាបឲ្យពោរពេញ យ៉ាងណាមិញ សាវករបស់ព្រះសម្មាសម្ពុទ្ធដែលបរិបូណ៌ ដោយទស្សនៈជាបណ្ឌិត រមែងគ្របសង្កត់បុគ្គល អ្នកមានសេចក្តីកំណាញ់ដោយហេតុ ៥ យ៉ាងគឺ អាយុ យស សម្បុរ សុខ និងអធិបតី បណ្ឌិតនោះឯង បរិបូណ៌ដោយភោគៈដល់ទៅលោកខាងមុខ រមែងរីករាយ ក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។

[៣៦] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបដ្ឋាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ នាងចុន្ទីរាជកុមារី មានរថ ៥០០ និងកុមារី ៥០០ ហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នា ខោ ចុន្ទី រាជកុមារី ភគវន្តំ ឯតទវោច អម្ហាកំ ភន្តេ ភាតា ចុន្ទោ នាម រាជកុមារោ សោ ឯវមាហ យទេវ សោ ហោតិ ឥត្ថី វា បុរិសោ វា ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ សោ កាយស្ស ភេទា បរម្មរណា សុគតិញ្ញេវ ឧបបជ្ជតិ នោ ទុគ្គតិន្តិ ។ សាហំ ភន្តេ ភគវន្តំ បុច្ឆាមិ កថំរូបេ នុ ខោ ភន្តេ សត្ថរិ បសន្នោ កាយស្ស ភេទា បរម្មរណា សុគតិញ្ញេវ ឧបបជ្ជតិ នោ ទុគ្គតឹ កថំរូបេ ធម្មេ បសន្នោ កាយស្ស ភេទា បរម្មរណា សុគតិញ្ញេវ ឧបបជ្ជតិ នោ ទុគ្គតឹ កថំរូបេ សង្ឃេ បសន្នោ កាយស្ស ភេទា បរម្មរណា សុគតិញ្ញេវ ឧបបជ្ជតិ នោ ទុគ្គតឹ កថំរូបេសុ សីលេសុ បរិបូរការី កាយស្ស ភេទា បរម្មរណា សុគតិញ្ញេវ ឧបបជ្ជតិ នោ ទុគ្គតិន្តិ ។

លុះនាងចុន្ទីរាជកុមារី ប្រថាប់ក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន រាជកុមារឈ្មោះចុន្ទៈ ជាបងខ្ញុំព្រះអង្គនោះ និយាយយ៉ាងនេះថា តាមតែបុគ្គលណាក៏ដោយ ទោះស្ត្រីក្តី បុរសក្តី ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងហើយ វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមសួរព្រះដ៏មានព្រះភាគថា បុគ្គលជ្រះថ្លា ក្នុងព្រះសាស្តា មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ ជ្រះថ្លាក្នុងព្រះធម៌ មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ ជ្រះថ្លាក្នុងព្រះសង្ឃ មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិ បំពេញក្នុងសីល មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។

យាវតា ចុន្ទ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញិនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ ។ យេ ខោ ចុន្ទ ពុទ្ធេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ចុន្ទ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហក្ខយោ វិរាគោ និរោធោ និព្ពានំ ។ យេ ខោ ចុន្ទ វិរាគេ ធម្មេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ចុន្ទ សង្ឃា វា គណា វា តថាគតសាវកសង្ឃោ តេសំ អគ្គមក្ខាយតិ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា

ម្នាលនាងចុន្ទី រាប់តាំងពីពួកសត្វឥតជើងក្តី មានជើង ២ ក្តី ជើង ៤ ក្តី ជើងច្រើនក្តី មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជ្រះថ្លា ក្នុងព្រះពុទ្ធ ពួកបុគ្គលនោះ ឈ្មោះថា ជ្រះថ្លា ក្នុងបុគ្គលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លា ក្នុងបុគ្គលដ៏ប្រសើរ ។ ម្នាលនាងចុន្ទី ពួកសង្ខតធម៌ក្តី អសង្ខតធម៌ក្តី ទាំងប៉ុន្មាន វិរាគធម៌ គឺធម៌ញុំាងសេចក្តីស្រវឹងឲ្យទ្រុឌទ្រោម នាំបង់នូវសេចក្តីស្រេកឃ្លាន គាស់រំលើងនូវសេចក្តីអាល័យ ផ្តាច់បង់នូវវដ្ដៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ មិនមានគ្រឿងចាក់ដោត ប្រាកដជាប្រសើរ ជាងពួកធម៌ទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជ្រះថ្លា ក្នុងវិរាគធម៌ ពួកបុគ្គលនោះ ឈ្មោះថាជ្រះថ្លា ក្នុងធម៌ដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លា ក្នុងធម៌ដ៏ប្រសើរ ។ ម្នាលនាងចុន្ទី សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវករបស់តថាគត បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨

ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ យេ ខោ ភិក្ខវេ សង្ឃេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ សីលានិ អរិយកន្តានិ តេសំ អគ្គមក្ខាយតិ យទិទំ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ ។ យេ ខោ ភិក្ខវេ អរិយកន្តេសុ សីលេសុ បរិបូរការិនោ អគ្គេ តេ បរិបូរការិនោ អគ្គេ ខោ បន បរិបូរការីនំ អគ្គោ វិបាកោ ហោតីតិ ។

សង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ជាអ្នកគួរទទួល ចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះ ហើយនាំមកបូជា គួរទទួល អាគន្តុកទាន គួរទទួលទក្ខិណាទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា គួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វលោក ប្រាកដជាប្រសើរ ជាងសង្ឃបុគ្គលៈទាំង នោះ ៗ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជ្រះថ្លា ក្នុងព្រះសង្ឃ ពួក បុគ្គលនោះ ឈ្មោះថាជ្រះថ្លា ក្នុងព្រះសង្ឃដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លា ក្នុងព្រះសង្ឃដ៏ប្រសើរ ៗ ម្នាល នាងចុន្ទី សីលដែលព្រះអរិយៈសរសើរទាំងអម្បាលម៉ាន ជាសីលមិន ដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលអ្នកជា ដែលវិញ្ញូជន សរសើរហើយ មិនប៉ះពាល់ ដោយតណ្ហានិងទិដ្ឋិ ប្រព្រឹត្តទៅដើម្បី សមាធិ នេះប្រាកដជាប្រសើរ ជាងសីលទាំងនោះ ៗ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជាអ្នកបំពេញក្នុងពួកសីល ដែលព្រះអរិយៈសរសើរ ហើយ ពួកបុគ្គលទាំងនោះ ឈ្មោះថាបានបំពេញ ក្នុងសីលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកបំពេញ ក្នុងសីលដ៏ប្រសើរ ៗ

## បឋមបណ្ណាសកេ សុមនវគ្គោ

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ
អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ
ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតីតិ ។

(៣៣) ឯកំ សមយំ ភគវា ភទ្ទិយេ វិហរតិ ជាតិយាវនេ ។ អថខោ ឧគ្គហោ មេណ្ឌកនត្តា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

បុណ្យគឺ អាយុដ៏ប្រសើរផង យសស័ក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចំរើនដល់ពួកបុគ្គលអ្នកព្រោះថានឹងវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ប្រសើរ ព្រោះថា ក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គល រកបុគ្គលដទៃក្រៃលែងជាងគ្មាន ព្រោះថា ក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាករាគៈ ជាធម៌ស្ងប់រម្ងាប់ នាំមកនូវសុខ ព្រោះថា ក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្ត រកខេត្តដទៃក្រៃលែងជាងគ្មាន ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ បុគ្គលអ្នកមានប្រាជ្ញា មានចិត្តដំកល់ ក្នុងធម៌ដ៏ប្រសើរ ជាអ្នកឲ្យនូវទានចំពោះបុគ្គល ដ៏ប្រសើរ តែងបានទៅកើតជាទេវតាឬមនុស្ស ដល់នូវសេចក្តីប្រសើរ រមែងរីករាយ ។

(៣៣) សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងជាតិយាវន ទៀបក្រុងភទ្ទិយៈ ។ គ្រានោះ ឧគ្គហមេណ្ឌកនត្តា (ជាចៅមេណ្ឌកសេដ្ឋី) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ ឧគ្គហោ មេណ្ឌកនត្តា ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ អត្តចតុត្ថោ ភត្តន្តិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ឧគ្គហោ មេណ្ឌកនត្តា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧគ្គហស្ស មេណ្ឌកនត្តុនោ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ឧគ្គហោ មេណ្ឌកនត្តា ភគវន្តំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ឧគ្គហោ មេណ្ឌកនត្តា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧគ្គហោ មេណ្ឌកនត្តា ភគវន្តំ ឯតទវោច ឥមា មេ ភន្តេ កុមារិយោ បតិកុលានិ គមិស្សន្តិ

លុះឧគ្គហមេណ្ឌកនត្តា អង្គុយក្នុងទីសមគួររួចហើយ បានក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ មានភិក្ខុជាគំរប់ ៤ នឹងព្រះអង្គ ទទួលភត្តខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគ ទទួលដោយតុណ្ហីភាព ។ គ្រានោះ ឧគ្គហមេណ្ឌកនត្តាដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចេញទៅ ។ ដល់វេលាព្រឹកនូវហើយ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅឯលំនៅរបស់ឧគ្គហមេណ្ឌកនត្តា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ ឧគ្គហមេណ្ឌកនត្តា អង្គាសព្រះដ៏មានព្រះភាគ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ដោយដៃខ្លួនឯង គ្រាតែព្រះដ៏មានព្រះភាគ ទ្រង់ឃាត់ ។ លុះឧគ្គហមេណ្ឌកនត្តា (ឃើញ) ព្រះដ៏មានព្រះភាគ ឆាន់រួចលែងលូកព្រះហស្តក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧគ្គហមេណ្ឌកនត្តា អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកកុមារីរបស់ខ្ញុំព្រះអង្គទាំងអម្បាលនេះ មុខជានឹងទៅកាន់ត្រកូលប្តី

ឱវទតុ តាសំ ភន្តេ ភគវា អនុសាសតុ តាសំ ភន្តេ ភគវា យំ តាសំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ ភគវា តា កុមារិយោ ឯតទវោច តស្មាតិហ កុមារិយោ ឯវំ សិក្ខិតព្វំ យស្ស វោ មាតាបិតរោ ភត្តុនោ ទស្សន្តិ អត្ថកាមា ហិតេសិនោ អនុកម្បកា អនុកម្បំ ឧបាទាយ តស្ស ភវិស្សាម បុព្វុដ្ឋាយិនិយោ បច្ឆានិបាតិនិយោ កឹការបដិស្សាវិនិយោ មនាបចារិនិយោ បិយវាទិនិយោតិ ឯវំ ហិ វោ កុមារិយោ សិក្ខិតព្វំ ។ តស្មាតិហ កុមារិយោ ឯវំ សិក្ខិតព្វំ យេ តេ ភត្តុ គរុនោ ភវិស្សន្តិ មាតាតិ វា បិតាតិ វា សមណព្រាហ្មណាតិ វា តេ សក្ករិស្សាម គរុករិស្សាម មានេស្សាម បូជេស្សាម អព្ភាគតេ ច អាសនោទកេន បដិបូជេស្សាមាតិ ឯវំ ហិ វោ កុមារិយោ សិក្ខិតព្វំ ។

បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទូន្មានពួកកុមារីទាំងនោះឲ្យបាន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ប្រៀនប្រដៅពួកកុមារីទាំងនោះ ដោយឱវាទានុសាសនៈណា ដែលនាំឲ្យបានប្រយោជន៍និងសេចក្ដីសុខ អស់កាលដ៏វែងដល់កុមារីទាំងនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកកុមារីទាំងនោះ យ៉ាងនេះថា ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សា យ៉ាងនេះថា មាតានិងបិតា ជាអ្នកប្រាថ្នាសេចក្ដីចំរើន ជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យសេចក្ដីអនុគ្រោះហើយឲ្យដល់បុរសជាស្វាមីណា យើងទាំងឡាយ ជាស្រីភ្ញាក់ឡើងមុនគេ ដេកក្រោយគេ ប្រុងខ្លួននឹងទទួលកិច្ចការអ្វី ៗ ប្រព្រឹត្តផ្គាប់ផ្គុន និយាយពាក្យផ្អែមល្ហែមដល់ស្វាមីនោះ ម្នាលកុមារីទាំងឡាយ ឲ្យនាងត្រូវសិក្សា យ៉ាងនេះចុះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា បុគ្គលណាជាទីគោរពនៃស្វាមីទោះជាមាតាក្ដី បិតាក្ដី សមណព្រាហ្មណ៍ក្ដី យើងទាំងឡាយនឹងធ្វើសក្ការៈ គោរព កប់អាន បូជាដល់បុគ្គលទាំងនោះ ទាំងទទួលគួរសមរៀបចំដោយអាសនៈនិងទឹកលាងជើង ចំពោះជនទាំងឡាយ ដែលមកដល់ហើយ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។

តស្មាតិហ កុមារិយោ ឯវំ សិក្ខិតព្វំ យេ តេ ភត្តុ អព្ភន្តរា កម្មន្តា ឧណ្ណាតិ វា កប្បាសាតិ វា តត្ថ ទក្ខា ភវិស្សាម អនលសា តត្រុបាយាយ វីមំសាយ សមន្នាគតា អលំ កាតុំ អលំ សំវិធាតុន្តិ ឯវញ្ហិ វោ កុមារិយោ សិក្ខិតព្វំ ។ តស្មាតិហ កុមារិយោ ឯវំ សិក្ខិតព្វំ យោ សោ ភត្តុ អព្ភន្តរោ អន្តោជនោ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេសំ កតញ្ច កតតោ ជានិស្សាម អកតញ្ច អកតតោ ជានិស្សាម គិលានកានញ្ច ពលាពលំ ជានិស្សាម ខាទនីយំ ភោជនីយំ ចស្ស បច្ចយំសេន វិភជិស្សា-មាតិ[១] ឯវញ្ហិ វោ កុមារិយោ សិក្ខិតព្វំ ។ តស្មាតិហ កុមារិយោ ឯវំ សិក្ខិតព្វំ យំ ភត្តា អាហរិស្សតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា តំ អារក្ខេន គុត្តិយា សម្បាទេស្សាម

១ ឱ. បច្ចំសេន វិភជិស្សាមាតិ ។ ម. បច្ចយំសេនាសនំ បច្ចត្តំសេន សំវិភជិស្សាមាតិ ។

ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ការងារទាំងឡាយណា ខាងក្នុងផ្ទះរបស់ប្តី ទោះរោមចៀមក្តី កប្បាសក្តី ពួកយើងនឹងជាស្រីឈ្លាសវៃ ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស បរិបូណ៌ដោយឧបាយនឹងការត្រិះរិះ ក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ជនណាជាជនខាងក្នុងផ្ទះរបស់ស្វាមី ទោះខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី ពួកយើងដឹងការងារដែលជនទាំងនោះធ្វើហើយ ព្រោះការងារដែលជនទាំងនោះ ធ្វើហើយផង ដឹងការងារដែលជនទាំងនោះ មិនបានធ្វើ ព្រោះការងារដែលជនទាំងនោះ មិនបានធ្វើផង ដឹងថាឈឺធ្ងន់ ឈឺស្រាលផង ហើយចែករំលែកខាទនីយភោជនីយាហារ ជាចំណែក ៗ ដល់ជនទាំងនោះផង ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារី ក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ស្វាមីនាំរបស់ណាមក ទោះទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី យើងទាំងឡាយនឹងធ្វើរបស់នោះ ឲ្យសម្រេចដោយការរក្សានឹងការគ្រប់គ្រង

តត្ថ ច ភវិស្សាម អធុត្តី អថេនី អសោណ្ឌី អវិនាសិកាតិ ឯវំ ហិ វោ កុមារិយោ សិក្ខិតព្វំ ។ ឥមេហិ ខោ កុមារិយោ បញ្ចហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

យោ នំ ភរតិ សព្វទា និច្ចំ អាតាបិ ឧស្សុកោ
សព្វកាមហរំ បោសំ ភត្តារំ នាតិមញ្ញតិ
ន ចាបិ សោត្ថិ ភត្តារំ ឥស្សាចារេន[១] រោសយេ
ភត្តុ ច គរុនោ សព្វេ បដិបូជេតិ បណ្ឌិតា
ឧដ្ឋាយិកា អនលសា សង្គហិតបរិជ្ជនា
ភត្តុ មនាបំ ចរតិ សំភតំ អនុរក្ខតិ ។
យា ឯវំ វត្តតី នារី ភត្តុ ឆន្ទវសានុគា
មនាបា នាម តេ ទេវា យត្ថ សា ឧបបជ្ជតីតិ ។

---

១ ឱ. ឥស្សាវាទេន ។

មិនជាស្រីអ្នកលេង មិនជាស្រីអ្នកលួច មិនជាស្រីអ្នកផឹកសុរា មិនមែនជាស្រីអ្នកបំផ្លាញរបស់ទ្រព្យដែលខ្លួនគ្រប់គ្រងនោះ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលនាងកុមារីទាំងឡាយ មាតុគ្រាម ប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងពួកទេវតាមានកាយជាទីគាប់ចិត្ត ។

ស្វាមីណា ចិញ្ចឹមភរិយានោះសព្វកាល មានព្យាយាមខ្វល់
ខ្វាយជានិច្ច ភរិយាមិនត្រូវមើលងាយស្វាមីអ្នកចិញ្ចឹម អ្នក
បំពេញសេចក្ដីប្រាថ្នាទាំងពួង (នោះ) ឡើយ ស្ត្រីល្អមិនត្រូវ
ក្រោធខឹងនឹងស្វាមី ដោយភរិយាប្រព្រឹត្តឫស្យាផង ស្ត្រីអ្នក
ចេះដឹង រមែងគួរសមនឹងពួកជនទាំងពួង អ្នកជាទីគោរព
របស់ស្វាមីផង ភរិយាជាស្ត្រីមានព្យាយាម មិនខ្ជិលច្រអូស
សង្គ្រោះជនជាខាងក្នុងផ្ទះស្វាមី ប្រព្រឹត្តកិច្ចការជាទីគាប់
ចិត្តរបស់ស្វាមី រក្សាទុកនូវសម្បត្តិដែលស្វាមីបានមកហើយ
ដោយប្រពៃ ។ នារីណាបានប្រព្រឹត្តយ៉ាងនេះ លុះតាម
អំណាចសេចក្ដីប្រាថ្នារបស់ស្វាមី នារីនោះ រមែងទៅកើត
ក្នុងពួកទេវតាទាំងនោះ ដែលមានកាយជាទីពេញចិត្ត ។

[៣៤] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ សីហោ សេនាបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សីហោ សេនាបតិ ភគវន្តំ ឯតទវោច សក្កា នុ ខោ ភន្តេ សន្ទិដ្ឋិកំ ទានផលំ បញ្ញាបេតុន្តិ ។ សក្កា សីហាតិ ភគវា អវោច ទាយកោ សីហ ទានបតិ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ យំបិ សីហ ទាយកោ ទានបតិ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ ឥទំបិ សន្ទិដ្ឋិកំ ទានផលំ ។ បុន ចបរំ សីហ ទាយកំ ទានបតឹ សន្តោ សប្បុរិសា ភជន្តិ យំបិ សីហ ទាយកំ ទានបតឹ សន្តោ សប្បុរិសា ភជន្តិ ឥទំបិ សន្ទិដ្ឋិកំ ទានផលំ ។ បុន ចបរំ សីហ ទាយកស្ស ទានបតិនោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ

(៣៤) សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅ ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ សីហសេនាបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសីហសេនាបតី អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ញត្តផលទាន ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯងបានឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសីហៈ អាចបញ្ញត្តបាន ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ដោយហេតុណា ហេតុនេះឯង ជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងគប់រកទាយកអ្នកម្ចាស់ទាន ម្នាលសីហៈ បើពួកសប្បុរស មានចិត្តស្ងប់រម្ងាប់ តែងគប់រកទាយកអ្នកម្ចាស់ទាន ដោយហេតុណា ហេតុនេះជាផលទាន ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត កិត្តិស័ព្ទដ៏ពីរោះរបស់ទាយកអ្នកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ

យំបិ សីហ ទាយកស្ស ទានបតិនោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ឥទំបិ សន្ទិដ្ឋិកំ ទានផលំ ។ បុន ចបរំ សីហ ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧប-សង្កមតិ អមង្កុភូតោ យំបិ សីហ ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ ឥទំបិ សន្ទិដ្ឋិកំ ទានផលំ ។ បុន ចបរំ សីហ ទាយកោ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ យំបិ សីហ ទាយកោ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ឥទំបិ សម្បរាយិកំ ទានផលន្តិ ។ ឯវំ វុត្តេ សីហោ សេនាបតិ

ម្នាលសីហៈ ឯកិត្តិស័ព្ទដ៏ពីរោះរបស់ទាយកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅដោយហេតុណា ហេតុនេះឯងជាផលទាន ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកម្ចាស់ទានចូលទៅកាន់បរិសទ្យណា ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី រមែងក្លៀវក្លាមិនមានសេចក្តីអៀនខ្មាស ម្នាលសីហៈ បើទាយកម្ចាស់ទាន ចូលទៅកាន់បរិសទ្យណាក៏ដោយ ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ក៏ក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ដោយហេតុណា ហេតុនេះជាផលទានដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលសីហៈ បើទាយកម្ចាស់ទានបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោកដោយហេតុណា ហេតុនេះជាផលទាន មានក្នុងលោកខាងមុខ ។ កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ សីហសេនាបតី

ភគវន្តំ ឯតទវោច យានីមានិ ភន្តេ ភគវតា ចត្តារិ សន្ទិដ្ឋិកានិ ទានផលានិ អក្ខាតានិ នាហំ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ អហំបេតានិ ជានាមិ ។ អហំ ភន្តេ ទាយកោ ទានបតិ ពហុនោ ជនស្ស បិយោ មនាបោ ។ អហំ ភន្តេ ទាយកោ ទានបតិ មំ សន្តោ សប្បុរិសា ភជន្តិ ។ អហំ ភន្តេ ទាយកោ ទានបតិ មយ្ហំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សីហោ សេនាបតិ ទាយកោ ការកោ សង្ឃុ-បដ្ឋាកោតិ ។ អហំ ភន្តេ ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមាមិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមាមិ អមង្កុភូតោ ។ យានីមានិ ភន្តេ ភគវតា ចត្តារិ សន្ទិដ្ឋិកានិ ទានផលានិ អក្ខាតានិ នាហំ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ អហំបេតានិ ជានាមិ ។

បានក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ផលទានទាំង ៤ ប្រការ ដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសំដែងប្រាប់ហើយនេះ ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ខ្ញុំព្រះអង្គបានដឹងផលទានទាំងនុ៎ះដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន ពួកសប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ តែងគប់រកខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន កិត្តិស័ព្ទដ៏ពីរោះរបស់ខ្ញុំ ក៏លាន់ឮថា សីហសេនាបតី ជាអ្នកឲ្យទាន ជាអ្នកធ្វើបុណ្យ អ្នកឧបដ្ឋាកសង្ឃ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន ចូលទៅកាន់បរិសទ្យណា ទោះជាខត្តិយបរិសទ្យ ព្រាហ្មណបរិសទ្យ គហបតិបរិសទ្យ សមណបរិសទ្យ រមែងក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ។ បពិត្រព្រះអង្គដ៏ចំរើន ផលទានទាំង ៤ ប្រការ ដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសំដែងហើយនេះ ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ដ្បិតខ្ញុំព្រះអង្គដឹងនូវផលទានទាំងនោះដែរ ។

យញ្ច ខោ មំ ភន្តេ ភគវា ឯវមាហ ទាយកោ សីហ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ។ ឯតាហំ ន ជានាមិ ឯត្ថ ច បនាហំ ភគវតោ សទ្ធាយ គច្ឆាមីតិ ។ ឯវមេតំ សីហ ឯវមេតំ សីហ ទាយកោ សីហ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ។

ទទំ បិយោ ហោតិ ភជន្តិ នំ ពហូ
កិត្តឹ ច បប្បោតិ យសស្ស វឌ្ឍតិ
អមង្កុភូតោ បរិសំ វិគាហតិ
វិសារទោ ហោតិ នរោ អមច្ឆរី
តស្មា ហិ ទានានិ ទទន្តិ បណ្ឌិតា
វិនេយ្យ មច្ឆេរមលំ សុខេសិនោ
តេ ទីឃរត្តំ តិទិវេ បតិដ្ឋិតា

បពិត្រព្រះអង្គដ៏ចំរើន ត្រង់ដែលព្រះដ៏មានព្រះភាគ បានត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះរួចហើយថា ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ខ្ញុំព្រះអង្គមិនដឹងហេតុនុ៎ះមែន ក៏ប៉ុន្តែថា ខ្ញុំព្រះអង្គបេះតែជឿព្រះដ៏មានព្រះភាគក្នុងផលទាននោះ ។ ម្នាលសីហៈ រឿងនុ៎ះពិតមែន ម្នាលសីហៈ រឿងនុ៎ះពិតមែន ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

នរជន មិនមានសេចក្ដីកំណាញ់ ជាអ្នកឲ្យទាន ជាទី
ស្រឡាញ់ (របស់ជនដ៏ច្រើន) ផង ពួកសប្បុរសជាច្រើន
តែងគប់រក ទាយកនោះផង (ទាយកនោះ) ដល់នូវ
កិត្តិស័ព្ទផង យសរមែងចំរើន ដល់ទាយកនោះផង
ទាយកនោះ ចូលទៅកាន់បរិសទ្យ មិនមានសេចក្ដីអៀន
ខ្មាស មានតែសេចក្ដីក្លៀវក្លាផង ហេតុដូច្នោះ បណ្ឌិត
ទាំងឡាយ អ្នកស្វែងរកសេចក្ដីសុខ ត្រូវលះបង់នូវមន្ទិល
គឺសេចក្ដីកំណាញ់ ហើយឲ្យនូវទានទាំងឡាយ បណ្ឌិត
ទាំងនោះ ស្ថិតនៅ ក្នុងស្ថានត្រៃត្រិង្សអស់កាលយូរអង្វែង

ទេវានំ សហាព្យតា រមន្តិ តេ
កតាវកាសា កតកុសលា ឥតោ ចុតា
សយម្បភា អនុវិចរន្តិ នន្ទនេ
តេ តត្ថ នន្ទន្តិ រមន្តិ មោទរេ
សមប្បិតា កាមគុណេហិ បញ្ចហិ ។
កត្វាន វាក្យំ អសិតស្ស តាទិនោ
រមន្តិ សគ្គេ សុគតស្ស សាវកាតិ ។

(៣៥) បញ្ចិមេ ភិក្ខវេ ទានេ អានិសំសា ។ កតមេ បញ្ច ។ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ សន្តោ សប្បុរិសា ភជន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ គិហិធម្មា អនបគតោ(១) ហោតិ កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ទានេ អានិសំសាតិ ។

១ ឱ. គិហិធម្មា អនបេតោ ។ ម. គិហិធម្មមនុបគតោ ។

បណ្ឌិតទាំងនោះទៅកើតក្នុងសហភាពនៃពួកទេវតា រីករាយសប្បាយ បណ្ឌិតទាំងនោះមានឱកាសធ្វើហើយ មានកុសលធ្វើហើយ ច្យុតអំពីលោកនេះ មានរស្មីខ្លួនឯង អន្ទោលទៅក្នុងទីជាទីត្រេកអរ បណ្ឌិតទាំងនោះ ស្កប់ស្កល់ដោយកាមគុណទាំង ៥ រីករាយ សប្បាយក្នុងទីនោះ ៗ ពួកសាវកទាំងអស់របស់ព្រះសុគត ធ្វើតាមពាក្យរបស់ព្រះតថាគត ព្រះអង្គមិនជាប់ដោយអកុសលធម៌ . ប្រកបដោយតាទិគុណហើយ រមែងរីករាយ ៗ

( ៣៥ ) ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងទាននេះ មាន ៥ យ៉ាង ៗ ៥ យ៉ាង ដូចម្តេចខ្លះ ៗ គឺជាទីស្រឡាញ់ ជាទីគាប់ចិត្តជនច្រើន ១ ពួកសប្បុរសអ្នកស្ងប់ រមែងគប់រក ១ មានកិត្តិស័ព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ មិនបានប្រាសចាកធម៌របស់គ្រហស្ថ ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ៗ ម្នាលភិក្ខុទាំងឡាយ នេះអានិសង្សក្នុងទានទាំង ៥ យ៉ាង ៗ

ទទមានោ បិយោ ហោតិ សតំ ធម្មំ អនុក្កមំ
សន្តោ នំ សទា ភជន្តិ សញ្ញតា [ព្រ]ហ្មចារយោ
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតនាសវោតិ ។

(៣៦) បញ្ចិមានិ ភិក្ខវេ កាលទានានិ ។ កតមានិ បញ្ច ។ អាគន្តុកស្ស ទានំ ទេតិ គមិកស្ស ទានំ ទេតិ គិលានស្ស ទានំ ទេតិ ទុព្ភិក្ខេ ទានំ ទេតិ យានិ តានិ នវសស្សានិ នវផលានិ តានិ បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច កាលទានានីតិ ។

កាលេ ទទន្តិ សប្បញ្ញា វទញ្ញូ វីតមច្ឆរា
កាលេន ទិន្នំ អរិយេសុ ឧជុភូតេសុ តាទិសុ
វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា ។

បុគ្គលកាលឲ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូលទៅ
តាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារី អ្នកសង្រួម
មានចិត្តស្ងប់រម្ងាប់ រមែងគប់រកបុគ្គលនោះសព្វកាល ពួក
ព្រហ្មចារីនោះ រមែងសំដែងធម៌ ជាគ្រឿងបន្ទោបង់នូវ
ទុក្ខទាំងអស់ ដល់បុគ្គលនោះ ទាំងបុគ្គលនោះដឹងនូវធម៌
ហើយជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ក្នុងលោកនេះ ។

[៣៦] ម្នាលភិក្ខុទាំងឡាយ កាលទាននេះមាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺឲ្យទានដល់អ្នកមកថ្មី ១ ឲ្យទានដល់អ្នកមានដំណើរ ១ ឲ្យទានដល់អ្នកមានជម្ងឺ ១ ឲ្យទានក្នុងពេលអត់បាយ ១ បានដំកល់ស្រូវថ្មី ផ្លែឈើដំបូងដល់បុគ្គលមានសីលទាំងឡាយជាដំបូង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាកាលទាន ៥ យ៉ាង ។

ពួកជនមានបញ្ញា ដឹងភាសិតរបស់អ្នកប្រាជ្ញ មានសេចក្ដី
កំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែង
ឲ្យទាន ក្នុងកាលគួរ ទានដែលបុគ្គលឲ្យ តាមកាល
គួរ ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមាន
កាយនឹងចិត្ត ប្រកបដោយតាទិគុណ ទក្ខិណាទាន
របស់បុគ្គលនោះ ជាទានមានផលបរិបូណ៌ ។

យេ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា
ន តេន ទក្ខិណា ឩនា តេបិ បុញ្ញស្ស ភាគិនោ ។
តស្មា ទទេ អប្បដិវានចិត្តោ យត្ថ ទិន្នំ មហប្ផលំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនន្តិ ។

(៣៧) ភោជនំ ភិក្ខវេ ទទមានោ ទាយកោ បដិគ្គាហកានំ បញ្ច ឋានានិ ទេតិ ។ កតមានិ បញ្ច ។ អាយុំ ទេតិ វណ្ណំ ទេតិ សុខំ ទេតិ ពលំ ទេតិ បដិភាណំ ទេតិ ។ អាយុំ ខោ បន ទត្វា អាយុស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា វណ្ណំ ទត្វា វណ្ណស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា សុខំ ទត្វា សុខស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា ពលំ ទត្វា ពលស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា បដិភាណំ ទត្វា បដិភាណស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា ។

ពួកជនណា អនុមោទនា ឬធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងទក្ខិណា-ទាននោះ ទក្ខិណាទានរបស់អ្នកទាំងនោះ ទើបបានឈ្មោះថាជាទានថយថោក ព្រោះតែអនុមោទនាឬធ្វើការខ្វល់ខ្វាយនោះក៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែកបុណ្យដែរ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលណាជាទានមានផលច្រើន បុគ្គលមានចិត្តមិនបានរួញរា គប្បីឲ្យទាន ចំពោះបុគ្គលនោះ ព្រោះថាបុណ្យទាំងឡាយ រមែងជាទីពឹងនៃពួកសត្វ ក្នុងលោកខាងមុខ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យភោជនាហារ ឈ្មោះថាឲ្យស្ថាន ៥ យ៉ាងដល់បដិគ្គាហកៈទាំងឡាយ ។ ស្ថាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យអាយុ ១ ឲ្យពណ៌សម្បុរ ១ ឲ្យសុខ ១ ឲ្យកម្លាំង ១ ឲ្យបដិភាណគឺប្រាជ្ញាវាងវៃ ១ ។ បុគ្គលដែលបានឲ្យអាយុហើយ រមែងបានចំណែកអាយុទិព្វ ឬអាយុជារបស់មនុស្ស ឲ្យពណ៌សម្បុរ រមែងបានចំណែកពណ៌សម្បុរទិព្វ ឬសម្បុររបស់មនុស្ស ឲ្យសុខ រមែងបានចំណែកសុខទិព្វ ឬសុខជារបស់មនុស្ស ឲ្យកម្លាំង រមែងបានចំណែកកម្លាំងទិព្វ ឬកម្លាំងជារបស់មនុស្ស ឲ្យបដិភាណ រមែងបានចំណែកបដិភាណជារបស់ទិព្វ ឬបដិភាណជារបស់មនុស្ស ។

ភោជនំ ភិក្ខវេ ទទមានោ ទាយកោ បដិគ្គាហកានំ ឥមានិ បញ្ច ឋានានិ ទេតីតិ ។

អាយុទោ ពលទោ ធីរោ វណ្ណទោ បដិភាណទោ
សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ ។
អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណកំ
ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតីតិ ។

(៣៨) បញ្ចិមេ ភិក្ខវេ សទ្ធេ កុលបុត្តេ អានិសំសា ។ កតមេ បញ្ច ។ យេ តេ ភិក្ខវេ លោកេ សន្តោ សប្បុរិសា តេ សទ្ធញ្ញេវ បឋមំ អនុកម្បន្តា អនុកម្បន្តិ នោ តថា អស្សទ្ធំ សទ្ធញ្ញេវ បឋមំ ឧបសង្កមន្តា ឧបសង្កមន្តិ នោ តថា អស្សទ្ធំ សទ្ធស្សេវ បឋមំ បដិគ្គណ្ហន្តា បដិគ្គណ្ហន្តិ នោ តថា អស្សទ្ធស្ស សទ្ធស្សេវ បឋមំ ធម្មំ ទេសេន្តា ទេសេន្តិ នោ តថា អស្សទ្ធស្ស សទ្ធោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ ទាយកកាលឲ្យភោជនាហារ ឈ្មោះថាឲ្យស្ថាន ៥ យ៉ាងនេះ ដល់បដិគ្គាហកៈទាំងឡាយ ។

ធីរជនអ្នកមានប្រាជ្ញា ជាអ្នកឲ្យអាយុ ឲ្យកម្លាំង ឲ្យពណ៌
សម្បុរ ឲ្យបដិភាណ ឲ្យសុខ (ដល់គេ) ហើយ ធីរជននោះ
រមែងបានសុខ ។ អ្នកប្រាជ្ញ ឲ្យអាយុ ពណ៌សម្បុរ
សេចក្តីសុខ ទាំងបដិភាណ ទៅកើតក្នុងទីណា ៗ រមែងមាន
អាយុវែង មានយសបរិវារ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ អានិសង្ស ក្នុងកុលបុត្តអ្នកមានសទ្ធានេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសប្បុរសដែលមានចិត្តស្ងប់ក្នុងលោក សប្បុរសទាំងនោះ កាលអនុគ្រោះ រមែងអនុគ្រោះតែបុគ្គលដែលមានសទ្ធាជាដំបូង មិនអនុគ្រោះបុគ្គល មិនមានសទ្ធាដូច្នោះទេ ១ កាលចូលទៅជិត រមែងចូលទៅជិតតែបុគ្គលមានសទ្ធាជាដំបូង មិនចូលទៅជិតបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលទទួល រមែងទទួលតែបុគ្គលមានសទ្ធាជាដំបូង មិនទទួលបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលសំដែងធម៌ ក៏សំដែងចំពោះតែបុគ្គលមានសទ្ធាជាដំបូង មិនសំដែងធម៌ចំពោះបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កុលបុត្តមានសទ្ធា លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ។

ឥមេ ខោ ភិក្ខវេ បញ្ច សទ្ធេ កុលបុត្តេ អានិសំសា ។ សេយ្យថាបិ ភិក្ខវេ សុភូមិយំ ចតុម្មហាបថេ មហានិគ្រោធោ សមន្តា បក្ខីនំ បដិសរណំ ហោតិ ឯវមេវ ខោ ភិក្ខវេ សទ្ធោ កុលបុត្តោ ពហុនោ ជនស្ស បដិសរណំ ហោតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានន្តិ ។

សាខាបត្តផលូបេតោ ខន្ធិមាវ មហាទុមោ
មូលវា ផលសម្បន្នោ បតិដ្ឋា ហោតិ បក្ខិនំ
មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា
ឆាយំ ឆាយត្ថិកា យន្តិ ផលត្ថា ផលភោជិនោ
តថេវ សីលសម្បន្នំ សទ្ធំ បុរិសបុគ្គលំ
និវាតវុត្តឹ អត្ថទ្ធំ សុរតំ សខិលំ មុទុំ
វីតរាគា វីតទោសា វីតមោហា អនាសវា
បុញ្ញក្ខេត្តានិ លោកស្មឹ សេវន្តិ តាទិសំ នរំ
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតនាសវោតិ ។

ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស ៥ ក្នុងកុលបុត្រអ្នកមានសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ដើមជ្រៃធំដុះលើផែនដីដ៏ល្អ ត្រង់ផ្លូវធំបែកជា ៤ រមែងជាទីពួនសម្ងំ នៃពួកបក្សីជុំវិញ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ កុលបុត្រដែលមានសទ្ធា រមែងជាទីពឹងពាក់អាស្រ័យនៃជនដ៏ច្រើន គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក៏យ៉ាងនោះដែរ ។

ដើមឈើធំ បរិបូណ៌ដោយមែក ស្លឹក ផ្លែ ដើម ឫស បរិបូណ៌ដោយផ្លែ ជាទីពឹងរបស់សត្វបក្សីទាំងឡាយ ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ដែលនៅក្នុងព្រៃរហោង ជាទីរីករាយចិត្ត ពួកសត្វដែលត្រូវការម្លប់ ក៏ទៅជ្រកម្លប់ ពួកសត្វដែលត្រូវការផ្លែ ក៏បរិភោគផ្លែ យ៉ាងណាមិញ បុរសបុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ប្រព្រឹត្ត ឱនលំទោន មិនរឹងរូស ស្លូតត្រង់ ទន់ភ្លន់ ពួកព្រះសង្ឃ ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាបុញ្ញក្ខេត្ត ក្នុងលោក រមែងគប់រកនរជនប្រាកដដូច្នោះ ពួកព្រះសង្ឃទាំងនោះ រមែងសំដែងធម៌ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ ដល់នរៈនោះ នរៈនោះដឹងនូវធម៌ច្បាស់ហើយ ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ក្នុងលោកនេះ ។

(៣៩) បញ្ចិមានិ ភិក្ខវេ ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានំ ។ កតមានិ បញ្ច ។ ភតោ វា នោ ភរិស្សតិ កិច្ចំ វា នោ ករិស្សតិ កុលវំសោ ចិរំ ឋស្សតិ ទាយជ្ជំ បដិបជ្ជតិ អថ វា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានន្តិ ។

បញ្ចដ្ឋានានិ សម្បស្សំ　បុត្តំ ឥច្ឆន្តិ បណ្ឌិតា<br>
ភតោ វា នោ ភរិស្សតិ　កិច្ចំ វា នោ ករិស្សតិ<br>
កុលវំសោ ចិរំ តិដ្ឋេ　ទាយជ្ជំ បដិបជ្ជតិ<br>
អថ វា បន បេតានំ　ទក្ខិណំ អនុប្បទស្សតិ

[៣៩] ម្នាលភិក្ខុទាំងឡាយ មាតាបិតា ពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។ ហេតុ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ បុត្រនឹងជួយធ្វើកិច្ចយើង ១ វង្សត្រកូលនឹងស្ថិតនៅយូរ ១ បុត្រប្រតិបត្តិទទួលយកមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសទក្ខិណាទានឲ្យដល់យើង ដែលធ្វើមរណកាលទៅកាន់លោកខាងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតា កាលពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។

អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង
៥ យ៉ាង រមែងចង់បានបុត្រ គឺបុត្រដែលយើងចិញ្ចឹមហើយ
នឹងចិញ្ចឹមយើងវិញ នឹងធ្វើកិច្ចការដល់យើង វង្សត្រកូលនឹង
ស្ថិតនៅយូរ ប្រតិបត្តិគួរដើម្បីទទួលយកមត៌ក មួយទៀត នឹង
ឧទ្ទិសទក្ខិណាទានឲ្យដល់យើង ដែលទៅកាន់លោកខាងមុខ

ឋានានេតានិ សម្បស្សំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
តស្មា សន្តោ សប្បុរិសា កតញ្ញូ កតវេទិនោ
ភរន្តិ មាតាបិតរោ បុព្វេ កតមនុស្សរំ
ករោន្តិ នេសំ កិច្ចានិ យថាតំ បុព្វការិនំ
ឱវាទការី ភតបោសី កុលវំសំ អហាបយំ
សទ្ធោ សីលេន សម្បន្នោ បុត្តោ ហោតិ បសំសិយោតិ ។

[៤០] ហិមវន្តំ ភិក្ខវេ បព្វតរាជំ និស្សាយ មហាសាលា បញ្ចហិ វឌ្ឍីហិ វឌ្ឍន្តិ ។ កតមាហិ បញ្ចហិ ។ សាខាបត្តបលាសេន វឌ្ឍន្តិ តចេន វឌ្ឍន្តិ បបដិកាយ វឌ្ឍន្តិ ផេគ្គុនា វឌ្ឍន្តិ សារេន វឌ្ឍន្តិ ។ ហិមវន្តំ ភិក្ខវេ បព្វតរាជំ និស្សាយ មហាសាលា ឥមាហិ បញ្ចហិ វឌ្ឍីហិ វឌ្ឍន្តិ ។ ឯវមេវ ខោ ភិក្ខវេ សទ្ធំ កុលបតឹ និស្សាយ អន្តោជនោ បញ្ចហិ វឌ្ឍីហិ វឌ្ឍតិ ។ កតមាហិ បញ្ចហិ ។

អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ យ៉ាងនេះហើយ រមែងចង់បានបុត្រ ហេតុដូច្នោះ ពួកសប្បុរសអ្នកស្ងប់រម្ងាប់ ជាកតញ្ញូកតវេទិបុគ្គល កាលរលឹកឃើញនូវឧបការគុណដែលលោកធ្វើហើយ ក្នុងកាលមុន រមែងចិញ្ចឹមមាតាបិតា រមែងជួយធ្វើកិច្ចការរបស់បុព្វការីទាំងនុ៎ះ តាមសមគួរ បុត្រអ្នកធ្វើតាមឱវាទ អ្នកចិញ្ចឹមមាតាបិតា ដែលលោកចិញ្ចឹមហើយ មិនញុំាងវង្សត្រកូលឲ្យសាបសូន្យជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល ដែលអ្នកផងគប្បីសរសើរ ។

[៤០] ម្នាលភិក្ខុទាំងឡាយ ដើមឈើធំ ចំរើនឡើងដោយសេចក្ដីចំរើន ៥ យ៉ាង ព្រោះអាស្រ័យស្ដេចភ្នំឈ្មោះហិមវន្ត ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺចំរើនដោយមែក ស្លឹក ត្រួយ ១ ចំរើនដោយសម្បក ១ ចំរើនដោយក្រមរ ១ ចំរើនដោយស្រាយ ១ ចំរើនដោយខ្លឹម ១ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើធំ ចំរើនឡើងដោយសេចក្ដីចំរើន ៥ យ៉ាងនេះ ព្រោះអាស្រ័យស្ដេចភ្នំឈ្មោះហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចំរើនដោយសេចក្ដីចំរើន ៥ យ៉ាង ព្រោះអាស្រ័យជន ជាម្ចាស់ត្រកូលមានសទ្ធាដូច្នោះដែរ ។ ៥ យ៉ាងដូចម្ដេចខ្លះ ។

សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ សុតេន វឌ្ឍតិ ចាគេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ សទ្ធំ ភិក្ខវេ កុលបតិំ និស្សាយ អន្តោជនោ ឥមាហិ បញ្ចហិ វឌ្ឍីហិ វឌ្ឍតីតិ ។

យថា ហិ បព្វតោ សេលោ អរញ្ញស្មិំ ព្រហាវនេ
តំ រុក្ខា ឧបនិស្សាយ វឌ្ឍន្តេ តេ វនប្បតី
តថេវ សីលសម្បន្នំ សទ្ធំ កុលបុត្តំ ឥធ
ឧបនិស្សាយ វឌ្ឍន្តិ បុត្តទារា ច ពន្ធវា
អមច្ចា ញាតិសង្ឃា ច យេ ចស្ស អនុជីវិនោ
ត្យស្ស សីលវតោ សីលំ ចាគំ សុចរិតានិ ច
បស្សមានានុកុព្វន្តិ យេ ភវន្តិ វិចក្ខណា
ឥធ ធម្មំ ចរិត្វាន សគ្គំ សុគតិគាមិនំ
នន្ទិនោ ទេវលោកស្មិំ មោទន្តិ កាមកាមិនោតិ ។

សុមនវគ្គោ ចតុត្ថោ ។

## បឋមបណ្ណាសក សុមនវគ្គ

គឺចំរើនដោយសទ្ធា ១ ចំរើនដោយសីល ១ ចំរើនដោយសុតៈ ១ ចំរើនដោយចាគៈ ១ ចំរើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចំរើនដោយសេចក្តីចំរើន ៥ យ៉ាងនេះ ព្រោះអាស្រ័យជន ជាម្ចាស់ត្រកូលមានសទ្ធា ។

ភ្នំថ្មក្នុងដងព្រៃធំ ដើមឈើធំ ៗ ទាំងនោះ រមែងចំរើនឡើង ព្រោះអាស្រ័យភ្នំថ្មនោះ យ៉ាងណាមិញ កូនប្រពន្ធទាំងឡាយ ផៅពង្សទាំងឡាយ អមាត្យទាំងឡាយ ពួកញាតិទាំងឡាយ ពួកជនអ្នកចិញ្ចឹមជីវិត ដោយសារបុគ្គលនោះ រមែងចំរើនឡើង ព្រោះអាស្រ័យនឹងកុលបុត្រអ្នកមានសទ្ធា បរិបូណ៌ដោយសីល ក្នុងលោកនេះ ពួកជនមានកូននឹងប្រពន្ធជាដើមនោះ ឃើញសីលផង ចាគៈផង នឹងសុចរិតទាំងឡាយផង របស់កុលបុត្រអ្នកមានសីលនោះហើយ រមែងធ្វើតាមយ៉ាងនោះដែរ ក្នុងលោកនេះ ពួកអ្នកប្រាជ្ញណា ជាអ្នកប្រព្រឹត្តធម៌ ជាអ្នកមានដំណើរទៅកាន់សុគតិ សួគ៌ ពួកអ្នកប្រាជ្ញនោះ ជាអ្នកត្រេកអរីករាយ សម្រេចដូចសេចក្តីប្រាថ្នា ក្នុងទេវលោក ។

ចប់ សុមនវគ្គ ទី ៤ ។

# តស្សុទ្ទានំ

សុមនា ចុន្ទី ឧគ្គហោ

សីហោ ទានានិសំសយោ

កាលភោជនសទ្ធា ច

បុត្តសាលេហិ តេ ទសាតិ ។

## ឧទ្ទាននៃសុមនវគ្គនោះគឺ

រឿងតាំងនោះមាន ១០ គឺរឿងនាងសុមនារាជកុមារី ១ ចុន្ទីរាជកុមារី ១ ឧគ្គហមេណ្ឌកនត្តា ១ សីហសេនាបតី ១ អានិសង្សទានតាំងឡាយ ១ កាលទាន ១ ភោជនាហារ ១ កុលបុត្រមានសទ្ធា ១ មាតាបិតាចង់បានកូន ១ ដើមឈើធំ ១ ។

# មុណ្ឌរាជវគ្គោ

[៤១] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច បញ្ចិមេ គហបតិ ភោគានំ អាទិយា ។ កតមេ បញ្ច ។ ឥធ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ អត្តានំ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ មាតាបិតរោ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ បុត្តទារទាសកម្មករបោរិសេ សុខេតិ បីណេតិ សម្មា សុខំ បរិហរតិ អយំ បឋមោ ភោគានំ អាទិយោ ។ បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ មិត្តាមច្ចេ សុខេតិ បីណេតិ

# បុណ្ណាភិជវគ្គ

(៤១) គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលគហបតី ការកាន់យកនូវភោគៈ នេះមាន ៤ យ៉ាង ។ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលគហបតី អរិយសាវក ក្នុងលោកនេះ មានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយសេចក្តីខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ហើយញ៉ាំងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ ញ៉ាំងមាតាបិតាឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ ញ៉ាំងបុត្រភរិយាទាសកម្មករនឹងបុរសទាំងឡាយឲ្យសុខ ឲ្យឆ្អែត រក្សាសេចក្តីសុខដោយប្រពៃ នេះជាការកាន់យកនូវភោគៈទី ១ ។ ម្នាលគហបតី មួយទៀត អរិយសាវក មានភោគៈទាំងឡាយ ដែលខ្លួនបានដោយការខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ រមែងញ៉ាំងមិត្រអាមាត្យឲ្យសុខ ឲ្យឆ្អែត

សម្មា សុខំ បរិហរតិ អយំ ទុតិយោ ភោគានំ អានិសំសោ ។ បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ យា តា ហោន្តិ អាបទា អគ្គិតោ វា ឧទកតោ វា រាជតោ វា ចោរតោ វា អប្បិយតោ វា ទាយាទតោ តថារូបាសុ អាបទាសុ ភោគេហិ បរិយោធាយ វត្តតិ សោត្ថឹ អត្តានំ ករោតិ អយំ តតិយោ ភោគានំ អានិសំសោ ។ បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ បញ្ច ពលឹ កត្តា ហោតិ ញាតិពលឹ អតិថិពលឹ បុព្វបេតពលឹ រាជពលឹ ទេវតាពលឹ អយំ ចតុត្ថោ ភោគានំ អានិសំសោ ។ បុន ចបរំ គហបតិ អរិយសាវកោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ

រក្សាសេចក្តីសុខដោយប្រពៃ  នេះជាការកាន់យកនូវភោគៈទាំងឡាយ ទី ២ ។ ម្នាលគហបតី មួយទៀត អរិយសាវក មានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយការខ្នះខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយ កម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ទុកការពារនូវសេចក្តីអន្តរាយ ដែលកើតអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីជនមិនជាទីស្រឡាញ់ អំពីអ្នកទាមទារមត៌ក ហើយ ក៏ធ្វើខ្លួនឲ្យដល់សួស្តី ព្រោះភោគៈទាំងឡាយនោះ នេះជាការកាន់ យកនូវភោគៈទាំងឡាយ ទី ៣ ។ ម្នាលគហបតី មួយទៀត អរិយសាវក មានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយការខ្នះខ្នែង ព្យាយាម សន្សំដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ហើយជាអ្នកធ្វើនូវពលី ៥ ប្រការ គឺញាតិពលី ១ អតិថិពលី ១ បុព្វេតពលី ១ រាជពលី ១ ទេវតាពលី ១ នេះជាការ កាន់យកនូវភោគៈទាំងឡាយ ទី ៤ ។ ម្នាលគហបតី មួយទៀត អរិយសាវក មានភោគៈទាំងឡាយ ដែលខ្លួនបានមកដោយការខ្នះ ខ្នែង ព្យាយាម ដែលខ្លួនសន្សំដោយកម្លាំងដៃ មានញើសហូរចេញ

ធម្មិកេហិ ធម្មលទ្ធេហិ យេ តេ សមណព្រាហ្មណា មទប្បមាទា បដិវិរតា ខន្តិសោរច្ចេ និវិដ្ឋា ឯកមត្តានំ ទមេន្តិ ឯកមត្តានំ សមេន្តិ ឯកមត្តានំ បរិនិព្វាបេន្តិ តថារូបេសុ សមណព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ អយំ បញ្ចមោ ភោគានំ អាទិយោ ។ ឥមេ ខោ គហបតិ បញ្ច ភោគានំ អាទិយា ។ តស្ស ចេ គហបតិ អរិយសាវកស្ស ឥមេ បញ្ច ភោគានំ អាទិយេ អាទិយតោ ភោគា បរិក្ខយំ គច្ឆន្តិ តស្ស ឯវំ ហោតិ យេ វត ភោគានំ អាទិយា តេ ចាហំ អាទិយាមិ ភោគា ច មេ បរិក្ខយំ គច្ឆន្តីតិ ឥតិស្ស ហោតិ អវិប្បដិសារោ ។

ប្រកបដោយធម៌ បានមកដោយធម៌ ពួកសមណព្រាហ្មណ៍ណា ប្រាសចាកសេចក្តីប្រមាទ ព្រោះស្រវឹង តាំងនៅក្នុងខន្តិ នឹងសោរច្ចៈ ទូន្មានតែខ្លួនឯងម្នាក់ រម្ងាប់តែខ្លួនឯងម្នាក់ រំលត់ (កិលេស) ចំពោះខ្លួនម្នាក់ ហើយដំកល់ទុកនូវទក្ខិណា មានផលខ្ពង់ខ្ពស់ ជាធម្មជាតឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ ចំពោះពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ នេះជាការកាន់យកនូវភោគៈទាំងឡាយ ទី៤ ។ ម្នាលគហបតី ទាំង៤នេះឯង ជាការកាន់យកនូវភោគៈទាំងឡាយ ។ ម្នាលគហបតី បើភោគៈទាំង៤យ៉ាងនេះ របស់អរិយសាវកនោះ ដល់នូវកិរិយាអស់ទៅ ព្រោះហេតុដែលបុគ្គលគប្បីកាន់យក ចំពោះហេតុដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អរិយសាវកនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ៎ ហេតុទាំងឡាយណា ដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អាត្មាអញកាន់យកនូវហេតុទាំងឡាយនោះផង ភោគៈទាំងឡាយរបស់អាត្មាអញ ក៏ដល់នូវកិរិយាអស់ទៅផងដូច្នោះ ហេតុនោះ អរិយសាវកនោះ មិនមានសេចក្តីស្តាយក្រោយសោះឡើយ ។

តស្ស ចេ គហបតិ អរិយសាវកស្ស ឥមេ បញ្ច ភោគានំ អាទិយេ អាទិយតោ ភោគា អភិវឌ្ឍន្តិ តស្ស ឯវំ ហោតិ យេ វត ភោគានំ អាទិយា តេ ចាហំ អាទិយាមិ ភោគា ច មេ អភិវឌ្ឍន្តីតិ ឥតិស្ស ហោតិ អវិប្បដិសារោ ។ ឧភយេនេវ អវិប្បដិសារោតិ ។

ភុត្តា ភោគា ភតា ភច្ចា វិតិណ្ណា អាបទាសុ មេ
ឧទ្ធគ្គា ទក្ខិណា ទិន្នា អថោ បញ្ច ពលី កតា
ឧបដ្ឋិតា សីលវន្តោ សញ្ញតា ព្រហ្មចារយោ
យទត្ថំ ភោគមិច្ឆេយ្យ បណ្ឌិតោ ឃរមាវសំ
សោ មេ អត្ថោ អនុប្បត្តោ កតំ អននុតាបិយំ

ម្នាលគហបតី បើភោគៈទាំង ៥ យ៉ាងនេះ អរិយសាវកនោះ ចំរើនឡើងព្រោះហេតុដែលគប្បីកាន់យក ចំពោះហេតុដែលបុគ្គលគប្បីកាន់យកភោគៈទាំងឡាយ អរិយសាវកនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុទាំងឡាយណា ដែលអញគប្បីកាន់យក នូវភោគៈទាំងឡាយ អាត្មាអញនឹងកាន់យកនូវហេតុទាំងនោះផង ភោគៈទាំងឡាយរបស់អញចំរើនឡើងផង ហេតុដូច្នោះនោះ អរិយសាវកនោះ ជាអ្នកឥតមានសេចក្ដីស្ដាយក្រោយសោះឡើយ ។ អរិយសាវកឥតមានសេចក្ដីស្ដាយក្រោយដោយហេតុទាំងពីរយ៉ាង ។

ភោគៈទាំងឡាយ ដែលអាត្មាអញបានបរិភោគហើយ មិត្រ
អាមាត្យអាត្មាអញបានចិញ្ចឹមហើយ អាត្មាអញបានកន្លង
ផុត អំពីសេចក្ដីអន្តរាយហើយ ទក្ខិណាដ៏ប្រសើរបំផុត
អាត្មាអញបានឲ្យហើយ មួយទៀត ពលីទាំង ៥ អាត្មា
អញបានធ្វើហើយ ពួកព្រហ្មចារីអ្នកមានសីល ជាអ្នក
សង្រួម អាត្មាអញបានដំកល់ទានទុកហើយ បណ្ឌិត
អ្នកនៅគ្រប់គ្រងផ្ទះ ប្រាថ្នាភោគៈ ដើម្បីប្រយោជន៍ណា
ប្រយោជន៍នោះ អាត្មាអញបានសម្រេចហើយ កម្មដែល
មិនបានក្ដៅក្រហាយ តាមក្រោយ អាត្មាអញបានធ្វើហើយ

ឯតំ អនុស្សរំ មច្ចោ អរិយធម្មេ ឋិតោ នរោ
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

[៤២] សប្បុរិសោ ភិក្ខវេ កុលេ ជាយមានោ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មាតាបិតូនំ អត្ថាយ ហិតាយ សុខាយ ហោតិ បុត្តទារស្ស អត្ថាយ ហិតាយ សុខាយ ហោតិ ទាសកម្មករបោរិសស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតិ ។ សេយ្យថាបិ ភិក្ខវេ មហាមេឃោ សព្វសស្សានិ សម្បាទេន្តោ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ ឯវមេវ ខោ ភិក្ខវេ សប្បុរិសោ កុលេ ជាយមានោ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ

សត្តគឺនរជន កាលរលឹកឃើញហេតុនុ៎ះ ឈ្មោះថាជាអ្នកឋិតនៅក្នុងអរិយធម៌ ពួកបណ្ឌិត តែងសរសើរបុគ្គលនុ៎ះ នាលោកនេះ បុគ្គលនោះ ដល់ទៅបរលោក រមែងរីករាយ ក្នុងស្ថានសួគ៌ ។

( ៤២ ) ម្នាលភិក្ខុទាំងឡាយ បើសប្បុរសកើតក្នុងត្រកូល រមែងកើត ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើនគ្នា ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់មាតាបិតាទាំងឡាយ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់កូនប្រពន្ធ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសុខដល់ពួកមិត្រអាមាត្យ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកសមណព្រាហ្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភ្លៀងធំ ញុំាងសំទូងទាំងអស់ឲ្យលូតលាស់ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសប្បុរស កើតក្នុងត្រកូល (នីមួយៗ) រមែងកើត ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន

មាតាបិតូនំ អត្ថាយ ហិតាយ សុខាយ ហោតិ បុត្តទារស្ស អត្ថាយ ហិតាយ សុខាយ ហោតិ ទាសកម្មករបោរិសស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតីតិ ។

ហិតោ ពហុន្នំ បដិបជ្ជ ភោគេ
តំ ទេវតា រក្ខតិ ធម្មគុត្តំ
ពហុស្សុតំ សីលវតូបបន្នំ
ធម្មេ ឋិតំ ន វិជហាតិ កិត្តិ ។

ធម្មដ្ឋំ សីលសម្បន្នំ សច្ចវាទឹ ហិរីមនំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។

ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់មាតាបិតាទាំងឡាយ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់កូនប្រពន្ធ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកមិត្រអាមាត្យ ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកសមណព្រាហ្មណ៍ ក៏យ៉ាងនោះដែរ ។

សប្បុរសមានប្រយោជន៍ដល់ពួកជនច្រើន ប្រើប្រាស់ភោគៈ
ទាំងឡាយ ទេវតា រមែងរក្សានូវសប្បុរសជាអ្នកគ្រប់គ្រង
ធម៌នោះ ជាពហុស្សុត្រ បរិបូណ៌ដោយសីលនិងវត្ត
កិត្តិស័ព្ទ មិនលះបង់នូវសប្បុរសអ្នកតាំងនៅក្នុងធម៌ ។
អ្នកណាមួយ អាចដើម្បីនិន្ទា បុគ្គលដែលឋិតនៅក្នុងធម៌
បរិបូណ៌ដោយសីល ពោលពាក្យសច្ចៈ មានចិត្តប្រកប
ដោយហិរិ បីដូចជាមាសជម្ពូនទនោះបាន · សូម្បីតែ
ពួកទេវតា ក៏រមែងសរសើរបុគ្គលនោះ ទាំងព្រហ្មក៏
សរសើរបុគ្គលនោះដែរ ។

(៤៣) អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច បញ្ចិមេ គហបតិ ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ កតមេ បញ្ច ។ អាយុ គហបតិ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ វណ្ណោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ សុខំ ឥដ្ឋំ កន្តំ មនាបំ ទុល្លភំ លោកស្មឹ យសោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ សគ្គា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ ឥមេ ខោ គហបតិ បញ្ច ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ ឥមេសំ ខោ គហបតិ បញ្ចន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ន អាយាចនហេតុ វា ន បត្ថនាហេតុ វា បដិលាភំ វទាមិ ។

(៤៣) គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ធម៌ ៥ យ៉ាង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលគហបតី អាយុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ពណ៌សម្បុរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ សុខជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ យសជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ស្ថានសួគ៌ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ។ ម្នាលគហបតី ធម៌ទាំង ៥ យ៉ាងនេះឯង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ។ ម្នាលគហបតី តថាគតមិនពោលនូវការបានចំពោះធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ ព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នាទេ ។

ឥមេសញ្ចេ គហបតិ បញ្ចន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ អាយាចនហេតុ វា បត្ថនហេតុ វា បដិលាភោ អភវិស្ស កោ ឥធ កេន ហាយេថ ។ ន ខោ គហបតិ អរហតិ អរិយសាវកោ អាយុកាមោ អាយុំ អាយាចិតុំ វា អភិនន្ទិតុំ វា អាយុស្ស វាបិ ហេតុ ។ អាយុកាមេន គហបតិ អរិយសាវកេន អាយុសំវត្តនិកា បដិបទា បដិបជ្ជិតព្វា អាយុសំវត្តនិកា ហិស្ស បដិបទា បដិបន្នា អាយុប្បដិលាភាយ សំវត្តតិ ។ សោ លាភី ហោតិ អាយុស្ស ទិព្វស្ស វា មានុសស្ស វា ។ ន ខោ គហបតិ អរហតិ អរិយសាវកោ វណ្ណកាមោ វណ្ណំ អាយាចិតុំ វា អភិនន្ទិតុំ វា វណ្ណស្ស វាបិ ហេតុ ។ វណ្ណកាមេន គហបតិ អរិយសាវកេន វណ្ណសំវត្តនិកា បដិបទា បដិបជ្ជិតព្វា វណ្ណសំវត្តនិកា ហិស្ស បដិបទា បដិបន្នា វណ្ណប្បដិលាភាយ សំវត្តតិ ។

ម្នាលគហបតី បើការបានចំពោះនូវធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ នេះ នឹងមានហើយ ព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នា នរណាមួយ ក្នុងលោកនេះ អាចញុំាងនរណាឲ្យសាបសូន្យបាន ។ ម្នាលគហបតី អរិយសាវក អ្នកប្រាថ្នានូវអាយុ មិនគួរបន់ស្រន់ ឬមិនគួរត្រេកអរនឹងអាយុ ឬក៏ព្រោះហេតុនៃអាយុឡើយ ។ ម្នាលគហបតី បដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវអាយុ ដែលអរិយសាវកអ្នកប្រាថ្នានូវអាយុ គប្បីប្រតិបត្តិ ដូចថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបាននូវអាយុ អរិយសាវកនោះ បានប្រតិបត្តិហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវអាយុ ។ អរិយសាវកនោះ ជាអ្នកបានអាយុជាទិព្វ ឬអាយុជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវកអ្នកប្រាថ្នាពណ៌សម្បុរ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងពណ៌សម្បុរ ឬក៏ព្រោះហេតុតែពណ៌សម្បុរទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានពណ៌សម្បុរ ដែលអរិយសាវកអ្នកប្រាថ្នាពណ៌សម្បុរ គប្បីប្រតិបត្តិ ដូចថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានពណ៌សម្បុរ អរិយសាវកនោះប្រតិបត្តិហើយ ប្រព្រឹត្តទៅ ដើម្បីបានពណ៌សម្បុរមែន ។

សោ លាភី ហោតិ វណ្ណស្ស ទិព្វស្ស វា មានុសស្ស វា ។ ន ខោ គហបតិ អរហតិ អរិយសាវកោ សុខកាមោ សុខំ អាយាចិតុំ វា អភិនន្ទិតុំ វា សុខស្ស វាបិ ហេតុ ។ សុខកាមេន គហបតិ អរិយសាវកេន សុខសំវត្តនិកា បដិបទា បដិបជ្ជិតព្វា សុខសំវត្តនិកា ហិស្ស បដិបទា បដិបន្នា សុខប្បដិលាភាយ សំវត្តតិ ។ សោ លាភី ហោតិ សុខស្ស ទិព្វស្ស វា មានុសស្ស វា ។ ន ខោ គហបតិ អរហតិ អរិយសាវកោ យសកាមោ យសំ អាយាចិតុំ វា អភិនន្ទិតុំ វា យសស្ស វាបិ ហេតុ ។ យសកាមេន គហបតិ អរិយសាវកេន យសសំវត្តនិកា បដិបទា បដិបជ្ជិតព្វា យសសំវត្តនិកា ហិស្ស បដិបទា បដិបន្នា យសប្បដិលាភាយ សំវត្តតិ ។ សោ លាភី ហោតិ យសស្ស ទិព្វស្ស វា មានុសស្ស វា ។ ន ខោ គហបតិ អរហតិ អរិយសាវកោ សគ្គកាមោ សគ្គំ អាយាចិតុំ វា អភិនន្ទិតុំ វា សគ្គានំ វាបិ ហេតុ ។

អរិយសាវកនោះ ជាអ្នកបានពណ៌សម្បុរទិព្វ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវក ជាអ្នកប្រាថ្នានូវសេចក្ដីសុខ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងសេចក្ដីសុខ ឬក៏ហេតុតែសេចក្ដីសុខទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានសេចក្ដីសុខ ដែលអរិយសាវកអ្នកប្រាថ្នាសេចក្ដីសុខ គប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានសេចក្ដីសុខ អរិយសាវកនោះប្រតិបត្តិហើយប្រព្រឹត្តទៅ ដើម្បីបានសេចក្ដីសុខមែន ។ អរិយសាវកនោះជាអ្នកបានសេចក្ដីសុខទិព្វ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយ-សាវកអ្នកប្រាថ្នាយសសក្តិ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងយស-សក្តិ ឬក៏ហេតុតែយសសក្តិទេ ។ ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានយសសក្តិ ដែលអរិយសាវកអ្នកប្រាថ្នាយសសក្តិគប្បីប្រតិបត្តិ ដ្បិតថា បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីយសសក្តិដែលអរិយសាវកនោះប្រដិបត្តិហើយ ប្រព្រឹត្តទៅ ដើម្បីបានយសសក្តិមែន ។ អរិយសាវកនោះ ជាអ្នកបានយសសក្តិទិព្វ ឬជារបស់មនុស្ស ។ ម្នាលគហបតី អរិយសាវកអ្នកប្រាថ្នាស្ថានសួគ៌ មិនគួរដើម្បីបន់ស្រន់ ឬត្រេកអរនឹងស្ថានសួគ៌ ឬក៏ហេតុតែស្ថានសួគ៌ទេ ។

សគ្គកាមេន គហបតិ អរិយសាវកេន សគ្គសំវត្ត-និកា បដិបទា បដិបជ្ជិតព្វា សគ្គសំវត្តនិកា ហិស្ស បដិបទា បដិបន្នា សគ្គប្បដិលាភាយ សំវត្តតិ ។ សោ លាភី ហោតិ សគ្គានន្តិ ។

អាយុំ វណ្ណំ យសំ កិត្តិំ សគ្គំ ឧច្ចាកុលីនតំ
រតិយោ បត្ថយានេន ឧឡារា អបរាបរា
អប្បមាទំ បសំសន្តិ បុញ្ញកិរិយាសុ បណ្ឌិតា ។
អប្បមត្តោ ឧភោ អត្ថេ អធិគណ្ហាតិ បណ្ឌិតោ
ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតីតិ ។

(៤៤) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧគ្គស្ស គហបតិនោ វេសាលិកស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ឧគ្គោ គហបតិ វេសាលិកោ

ម្នាលគហបតី បដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានទៅកើតក្នុងស្ថានសួគ៌ អរិយសាវកអ្នកប្រាថ្នាស្ថានសួគ៌ គប្បីប្រតិបត្តិ ផ្សិតជាបដិបទាមានកិរិយាប្រព្រឹត្តទៅ ដើម្បីបានស្ថានសួគ៌ អរិយសាវកនោះប្រតិបត្តិហើយប្រព្រឹត្តទៅ ដើម្បីបានស្ថានសួគ៌មែន ៗ អរិយសាវកនោះ ជាអ្នកបានទៅកើតស្ថានសួគ៌ ៗ

អ្នកប្រាជ្ញទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ ព្រោះប្រាថ្នានូវសេចក្តីត្រេកអរគឺ អាយុ ពណ៌សម្បុរ យសសក្តិ កិត្តិស័ព្ទ ស្ថានសួគ៌ ត្រកូលខ្ពស់ ដ៏លើសលុបតៗទៅ ៗ អ្នកប្រាជ្ញមិនមានសេចក្តីប្រមាទ រមែងបានសម្រេចប្រយោជន៍ទាំងពីរគឺប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ១ ប្រយោជន៍ក្នុងបរលោក ១ អ្នកមានប្រាជ្ញាដែលហៅថា បណ្ឌិត ព្រោះបាននូវប្រយោជន៍ ៗ

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងកូដាគារសាលានាមហាវ័ន ទៀបក្រុងវេសាលី ៗ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃឧគ្គគហបតី អ្នកក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ៗ លំដាប់នោះ ឧគ្គគហបតី អ្នកក្រុងវេសាលី

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧគ្គោ គហបតិ វេសាលិកោ ភគវន្តំ ឯតទវោច សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។ មនាបំ មេ ភន្តេ សាលបុប្ផកំ ខាទនីយំ តំ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។ មនាបំ មេ ភន្តេ សម្បន្នវរសូករមំសំ(១) តំ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ

---

១ ឱ. ម. សម្បន្នកោលកំ សូករមំសំ ។

ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកក្រុងវេសាលី អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា អ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន ខាទនីយាហារ ប្រាកដស្មើដោយផ្កាសាលព្រឹក្ស ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទទួលនូវខាទនីយាហារនោះ ដើម្បីសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន សូករមំសៈដ៏ប្រសើរ ស្អាតជាទីគាប់ចិត្ត របស់ខ្ញុំព្រះអង្គមាន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលសូករមំសៈនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ

សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។ មនាបំ មេ ភន្តេ និព្វត្តតេលកំ នាលិយសាកំ(១) តំ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។ មនាបោ មេ ភន្តេ សាលីនំ ឱទនោ វិចិតកាឡកោ អនេកសូបោ អនេកព្យញ្ជនោ តំ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។

---

១ និព្វត្តតេលកំ នាឡិយសាកន្តិ បាឋោ អដ្ឋកថាយំ ទិស្សតិ ។

បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន នាលិយសាក [១] ដែលច្រឡំដោយប្រេង ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគទ្រង់ទទួលនាលិយសាកនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួល ដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន បាយស្រូវសាលី ឥតមានរនុក មានសំឡច្រើនមុខ មានម្ហូបក្រៀមច្រើនមុខ ជាទីគាប់ចិត្តខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគទ្រង់ទទួលនូវភោជននោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលអ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។

---

១ នាលិយសាកនេះ សំដៅយកភោជនីយាហារ ដែលគេច្របាច់ជាមួយនឹងម្សៅស្រូវសាលី ហើយចំអិនក្នុងសប្បិដែលលាយដោយខីរជាដើមរួចលាយដោយរសផ្អែម ៤ យ៉ាង ទើបអប់ឲ្យក្រអូប ។ អដ្ឋកថា ។ បើតាមសេចក្តីប្តូលបិត្ត គឺសំឡប្រហិត ។

មនាបានិ មេ ភន្តេ កាសិកានិ វត្ថានិ តានិ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ មនាបទាយី លភតេ មនាបន្តិ ។ មនាបោ មេ ភន្តេ បល្លង្កោ គោណកត្ថតោ បដិកត្ថតោ បដលិកត្ថតោ កទលិមិគបវរប្បច្ចត្ថរណោ សឧត្តរច្ឆទោ ឧភតោលោហិតកុបធានោ ។ អបិច ភន្តេ មយមេតំ ជានាម នេតំ ភគវតោ កប្បតីតិ ឥទំ មេ ភន្តេ ចន្ទនផលកំ អគ្ឃតិ អធិកសតសហស្សំ តំ មេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧបាទាយ ។

បពិត្រព្រះអង្គដ៏ចំរើន សម្ពត់ទាំងឡាយនៅក្នុងដែនកាសី ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគទទួលសម្ពត់ទាំងនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួល ដើម្បីសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគថា បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន បល្ល័ង្កដែលក្រាលដោយព្រំ មានរោមវែង (ជាង ៤ ធ្នាប់) កម្រាលពណ៌សដែលធ្វើដោយរោមសត្វ កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម កម្រាលដ៏ឧត្តម ដែលធ្វើដោយស្បែកសត្វឈ្លូស មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតានមានពណ៌ក្រហម ជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចំរើនមួយទៀត យើងខ្ញុំដឹងរបស់នុ៎ះថា របស់នុ៎ះមិនគួរដល់ព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ផែនក្តារខ្លឹមចន្ទន៍របស់ខ្ញុំព្រះអង្គនេះថ្លៃជាងមួយសែន សូមព្រះដ៏មានព្រះភាគទទួលផែនក្តារនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួល ដើម្បីអនុគ្រោះ ។

អថខោ ភគវា ឧគ្គំ គហបតឹ វេសាលិកំ ឥមិនា អនុមោទនីយេន អនុមោទិ

មនាបទាយី លភតេ មនាបំ
យោ ឧជុភូតេសុ ទទាតិ ឆន្ទសា
អច្ឆាទនំ សយនមថន្នបានំ
នានប្បការានិ ច បច្ចយានិ
ចត្តញ្ច មុត្តញ្ច អនុគ្គហីតំ
ខេត្តូបមេ អរហន្តេ វិទិត្វា
សោ ទុច្ចជំ សប្បុរិសោ ចជិត្វា
មនាបទាយី លភតេ មនាបន្តិ ។

អថខោ ភគវា ឧគ្គំ គហបតឹ វេសាលិកំ ឥមិនា អនុមោទនីយេន អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ឧគ្គោ គហបតិ វេសាលិកោ អបរេន សមយេន កាលមកាសិ កាលកតោ ច ឧគ្គោ គហបតិ វេសាលិកោ អញ្ញតរំ មនោមយំ កាយំ ឧបបជ្ជិ ។ តេន ខោ បន សមយេន ភគវា

លំដាប់នោះ ព្រះដ៏មានព្រះភាគ អនុមោទនា ដោយអនុមោទនីយ-គាថានេះ ចំពោះឧគ្គគហបតី អ្នកក្រុងវេសាលីថា

បុគ្គលឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ
សប្បុរសណាដឹងនូវពួកព្រះអរហន្ត ឧបមាដូចជាស្រែហើយ
ប្រគេនសំពត់ស្លៀក ដណ្តប់ ដំណេក បាយ ទឹក នឹង
បច្ច័យទាំងឡាយ មានប្រការផ្សេង ៗ ដែលខ្លួនបរិច្ចាគ
ហើយផង លះបង់ហើយផង មិនមានស្តាយផង ចំពោះ
លោកអ្នកមានកាយវាចាចិត្តត្រង់ សប្បុរសនោះ ឈ្មោះថា
លះបង់ហើយ នូវវត្ថុដែលគេលះបង់បានដោយកម្រ បុគ្គល
អ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ អនុមោទនា ដោយអនុមោទនី-យគាថានេះ ចំពោះឧគ្គគហបតី អ្នកក្រុងវេសាលី ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ លំដាប់នោះ ឧគ្គគហបតី អ្នកក្រុងវេសាលី ក៏ធ្វើមរណកាល ក្នុងសម័យក្រោយមក លុះឧគ្គគហបតី អ្នកក្រុងវេសាលី ធ្វើមរណកាលហើយ ក៏ទៅកើតក្នុងពួកទេវតាដែលសម្រេចដោយចិត្តណាមួយ (១) ។ សម័យនោះសោត ព្រះដ៏មានព្រះភាគ

---

១ តាមអដ្ឋកថា ថា ទៅកើតក្នុងពួកទេវតា ដែលកើតក្នុងសុទ្ធាវាសទាំងឡាយ ដោយឯកជ្ឈានចិត្ត ។

សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ឧគ្គោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ ឧគ្គំ ទេវបុត្តំ ភគវា ឯតទវោច កច្ចិ តេ ឧគ្គ យថាធិប្បាយោតិ ។ តគ្ឃ មេ ភគវា យថាធិប្បាយោតិ ។ អថខោ ភគវា ឧគ្គំ ទេវបុត្តំ គាថាយ អជ្ឈភាសិ

មនាបទាយី លភតេ មនាបំ
អគ្គស្ស ទាតា លភតេ បុនគ្គំ
វរស្ស ទាតា វរលាភី ច ហោតិ
សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ
អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ
ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតីតិ ។

គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ឧគ្គទេវបុត្រ កាលរាត្រី កន្លងទៅហើយ មានរស្មីដ៏រុងរឿង បំភ្លឺវត្តជេតពនទាំងអស់ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ ។ លុះឧគ្គទេវបុត្រ ឈរក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលឧគ្គៈ សេចក្តីសមតាមបំណងរបស់អ្នកមានដែរឬទេ ។ បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់ជ្រាប សេចក្តីសមប្រកបតាមបំណងរបស់ខ្ញុំព្រះអង្គមានដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគបានត្រាស់នឹងឧគ្គទេវបុត្រ ដោយគាថាទាំងឡាយថា

បុគ្គលអ្នកឲ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្ត
វិញ បុគ្គលអ្នកឲ្យរបស់ខ្ពង់ខ្ពស់ រមែងបានរបស់ខ្ពង់ខ្ពស់វិញ
បុគ្គលអ្នកឲ្យរបស់ប្រសើរ រមែងបានរបស់ដ៏ប្រសើរវិញ
បុគ្គលអ្នកឲ្យរបស់ដ៏ថ្លៃថ្លា រមែងបាននូវឋានៈដ៏ថ្លៃថ្លាវិញ
នរៈណា អ្នកឲ្យរបស់ខ្ពង់ខ្ពស់ផង អ្នកឲ្យរបស់ប្រសើរផង
អ្នកឲ្យរបស់ថ្លៃថ្លាផង នរៈនោះ កើតក្នុងទីណាៗ ជាអ្នក
មានអាយុវែង មានយសសក្តិ ក្នុងទីនោះៗ ។

(៤៥) បញ្ចិមេ ភិក្ខវេ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ បញ្ច ។ យស្ស ភិក្ខវេ ភិក្ខុ ចីវរំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ យស្ស ភិក្ខវេ ភិក្ខុ បិណ្ឌបាតំ បរិភុញ្ជមានោ... យស្ស ភិក្ខវេ ភិក្ខុ វិហារំ បរិភុញ្ជមានោ... យស្ស ភិក្ខវេ ភិក្ខុ មញ្ចបីឋំ បរិភុញ្ជមានោ... យស្ស ភិក្ខវេ ភិក្ខុ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ

(៤៥) ម្នាលភិក្ខុទាំងឡាយ គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ នេះមាន ៥ យ៉ាង ប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសុខ ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់ចីវររបស់គហបតីណា បានសម្រេចចេតោសមាធិ មានប្រមាណមិនបាន គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ របស់គហបតីនោះ ប្រព្រឹត្តទៅដើម្បីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ មានប្រមាណមិនបានទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុបរិភោគបិណ្ឌបាតរបស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់វិហាររបស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុប្រើប្រាស់គ្រែនិងតាំងរបស់គហបតីណា ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុបរិភោគនូវគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់គហបតីណា ... ហើយបានសម្រេចចេតោសមាធិ មានប្រមាណមិនបាន គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក

សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ ឥមេហិ ច បន ភិក្ខវេ បញ្ចហិ បុញ្ញាភិសន្ទេហិ កុសលាភិសន្ទេហិ សមន្នាគតស្ស អរិយសាវកស្ស ន សុករំ បុញ្ញស្ស បមាណំ គហេតុំ ឯត្តកោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតីតិ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ។

នាំឲ្យកើតក្នុងស្ថានសួគ៌ របស់គហបតីនោះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីសេចក្តីសុខ មានប្រមាណមិនបានទេ ។ ម្នាលភិក្ខុទាំងឡាយ គំនរបុណ្យ គំនរកុសល ៥ យ៉ាងនេះឯង ជាធម៌ប្រមូលមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវកដែលបរិបូណ៌ដោយគំនរបុណ្យ គំនរកុសល ៥ យ៉ាងនេះហើយ បុគ្គលមិនងាយប្រមាណបុណ្យថា គំនរបុណ្យ គំនរកុសល ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ មានប្រមាណប៉ុណ្ណេះបានឡើយ គំនរបុណ្យ រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថាគំនរបុណ្យច្រើនប៉ុណ្ណោះ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទេ ន សុករំ ឧទកស្ស បមាណំ គហេតុំ ឯត្តកានិ ឧទកាឡ្ហកានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតានីតិ វា ឯត្តកានិ ឧទកាឡ្ហកសហស្សានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតសហស្សានីតិ វា អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាឧទកក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ឥមេហិ បញ្ចហិ បុញ្ញាភិសន្ទេហិ កុសលាភិសន្ទេហិ សមន្នាគតស្ស អរិយសាវកស្ស ន សុករំ បុញ្ញស្ស បមាណំ គហេតុំ ឯត្តកោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតីតិ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតីតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយនឹងកំណត់នូវប្រមាណនៃទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណេះអាឡ្ហកក្តី ទឹកប៉ុណ្ណេះរយអាឡ្ហកក្តី ទឹកប៉ុណ្ណេះពាន់អាឡ្ហកក្តី ទឹកប៉ុណ្ណេះសែនអាឡ្ហកក្តី ដូច្នេះបានឡើយ ត្រឹមតែរាប់បានថា គំនរទឹកដ៏ធំប៉ុណ្ណោះ នឹងគប្បីរាប់មិនបាន ប្រមាណមិនកើត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលបរិបូណ៌ដោយគំនរបុណ្យ គំនរកុសលទាំង ៥ នេះ ហើយបុគ្គលមិនងាយនឹងកំណត់ប្រមាណបុណ្យថា គំនរបុណ្យ គំនរកុសល ប្រមូលមកនូវសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក នាំឲ្យកើតក្នុងស្ថានសួគ៌ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ប៉ុណ្ណេះបានឡើយ ត្រឹមតែរាប់ថា គំនរបុណ្យដ៏ធំប៉ុណ្ណោះ នឹងគប្បីរាប់មិនបាន ប្រមាណមិនកើត ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

មហោទធឹ អបរិមិតំ មហាសរំ
ពហុភេរវំ រតនគណានមាលយំ
នជ្ជោ យថា មច្ឆគណសង្ឃសេវិតា
បុថូ សវន្តី ឧបយន្តិ សាគរំ
ឯវំ នរំ អន្នទបានវត្ថទំ
សេយ្យានិសជ្ជត្ថរណស្ស[1] ទាយកំ
បុញ្ញស្ស ធារា ឧបយន្តិ បណ្ឌិតំ
នជ្ជោ យថា វារិវហាវ សាគរន្តិ ។

[៤៦] បញ្ចិមា ភិក្ខវេ សម្បទា ។ កតមា បញ្ច ។ សទ្ធាសម្បទា សីលសម្បទា សុតសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ ឥមា ខោ ភិក្ខវេ បញ្ច សម្បទាតិ ។

---

១ ម. សេយ្យានិបច្ចត្ថរណស្ស ។

ស្ទឹងទាំងឡាយ ដ៏ច្រើន ដែលហ្វូងត្រីអាស្រ័យនៅ រមែងហូរទៅ ជោរទៅកាន់សាគរ ដែលទ្រទ្រង់ទឹកដ៏ច្រើន ប្រមាណមិនបាន ជាស្រះធំ មានភ័យច្រើន ជាទីកើតនៃគំនរកែវ យ៉ាងណាមិញ ធារបុណ្យ រមែងជន់ជោរទៅរកនរៈជាបណ្ឌិត ដែលជាអ្នកឲ្យបាយ ទឹក សំពត់ អ្នកឲ្យទីដេក ទីអង្គុយ គ្រឿងកម្រាលយ៉ាងនោះដែរ ដូចជាទឹកក្នុងស្ទឹងទាំងឡាយ ហូរទៅកាន់សមុទ្រសាគរ ។

(៤៦) ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ សុតសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង សម្បទា ៥ យ៉ាង ។

(៤៧) បញ្ចិមានិ ភិក្ខវេ ធនានិ ។ កតមានិ បញ្ច ។ សទ្ធាធនំ សីលធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។ កតមញ្ច ភិក្ខវេ សទ្ធាធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាធនំ ។ កតមញ្ច ភិក្ខវេ សីលធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតា បដិវិរតោ ហោតិ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ឥទំ វុច្ចតិ ភិក្ខវេ សីលធនំ ។ កតមញ្ច ភិក្ខវេ សុតធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ ពហុស្សុតោ ហោតិ ។បេ។ ទិដ្ឋិយា សុប្បដិវិទ្ធា ឥទំ វុច្ចតិ ភិក្ខវេ សុតធនំ ។ កតមញ្ច ភិក្ខវេ ចាគធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ វិគតមល-មច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ

[៤៧] ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៥ យ៉ាង ៥ យ៉ាង ដូចម្តេចខ្លះ ។ ទ្រព្យគឺសទ្ធា ១ ទ្រព្យគឺសីល ១ ទ្រព្យគឺសុតៈ ១ ទ្រព្យគឺចាគៈ ១ ទ្រព្យគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្តីត្រាស់ដឹង របស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងអរិយសច្ច វែងវិលមកកាន់កពចីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺសីល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យជាគ្រឿងស្រវឹង ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសីល ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺសុតៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកស្តាប់ច្រើន ។បេ។ ចាក់ធ្លុះដោយប្រាជ្ញា ព្រោះសេចក្តីឃើញ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសុតៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺចាគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានចិត្តដែលសេចក្តីកំណាញ់ជាមន្ទិលទៅប្រាសហើយ នៅគ្រប់គ្រងនូវផ្ទះ មានចាគៈរួចហើយ

បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ ឥទំ វុច្ចតិ ភិក្ខវេ ចាគធនំ ។ កតមញ្ច ភិក្ខវេ បញ្ញាធនំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាធនំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ធនានីតិ ។

យស្ស សទ្ធា តថាគតេ អចលា សុប្បតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ
សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ ។

មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងទាននិងការចែករំលែក ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺចាគៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះទ្រព្យគឺបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបព្រម ដោយប្រាជ្ញាជាគ្រឿងយល់សេចក្តីចំរើននិងវិនាស ប្រាជ្ញាដ៏មោះមុត ប្រសើរ ជាបញ្ញាឲ្យដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទ្រព្យ ៥ យ៉ាង ។

សទ្ធារបស់បុគ្គលណា មិនញាប់ញ័រ បានដម្កល់ទុកប្រពៃ ក្នុងព្រះតថាគត មួយទៀត សីលរបស់បុគ្គលណា ជាសីលល្អ ជាទីត្រេកអររបស់ព្រះអរិយៈ ដែលព្រះអរិយៈសរសើរហើយ បុគ្គលណាមានសេចក្តីជ្រះថ្លា ក្នុងព្រះសង្ឃ ទាំងមានកិរិយាឃើញត្រង់ អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនទាល់ក្រ ទាំងជីវិតរបស់បុគ្គលនោះ មិនឥតអំពើ ហេតុដូច្នោះ អ្នកប្រាជ្ញកាលបើរលឹកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង កិរិយាឃើញធម៌ផង ។

(៤៨) បញ្ចិមានិ ភិក្ខវេ អលព្ភនីយានិ ឋានានិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ កតមានិ បញ្ច ។ ជរាធម្មំ មា ជីរីតិ អលព្ភនីយំ ឋានំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ព្យាធិធម្មំ មា ព្យាធិយីតិ... មរណធម្មំ មា មិយ្យីតិ... ខយធម្មំ មា ខិយីតិ .. នស្សនធម្មំ មា នស្សីតិ អលព្ភនីយំ ឋានំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ អស្សុតវតោ ភិក្ខវេ បុថុជ្ជនស្ស ជរាធម្មំ ជីរតិ សោ ជរាធម្មេ ជិណ្ណេ ន ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស ជរាធម្មំ ជីរតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ ជរាធម្មំ ជីរតិ អហញ្ចេវ ខោ បន ជរាធម្មេ ជិណ្ណេ សោចេយ្យំ

(៤៨) ម្នាលភិក្ខុទាំងឡាយ អលព្ភនីយដ្ឋាន ៥ យ៉ាង (ហេតុដែលមិនគប្បីបាន) ដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយ ក្នុងលោក (បានតាមប្រាថ្នា) ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺ សមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយ ក្នុងលោក មិនគប្បីបាន (តាមប្រាថ្នា) ថា របស់ដែលមានជរា ជាធម្មតា កុំជរាឡើយ ១ របស់ដែលមានព្យាធិ ជាធម្មតា កុំឈឺចាប់ឡើយ ... ១ របស់ដែលមានមរណៈ ជាធម្មតា កុំស្លាប់ឡើយ ... ១ របស់ដែលមានការអស់ទៅ ជាធម្មតា កុំអស់ទៅឡើយ ... ១ ហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបានតាមប្រាថ្នាថា របស់ដែលមានសេចក្តីវិនាស ជាធម្មតា កុំវិនាសឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ជរាធម៌របស់បុថុជ្ជន អ្នកមិនបានស្តាប់ រមែងគ្រាំគ្រា បុថុជ្ជននោះ មិនបានពិចារណាក្នុងជរាធម៌ដែលគ្រាំគ្រាហើយថា មិនគ្រាំគ្រាចំពោះតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ ការច្យុតិ ការកើតឡើង របស់សត្វទាំងឡាយ ត្រឹមណា ជរាធម៌របស់សត្វទាំងអស់ រមែងគ្រាំគ្រាត្រឹមនោះដែរ កាលបើជរាធម៌គ្រាំគ្រាហើយ អាត្មាអញត្រូវតែសោកសង្រេង

កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សូតិ ។ សោ ជរាធម្មេ ជិណ្ណេ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ វិទ្ធោ សវិសេន សោកសល្លេន អត្តានញ្ញេវ បរិតាបេតិ ។ បុន ចបរំ ភិក្ខវេ អស្សុតវតោ បុថុជ្ជនស្ស ព្យាធិធម្មំ ព្យាធិយតិ... មរណធម្មំ មិយ្យតិ... ខយធម្មំ ខិយតិ... នស្សនធម្មំ នស្សតិ សោ នស្សនធម្មេ នដ្ឋេ ន ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស នស្សនធម្មំ នស្សតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ នស្សនធម្មំ នស្សតិ អហញ្ចេវ ខោ បន នស្សនធម្មេ នដ្ឋេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ

លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេងភ្លេច អាត្មាអញ មិនគប្បីឃ្លានភត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏ប្រព្រឹត្តទៅមិនបានផង ពួកជនជាសត្រូវក៏មានចិត្តរីករាយផង ពួកមិត្រសំឡាញ់តូចចិត្តផង ។ កាលបើជរាធម៌គ្រាំគ្រាហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនបានស្ដាប់ ត្រូវសរដែលសេចក្ដីសោក លាបដោយថ្នាំពិស ចាក់ហើយ រមែងញាំញីខ្លួនឯងឲ្យក្ដៅក្រហាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្យាធិធម៌របស់បុថុជ្ជនអ្នកមិនបានស្ដាប់ រមែងឈឺចាប់... មរណធម៌ រមែងស្លាប់... ខយធម៌ (របស់សម្រាប់អស់ទៅ) ជាធម្មតា រមែងអស់ទៅ... នស្សនធម៌ (របស់សម្រាប់វិនាស) ជាធម្មតា រមែងវិនាសទៅ បុថុជ្ជននោះ មិនពិចារណាក្នុងនស្សនធម៌ ដែលវិនាសទៅថា នស្សនធម៌ មិនមែនវិនាសទៅចំពោះលើអាត្មាអញតែម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្ដីច្យុតិ និងសេចក្ដីកើតឡើងរបស់សត្វទាំងឡាយ មាននៅត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមណោះ កាលបើនស្សនធម៌ វិនាសទៅហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល

ឧរត្តាឡិំ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សុន្តិ ។ សោ នស្សនធម្មេ នដ្ឋេ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡិំ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ វិទ្ធោ សវិសេន សោកសល្លេន អត្តានញ្ញេវ បរិតាបេតិ ។ សុតវតោ ច ខោ ភិក្ខវេ អរិយសាវកស្ស ជរាធម្មំ ជីរតិ សោ ជរាធម្មេ ជិណ្ណេ ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស ជរាធម្មំ ជីរតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ ជរាធម្មំ ជីរតិ អហញ្ចេវ ខោ បន ជរាធម្មេ ជិណ្ណេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡិំ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ

គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានភត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារមិនប្រព្រឹត្តទៅបានផង ទាំងពួកជនជាសត្រូវ ក៏មានចិត្តត្រេកអរផង ពួកមិត្រសំឡាញ់ ក៏តូចចិត្តផង ។ កាលបើនស្សនធម៌ វិនាសទៅហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនបានស្តាប់ដែលសរគឺសោក លាបដោយថ្នាំពិសចាក់ហើយ រមែងញាំងខ្លួនឯងឲ្យក្តៅក្រហាយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកជរាធម៌របស់អរិយសាវកអ្នកបានស្តាប់ រមែងគ្រាំគ្រាទៅដែរ ប៉ុន្តែអរិយសាវកនោះ តែងពិចារណាឃើញ ក្នុងជរាធម៌ដែលគ្រាំគ្រាដូច្នេះថា ជរាធម៌រមែងមិនគ្រាំគ្រាទៅចំពោះតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើងរបស់សត្វទាំងឡាយ នៅមានត្រឹមណា ជរាធម៌របស់សត្វទាំងអស់ រមែងគ្រាំគ្រាទៅត្រឹមណោះ កាលបើជរាធម៌គ្រាំគ្រាទៅហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនគប្បីឃ្លានភត្តផង សម្បុរអាក្រក់ គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅបានផង

អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សូតិ ។ សោ ជរាធម្មេ ជិណ្ណេ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ សុតវា អរិយសាវកោ អព្ពុហិ សវិសំ សោកសល្លំ យេន វិទ្ធោ អស្សុតវា បុថុជ្ជនោ អត្តានញ្ញេវ បរិតាបេតិ ។ អសោកោ វិសល្លោ អរិយសាវកោ អត្តានញ្ញេវ បរិនិព្វាបេតិ ។ បុន ចបរំ ភិក្ខវេ សុតវតោ អរិយសាវកស្ស ព្យាធិធម្មំ ព្យាធិយតិ... មរណធម្មំ មិយ្យតិ... ខយធម្មំ ខិយតិ... នស្សនធម្មំ នស្សតិ សោ នស្សនធម្មេ នដ្ឋេ ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេ-វេកស្ស នស្សនធម្មំ នស្សតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ នស្សនធម្មំ នស្សតិ អហញ្ចេវ ខោ បន នស្សនធម្មេ នដ្ឋេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ

ពួកជនជាសត្រូវ មានចិត្តត្រេកអរផង ពួកមិត្រសំឡាញ់ក៏តូចចិត្តផង ។ កាលបើជរាធម៌គ្រាំគ្រាទៅហើយ អរិយសាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេចឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរគឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវក អ្នកបានស្តាប់ហើយ ដកហើយនូវសរគឺសោក ដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវក អ្នកមិនមានសរគឺសោក រមែងញុំាងខ្លួនឯងឲ្យរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្យាធិធម៌របស់អរិយសាវក អ្នកបានស្តាប់ រមែងឈឺចាប់... មរណធម៌ រមែងស្លាប់... ខយធម៌ រមែងអស់ទៅ... នស្សនធម៌ រមែងវិនាសទៅ អរិយសាវកនោះ ពិចារណាឃើញច្បាស់ ក្នុងនស្សនធម៌ដែលវិនាសទៅហើយ ដូច្នេះថា នស្សនធម៌ មិនវិនាសទៅចំពោះលើអាត្មាអញតែម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើងនៃសត្វទាំងឡាយ នៅមានត្រឹមណា នស្សនធម៌របស់សត្វទាំងអស់វិនាសទៅត្រឹមណោះ កាលបើនស្សនធម៌វិនាសទៅហើយ អាត្មាអញគប្បីសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង

ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សុន្តិ ។ សោ នស្សនធម្មេ នដ្ឋេ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ សុតវា អរិយសាវកោ អព្ពុហិ សវិសំ សោកសល្លំ យេន វិទ្ធោ អស្សុតវា បុថុជ្ជនោ អត្តានញ្ញេវ បរិតាបេតិ ។ អសោកោ វិសល្លោ អរិយសាវកោ អត្តានញ្ញេវ បរិនិព្វាបេតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អលព្ភនីយានិ ឋានានិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។

ភ្លេច អាត្មាអញមិនគប្បីឃ្លានកន្តង់ សម្បុរអាក្រក់ គប្បីធ្លាក់ចុះក្នុងកាយផង ការងារ ក៏មិនប្រព្រឹត្តទៅបានផង ពួកជនជាសត្រូវក៏ត្រេកអរផង ពួកមិត្រសំឡាញ់ក៏តូចចិត្តផង ។ កាលបើនស្សនធម៌វិនាសទៅហើយ អរិយសាវកនោះ មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរគឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឯងឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវក អ្នកបានស្តាប់ ហើយដកនូវសរគឺសោកដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវក អ្នកមិនមានសរគឺសោក រមែងញុំាងខ្លួនឯងឲ្យរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ អលព្ភនីយដ្ឋាន ៥ យ៉ាងនេះឯង ជាហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយក្នុងលោក មិនគប្បីបាន (តាមប្រាថ្នា) ។

ន សោចនាយ បរិទេវនាយ
អត្ថោ ឥធ លព្ភតិ[១] អបិ អប្បកោបិ
សោចន្តមេនំ ទុក្ខិតំ វិទិត្វា
បច្ចត្ថិកា អត្តមនា ភវន្តិ
យតោ ច ខោ បណ្ឌិតោ អាបទាសុ
ន វេធតិ អត្ថវិនិច្ឆយញ្ញូ
បច្ចត្ថិកាស្ស ទុក្ខិតា
ភវន្តិ ទិស្វា មុខំ អវិការំ បុរាណំ
ជប្បេន មន្តេន សុភាសិតេន
អនុប្បទានេន បវេណិយា វា
យថា យថា យត្ថ លភេថ អត្ថំ
តថា តថា តត្ថ បរក្កមេយ្យ
សចេ បជានេយ្យ អលព្ភនេយ្យោ
មយា វា អញ្ញេន វា ឯស អត្ថោ
អសោចមានោ អធិវាសយេយ្យ
កម្មំ ទឡ្ហំ កិន្តិ ករោមិទានីតិ ។

---

១ ឱ. ម. លព្ភា ។

ប្រយោជន៍ក្នុងលោកនេះ ទោះណាជាតិចតួច បុគ្គលមិនមែនបាន ព្រោះសេចក្តីសោក ព្រោះសេចក្តីខ្សឹកខ្សួលឡើយ ពួកជនជាសត្រូវឃើញជននោះ កំពុងសោកសង្រេងដល់នូវទុក្ខ ជាអ្នកមានចិត្តត្រេកអរ លុះណាតែបណ្ឌិត អ្នកឈ្វេងយល់ ក្នុងការវិនិច្ឆ័យនូវហេតុនិងផល ទើបមិនញាប់ញ័រក្នុងឧបទ្រពទាំងឡាយ ពួកជនជាសត្រូវ ឃើញមុខបណ្ឌិតនោះមិនប្រែប្រួល នៅដដែល ហើយខ្លួនឯងក៏ដល់នូវទុក្ខវិញ បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការណា ៗ គប្បីព្យាយាមក្នុងទីនោះ ដោយប្រការនោះ ៗ គឺការនិយាយសរសើរក្តី ការរាយមន្តក្តី ការនិយាយជាសុភាសិតក្តី បវេណី (វង្សត្រកូល) ក្តី បើសិនជាបុគ្គលដឹងច្បាស់ថា ប្រយោជន៍នេះ អាត្មាអញក្តី បុគ្គលដទៃក្តី មិនគប្បីបានទេ មិនសោកសៅ គប្បីអត់ធ្មត់ថា កម្មដ៏មាំ (អាត្មាអញបានសន្សំទុកហើយ) ឥឡូវនេះ អាត្មាអញធ្វើដូចម្តេច ៗ

(៤៩) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ រាជា បសេនទិ កោសលោ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន មល្លិកា ទេវី កាលកតា ហោតិ ។ អថខោ អញ្ញតរោ បុរិសោ យេន រាជា បសេនទិ កោសលោ តេនុប-សង្កមិ ឧបសង្កមិត្វា រញ្ញោ បសេនទិស្ស កោស-លស្ស ឧបកណ្ណកេ អារោចេសិ មល្លិកា ទេវ ទេវី កាលកតាតិ ។ ឯវំ វុត្តេ រាជា បសេនទិ កោសលោ ទុក្ខី ទុម្មនោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។ អថខោ ភគវា រាជានំ បសេនទឹ កោសលំ ទុក្ខឹ ទុម្មនំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា រាជានំ បសេនទឹ កោសលំ ឯតទវោច

[៤៩] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះរាជាបសេនទិកោសល ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ ក្នុងសម័យនោះ ព្រះនាងមល្លិកាទេវី ទើបនឹងទិវង្គតទៅ ។ លំដាប់នោះ មានបុរសម្នាក់ចូលទៅគាល់ព្រះរាជាបសេនទិកោសល លុះចូលទៅដល់ហើយ ក្រាបទូលជិតព្រះកាណ៌ នៃព្រះរាជាបសេនទិ-កោសលថា បពិត្រព្រះសម្មតិទេព ព្រះនាងមល្លិកាទេវី ទិវង្គតទៅហើយ ។ កាលរាជបុរស ក្រាបទូលដូច្នេះហើយ ព្រះរាជាបសេនទិ-កោសល មានទុក្ខទោមនស្ស មានព្រះសុរង៏ឱនចុះ មានព្រះភក្ត្រជ្រប់ គង់សញ្ជប់សញ្ជឹង មិនមានបដិភាណ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ព្រះរាជាបសេនទិកោសល ទ្រង់មានទុក្ខទោមនស្ស មានព្រះសុរង៏ឱនចុះ មានព្រះភក្ត្រជ្រប់ សញ្ជប់សញ្ជឹង មិនមានបដិភាណ ហើយបានត្រាស់នឹងព្រះរាជាបសេនទិកោសលយ៉ាងនេះថា

បញ្ចិមានិ មហារាជ អលព្ភនីយានិ ឋានានិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ កតមានិ បញ្ច ។ ជរាធម្មំ មា ជីរីតិ អលព្ភនីយំ ឋានំ ។បេ។

ន សោចនាយ ន បរិទេវនាយ ។បេ។

កម្មំ ទឡ្ហំ កិន្តិ ករោមិទានីតិ ។

(៥០) ឯកំ សមយំ អាយស្មា នារទោ បាដលិបុត្តេ វិហរតិ កុក្កុដារាមេ ។ តេន ខោ បន សមយេន មុណ្ឌស្ស រញ្ញោ ភទ្ទា ទេវី កាលកតា ហោតិ បិយា មនាបា ។ សោ ភទ្ទាយ ទេវិយា កាលកតាយ បិយាយ មនាបាយ នេវ នហាយតិ ន វិលិម្បតិ ន ភត្តំ ភុញ្ជតិ ន កម្មន្តំ បយោជេតិ រត្តិន្ទិវំ ភទ្ទាយ ទេវិយា សរីរេ អជ្ឈោមុច្ឆិតោ ។ អថខោ មុណ្ឌោ រាជា បិយកំ សោការក្ខំ(១) អាមន្តេសិ តេនហិ សម្ម បិយក ភទ្ទាយ ទេវិយា សរីរំ អយសាយ តេលទោណិយា បក្ខិបិត្វា

---

១ ឱ. ម. កោសារក្ខំ ។

បពិត្រមហារាជ អលព្ភនីយដ្ឋាន គឺហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយ ក្នុងលោក មិនគប្បីបានតាមសេចក្តីប្រាថ្នា នេះមាន ៥ យ៉ាង ។ ៥ យ៉ាង ដូចម្តេចខ្លះ ។ ហេតុមិនគប្បីបានតាមសេចក្តីប្រាថ្នាថា ជរាធម៌ កុំគ្រាំគ្រាឡើយដូច្នេះ ។បេ។

មិនមានបានព្រោះសោក ព្រោះខ្សឹកខ្សួលឡើយ ។បេ។

កម្ពង់មាំ (អាត្មាអញបានសន្សំទុកហើយ) ឥឡូវនេះ

អាត្មាអញធ្វើដូចម្តេចហ្ន៎ ។

(៥០) សម័យមួយ នារទៈដ៏មានអាយុ គង់នៅក្នុងកុក្កុដារាម ទៀបក្រុងបាតលិបុត្ត ។ ក៏សម័យនោះ ព្រះនាងភទ្ទាទេវី ជាទីស្រឡាញ់ ពេញព្រះទ័យនៃព្រះរាជាមុណ្ឌៈទិវង្គតទៅ ។ កាលព្រះនាងភទ្ទាទេវី ជាទីស្រឡាញ់ពេញព្រះទ័យទិវង្គតទៅហើយ ទ្រង់មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងារសោះ ទ្រង់ជាប់ព្រះទ័យតែនឹងសរីរៈព្រះនាងភទ្ទាទេវីតាំងយប់តាំងថ្ងៃ ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈ ទ្រង់ត្រាស់ហៅ សោការក្ខាមាត្យ ដែលគាប់ព្រះទ័យមកថា ម្នាលសំឡាញ់ ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរដាក់នូវសរីរៈនាងភទ្ទាទេវីទៅក្នុងស្នូកប្រេងជាវិការនៃដែក

អញ្ញិស្សា អយសាយ ទោណិយា បដិកុជ្ជថ យថា
មយំ ភទ្ទាយ ទេវិយា សរីរំ ចិរតរំ បស្សេយ្យាម-
មាតិ ។ ឯវំ ទេវាតិ ខោ បិយកោ កោសារក្ខោ
មុណ្ឌស្ស រញ្ញោ បដិស្សុត្វា ភទ្ទាយ ទេវិយា សរីរំ
អយសាយ តេលទោណិយា បក្ខិបិត្វា អញ្ញិស្សា
អយសាយ ទោណិយា បដិកុជ្ជិ ។ អថខោ
បិយកស្ស កោសារក្ខស្ស ឯតទហោសិ ឥមស្ស
ខោ មុណ្ឌស្ស រញ្ញោ ភទ្ទា ទេវី កាលកតា បិយា
មនាបា ។ សោ ភទ្ទាយ ទេវិយា កាលកតាយ
បិយាយ មនាបាយ នេវ នហាយតិ ន វិលិម្បតិ ន
ភត្តំ ភុញ្ជតិ ន កម្មន្តំ បយោជេតិ រត្តិន្ទិវំ ភទ្ទាយ
ទេវិយា សរីរេ អជ្ឈោមុច្ឆិតោ ។ កំ នុ ខោ មុណ្ឌោ
រាជា សមណំ វា ព្រាហ្មណំ វា បយិរុបាសេយ្យ យស្ស
ធម្មំ សុត្វា សោកសល្លំ បជហេយ្យាតិ ។ អថខោ
បិយកស្ស កោសារក្ខស្ស ឯតទហោសិ អយំ ខោ
អាយស្មា នារទោ បាដលិបុត្តេ វិហរតិ កុក្កុដារាមេ ។

ហើយគ្រប ដោយស្បូកដែកដទៃទៀត ទុកឲ្យយើងគ្រាន់ឃើញសរីរៈនាងភទ្ទាទេវី យូរក្រលបន្តិច ៗ សោការក្ខាមាត្យ ជាទីគាប់ព្រះទ័យទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយដាក់សរីរៈព្រះនាងភទ្ទាទេវី ក្នុងស្បូកប្រេងជាវិការនៃដែកហើយ គ្របដោយស្បូកដែកដទៃទៀត ។ លំដាប់នោះ សោការក្ខាមាត្យជាទីស្រឡាញ់ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះនាងភទ្ទាទេវីជាទីស្រឡាញ់ពេញព្រះទ័យនៃព្រះរាជាមុណ្ឌៈនេះ ទិវង្គតទៅហើយកាលព្រះនាងភទ្ទាទេវី ជាទីស្រឡាញ់ពេញព្រះទ័យ ទិវង្គតទៅហើយ ព្រះរាជានោះ មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងាររសោះ ទ្រង់ជប់ទៅក្នុងសរីរៈព្រះនាងភទ្ទាទេវី ទាំងយប់ទាំងថ្ងៃ ៗ ព្រះរាជាមុណ្ឌៈចូលទៅជិតសមណព្រាហ្មណ៍ណាហ្ន៎ ហើយស្ដាប់ធម៌របស់សមណព្រាហ្មណ៍ណា ទើបនឹងគប្បីលះបង់នូវសរគឺសេចក្ដីសោកចេញបាន ។ លំដាប់នោះ សោការក្ខាមាត្យ ជាទីគាប់ព្រះទ័យ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះនារទៈដ៏មានអាយុនេះ គង់នៅក្នុងកុក្កុដារាម ទៀបក្រុង បាតលិបុត្ត ។

តំ ខោ បនាយស្មន្តំ នារទំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ បណ្ឌិតោ ព្យត្តោ មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណប្បដិភាណោ វុឌ្ឍោ ចេវ អរហា ច យន្នូន មុណ្ឌោ រាជា អាយស្មន្តំ នារទំ បយិរុបាសេយ្យ អប្បេវ នាម មុណ្ឌោ រាជា អាយស្មតោ នារទស្ស ធម្មំ សុត្វា សោកសល្លំ បជហេយ្យាតិ ។ អថខោ បិយកោ សោការក្ខោ យេន មុណ្ឌោ រាជា តេនុបសង្កមិ ឧបសង្កមិត្វា មុណ្ឌំ រាជានំ ឯតទវោច អយំ ខោ ទេវ អាយស្មា នារទោ បាដលិបុត្តេ វិហរតិ កុក្កុដារាមេ តំ ខោ បនាយស្មន្តំ នារទំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ បណ្ឌិតោ ព្យត្តោ មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណប្បដិភាណោ វុឌ្ឍោ ចេវ អរហា ច យទិ បន ទេវោ អាយស្មន្តំ នារទំ បយិរុបាសេយ្យ អប្បេវ នាម ទេវោ អាយស្មតោ នារទស្ស ធម្មំ សុត្វា សោកសល្លំ បជហេយ្យាតិ ។ តេនហិ សម្ម បិយក អាយស្មន្តំ នារទំ បដិវេទេហិ ។

ព្រះនារទៈដ៏មានអាយុនោះ មានកិត្តិស័ព្ទដ៏ពីរោះ ខ្ចរខ្ចាយទៅយ៉ាងនេះថា ជាបណ្ឌិត វាងវៃ ជាអ្នកប្រាជ្ញ បានស្តាប់ច្រើន មានពាក្យដ៏វិចិត្រ មានបដិភាណល្អ មានវ័យចំរើនផង ជាព្រះអរហន្តផង បើដូច្នោះគួរតែ ព្រះករុណាចូលទៅរកព្រះនារទៈដ៏មានអាយុ ធ្វើដូចម្តេចហ្ន៎ ឲ្យព្រះករុណាទ្រង់ព្រះសណ្តាប់ធម៌ព្រះនារទៈដ៏មានអាយុ ហើយ លះបង់នូវសរគឺសោកចេញបាន ។ លំដាប់នោះ សោកាវត្តាមាត្យ ជាទីគាប់ព្រះទ័យ ក៏ចូលទៅគាល់ព្រះករុណា លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះករុណាយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ព្រះនារទៈដ៏មានអាយុនេះ គង់នៅក្នុងកុក្កុដារាមៈជិតក្រុងបាតលិបុត្ត ព្រះនារទៈដ៏មានអាយុនោះ មានកិត្តិស័ព្ទដ៏ពីរោះ ខ្ចរខ្ចាយទៅយ៉ាងនេះថា ជាបណ្ឌិត វាងវៃ ជាអ្នកប្រាជ្ញ បានស្តាប់ច្រើន មានពាក្យដ៏វិចិត្រ មានបដិភាណល្អ ហើយមានវ័យចំរើនផង ជាព្រះអរហន្តផង បើព្រះសម្មតិទេព ចូលទៅរកព្រះនារទៈដ៏មានអាយុ ធ្វើដូចម្តេចហ្ន៎ ឲ្យព្រះសម្មតិទេព ទ្រង់ព្រះសណ្តាប់ធម៌ ព្រះនារទៈដ៏មានអាយុ ហើយលះបង់នូវសរគឺសោកបាន ។ ម្នាលសំឡាញ់ ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរទៅផ្តៀងព្រះនារទៈដ៏មានអាយុចុះ ។

កថញ្ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ បុព្វេ អប្បដិសំវិទិតំ ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ ឯវំ ទេវាតិ ខោ បិយកោ សោការក្ខោ មុណ្ឌស្ស រញ្ញោ បដិស្សុត្វា យេនាយស្មា នារទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ នារទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បិយកោ សោការក្ខោ អាយស្មន្តំ នារទំ ឯតទវោច ឥមស្ស ភន្តេ មុណ្ឌស្ស រញ្ញោ ភទ្ទា ទេវី កាលកតា បិយា មនាបា ។ សោ ភទ្ទាយ ទេវិយា កាលកតាយ បិយាយ មនាបាយ នេវ ន្ហាយតិ ន វិលិម្បតិ ន ភត្តំ ភុញ្ជតិ ន កម្មន្តំ បយោជេតិ រត្តិន្ទិវំ ភទ្ទាយ ទេវិយា សរីរេ អជ្ឈោមុច្ឆិតោ ។ សាធុ ភន្តេ អាយស្មា នារទោ មុណ្ឌស្ស រញ្ញោ តថា ធម្មំ ទេសេតុ យថា មុណ្ឌោ រាជា អាយស្មតោ នារទស្ស ធម្មំ សុត្វា សោកសល្លំ បជហេយ្យាតិ ។

ដ្បិតថា បុគ្គលប្រាកដដូចជាយើង មិនសមបើនឹងចូលទៅរកសមណព្រាហ្មណ៍ នៅក្នុងដែន ដែលមិនទាន់បានផ្ទៀងជាមុនទេ ។ សោការក្ខាមាត្យ ជាទីគាប់ព្រះទ័យទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅរកព្រះនារទៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោការក្ខាមាត្យ ជាទីគាប់ព្រះទ័យអង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះនារទៈដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចំរើន ព្រះនាងភទ្ទាទេវី ជាទីស្រឡាញ់ពេញព្រះទ័យរបស់ព្រះរាជាមុណ្ឌៈនេះ ទិវង្គតទៅហើយ ។ កាលព្រះនាងភទ្ទាទេវី ជាទីស្រឡាញ់ពេញព្រះទ័យ ទិវង្គតទៅហើយ ព្រះរាជានោះទ្រង់មិនស្រង់ទឹក មិនប្រោះព្រំ មិនសោយក្រយាស្ងោយ មិនប្រកបការងារ ទ្រង់ផ្ទប់ព្រះទ័យ តែក្នុងសរីរៈព្រះនាងភទ្ទាទេវី ទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះនារទៈដ៏មានអាយុ មេត្តាសំដែងធម៌ដល់ព្រះរាជាមុណ្ឌៈឲ្យទាន ឲ្យព្រះរាជាមុណ្ឌៈទ្រង់ព្រះសណ្ដាប់ធម៌នៃព្រះនារទៈដ៏មានអាយុហើយ លះបង់នូវសរគឺសោកបាន ។

យស្សុទានិ ពិយក មុណ្ឌោ រាជា កាលំ មញ្ញតីតិ ។ អថខោ ពិយកោ សោការក្ខោ ឧដ្ឋាយាសនា អាយស្មន្តំ នារទំ អភិវាទេត្វា បទក្ខិណំ កត្វា យេន មុណ្ឌោ រាជា តេនុបសង្កមិ ឧបសង្កមិត្វា មុណ្ឌំ រាជានំ ឯតទវោច កតាវកាសោ ខោ ទេវ អាយស្មតា នារទេន ។ យស្សុទានិ ទេវោ កាលំ មញ្ញតីតិ ។ តេនហិ សម្ម ពិយក ភទ្រានិ ភទ្រានិ យានានិ យោជាបេហីតិ ។ ឯវំ ទេវាតិ ខោ ពិយកោ សោការក្ខោ មុណ្ឌស្ស រញ្ញោ បដិស្សុត្វា ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា មុណ្ឌំ រាជានំ ឯតទវោច យុត្តានិ ខោ តេ ទេវ ភទ្រានិ ភទ្រានិ យានានិ ។ យស្សុទានិ ទេវោ កាលំ មញ្ញតីតិ ។ អថខោ មុណ្ឌោ រាជា ភទ្រានិ ភទ្រានិ យានានិ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ យេន កុក្កុដារាមោ តេន បាយាសិ មហច្ចរាជានុភាវេន អាយស្មន្តំ នារទំ ទស្សនាយ ។

ម្នាលបុរស ជាទីស្រឡាញ់ ព្រះរាជាមុណ្ឌៈ សំគាល់កាលគួរដែលស្ដេចមក ក្នុងកាលឥឡូវនេះចុះ ៗ លំដាប់នោះ សោការក្ខាមាត្យ ជាទីគាប់ព្រះទ័យ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយធ្វើប្រទក្សិណ ចូលទៅគាល់ព្រះរាជាមុណ្ឌៈ លុះចូលទៅដល់ហើយ ក៏បានក្រាបទូលព្រះរាជាមុណ្ឌៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ព្រះនារទៈដ៏មានអាយុ បើកឱកាសថ្វាយហើយ ៗ ព្រះសម្មតិទេព សំគាល់កាលគួរទើបស្ដេចទៅឥឡូវនេះចុះ ៗ ម្នាលសំឡាញ់ជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរប្រើនាយសារថីឲ្យរៀបយានល្អ ៗ ៗ សោការក្ខាមាត្យ ជាទីគាប់ព្រះទ័យទទួលព្រះរាជឱង្ការព្រះរាជាមុណ្ឌៈថា ព្រះករុណាថ្លៃវិសេស ហើយប្រើនាយសារថីឲ្យរៀបយានល្អ ៗ ហើយក្រាបទូលព្រះរាជាមុណ្ឌៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព យានល្អ ៗ សម្រាប់ព្រះអង្គរៀបចំរួចស្រេចហើយ ៗ ព្រះសម្មតិទេព សំគាល់កាលគួរដែលព្រះអង្គនឹងស្ដេចទៅ ក្នុងកាលឥឡូវនេះចុះ ៗ លំដាប់នោះ ព្រះរាជាមុណ្ឌៈស្ដេចឡើងគង់យានល្អ ៗ ចូលទៅឯកុក្កុដារាម ដោយយានល្អ ៗ ដោយអានុភាពធំ ដើម្បីចួបព្រះនារទៈដ៏មានអាយុ ៗ

យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ អារាមំ បាវិសិ ។ អថខោ មុណ្ឌោ រាជា យេន អាយស្មា នារទោ តេនុប-សង្កមិ ឧបសង្កមិត្វា អាយស្មន្តំ នារទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ មុណ្ឌំ រាជានំ អាយស្មា នារទោ ឯតទវោច បញ្ចិមានិ មហារាជ អលព្ភនីយានិ ឋានានិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ កតមានិ បញ្ច ។ ជរាធម្មំ មា ជីរីតិ អលព្ភនីយំ ឋានំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ព្យាធិធម្មំ មា ព្យាធីយីតិ... មរណធម្មំ មា មីយីតិ... ខយធម្មំ មា ខីយីតិ... នស្សនធម្មំ មា នស្សីតិ អលព្ភនីយំ ឋានំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ អស្សុតវតោ មហារាជ បុថុជ្ជនស្ស ជរាធម្មំ

ទីដែលយាន ទៅបានត្រឹមណា ព្រះរាជាក៏ស្តេចទៅ ដោយយានត្រឹមនោះ ហើយស្តេចចុះអំពីយាន ទ្រង់ព្រះដំណើរដោយព្រះបាទ ចូលទៅអារាម ៗ លំដាប់នោះ ព្រះរាជាមុណ្ឌៈចូលទៅរកព្រះនារទៈដ៏មានអាយុ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះនារទៈដ៏មានអាយុ ហើយប្រថាប់ក្នុងទីដ៏សមគួរ ៗ លុះព្រះរាជាមុណ្ឌៈគង់ក្នុងទីដ៏សមគួរហើយ ព្រះនារទៈដ៏មានអាយុ ថ្វាយព្រះពរយ៉ាងនេះថា ថ្វាយព្រះពរមហារាជ អលព្ភនីយដ្ឋាន គឺហេតុ ដែលសមណព្រាហ្មណ៍ ទេវតា មារព្រហ្មឬបុគ្គលណាមួយ ក្នុងលោក មិនគប្បីបានតាមប្រាថ្នានេះ មាន ៥ យ៉ាង ៗ ៥ យ៉ាង ដូចម្តេចខ្លះ ៗ គឺហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយ ក្នុងលោក មិនគប្បីបានតាមសេចក្តីប្រាថ្នាថា ជរាធម៌ កុំគ្រាំគ្រាឡើយ ព្យាធិធម៌ កុំឈឺចាប់ដូច្នេះឡើយ ... មរណធម៌ កុំស្លាប់ដូច្នេះឡើយ ... ខយធម៌ កុំអស់ទៅដូច្នេះឡើយ... ហេតុដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គលណាមួយ ក្នុងលោក មិនគប្បីបានតាមសេចក្តីប្រាថ្នាថា នស្សនធម៌ កុំវិនាសទៅដូច្នេះ ៗ បពិត្រមហារាជ ជរាធម៌របស់បុថុជ្ជន អ្នកមិនបានស្តាប់

ជីរតិ សោ ជរាធម្មេ ជិណ្ណេ ន ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស ជរាធម្មំ ជីរតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ ជរាធម្មំ ជីរតិ អហញ្ចេវ ខោ បន ជរាធម្មេ ជិណ្ណេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆា-ទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សុន្តិ ។ សោ ជរាធម្មេ ជិណ្ណេ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ អយំ វុច្ចតិ មហារាជ អស្សុតវា បុថុជ្ជនោ វិទ្ធោ សវិសេន សោកសល្លេន អត្តានញ្ញេវ បរិតាបេតិ ។ បុន ចបរំ មហារាជ អស្សុតវតោ បុថុជ្ជនស្ស ព្យាធិធម្មំ ព្យាធិយតិ... មរណធម្មំ មិយ្យតិ... ខយធម្មំ ខិយតិ... នស្សនធម្មំ នស្សតិ សោ

រមែងគ្រាំគ្រាទៅ បុថុជ្ជននោះ មិនពិចារណា ក្នុងជរាធម៌ដែលគ្រាំគ្រាទៅដូច្នេះថា ជរាធម៌ មិនគ្រាំគ្រាចំពោះតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើង នៃសត្វទាំងឡាយ នៅមានដរាបណា ជរាធម៌របស់សត្វទាំងឡាយ ទាំងអស់ រមែងគ្រាំគ្រាទៅដរាបនោះ កាលបើជរាធម៌ គ្រាំគ្រាទៅហើយ អាត្មាអញ គប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនឃ្លានភត្តផង សម្បុរអាក្រក់ គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅផង ពួកជន ជាសត្រូវ ក៏មានចិត្តត្រេកអរផង មិត្តសំឡាញ់ក៏តូចចិត្តផង ដូច្នេះ ៗ កាលបើជរាធម៌នោះគ្រាំគ្រាហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ នេះហៅថា បុថុជ្ជន អ្នកមិនបានស្តាប់ ត្រូវសរគឺសោក ដែលលាបដោយថ្នាំពិសចាក់ហើយ ញាំងខ្លួនឯងឲ្យក្តៅក្រហាយ ៗ បពិត្រមហារាជ មួយទៀត ព្យាធិធម៌ របស់បុថុជ្ជន អ្នកមិនបានស្តាប់ តែងឈឺចាប់... មរណធម៌ រមែងស្លាប់... ខយធម៌ រមែងអស់ទៅ... នស្សនធម៌ រមែងវិនាសទៅ បុថុជ្ជននោះ

នស្សនធម្មេ នដ្ឋេ ន ឥតិ បដិសញ្ចិក្ខតិ ន ខោ បយ្ហេវេកស្ស នស្សនធម្មំ នស្សតិ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ នស្សនធម្មំ នស្សតិ អហញ្ចេវ ខោ បន នស្សនធម្មេ នដ្ឋេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សូតិ ។ សោ នស្សនធម្មេ នដ្ឋេ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ អយំ វុច្ចតិ មហារាជ អស្សុតវា បុថុជ្ជនោ វិទ្ធោ សវិសេន សោកសល្លេន អត្តានញ្ញេវ បរិតាបេតិ ។ សុតវតោ ច ខោ មហារាជ អរិយសាវកស្ស ជរាធម្មំ ជីរតិ សោ ជរាធម្មេ ជិណ្ណេ ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស ជរាធម្មំ ជីរតិ

មិនពិចារណា ក្នុងនស្សនធម៌ដែលវិនាសទៅហើយដូច្នេះថា នស្សនធម៌ មិនវិនាសទៅចំពោះតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើងរបស់សត្វទាំងឡាយ នៅមានត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមនោះ កាលបើនស្សនធម៌ វិនាសទៅហើយ អាត្មាអញក៏គប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញ មិនឃ្លានភត្តផង សម្បុរអាក្រក់គប្បីធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅផង ពួកជន ជាសត្រូវ មានចិត្តត្រេកអរផង មិត្រសំឡាញ់តូចចិត្តផង កាលបើ នស្សនធម៌ វិនាសទៅហើយ បុថុជ្ជននោះ ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ នេះហៅថា បុថុជ្ជនមិនបានស្តាប់ ដែលសរគឺសោក លាបដោយថ្នាំពិស ចាក់ហើយ ញុំាងខ្លួនឯងឲ្យក្តៅក្រហាយ ។ បពិត្រមហារាជ ជរាធម៌ របស់អរិយសាវក អ្នកបានស្តាប់ហើយ គ្រាំគ្រាទៅ អរិយសាវក នោះ ពិចារណាក្នុងជរាធម៌ ដែលគ្រាំគ្រាទៅហើយដូច្នេះថា ជរាធម៌ មិនគ្រាំគ្រាទៅ ចំពោះតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ

អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ ជរាធម្មំ ជីរតិ អហញ្ចេវ ខោ បន ជរាធម្មេ ជិណ្ណេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សូតិ ។ សោ ជរាធម្មេ ជិណ្ណេ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ អយំ វុច្ចតិ មហារាជ សុតវា អរិយសាវកោ អព្ពុហិ សវិសំ សោកសល្លំ យេន វិទ្ធោ អស្សុតវា បុថុជ្ជនោ អត្តានញ្ញេវ បរិតាបេតិ ។ អសោកោ វិសល្លោ អរិយសាវកោ អត្តានញ្ញេវ បរិនិព្វាបេតិ ។ បុន ចបរំ មហារាជ សុតវតោ អរិយសាវកស្ស ព្យាធិធម្មំ ព្យាធិយតិ ... មរណធម្មំ មិយ្យតិ ... ខយធម្មំ ខិយតិ ... នស្សនធម្មំ នស្សតិ

ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើងរបស់សត្វទាំងឡាយ នៅមានត្រឹមណា ជរាធម៌របស់សត្វទាំងអស់ រមែងគ្រាំគ្រាទៅត្រឹមនោះ កាលបើជរាធម៌ គ្រាំគ្រាហើយ អាត្មាអញគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញគប្បីមិនឃ្លានភត្តផង សម្បុរអាក្រក់ក៏ធ្លាក់ចុះក្នុងកាយផង ការងារមិនប្រព្រឹត្តទៅផង ពួកជន ជាសត្រូវមានចិត្តត្រេកអរផង ពួកមិត្រសំឡាញ់តូចចិត្តផង ៗ កាលបើជរាធម៌គ្រាំគ្រាហើយ អរិយសាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហារាជ បុថុជ្ជន អ្នកមិនបានស្តាប់ ដែលសរគឺសោក លាបដោយថ្នាំពិសណាចាក់ហើយ រមែងញុំាងខ្លួនឲ្យក្តៅក្រហាយ នេះហៅថាអរិយសាវក អ្នកបានស្តាប់ បានដកនូវសរគឺសោក ដែលលាបដោយថ្នាំពិសនោះបាន ៗ អរិយសាវក ដែលមិនមានសរគឺសោក រមែងញុំាងខ្លួនឯងឲ្យរលត់ទុក្ខបាន ៗ បពិត្រមហារាជ មួយទៀត ព្យាធិធម៌របស់អរិយសាវកអ្នកបានស្តាប់ហើយ រមែងឈឺចាប់... មរណធម៌រមែងស្លាប់... ខយធម៌ រមែងអស់ទៅ... នស្សនធម៌ រមែងវិនាសទៅ

សោ នស្សនធម្មេ នដ្ឋេ ឥតិ បដិសញ្ចិក្ខតិ ន ខោ មយ្ហេវេកស្ស នស្សនធម្មំ នស្សតិ អថ ខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ សត្តានំ នស្សនធម្មំ នស្សតិ អហញ្ចេវ ខោ បន នស្សនធម្មេ នដ្ឋេ សោចេយ្យំ កិលមេយ្យំ បរិទេវេយ្យំ ឧរត្តាឡឹ កន្ទេយ្យំ សម្មោហំ អាបជ្ជេយ្យំ ភត្តម្បិ មេ នច្ឆាទេយ្យ កាយេបិ ទុព្វណ្ណិយំ ឱក្កមេយ្យ កម្មន្តាបិ នប្បវត្តេយ្យុំ អមិត្តាបិ អត្តមនា អស្សុ មិត្តាបិ ទុម្មនា អស្សុន្តិ ។ សោ នស្សនធម្មេ នដ្ឋេ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ អយំ វុច្ចតិ មហារាជ សុតវា អរិយសាវកោ អព្វុឡ្ហំ សវិសំ សោកសល្លំ យេន វិទ្ធោ អស្សុតវា បុថុជ្ជនោ អត្តានញ្ញេវ បរិតាបេតិ ។ អសោកោ វិសល្លោ អរិយសាវកោ

អរយសាវកនោះ ពិចារណា ក្នុងនស្សនធម៌ ដែលវិនាសទៅដូច្នេះថា នស្សនធម៌ មិនវិនាសទៅចំពោះលើតែអាត្មាអញម្នាក់ឯងទេ ដោយពិតនោះ ដំណើរមក ដំណើរទៅ សេចក្តីច្យុតិ សេចក្តីកើតឡើង នៃសត្វទាំងឡាយ នៅត្រឹមណា នស្សនធម៌របស់សត្វទាំងអស់ រមែងវិនាសទៅត្រឹមនោះ កាលបើនស្សនធម៌ វិនាសទៅហើយ អាត្មាអញសោតគប្បីសោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច អាត្មាអញមិនឃ្លានភក្តផង សម្បុរអាក្រក់ក៏ធ្លាក់ចុះក្នុងកាយផង ការងារក៏មិនប្រព្រឹត្តទៅផង ពួកជន ជាសត្រូវមានចិត្តត្រេកអរផង ពួកមិត្រសំឡាញ់ក៏តូចចិត្តផង ។ កាលបើនស្សនធម៌ វិនាសទៅហើយ អរិយសាវកនោះ ក៏មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច បពិត្រមហាពជ បុថុជ្ជនអ្នកមិនបានស្តាប់ ដែលសរគឺសោក លាបដោយថ្នាំពិសណា ចាក់ហើយ រមែងញុំាងខ្លួនឲ្យក្តៅក្រហាយ នេះហៅថា អរិយសាវកអ្នកបានស្តាប់ បានដកនូវសរគឺសោក ដែលលាបដោយថ្នាំពិសនោះបាន ។ អរិយសាវកមិនមានសរគឺសោក

អត្តានញ្ញេវ បរិតាបេតិ ។ ឥមានិ ខោ មហារាជ បញ្ច អលព្ភនីយានិ ឋានានិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិំ ។

ន សោចនាយ ន បរិទេវនាយ
អត្ថោ ឥធ លព្ភតិ អបិ អប្បកោបិ
សោចន្តមេនំ ទុក្ខិតំ វិទិត្វា
បច្ចត្ថិកា អត្តមនា ភវន្តិ
យតោ ច ខោ បណ្ឌិតោ អាបទាសុ
ន វេធតិ អត្ថវិនិច្ឆយញ្ញូ
បច្ចត្ថិកាស្ស ទុក្ខិតា ភវន្តិ
ទិស្វា មុខំ អវិការំ បុរាណំ
ជប្បេន មន្តេន សុភាសិតេន
អនុប្បទានេន បវេណិយា វា
យថា យថា យត្ថ លភេថ អត្ថំ
តថា តថា តត្ថ បរក្កមេយ្យ

រមែងញ៉ាំងខ្លួនឲ្យរលត់ទុក្ខបាន ។ បពិត្រមហារាជ អលព្ភនីយដ្ឋាន ៥ យ៉ាងនេះឯង ដែលសមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬបុគ្គល ណាមួយក្នុងលោក មិនគប្បីបានតាមប្រាថ្នា ។

ប្រយោជន៍ក្នុងលោកនេះ សូម្បីបន្តិចបន្តួច បុគ្គលមិនបាន ព្រោះសេចក្តីសោកខ្សឹកខ្សួលឡើយ ពួកជនជាសត្រូវឃើញ បុគ្គលនុ៎ះ កំពុងសោកសៅ ដល់នូវទុក្ខក៏មានចិត្តត្រេកអរ លុះណាតែបណ្ឌិត អ្នកឈ្លៀសយល់នូវហេតុផល ទើបមិន ញាប់ញ័រ ក្នុងឧបទ្រពទាំងឡាយ ពួកជនជាសត្រូវឃើញ (ទឹក) មុខ បណ្ឌិតនោះមិនប្រែប្រួលប្លែកអំពីដើម ក៏កើត ទុក្ខវិញ បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការ ណា ៗ គប្បីព្យាយាមក្នុងទីនោះៗ ដោយប្រការដូច្នោះៗ

សចេ បជានេយ្យ អលព្ភនេយ្យោ
មយា វា អញ្ញេន វា ឯស អត្ថោ
អសោចមានោ អធិវាសយេយ្យ
កម្មំ ទឡ្ហំ កិន្តិ ករោមិ ទានីតិ ។

ឯវំ វុត្តេ មុណ្ឌោ រាជា អាយស្មន្តំ នារទំ ឯតទ-វោច កោ នាមោ[1] អយំ ភន្តេ ធម្មបរិយាយោតិ ។ សោកសល្លហរណោ នាម អយំ មហារាជ ធម្ម-បរិយាយោតិ ។ តគ្ឃ ភន្តេ សោកសល្លហរណោ តគ្ឃ ភន្តេ សោកសល្លហរណោ ឥមំ ហិ មេ ភន្តេ ធម្មបរិយាយំ សុត្វា សោកសល្លំ បហីនន្តិ ។ អថខោ មុណ្ឌោ រាជា បិយកំ សោការក្ខំ អាមន្តេសិ តេនហិ សម្ម បិយក ភទ្ទាយ ទេវិយា សរីរំ ឈាបេថ ថូបញ្ចស្សា ករោថ ។ អជ្ជតគ្គេទានិ មយំ នហាយិស្សាម ចេវ វិលិម្បិស្សាម ភត្តំ ភុញ្ជិស្សាម កម្មន្តេ ច បយោជេស្សាមាតិ ។

១ ឱ. កោ នុ ខោ ។

គឺការនិយាយសរសើរក្តី ការកេយមន្តក្តី ការនិយាយជាសុ-ភាសិតក្តី ការផ្តល់ឲ្យក្តី បវេណីក្តី បើបុគ្គលដឹងថា ប្រយោជន៍នុះ អាត្មាអញក្តី អ្នកដទៃក្តី មិនគប្បីបានតាមសេចក្តីប្រាថ្នាទេ ហើយមិនសោកសៅ គប្បីអត់ធ្មត់ថា កម្មដ៏មាំ (អាត្មាអញបានសន្សំទុកហើយ) ឥឡូវនេះ អាត្មាអញ ធ្វើដូចម្តេចហ្ន៎ ។ កាលព្រះនារទៈសំដែងយ៉ាងនេះហើយ ព្រះរាជាមុណ្ឌៈបានទូលព្រះនារទៈដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចំរើន ធម្មបរិយាយនេះ ឈ្មោះអ្វី ។ បពិត្រមហារាជ ធម្មបរិយាយនេះ ឈ្មោះថា សោក-សល្លហរណៈគឺឧបាយជាគ្រឿងដកនូវសរគឺសោក ។ បពិត្រព្រះករុណា មែនហើយ ហៅថា សោកសល្លហរណធម៌ បពិត្រព្រះករុណា មែនហើយ ហៅថា សោកសល្លហរណធម៌ បពិត្រព្រះករុណា ខ្ញុំព្រះករុណាបានស្តាប់ធម្មបរិយាយនេះហើយ ក៏លះបង់នូវសរគឺសោកបាន ។ លំដាប់នោះ ព្រះរាជាមុណ្ឌៈត្រាស់ហៅសោការក្ខាមាត្យជាទីគាប់ព្រះទ័យថា ម្នាលសំឡាញ់ ជាទីស្រឡាញ់ បើដូច្នោះ ចូរអ្នករំលាយសរីរៈនាងភទ្ទាទេវី ហើយកសាងព្រះស្តូបដើម្បីបញ្ចុះធាតុនាងភទ្ទាទេវីនោះ ។ ចាប់ដើមតាំងពីថ្ងៃនេះទៅ យើងនឹងងូតទឹកផង ប្រោះព្រំផង បរិភោគភត្តផង ប្រកបការងារទាំងឡាយផង ។

ចប់ មុណ្ឌរាជវគ្គ ទី ៥ ។

## តស្សុទ្ទានំ

អាជិយោ សប្បុរិសោ ច

ឥដ្ឋា មជាបជាយឹកិសដ្ឋំ

សម្បន្នា ច ជលំ ហាលំ

កោសលោ ជារខេន ឆាតិ ។

បឋមោ បណ្ណាសកោ និដ្ឋិតោ ។

## ឧទ្ទាននៃមុណ្ឌរាជវគ្គ នោះគឺ

ហេតុទាំងឡាយ ដែលបុគ្គលគប្បីបានទ្រព្យ ១ សប្បុរសកើតក្នុងត្រកូល ១ ធម៌ទាំងឡាយជាទីប្រាថ្នា ១ បុគ្គលអ្នកឲ្យនូវរបស់ជាទីគាប់ចិត្ត តែងបានរបស់ជាទីគាប់ចិត្តវិញ ១ គំនរបុណ្យ ១ សម្បទា ១ ទ្រព្យ ១ ហេតុដែលបុគ្គលមិនគប្បីបានតាមប្រាថ្នា ១ ព្រះរាជាបសេនទិកោសលព្រួយព្រះហឫទ័យ ១ នារទៈសំដែងធម៌ ១ ។

ចប់ បឋមបណ្ណាសក ។

# ទុតិយបណ្ណាសកោ

## នីវរណវគ្គោ

(៥១) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច បញ្ចិមេ ភិក្ខវេ អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្ពលីករណា ។ កតមេ បញ្ច ។ កាមច្ឆន្ទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ អជ្ឈារុហោ បញ្ញាយ ទុព្ពលីករណោ ព្យាបាទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ អជ្ឈារុហោ បញ្ញាយ ទុព្ពលីករណោ ថីនមិទ្ធំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ អជ្ឈារុហំ បញ្ញាយ ទុព្ពលីករណំ ឧទ្ធច្ចកុក្កុច្ចំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ អជ្ឈារុហំ បញ្ញាយ ទុព្ពលីករណំ វិចិកិច្ឆា ភិក្ខវេ អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្ពលីករណា ។

# ទុតិយបណ្ណាសក

## នីវរណវគ្គ

(៥១) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌៥ យ៉ាងនេះ ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ធម៌៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺកាមច្ឆន្ទៈ ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ ព្យាបាទៈ ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈ ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចៈ ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆា ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ១ ។

ឥមេ ខោ ភិក្ខវេ បញ្ច អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្ពលីករណា ។ សោ វត ភិក្ខវេ ភិក្ខុ ឥមេ បញ្ច អាវរណេ នីវរណេ ចេតសោ អជ្ឈារុហេ បញ្ញាយ ទុព្ពលីករណេ អប្បហាយ អពលាយ បញ្ញាយ ទុព្ពលាយ អត្តត្ថំ វា ញស្សតិ បរត្ថំ វា ញស្សតិ ឧភយត្ថំ វា ញស្សតិ ឧត្តរិ វា មនុស្សធម្មា អលមរិយញាណ-ទស្សនវិសេសំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ នទី បព្វតេយ្យា ទូរង្គមា សីឃសោតា ហារហារិនី តស្សា បុរិសោ ឧភតោ នង្គលមុខានិ វិវរេយ្យ ឯវំ ហិ សោ ភិក្ខវេ មជ្ឈេ នទិយា សោតោ វិក្ខិត្តោ វិសដោ ព្យាទិន្នោ នេវ ទូរង្គមោ អស្ស ន សីឃសោតោ ន ហារហារី(១) ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ ឥមេ បញ្ច អាវរណេ នីវរណេ ចេតសោ អជ្ឈារុហេ បញ្ញាយ ទុព្ពលីករណេ អប្បហាយ អពលាយ បញ្ញាយ ទុព្ពលាយ អត្តត្ថំ វា ញស្សតិ

---

១ ម. ហារហារិនី ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសោត មិនបានលះបង់ធម៌ ៥ នេះ ដែលជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុបជាងមនុស្សធម៌[1] តទៅ ដោយប្រាជ្ញាមិនមានកម្លាំង នឹងមានកម្លាំងថយ ដូច្នេះនុ៎ះ មិនជាហេតុជាទីតាំងឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹង ហូរចុះអំពីភ្នំ ប្រព្រឹត្តទៅកាន់ទីឆ្ងាយ មានខ្សែទឹកដ៏រហ័ស ហូរនាំយកទាំងសំណាត់ទៅ មានបុរស បើកមាត់ប្រឡាយសងខាងស្ទឹងនោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ខ្សែទឹកត្រង់កណ្តាលស្ទឹងនោះ នឹងហូរពេចសាចព្រាចទៅផ្សេងៗ មិនប្រព្រឹត្តទៅកាន់ទីឆ្ងាយបាន ខ្សែទឹកមិនបានរហ័ស ទាំងមិនបានហូរនាំយកសំណាត់ទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនបានលះនូវធម៌ ៥ យ៉ាងនេះ ដែលជាគ្រឿងទប់ រាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន

១ សំដៅយកកម្មបថទាំង ១០ ។ អដ្ឋកថា ។

បរត្ថំ វា ញស្សតិ ឧភយត្ថំ វា ញស្សតិ ឧត្តរឹ វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ ឥមេ បញ្ច អាវរណេ នីវរណេ ចេតសោ អជ្ឈារុហេ បញ្ញាយ ទុព្វលីករណេ បហាយ ពលវតិយា បញ្ញាយ អត្តត្ថំ វា ញស្សតិ បរត្ថំ វា ញស្សតិ ឧភយត្ថំ វា ញស្សតិ ឧត្តរឹ វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ នទី បព្វតេយ្យា ទូរង្គមា សីឃសោតា ហារហារិនី តស្សា បុរិសោ ឧភតោ នង្គលមុខានិ បិទហេយ្យ ឯវំ ហិ សោ ភិក្ខវេ មជ្ឈេ នទិយា សោតោ អវិក្ខិត្តោ អវិសដោ អព្យាទិន្នោ ទូរង្គមោ ចេវ អស្ស សីឃសោតោ ច ហារហារី ច ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ ឥមេ បញ្ច អាវរណេ នីវរណេ ចេតសោ អជ្ឈារុហេ បញ្ញាយ ទុព្វលីករណេ បហាយ ពលវតិយា បញ្ញាយ អត្តត្ថំ វា ញស្សតិ

ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុបជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមិនមានកម្លាំង នឹងមានកម្លាំងថយដូច្នេះទុះ+ ក៏មិនជាហេតុជាទីតាំង យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ លុះភិក្ខុនោះបានលះបង់នូវធម៌ ៥ យ៉ាងនេះ ដែលជាគ្រឿងទប់កាំង គ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាពដ៏លើសលុប ជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមានកម្លាំងដូច្នេះ នេះទើបជាហេតុជាទីតាំងបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ទឹង ហូរចុះអំពីភ្នំ ប្រព្រឹត្តទៅកាន់ទីឆ្ងាយ មានខ្សែទឹកដ៏រហ័ស ហូរនាំយកទាំងសំណាត់ទៅ មានបុរសទប់មាត់ប្រឡាយសងខាងស្ទឹងនោះ កាលបើយ៉ាងនេះ ខ្សែទឹកត្រង់កណ្តាលស្ទឹងនោះ មិនបានហូរពេចសាចព្រាចទៅផ្សេងៗ ល្មមប្រព្រឹត្តទៅកាន់ទីឆ្ងាយ ជាខ្សែទឹកដ៏រហ័សទាំងហូរនាំយកសំណាត់ទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសោត បានលះបង់នូវធម៌ ៥ យ៉ាងនេះ ដែលជាគ្រឿងទប់ កាំងគ្របសង្កត់នូវចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ នឹងដឹងនូវប្រយោជន៍ខ្លួន

បរត្តំ វា ញស្សតិ ឧភយត្តំ វា ញស្សតិ ឧត្តរី វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិ-ករិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(៥២) អកុសលរាសីតិ ភិក្ខវេ វទមានោ បញ្ច នីវរណេ សម្មា វទមានោ វទេយ្យ ។ កេវលោចាយំ[១] ភិក្ខវេ អកុសលរាសិ យទិទំ បញ្ច នីវរណា ។ កតមេ បញ្ច ។ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។ អកុសលរាសីតិ ភិក្ខវេ វទមានោ ឥមេ បញ្ច នីវរណេ សម្មា វទមានោ វទេយ្យ ។ កេវលោចាយំ ភិក្ខវេ អកុសលរាសិ យទិទំ ឥមេ បញ្ច នីវរណាតិ ។

(៥៣) បញ្ចិមានិ ភិក្ខវេ បធានិយង្គានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ

---

១ ឱ. កេវលោហាយំ ។ ម. កេវលោសាយំ ។

ដឹងនូវប្រយោជន៍អ្នកដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវញាណទស្សនវិសេស ល្មមឲ្យបាននូវអរិយភាព ដ៏លើសលុបជាងមនុស្សធម៌តទៅ ដោយប្រាជ្ញាមានកម្លាំង ដូច្នេះ នេះក៏ជាហេតុជាទីតាំង យ៉ាងនោះដែរ ។

(៩២) ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា គំនរអកុសល (បើ) ពោលឲ្យត្រូវ គួរហៅថា នីវរណៈ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ គំនរអកុសលទាំងអស់ ក៏គឺនីវរណៈទាំង៥ យ៉ាងនេះ ។ នីវរណៈ៥ តើដូចម្តេច ។ គឺកាមច្ឆន្ទនីវរណៈ១ ព្យាបាទនីវរណៈ១ ថីនមិទ្ធនីវរណៈ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ១ វិចិកិច្ឆានីវរណៈ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា គំនរអកុសល (បើ) ពោលឲ្យត្រូវគួរហៅថា នីវរណៈ៥ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ គំនរអកុសលទាំងអស់ ក៏គឺនីវរណៈ៥ យ៉ាងនេះ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្តីព្យាយាមនេះ មាន៥ យ៉ាង ។ អង្គ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធាជឿ ញាណគ្រឿងត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក

អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ អារទ្ធវិរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ ឥមានិ ខោ ភិក្ខវេ បញ្ច បធានិយង្គានីតិ ។

(៥៤) បញ្ចិមេ ភិក្ខវេ អសមយា បធានាយ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ ជិណ្ណោ ហោតិ ជរាយាភិភូតោ អយំ ភិក្ខវេ បឋមោ អសមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ព្យាធិតោ ហោតិ

ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតា នឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធលែងវិលមកកាន់កពភ៌ទៀត ១ ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើង សម្រាប់ដុតកំដៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្ដៅពេក ជាយ៉ាងកណ្ដាល គួរនឹងធ្វើព្យាយាមបាន ១ ជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកធ្វើខ្លួន ឲ្យប្រាកដតាមពិតក្នុងសំណាក់គ្រូ នឹងពួកសព្រហ្មចារីជាវិញ្ញូជន ១ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ ធ្វើកុសលធម៌ឲ្យសម្រេច មានកម្លាំងប្រឹងស្វាត មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ ១ ជាអ្នកមានបញ្ញាប្រកបដោយបញ្ញា អាចកំណត់នូវការកើតនឹងការរលត់ដ៏ប្រសើរជាគ្រឿងទំលុះទំលាយ (កិលេស) អាចកំណត់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃបាន ១ ។ ម្នាលភិក្ខុទាំងឡាយ អង្គនៃសេចក្ដីព្យាយាមមាន ៥ នេះឯង ។

[៥៤] ម្នាលភិក្ខុទាំងឡាយ អសម័យ (សម័យមិនគួរ) ៥ យ៉ាងនេះ ដើម្បីព្យាយាម ។ អសម័យ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្រាំគ្រា ត្រូវជរាគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ១ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានព្យាធិ

ព្យាធិនាភិភូតោ អយំ ភិក្ខវេ ទុតិយោ អសមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ ទុព្ភិក្ខំ ហោតិ ទុស្សស្សំ ទុល្លភបិណ្ឌំ ន សុករំ ឧញ្ឆេន បគ្គហេន យាបេតុំ អយំ ភិក្ខវេ តតិយោ អសមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ ភយំ ហោតិ អដវីសង្កោបោ[១] ចក្កសមារុឡ្ហា ជានបទា បរិយាយន្តិ អយំ ភិក្ខវេ ចតុត្ថោ អសមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ សង្ឃោ ភិន្នោ ហោតិ សង្ឃេ ខោ បន ភិក្ខវេ ភិន្នេ អញ្ញមញ្ញំ អក្កោសា ច ហោន្តិ អញ្ញមញ្ញំ បរិភាសា ច ហោន្តិ អញ្ញមញ្ញំ បរិក្ខេបា ច ហោន្តិ អញ្ញមញ្ញំ បរិច្ចជា[២] ច ហោន្តិ តត្ថ អប្បសន្នា ចេវ នប្បសីទន្តិ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តំ ហោតិ អយំ ភិក្ខវេ បញ្ចមោ អសមយោ បធានាយ ។ ឥមេ ខោ ភិក្ខវេ បញ្ច អសមយា បធានាយ ។

---

១ ឱ. អដវីសំកោបោ ។ ២ ឱ. បរិច្ចជា ច ។

ត្រូវព្យាធិគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ២ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្រុកអំណត់អត់បាយ មានស្រូវមិនល្អ រកបិណ្ឌបាត បានដោយក្រ មិនងាយបុគ្គលព្យាយាមស្វែងរកអាហារបានឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ៣ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត (ស្រុក) មានភ័យ(១) មានការរំភើបក្រើក ក្នុងដងព្រៃ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយានហើយបរទៅ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ៤ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃបែកគ្នា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការជេរគ្នានឹងគ្នា ក៏រមែងមាន ការប្រទេចគ្នានឹងគ្នា ក៏រមែងមាន ការនិយាយបោះបោកគ្នានឹងគ្នា ក៏រមែងមាន ការបោះបង់ចោលគ្នានឹងគ្នា ក៏រមែងមាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃនោះឯង ក៏នៅតែមិនជ្រះថ្លា ពួកជនខ្លះដែលជ្រះថ្លាហើយ ក៏ប្រែចិត្តផ្សេងទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអសម័យទី ៥ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ យ៉ាងនេះឯង ជាអសម័យដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ អសម័យ (សម័យមិនគួរ) ៥ យ៉ាងនេះឯង ដើម្បីព្យាយាម ។

---

១ បានសេចក្តីថា ស្រុកកើតចម្បាំង ។

បញ្ចិមេ ភិក្ខវេ សមយា បធានាយ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ ទហរោ ហោតិ យុវា សុសុ កាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អយំ ភិក្ខវេ បឋមោ សមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិ-សីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ អយំ ភិក្ខវេ ទុតិយោ សមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ សុភិក្ខំ ហោតិ សុសស្សំ សុលភ-បិណ្ឌំ សុករំ ឧញ្ឆេន បគ្គហេន យាបេតុំ អយំ ភិក្ខវេ តតិយោ សមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ មនុស្សា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ អយំ ភិក្ខវេ ចតុត្ថោ សមយោ បធានាយ ។ បុន ចបរំ ភិក្ខវេ សង្ឃោ សមគ្គោ សម្មោទ-មានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតិ

ម្នាលភិក្ខុទាំងឡាយ សម័យ ៥ យ៉ាងនេះ ដើម្បីព្យាយាម ។ សម័យ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្មេងកំលោះ ពេញកម្លាំង មានសក់ខ្មៅ ប្រកបដោយវ័យ កំពុងចំរើន គឺវ័យជាបឋម ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ១ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយធាតុភ្លើង ជាគ្រឿងផុតកំដៅយ៉ាងល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដើម្បីព្យាយាមបាន ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ២ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្រុកសម្បូរភិក្ខា មានស្រូវល្អ រកបិណ្ឌបាត បានងាយ បុគ្គលងាយព្យាយាមស្វែងរកអាហារបាន ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៣ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកមនុស្សព្រមព្រៀងគ្នា រួសរាយរកគ្នា មិនវិវាទគ្នា រលាយចូលគ្នា ដូចទឹកដោះលាយនឹងទឹក សំឡឹងមើលគ្នា ទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៤ ដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃព្រមព្រៀងគ្នា រួសរាយរកគ្នា មិនវិវាទគ្នា មានបាលីសម្រាប់សំដែងឡើងតែមួយ នៅជាសុខសប្បាយ

សង្ឃេ ខោ បន ភិក្ខវេ សមគ្គេ ន ចេវ អញ្ញមញ្ញំ អក្កោសា ហោន្តិ ន ច អញ្ញមញ្ញំ បរិភាសា ហោន្តិ ន ច អញ្ញមញ្ញំ បរិក្ខេបា ហោន្តិ ន ច អញ្ញមញ្ញំ បរិច្ចជា ហោន្តិ តត្ថ អប្បសន្នា ចេវ បសីទន្តិ បសន្នានញ្ច ភិយ្យោភាវោ[១] ហោតិ អយំ ភិក្ខវេ បញ្ចមោ សមយោ បធានាយ ។ ឥមេ ខោ ភិក្ខវេ បញ្ច សមយា បធានាយាតិ ។

[៥៥] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ ឧភោ មាតាបុត្តា វស្សាវាសំ ឧបគមឹសុ[២] ភិក្ខុ ច ភិក្ខុនី ច ។ តេ អញ្ញមញ្ញស្ស អភិណ្ហំ ទស្សនកាមា អហេសុំ មាតាបិ បុត្តស្ស អភិណ្ហំ ទស្សនកាមា អហោសិ បុត្តោបិ មាតរំ អភិណ្ហំ ទស្សនកាមោ អហោសិ ។ តេសំ អភិណ្ហំ ទស្សនា សំសគ្គោ អហោសិ សំសគ្គេ

១ ម. ភិយ្យោភាវាយ ។ ២ ម. ឧបសង្កមឹសុ ។

ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការជេរគ្នានឹងគ្នា ក៏មិនមាន ការប្រទេចគ្នានឹងគ្នា ក៏មិនមាន ការស្រដីបោះបោករកគ្នានឹងគ្នា ក៏មិនមាន ការលះបង់ចោលគ្នានឹងគ្នា ក៏មិនមាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃនោះ ក៏ជ្រះថ្លាឡើង ពួកជនដែលជ្រះថ្លាហើយ ក៏រឹតតែជ្រះថ្លាក្រៃពេក ម្នាលភិក្ខុទាំងឡាយ នេះជាសម័យទី ៥ គួរប្រព្រឹត្តដើម្បីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ យ៉ាងនេះឯង ជាសម័យគួរប្រព្រឹត្តដើម្បីព្យាយាម ។

[៥៥] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ជនពីរនាក់គឺភិក្ខុ ១ ភិក្ខុនី ១ ជាមាតានឹងបុត្រ បានចូលទៅនៅចាំវស្សាទៀបក្រុងសាវត្ថី ។ ជនទាំងពីរនោះ ជាអ្នកប្រាថ្នាឲ្យឃើញគ្នានឹងគ្នាជារឿយ ៗ គឺមាតាក៏ជាអ្នកប្រាថ្នាឲ្យឃើញបុត្ររឿយ ៗ ចំណែកបុត្រក៏ជាអ្នកប្រាថ្នាឲ្យឃើញមាតារឿយ ៗ ។ ការនៅប្រឡូកប្រឡំកើតមានព្រោះជនទាំងនោះបានឃើញគ្នារឿយ ៗ កាលបើការនៅប្រឡូកប្រឡំ

សតិ វិស្សាសោ អហោសិ វិស្សាសេ សតិ ឱតារោ អហោសិ ។ តេ ឱតិណ្ណចិត្តា សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវឹសុ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សាវត្ថិយំ ឧភោ មាតាបុត្តា វស្សាវាសំ ឧបគមឹសុ ភិក្ខុ ច ភិក្ខុនី ច ។ តេ អញ្ញមញ្ញស្ស អភិណ្ហំ ទស្សនកាមា អហេសុំ មាតាបិ បុត្តស្ស អភិណ្ហំ ទស្សនកាមា អហោសិ បុត្តោបិ មាតរំ អភិណ្ហំ ទស្សនកាមោ អហោសិ ។ តេសំ អភិណ្ហំ ទស្សនា សំសគ្គោ អហោសិ សំសគ្គេ សតិ វិស្សាសោ អហោសិ វិស្សាសេ សតិ ឱតារោ អហោសិ ។ តេ ឱតិណ្ណចិត្តា សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវឹសូតិ ។

មានហើយ សេចក្ដីសុខស្រួលក៏កើតមាន កាលបើមានសេចក្ដីសុខ
ស្រួលហើយ សេចក្ដីស្ងប់ចិត្តក៏កើតមាន ។ ជនទាំងពីរនោះ
លុះមានចិត្តស្ងប់ រកគ្នាហើយ ក៏មិនបានលាសិក្ខា មិនបានធ្វើឲ្យ
ជាក់ច្បាស់នូវភាពនៃខ្លួនមានកម្លាំងថយ ស្រាប់តែសេពនូវមេថុនធម្ម ។
គ្រានោះ មានភិក្ខុច្រើនរូបបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូល
ទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។
លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មាន
ព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស មានជនពីរនាក់
គឺភិក្ខុ ១ ភិក្ខុនី ១ ជាមាតានិងបុត្ត បានចូលមកនៅចាំវស្សាក្នុងក្រុង
សាវត្ថីនេះ ។ ជនទាំងពីរនោះ ជាអ្នកប្រាថ្នាឲ្យឃើញគ្នានឹងគ្នាជារឿយ ៗ
គឺមាតា ក៏ជាអ្នកប្រាថ្នាឲ្យឃើញបុត្ររឿយ ៗ ចំណែកបុត្រក៏ជាអ្នកប្រាថ្នា
ឲ្យឃើញមាតារឿយ ៗ ។ ការនៅប្រឡុកប្រឡំគ្នាក៏កើតមាន ក៏ព្រោះ
ជនទាំងពីរនោះ បានឃើញគ្នារឿយ ៗ កាលបើមានការនៅប្រឡុក
ប្រឡំហើយ សេចក្ដីសុខស្រួលក៏កើតមាន កាលបើមានសេចក្ដី
សុខស្រួលហើយ សេចក្ដីស្ងប់ចិត្តក៏កើតមាន ។ ជនទាំងពីរនោះ
លុះមានចិត្តស្ងប់ រកគ្នាហើយ ក៏មិនបានលាសិក្ខា មិនបានធ្វើឲ្យ
ជាក់ច្បាស់ នូវភាពនៃខ្លួនមានកម្លាំងថយ ស្រាប់តែសេពមេថុនធម្ម ។

កិន្នុ សោ ភិក្ខវេ មោឃបុរិសោ មញ្ញតិ ន
មាតា បុត្តេ សារជ្ជតិ បុត្តោ វា បន មាតរីតិ ។
នាហំ ភិក្ខវេ អញ្ញំ ឯករូបំបិ សមនុបស្សាមិ ឯវំ
រជនីយំ ឯវំ កមនីយំ ឯវំ មទនីយំ ឯវំ ពន្ធនីយំ ឯវំ
មុច្ឆនីយំ ឯវំ អន្តរាយករំ អនុត្តរស្ស យោគក្ខេមស្ស
អធិគមាយ យថយិទំ ភិក្ខវេ ឥត្ថីរូបំ ។ ឥត្ថីរូបេ
ភិក្ខវេ សត្តា រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា តេ
ទីឃរត្តំ សោចន្តិ ឥត្ថីរូបវសានុគា ។ នាហំ ភិក្ខវេ
អញ្ញំ ឯកសទ្ទំបិ... ឯកគន្ធំបិ... ឯករសំបិ...
ឯកផោដ្ឋព្វំបិ សមនុបស្សាមិ ឯវំ រជនីយំ ឯវំ
កមនីយំ ឯវំ មទនីយំ ឯវំ ពន្ធនីយំ ឯវំ មុច្ឆនីយំ
ឯវំ អន្តរាយករំ អនុត្តរស្ស យោគក្ខេមស្ស
អធិគមាយ យថយិទំ ភិក្ខវេ ឥត្ថីផោដ្ឋព្វោ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះ ដឹងដែរឬមិនដឹងទេថា មាតារមែងត្រេកអរក្នុងបុត្រ ឬថាបុត្រក៏រមែងត្រេកអរក្នុងមាតា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាគេមិនឃើញនូវរូបដទៃ សូម្បីតែរូបមួយ ដែលជាទីតាំងនៃតម្រេក យ៉ាងនេះ ជាទីតាំងនៃសេចក្ដីប្រាថ្នាយ៉ាងនេះ ជាទីតាំងនៃសេចក្ដីស្រវឹង យ៉ាងនេះ ជាទីតាំងនៃចំណង យ៉ាងនេះ ជាទីតាំងនៃសេចក្ដីជាប់នៅ យ៉ាងនេះ ទឹងធ្វើឲ្យអន្តរាយ ដល់ការបានសេចក្ដីក្សេមចាកយោគៈដ៏ប្រសើរលើស យ៉ាងនេះ ដូចជារូបស្រីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វត្រេកអរ ជាប់ជំពាក់ សញ្ចប់ជាប់ស៊ប់នៅ ក្នុងរូបស្រីហើយ សត្វពួកនោះឈ្មោះថា លុះក្នុងអំណាចនៃរូបស្រី រមែងសោកស្ដាយអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញនូវសំឡេងដទៃ សូម្បីតែសំឡេងមួយ ... នូវក្លិនដទៃ សូម្បីតែក្លិនមួយ ... នូវរសដទៃ សូម្បីតែរសមួយ ... នូវផ្សព្វដទៃ សូម្បីតែផ្សព្វមួយ ដែលជាទីតាំងនៃតម្រេក យ៉ាងនេះ ជាទីតាំងនៃសេចក្ដីប្រាថ្នា យ៉ាងនេះ ជាទីតាំងនៃសេចក្ដីស្រវឹង យ៉ាងនេះ ជាទីតាំងនៃចំណង យ៉ាងនេះ ជាទីតាំងនៃសេចក្ដីជាប់នៅ យ៉ាងនេះ ទឹងធ្វើឲ្យអន្តរាយដល់ការបានសេចក្ដីក្សេមចាកយោគៈ ដ៏ប្រសើរលើសយ៉ាងនេះ ដូចជាផ្សព្វនៃស្រីនេះទេ ។

ឥត្ថីផោដ្ឋព្វេ ភិក្ខវេ សត្តា រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា តេ ទីឃរត្តំ សោចន្តិ ឥត្ថីផោដ្ឋព្វវសានុគា ។ ឥត្ថី ភិក្ខវេ គច្ឆន្តីបិ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ ឋិតាបិ និសិន្នាបិ សយានាបិ និបន្នាបិ ហសន្តីបិ ភណន្តីបិ គាយន្តីបិ រោទន្តីបិ ឧគ្ឃាដិតាបិ មតាបិ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ ។ យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ សមន្តបាសោ មារស្សាតិ មាតុគាមញ្ញេវ សម្មា វទមានោ វទេយ្យ សមន្តបាសោ មារស្សាតិ ។

សល្លបេ អសិហត្ថេន បិសាចេនបិ សល្លបេ
អាសីវិសម្បិ អាសីទេ យេន ទដ្ឋោ ន ជីវតិ
នត្វេវ ឯកោ ឯកាយ មាតុគាមេន សល្លបេ ។
មុដ្ឋស្សតឹ តា ពន្ធន្តិ បេក្ខិតេន ម្ហិតេន (១) ច
អថោបិ ទុន្និវត្ថេន មញ្ជុនា ភណិតេន ច

១ ម. សិតេន ច ។

ម្នាលភិក្ខុទាំងឡាយ សត្វត្រេកអរ ជាប់ចំពាក់ សញ្ជប់ជ្រប់ស៊ប់នៅក្នុងផ្សព្វនៃស្រីហើយ សត្វពួកនោះ ឈ្មោះថា លុះក្នុងអំណាចនៃផ្សព្វស្រី រមែងសោកស្តាយអស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ស្រីទោះកំពុងដើរក្តី ក៏រមែងគ្របសង្កត់ចិត្តបុរសបាន ទោះឈរក្តី អង្គុយក្តី ដេកក្តី ក្រាបចុះក្តី ការនិយាយក្តី ច្រៀងក្តី យំក្តី ហើមប៉ោងក្តី ស្លាប់ក្តី ក៏រមែងគ្របសង្កត់នូវចិត្តនៃបុរសបាន ។ ម្នាលភិក្ខុទាំងឡាយ តាមពិតថា បុគ្គលកាលបើហៅមាតុគ្រាមនោះឲ្យត្រូវ គួរហៅថាជា អន្ទាក់ (សម្រាប់ទាក់) ដោយជុំវិញរបស់មារដូច្នេះ បុគ្គលកាលបើហៅមាតុគ្រាមឲ្យត្រូវ គួរហៅថាជា អន្ទាក់ដោយជុំវិញរបស់មារដូច្នេះ ។

បុគ្គលចរចាជាមួយនឹងជន ដែលមានដាវក្នុងដៃក្តី ចរចាជា
មួយនឹងបិសាចក្តី ប៉ះពាល់នឹងអាសិរពិស ហើយត្រូវ
អាសិរពិសចឹកស្លាប់ក្តី (ប្រសើរជាង) មិនគួរចរចា
ជាមួយនឹងមាតុគ្រាម តែមួយនឹងមួយឡើយ ។ ពួក
មាតុគ្រាមនោះ រមែងចងបុរសដែលភ្លេចស្មារតី ដោយការ
សំឡឹងមើលផង ដោយកិរិយាញញឹមផង មួយយ៉ាងទៀត
ដោយការស្លៀកមិនស្រួលផង ដោយសំដីដ៏ពីរោះផង

នេសោ ជនោ ស្វាសន្តោ[1] អបិ ឧត្បាដិតោ មតោ ។
បញ្ច កាមគុណា ឯតេ ឥត្ថីរូបស្មិំ ទិស្សរេ
រូបា សទ្ទា រសា គន្ធា ផោដ្ឋព្វា ច មនោរមា ។
តេសំ កាមោឃវូឡ្ហានំ កាមេ អបរិជានតំ
កាលំ គតំ ភវាភវំ សំសារស្មឹ បុរក្ខតា
យេ ច កាមេ បរិញ្ញាយ ចរន្តិ អកុតោភយា
តេ វេ បារគតា លោកេ យេ បត្តា អាសវក្ខយន្តិ ។

(៤៦) អថខោ អញ្ញតរោ ភិក្ខុ យេន សកោ ឧបជ្ឈាយោ តេនុបសង្កមិ ឧបសង្កមិត្វា សកំ ឧបជ្ឈាយំ ឯតទវោច ឯតរហិ មេ ភន្តេ មធុរកជាតោ ចេវ កាយោ ទិសា ច មេ ន បក្ខាយន្តិ ធម្មា ច មំ នប្បដិភន្តិ ថីនមិទ្ធញ្ច មេ ចិត្តំ បរិយាទាយ តិដ្ឋតិ

---

១ ឱ. ស្វាសិសន្តោ ។ ម. ស្វាសីសកោ ។

ជនគឺមាតុគ្រាមនុ៎ះ មិនមែនបៀតបៀនបុរសតែ (ត្រឹមរស់នៅ) ប៉ុណ្ណោះទេ ទោះបីហើមប៉ោងឬស្លាប់ហើយក៏ (គង់នៅតែបៀតបៀនដែរ) ។ កាមគុណទាំង ៥ នុ៎ះ គឺរូប សំឡេង ក្លិន រស ផ្សព្វ ដែលជាតម្រេកនៃចិត្ត រមែងប្រាកដក្នុងរូបនៃស្ត្រី ។ កាលបុរសទាំងនោះ ដែលជំនន់គឺកាមកួបនាំទៅ មិនបានកំណត់ដឹងនូវកាមទាំងឡាយ រមែងធ្វើនូវគតិនិងការកើតរឿយ ៗ អស់វដ្តកាលក្នុងសង្សារវដ្តទៅខាងមុខ ។ លុះតែបុរសទាំងឡាយណា កំណត់ដឹងនូវកាមទាំងឡាយបាន ទើបបុរសនោះ មិនមានភ័យអំពីទីណាឡើយ ឬបុរសទាំងឡាយណា បានដល់នូវការអស់ទៅនៃអាសវៈក្នុងលោកហើយ បុរសទាំងនោះទើបឈ្មោះថា បានដល់នូវត្រើយ គឺព្រះនិព្វាន ។

(៨៦) គ្រានោះឯង មានភិក្ខុមួយរូប បានចូលទៅរកឧបជ្ឈាយ៍របស់ខ្លួន លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងឧបជ្ឈាយ៍របស់ខ្លួនថា បពិត្រព្រះថេរៈដ៏ចំរើន ឥឡូវនេះកាយរបស់ខ្ញុំ មានសភាពធ្ងន់ ទាំងទិសក៏មិនប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈគ្របសង្កត់ចិត្តរបស់ខ្ញុំ

អនភិរតោ ច ព្រហ្មចរិយំ ចរាមិ អត្ថិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។ អថខោ សោ ភិក្ខុ តំ សទ្ធិវិហារិកំ ភិក្ខុំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អយំ ភន្តេ ភិក្ខុ ឯវមាហ ឯតរហិ មេ ភន្តេ មធុរកជាតោ ចេវ កាយោ ទិសា ច មេ ន បក្ខាយន្តិ ធម្មា ច មំ នប្បដិភន្តិ ថីនមិទ្ធញ្ច មេ ចិត្តំ បរិយាទាយ តិដ្ឋតិ អនភិរតោ ច ព្រហ្មចរិយំ ចរាមិ អត្ថិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។ ឯវញ្ហេតំ ភិក្ខុ ហោតិ ។ យោ ឥន្ទ្រិយេសុ អគុត្តទ្វារស្ស ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តស្ស អវិបស្សកស្ស កុសលានំ ធម្មានំ បុព្វរត្តាបររត្តំ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគំ អននុយុត្តស្ស វិហរតោ យំ មធុរកជាតោ ចេវ កាយោ ហោតិ ទិសា ចស្ស ន បក្ខាយន្តិ ធម្មា

ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្តីអផ្សុក សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មានដល់ខ្ញុំ ។ លំដាប់នោះឯង ភិក្ខុនោះបាននាំភិក្ខុជាសទ្ធិវិហារិកនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះពោលយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ឥឡូវនេះ កាយរបស់ខ្ញុំ មានសភាពធ្ងន់ ទាំងទិសក៏មិនប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្តីអផ្សុក សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មានដល់ខ្ញុំ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ហេតុនុ៎ះ រមែងមានយ៉ាងហ្នឹងឯង ។ កាលបើភិក្ខុមិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណ ក្នុងភោជន មិនបានប្រកបរឿយៗនូវការភ្ញាក់រលឹក មិនពិចារណា ការរក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើមនឹងរាត្រីខាងចុង មិនបានប្រឹងប្រែងប្រកបព្យាយាម ចំរើននូវធម៌ទាំងឡាយជាចំណែកនៃពោធិញ្ញាណ កាយរបស់ភិក្ខុនោះ រមែងមានសភាពធ្ងន់ ទាំងទិសក៏មិនបានប្រាកដដល់ភិក្ខុនោះ ធម៌ទាំងឡាយ

ច តំ នប្បដិភន្តិ ថីនមិទ្ធញ្ចស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ អនភិរតោ ច ព្រហ្មចរិយំ ចរតិ ហោតិ ចស្ស ធម្មេសុ វិចិកិច្ឆា ។ តស្មាតិហ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ ឥន្ទ្រិយេសុ គុត្តទ្វារោ ភវិស្សាមិ ភោជនេ មត្តញ្ញូ ជាគរិយំ អនុយុត្តោ វិបស្សកោ កុសលានំ ធម្មានំ បុព្វរត្តាបររត្តំ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគំ អនុយុត្តោ វិហរិស្សាមីតិ ។ ឯវំ ហិ តេ ភិក្ខុ សិក្ខិតព្វន្តិ ។ អថខោ សោ ភិក្ខុ ភគវតា ឥមិនា ឱវាទេន ឱវទិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ

កំមិនជាក់ច្បាស់ដល់ភិក្ខុនោះ ថីនមិទ្ធៈក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ភិក្ខុនោះ រមែងប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្តីអផ្សុក សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មានដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ ព្រោះហេតុនោះ អ្នកត្រូវសិក្សា ក្នុងសាសនានេះ យ៉ាងនេះថា អាត្មាអញនឹងជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណ ក្នុងភោជន ប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ពិចារណា រាវរក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើម នឹងរាត្រីខាងចុង ប្រឹងប្រកបការព្យាយាម បំរើននូវធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ ។ ម្នាលភិក្ខុ អ្នកត្រូវសិក្សាយ៉ាងនេះឯង ។ លំដាប់នោះ ភិក្ខុនោះ លុះព្រះដ៏មានព្រះភាគទ្រង់ទូន្មាន ដោយឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចធ្វើប្រទក្សិណ ចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះ គេចចេញទៅតែម្នាក់ឯង ជាអ្នកមិនធ្វេសប្រហែស មានព្យាយាមដុតបំផ្លាញនូវកិលេស មានចិត្តស្ទុង់ទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះ បួសកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់គុណវិសេសណា ក៏បានធ្វើឲ្យជាក់ច្បាស់ បានដល់នូវគុណវិសេស ដ៏លើសលុបនោះ ជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន អស់កាលមិនយូរ

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសិ ។ អថខោ សោ ភិក្ខុ អរហត្តប្បត្តោ យេន សកោ ឧបជ្ឈាយោ តេនុបសង្កមិ ឧបសង្កមិត្វា សកំ ឧបជ្ឈាយំ ឯតទវោច ឯតរហិ មេ ភន្តេ ន ចេវ មធុរកជាតោ កាយោ ទិសា ច មេ បក្ខាយន្តិ ធម្មា ច មំ បដិភន្តិ ថីនមិទ្ធញ្ច មេ ចិត្តំ ន បរិយាទាយ តិដ្ឋតិ អភិរតោ ច ព្រហ្មចរិយំ ចរាមិ នត្ថិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។ អថខោ សោ ភិក្ខុ តំ សទ្ធិវិហារិកំ ភិក្ខុំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អយំ ភន្តេ ភិក្ខុ ឯវមាហ ឯតរហិ មេ ភន្តេ ន ចេវ មធុរកជាតោ កាយោ ទិសា ច មេ បក្ខាយន្តិ ធម្មា ច មំ បដិភន្តិ

ហើយបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏ជាព្រះអរហន្តមួយអង្គដែរ ។ លុះភិក្ខុនោះ បានសម្រេចអរហត្តហើយ ក៏ចូលទៅរកឧបជ្ឈាយ៍របស់ខ្លួន លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងឧបជ្ឈាយ៍របស់ខ្លួនយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចំរើន ឥឡូវនេះកាយរបស់ខ្ញុំលែងធ្ងន់ហើយ ទិសទាំងឡាយក៏ប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ខ្ញុំ ថីនមិទ្ធៈក៏លែងគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ សេចក្តីសង្ស័យក្នុងធម៌ទាំង-ឡាយក៏មិនមានដល់ខ្ញុំឡើយ ។ លំដាប់នោះឯង ភិក្ខុនោះបាននាំភិក្ខុជាសទ្ធិវិហារិក នោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះបាននិយាយយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចំរើន ឥឡូវនេះ កាយរបស់ខ្ញុំលែងធ្ងន់ ហើយ ទិសទាំងឡាយក៏ប្រាកដដល់ខ្ញុំ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ខ្ញុំ

ថីនមិទ្ធញ្ច មេ ចិត្តំ ន បរិយាទាយ តិដ្ឋតិ អភិរតោ ច ព្រហ្មចរិយំ ចរាមិ នត្ថិ ច មេ ធម្មេសុ វិចិកិច្ឆាតិ ។ ឯវញ្ហេតំ ភិក្ខុ ហោតិ ។ ឥន្ទ្រិយេសុ គុត្តទ្វារស្ស ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តស្ស វិបស្សកស្ស កុសលានំ ធម្មានំ បុព្វរត្តាបររត្តំ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគំ អនុយុត្តស្ស វិហរតោ យំ ន ចេវ មធុរកជាតោ កាយោ ហោតិ ទិសា ចស្ស បក្ខាយន្តិ ធម្មា ច នំ បដិភន្តិ ថីនមិទ្ធញ្ចស្ស ចិត្តំ ន បរិយាទាយ តិដ្ឋតិ អភិរតោ ច ព្រហ្មចរិយំ ចរតិ ន ចស្ស ហោតិ ធម្មេសុ វិចិកិច្ឆា ។ តស្មាតិហ វោ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឥន្ទ្រិយេសុ គុត្តទ្វារា ភវិស្សាម ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា វិបស្សកា កុសលានំ ធម្មានំ បុព្វរត្តាបររត្តំ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគំ អនុយុត្តា វិហរិស្សាមាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

ថីនមិទ្ធៈក៏លែងគ្របសង្កត់ចិត្តរបស់ខ្ញុំ ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មិនមានដល់ខ្ញុំ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ហេតុនុ៎ះ រមែងមានយ៉ាងហ្នឹងឯង ។ កាលបើភិក្ខុបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណ ក្នុងភោជន ប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ពិចារណា ភាវក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើមនឹងរាត្រីខាងចុង ប្រឹងប្រកបការព្យាយាមចំរើនធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ កាយរបស់ភិក្ខុនោះរមែងមិនធ្ងន់ ទិសទាំងឡាយក៏ប្រាកដដល់ភិក្ខុនោះ ធម៌ទាំងឡាយក៏ជាក់ច្បាស់ដល់ភិក្ខុនោះ ថីនមិទ្ធៈក៏មិនគ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ភិក្ខុនោះប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ ទាំងសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ក៏មិនមានដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះអ្នកទាំងឡាយត្រូវសិក្សា ក្នុងសាសនានេះ យ៉ាងនេះថា ពួកយើងនឹងជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណ ក្នុងភោជនប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ពិចារណា ភាវក នូវពួកធម៌ជាកុសល អស់រាត្រីខាងដើមនឹងរាត្រីខាងចុង ប្រឹងប្រកបការព្យាយាមចំរើនធម៌ទាំងឡាយ ជាចំណែកនៃពោធិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។

(៨៧) បញ្ចិមានិ ភិក្ខវេ ឋានានិ អភិណ្ហំ បច្ចវេក្ខិតព្ពានិ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។ កតមានិ បញ្ច ។ ជរាធម្មោម្ហិ ជរំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្ពំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។ ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្ពំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។ មរណធម្មោម្ហិ មរណំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្ពំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។ សព្ពេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ អភិណ្ហំ បច្ចវេក្ខិតព្ពំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។ កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ អភិណ្ហំ បច្ចវេក្ខិតព្ពំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្ពជិតេន វា ។

(៥៧) ម្នាលភិក្ខុទាំងឡាយ ស្ថាន ៥ យ៉ាងនេះ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ។ ស្ថាន ៥ យ៉ាង តើដូចម្តេច ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ តែងមានសេចក្តីព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ១ ។ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះ ១ ។

កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច ជរាធម្មោម្ហិ ជរំ
អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា
បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។
អត្ថិ ភិក្ខវេ សត្តានំ យោព្វនេ យោព្វនមទោ
យេន មទេន សត្តា កាយេន ទុច្ចរិតំ ចរន្តិ វាចាយ
ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ ។ តស្ស
តណ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ យោ យោព្វនេ
យោព្វនមទោ សោ សព្វសោ វា បហីយតិ តនុ
វា បន ហោតិ ។ ឥទំ ខោ ភិក្ខវេ អត្ថវសំ បដិច្ច
ជរាធម្មោម្ហិ ជរំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ
ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិ-
តេន វា ។ កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច ព្យាធិ-
ធម្មោម្ហិ ព្យាធឹ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ
ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។
អត្ថិ ភិក្ខវេ សត្តានំ អារោគ្យេ អារោគ្យមទោ
យេន មទេន សត្តា កាយេន ទុច្ចរិតំ ចរន្តិ
វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ ។

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹង ក្នុងវ័យដ៏ចំរើន ដែលជាហេតុនាំឲ្យពួកសត្វ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ៗ កាលបើបុគ្គលនោះ ពិចារណាស្ថាននោះរឿយ ៗ ហើយ កិលេសបង់យោព្វនមទៈ (សេចក្តីស្រវឹង ក្នុងវ័យដ៏ចំរើន) ដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ស្រាលស្តើងទៅបាន ៗ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹង ក្នុងភាពនៃខ្លួនជាអ្នកមិនមានរោគ ដែលជាហេតុនាំឲ្យពួកសត្វ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ៗ

តស្ស តដ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ យោ អារោគ្យេ អារោគ្យមទោ សោ សព្វសោ វា បហីយតិ តនុ វា បន ហោតិ ។ ឥទំ ខោ ភិក្ខវេ អត្ថវសំ បដិច្ច ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច មរណធម្មោម្ហិ មរណំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ អត្ថិ ភិក្ខវេ សត្តានំ ជីវិតេ ជីវិតមទោ យេន មទេន សត្តា កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ ។ តស្ស តដ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ យោ ជីវិតេ ជីវិតមទោ សោ សព្វសោ វា បហីយតិ តនុ វា បន ហោតិ ។ ឥទំ ខោ ភិក្ខវេ អត្ថវសំ បដិច្ច មរណធម្មោម្ហិ មរណំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។

កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយ ៗ ហើយ គង់លះបង់អារោគ្យមទៈ (សេចក្តីស្រវឹងក្នុងភាវៈនៃខ្លួនមិនមានរោគ) ដោយសព្វគ្រប់ ឬពុំនោះសោត គង់ស្រាលស្តើងទៅបាន ៗ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹង ក្នុងជីវិតដែលជាហេតុនាំឲ្យពួកសត្វ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ៗ កាលបើបុគ្គលនោះពិចារណានូវស្ថាននោះរឿយ ៗ ហើយ គង់លះបង់ជីវិតមទៈ (សេចក្តីស្រវឹង ក្នុងជីវិត) ដោយសព្វគ្រប់ ឬពុំនោះសោត គង់ស្រាលស្តើងទៅបាន ៗ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ៗ

កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ អត្ថិ ភិក្ខវេ សត្តានំ បិយេសុ ឆន្ទរាគោ យេន រាគេន សត្តា កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ ។ តស្ស តណ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ យោ បិយេសុ ឆន្ទរាគោ សោ សព្វសោ វា បហីយតិ តនុ វា បន ហោតិ ។ ឥទំ ខោ ភិក្ខវេ អត្ថវសំ បដិច្ច សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញ តែងមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានតម្រេកក្រៃលែង ក្នុងសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ដែលជាហេតុនាំឲ្យសត្វ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗហើយ គង់លះបង់នូវរាគ (តម្រេកក្រៃលែង) ក្នុងសត្វនិងសង្ខារដោយសព្វគ្រប់ ឬពុំនោះសោត គង់ស្រាលស្តើងទៅបានៗ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញ មានសេចក្តីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

អត្ថិ ភិក្ខវេ សត្តានំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ តស្ស តណ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ សព្វសោ វា ទុច្ចរិតំ បហីយតិ តនុ វា បន ហោតិ ។ ឥទំ ខោ ភិក្ខវេ អត្ថវសំ បដិច្ច កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ ស ខោ សោ[១] ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ន ខោ អហញ្ញេវេកោ ជរាធម្មោ ជរំ អនតីតោ អថខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេ សត្តា ជរាធម្មា ជរំ អនតីតាតិ តស្ស តណ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ[២]

---

១ ឱ. ម. សចេ សោ ។ ២ ម. សញ្ញោជនានិ សព្វសោ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានកាយទុច្ចរិត វចីទុច្ចរិត មនោ-ទុច្ចរិត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយ ៗ ហើយ គង់លះបង់ទុច្ចរិត ដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ថា អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនោះ តែងពិចារណាថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានជរា ជាធម្មតា មិនកន្លងជរាទៅបាន ទោះបីពួកសត្វដែលមានការទៅកាន់មក ទៅកាន់ទៅ ច្យុតនឹងកើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏តែងមានជរា ជាធម្មតា មិនកន្លងជរាទៅបានដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះរឿយ ៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះ រមែងសេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះ ។ កាលបើ អរិយសាវកនោះ សេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ

បហីយន្តិ អនុសយា ព្យន្តី ហោន្តិ ។ ន ខោ អហញ្ញេវេកោ(១) ព្យាធិធម្មោ ព្យាធឹ អនតីតោ អថ ខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេ សត្តា ព្យាធិធម្មា ព្យាធឹ អនតីតាតិ តស្ស ឋានំ អភិណ្ហំ បច្ចវេក្ខតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តី ហោន្តិ ។ ន ខោ អហញ្ញេវេកោ មរណធម្មោ មរណំ អនតីតោ អថ ខោ យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេ សត្តា មរណធម្មា មរណំ អនតីតាតិ តស្ស ឋានំ អភិណ្ហំ បច្ចវេក្ខតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ ។

---

១ ម. អហញ្ចេវេកោ ។

ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយ ក៏វិនាសទៅ ៗ (អរិយសាវកនោះពិចារណា) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានព្យាធិ ជាធម្មតា មិនកន្លងព្យាធិទៅបាន ទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏មានព្យាធិ ជាធម្មតា មិនកន្លងព្យាធិទៅបានដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះ រឿយ ៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ៗ អរិយសាវកនោះ សេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះ ៗ កាលបើអរិយសាវកនោះ សេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយ ក៏វិនាសទៅ ៗ (អរិយសាវកនោះពិចារណា) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះរឿយ ៗ ហើយ លោកុត្តរមគ្គ ក៏កើតឡើងព្រម ៗ អរិយសាវកនោះ រមែងសេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះ ៗ

តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីក-
រោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តី
ហោន្តិ ។ ន ខោ មយ្ហេវេកស្ស សព្វេហិ បិយេហិ
មនាបេហិ នានាភាវោ វិនាភាវោ អថខោ យាវតា
សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ សព្វេសំ
សត្តានំ បិយេហិ មនាបេហិ នានាភាវោ វិនាភា-
វោតិ តស្ស តដ្ឋានំ អភិណ្ហំ បច្ចវេក្ខតោ មគ្គោ
សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ
ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវ-
យតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ
អនុសយា ព្យន្តី ហោន្តិ ។ ន ខោ អហញ្ញេវេកោ
កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ
កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា
បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អថខោ
យាវតា សត្តានំ អាគតិ គតិ ចុតិ ឧបបត្តិ

កាលបើអរិយសាវកនោះ សេព ចំរើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ ហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិ-លេសទាំងឡាយ ក៏វិនាសទៅ ។ (អរិយសាវកនោះពិចារណា) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្ដីព្រាត់ប្រាសនិរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ទោះពួកសត្វ ដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ មានសេចក្ដីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួងដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាន នោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវកនោះ រមែងសេព ចំរើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ កាលបើអរិយសាវក នោះ សេព ចំរើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោ-ជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយ ក៏វិនាសទៅ ។ (អរិយសាវកនោះពិចារណា) ថា មិនមែនតែអាត្មាអញ តែម្នាក់ឯងទេ ដែលមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្ម ជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើ កម្មណា ទោះល្អក្ដី អាក្រក់ក្ដី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ ទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន

សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តីតិ តស្ស ឋានំ អភិណ្ហំ បច្ចវេក្ខតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តី ហោន្តីតិ ។

ព្យាធិធម្មា ជរាធម្មា អថោ មរណធម្មិនោ
យថា ធម្មា តថា សត្តា[១] ជិគុច្ឆន្តិ បុថុជ្ជនា ។
អហញ្ចេតំ ជិគុច្ឆេយ្យំ ឯវំ ធម្មេសុ បាណិសុ
ន មេតំ បតិរូបស្ស មម ឯវំ វិហារិនោ ។
សោហំ ឯវំ វិហរន្តោ ញត្វា ធម្មំ និរូបធឹ
អារោគ្យេ យោព្វនស្មឹ ជីវិតស្មិញ្ច យេ មទា
សព្វេ មទេ អភិភោស្មិ នេក្ខម្មំ ទដ្ឋុ ខេមតោ ។

---

១ ឱ. ម. សត្តា ។

ពួកសត្វទាំងអស់ ក៏មានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ពួកសត្វនឹងធ្វើកម្មណាទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះដែរ កាលបើអរិយសាវកនោះ ពិចារណានូវស្ថាននោះរឿយ ៗ ហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ៗ អរិយសាវកនោះ រមែងសេព ចំរើន ធ្វើរឿយ ៗ នូវលោកុត្តរមគ្គនោះ ៗ កាលបើអរិយសាវកនោះសេព ចំរើន ធ្វើរឿយ ៗនូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយ ក៏វិនាសទៅ ៗ

ធម៌ទាំងឡាយ គឺព្យាធិធម៌ ជរាធម៌ នឹងមរណធម៌ មាន
នៅយ៉ាងណា ពួកបុថុជ្ជន ជាសប្បុរស រមែងស្អប់ខ្ពើម
យ៉ាងនោះ ៗ កាលបើពួកសត្វ មានសភាវៈយ៉ាងនេះ
ហើយ តថាគតក៏គួរធុញទ្រាន់នឹងសភាវៈនុះ+ដែរ ហេតុនុះ+
មិនមានដល់តថាគត មានសភាពដ៏សមគួរ មានវិហារធម៌
យ៉ាងនេះ ៗ តថាគតនោះ កាលបើនៅយ៉ាងនេះ ក៏ដឹងនូវ
ធម៌ដែលប្រាសចាកឧបធិ បានឃើញបព្វជ្ជាថាជាការក្សេម
គ្របសង្កត់នូវសេចក្តីស្រវឹងទាំងពួង គឺស្រវឹង ក្នុងភាវៈ
នៃខ្លួនជាបុគ្គលមិនមានរោគ ក្នុងវ័យ ក្នុងជីវិតបាន ៗ

តស្ស មេ អហុ ឧស្សាហោ និព្វានំ អភិបស្សតោ
នាហំ ភព្វោ ឯតរហិ កាមានិ បដិសេវិតុំ
អនិវត្តិ ភវិស្សាមិ ព្រហ្មចេរបរាយនោតិ(១) ។

(៥៨) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ មហាវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ តេន ខោ បន សមយេន សម្ពហុលា លិច្ឆវិកុមារកា សជ្ជានិ ធនូនិ អាទាយ កុក្កុរសង្ឃបរិវុតា មហាវនេ អនុចង្កមមានា អនុវិចរមានា អទ្ទសំសុ ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ ទិស្វា សជ្ជានិ ធនូនិ និក្ខិបិត្វា កុក្កុរសង្ឃំ ឯកមន្តំ ឧយ្យោជេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា តុណ្ហីភូតា តុណ្ហីភូតា

---

១ ឱ. ម. ព្រហ្មចរិយបរាយនោតិ ។

សេចក្តីព្យាយាមកើតមានដល់តថាគតនោះ កាលដែលឃើញច្បាស់នូវព្រះនិព្វាន តថាគតមិនគួរដើម្បីសេពកាមទាំងឡាយបានវិញ ក្នុងកាលឥឡូវនេះទេ តថាគតនឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌តទៅ មិនបានត្រឡប់វិញឡើយ ។

(៥៨) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារ-សាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនឹងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចទៅបិណ្ឌ-បាតក្នុងនគរវេសាលី រួចត្រឡប់មកពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តហើយ ស្តេចចូលទៅកាន់មហាវ័ន គង់សម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយដើម ។ សម័យនោះឯង ពួកលិច្ឆវិកុមារច្រើនអង្គ កាន់យកនូវធ្នូដែលខ្លួនដំឡើងហើយមានពួកឆ្កែហោមរោម ដើរសញ្ចរទៅមកក្នុងមហាវ័ន បានឃើញព្រះដ៏មានព្រះភាគ ទ្រង់គង់ក្រោមម្លប់ឈើមួយដើម លុះឃើញហើយ ក៏ដាក់ធ្នូដែលខ្លួនដំឡើងចេញហើយ បញ្ជូនពួកឆ្កែទៅក្នុងទីសមគួរ រួចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ មានសភាពស្ងប់ស្ងៀម

បញ្ជលិកា ភគវន្តំ បយិរុបាសន្តិ ។ តេន ខោ បន សមយេន មហានាមោ លិច្ឆវី មហាវនេ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ អទ្ទស តេ លិច្ឆវិកុមារកេ តរុណេ តរុណេ បញ្ជលិកេ ភគវន្តំ បយិរុបាសន្តេ ទិស្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ លិច្ឆវី ឧទានំ ឧទានេសិ ភវិស្សន្តិ វជ្ជី ភវិស្សន្តិ វជ្ជីតិ ។ កឹ បន ត្វំ មហានាម ឯវំ វទេសិ ភវិស្សន្តិ វជ្ជី ភវិស្សន្តិ វជ្ជីតិ ។ ឥមេ ភន្តេ លិច្ឆវិកុមារកា ចណ្ឌា ផរុសា អបានុភា(១) យានិ តានិ កុលេសុ បហេណកានិ បហីយន្តិ ឧច្ឆូតិ វា ពទរាតិ វា បូវាតិ វា មោទកាតិ វា សង្កុលិកាតិ វា តានិ វិលុម្បិត្វា វិលុម្បិត្វា ខាទន្តិ កុលិត្ថីនំបិ កុលកុមារីនំបិ បច្ឆាលិយំ ខិបន្តិ តេទានិមេ តរុណា តរុណា បញ្ជលិកា ភគវន្តំ បយិរុបាសន្តីតិ ។

---

១ ឱ. អបធិហា ។ ម. អញាន្ធូភា ។

ផ្គងអញ្ជលីចូលទៅអង្គុយជិត ព្រះដ៏មានព្រះភាគ ។ សម័យនោះ មហានាមលិច្ឆវី ដើរសញ្ចរទៅមកសម្រួលស្នងក្នុងមហាវន បានឃើញពួកលិច្ឆវិកុមារទាំងនោះ កំពុងមានភាពស្ងប់ស្ងៀម ផ្គងអញ្ជលីចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ លុះបានឃើញហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះស្តេចមហានាមលិច្ឆវី អង្គុយក្នុងទីសមគួរហើយ ក៏បន្លឺឡើងនូវឧទានថា ពួកស្តេចវជ្ជីនឹងចំរើន ពួកស្តេចវជ្ជីនឹងចំរើន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលមហានាម ចុះក៏បានជានិយាយថា ពួកស្តេចវជ្ជីនឹងចំរើន ពួកស្តេចវជ្ជីនឹងចំរើន យ៉ាងនេះ ។ ស្តេចមហានាមលិច្ឆវី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកលិច្ឆវិកុមារទាំងនេះ ធ្លាប់តែកាចអាក្រក់ រឹងរូស (ពេកណាស់) ដំនួនទាំងឡាយណា ទោះជាអំពៅក្តី ផ្លែពុទ្រាក្តី នំក្តី ត្រប៉ែក្តី ព្រាបលក្តី ដែលគេបញ្ជូនទៅ ចំពោះត្រកូលទាំងឡាយ ក៏ចេះតែប្លន់ដណ្តើមយកស៊ីនូវជំនូនទាំងនោះ (មិនតែប៉ុណ្ណោះថែមទាំងទៅ) ពីខាងក្រោយធាក់ខ្នងពួកស្រីក្នុងត្រកូលខ្លះ នឹងពួកកុមារីក្នុងត្រកូលខ្លះ ឥឡូវនេះ ពួកលិច្ឆវិកុមារទាំងនោះ (បែរជា) មានសភាពស្ងប់ស្ងៀម ផ្គងអញ្ជលីចូលមកអង្គុយជិតព្រះដ៏មានព្រះភាគវិញ ។ ព្រះដ៏មានព្រះភាគត្រាស់ថា

យស្ស កស្សចិ មហានាម កុលបុត្តស្ស បញ្ច ធម្មា សំវិជ្ជន្តិ យទិ វា រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យទិ វា រដ្ឋិកស្ស បេត្តនិកស្ស យទិ វា សេនាយ សេនាបតិកស្ស យទិ វា គាមគាមិកស្ស យទិ វា បូគគាមណិកស្ស យេ វា បន កុលេសុ បច្ចេកាធិបច្ចំ ការេន្តិ វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ ។ កតមេ បញ្ច ។ ឥធ មហានាម កុលបុត្តោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ មាតាបិតរោ សក្ករោតិ គរុករោតិ មានេតិ បូជេតិ ។ តមេនំ មាតាបិតរោ សក្កតា គរុកតា មានិតា បូជិតា កល្យាណេន មនសា អនុកម្បន្តិ ចិរំ ជីវ ទីឃមាយុំ បាលេហីតិ ។ មាតាបិតានុកម្បិតស្ស មហានាម កុលបុត្តស្ស វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ ។

ម្នាលមហានាម ធម៌ទាំងឡាយ ៥ យ៉ាង មានដល់កុលបុត្តណា នីមួយ ទោះជាព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយក្តី ទោះជាអ្នកបរិភោគនូវដែនក្តី បរិភោគនូវសម្បត្តិដែលបិតាឲ្យក្តី ទោះជាសេនាបតីនៃសេនាក្តី ទោះជាម្ចាស់នៃស្រុកក្តី ទោះជាធំជាងពួកក្តី មួយទៀត ពួកជនណា ឲ្យគេធ្វើនូវភាពនៃខ្លួនជាធំដោយឡែក ក្នុងត្រកូលទាំងឡាយ សេចក្តីចំរើនមានប្រាកដដល់ (ជនទាំងឡាយនោះ) មិនបានសាបសូន្យឡើយ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលមហានាម កុលបុត្តក្នុងលោកនេះ ធ្វើសក្ការៈ ធ្វើគារព រាប់អាន បូជាមាតាបិតាដោយភោគៈ ដែលបានដោយការសង្វាតប្រឹងប្រែង ដែលសន្សំមក ដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ មាតាបិតា ដែលកុលបុត្តបានធ្វើសក្ការៈ ធ្វើគារព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្តនោះ ដោយចិត្តដ៏ល្អថា ចូរអ្នករស់នៅ អស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្ត ដែលមាតាបិតាអនុគ្រោះហើយ រមែងមានតែសេចក្តីចំរើនប្រាកដ មិនបានសាបសូន្យឡើយ ។

បុន ចបរំ មហានាម កុលបុត្តោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ បុត្តទារទាសកម្មករបោរិសេ សក្ករោតិ គរុករោតិ មានេតិ បូជេតិ ។ តមេនំ បុត្តទារទាសកម្មករបោរិសា សក្កតា គរុកតា មានិតា បូជិតា កល្យាណេន មនសា អនុកម្បន្តិ ចិរំ ជីវ ទីឃមាយុំ បាលេហីតិ ។ បុត្តទារទាសកម្មករបោរិសានុកម្បិតស្ស មហានាម កុលបុត្តស្ស វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ ។ បុន ចបរំ មហានាម កុលបុត្តោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ ខេត្តកម្មន្តសាមន្តសព្យោហារេ សក្ករោតិ គរុករោតិ មានេតិ បូជេតិ ។ តមេនំ ខេត្តកម្មន្តសាមន្តសព្យោហារា សក្កតា គរុកតា មានិតា បូជិតា កល្យាណេន មនសា អនុកម្បន្តិ ចិរំ ជីវ ទីឃមាយុំ បាលេហីតិ ។

ម្នាលមហានាម មួយទៀត កុលបុត្តធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជានូវកូនប្រពន្ធនិងបុរសជាទាសៈនិងកម្មករទាំងឡាយ ដោយភោគៈ ដែលបានមកដោយការសង្វាតប្រឹងប្រែង ដែលសន្សំមក ដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ កូនប្រពន្ធនិងបុរសជាទាសៈនិងកម្មករទាំងឡាយ ដែលកុលបុត្តបានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្តនោះដោយចិត្តដ៏ល្អថា ចូរអ្នករស់នៅ អស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្ត ដែលកូនប្រពន្ធនិងបុរសជាទាសៈ និងកម្មករទាំងឡាយអនុគ្រោះហើយ សេចក្តីចំរើនមានប្រាកដមិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្តធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជានូវពួកជនជិតខាងនៃស្រែនិងការងាររបស់ខ្លួន និងជនអ្នកពស់ទីដី ដោយភោគៈទាំងឡាយ ដែលបានដោយការសង្វាតប្រឹងប្រែង ដែលសន្សំទុក ដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួកជនជិតខាងនៃស្រែនិងការងារ និងជនអ្នកពស់ទីដី ដែលកុលបុត្តបានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្តនោះដោយចិត្តដ៏ល្អថា អ្នកចូររស់នៅ អស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។

ខេត្តកម្មន្តសាមន្តសព្យោហារានុកម្បិតស្ស មហានាម
កុលបុត្តស្ស វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ ។
បុន ចបរំ មហានាម កុលបុត្តោ ឧដ្ឋានវីរិយាធិ-
គតេហិ ភោគេហិ ពាហាពលបរិចិតេហិ សេទា-
វក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ យា តា ពលិ-
ប្បដិគ្គាហិកា ទេវតា តំ សក្ករោតិ គរុករោតិ
មានេតិ បូជេតិ ។ តមេនំ ពលិប្បដិគ្គាហិកា ទេវតា
សក្កតា គរុកតា មានិតា បូជិតា កល្យាណេន
មនសា អនុកម្បន្តិ ចិរំ ជីវ ទីឃមាយុំ បាលេហីតិ ។
ទេវតានុកម្បិតស្ស មហានាម កុលបុត្តស្ស វុឌ្ឍិយេវ
បាដិកង្ខា នោ បរិហានិ ។ បុន ចបរំ មហានាម
កុលបុត្តោ ឧដ្ឋានវីរិយាធិគតេហិ ភោគេហិ ពាហាព-
លបរិចិតេហិ សេទាវក្ខិត្តេហិ ធម្មិកេហិ ធម្មលទ្ធេហិ
សមណព្រាហ្មណេ សក្ករោតិ គរុករោតិ មានេតិ
បូជេតិ ។ តមេនំ សមណព្រាហ្មណា សក្កតា គរុកតា
មានិតា បូជិតា កល្យាណេន មនសា អនុកម្បន្តិ

ម្នាលមហានាម កាលបើកុលបុត្តដែលពួកជនជិតខាងស្រែ ទីងការងារ ទីងជនអ្នកកាស់ទីដី បានអនុគ្រោះហើយ សេចក្តីចំរើនក៏មានប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្តធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាពួកទេវតា ដែលជាអ្នកទទួលនូវគ្រឿងបូជា ដោយភោគៈដែលបានមក ដោយការសង្វាតប្រឹងប្រែង ដែលសន្សំទុក ដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួកទេវតា ដែលជាអ្នកទទួលគ្រឿងបូជា ដែលកុលបុត្តបានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះនូវកុលបុត្រនោះ ដោយចិត្តដ៏ល្អថា អ្នកចូររស់នៅ រស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ។ ម្នាលមហានាម កាលបើកុលបុត្ត ដែលទេវតាអនុគ្រោះហើយ សេចក្តីចំរើន ក៏មានប្រាកដ មិនបានសាបសូន្យឡើយ ។ ម្នាលមហានាម មួយទៀត កុលបុត្តធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាពួកសមណព្រាហ្មណ៍ ដោយភោគៈដែលបានមក ដោយការសង្វាតប្រឹងប្រែង ដែលសន្សំទុក ដោយកំឡាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ១ ។ ពួកសមណព្រាហ្មណ៍ ដែលកុលបុត្តបានធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជាហើយ រមែងអនុគ្រោះកុលបុត្តនោះ ដោយចិត្តដ៏ល្អថា

ចិរំ ជីវំ ទីឃមាយុំ បាលេហីតិ ។ សមណព្រាហ្មណា-
នុកម្បិតស្ស មហានាម កុលបុត្តស្ស វុឌ្ឍិយេវ
បាដិកង្ខា នោ បរិហានិ ។ យស្ស កស្សចិ
មហានាម កុលបុត្តស្ស ឥមេ បញ្ច ធម្មា សំវិជ្ជន្តិ
យទិ វា រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យទិ
វា រដ្ឋិកស្ស បេត្តនិកស្ស យទិ វា សេនាយ សេនា-
បតិកស្ស យទិ វា គាមគាមិកស្ស យទិ វា បូគគា-
មណិកស្ស យេ វា បន កុលេសុ បច្ចេកាធិបច្ចំ
ការេន្តិ វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានីតិ ។

មាតាបិតុកិច្ចករោ បុត្តទារហិតោ សទា
អន្តោជនស្ស អត្ថាយ យេ ចស្ស អនុជីវិនោ
ឧភិន្នញ្ញេវ អត្ថាយ វទញ្ញូ ហោតិ សីលវា

អ្នកបួសនៅ អស់កាលយូរ ចូររក្សាអាយុឲ្យបានវែង ៗ ម្នាលមហានាម កាលបើកុលបុត្តដែលពួកសមណព្រាហ្មណអនុគ្រោះហើយ សេចក្តីចំរើនក៏មានប្រាកដ មិនបានសាបសូន្យឡើយ ៗ ម្នាលមហានាម ធម៌ទាំង ៥ យ៉ាងនេះ មានដល់កុលបុត្តណានីមួយ ទោះជាព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយក្តី ទោះជាអ្នកបរិភោគនូវដែនក្តី បរិភោគនូវសម្បត្តិដែលបិតាឲ្យក្តី ទោះជាសេនាបតីនៃសេនាក្តី ទោះជាម្ចាស់នៃស្រុកក្តី ទោះជាធំជាងពួកក្តី មួយវិញទៀត ពួកជនណាដែលឲ្យគេធ្វើនូវភាពនៃខ្លួនជាធំដោយឡែក ក្នុងត្រកូលទាំងឡាយ សេចក្តីចំរើនមានប្រាកដដល់ (ជនទាំងឡាយនោះ) មិនបានសាបសូន្យទៅឡើយ ៗ

កុលបុត្តអ្នកធ្វើកិច្ចជំនួសមាតាបិតា ទំនុកបំរុងកូនទីងប្រពន្ធសព្វៗ កាល ប្រតិបត្តិជាប្រយោជន៍ដល់ជនទាំង ២ ពួក គឺជាប្រយោជន៍ដល់ជនក្នុងផ្ទះ ទីងជនដែលចូលមកជ្រកអាស្រ័យចិញ្ចឹមជីវិត ជាអ្នកដឹងនូវពាក្យពេចន៍នៃសូម ជាអ្នកមានសីល

ញាតីនំ បុព្វបេតានំ    និច្ចេ ធម្មេ ច ជីវិតំ
សមណានំ ព្រាហ្មណានំ    ទេវតានញ្ច បណ្ឌិតោ
វិត្តិសញ្ជននោ ហោតិ    ធម្មេន ឃរមាវសំ
សោ ការិត្វាន កល្យាណំ    បុជ្ជោ ហោតិ បសំសិយោ
ឥធេវ នំ បសំសន្តិ    បេច្ច សគ្គេ បមោទតីតិ ។

(៤៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ទុល្លភោ វុឌ្ឍបព្វជិតោ ។ កតមេហិ បញ្ចហិ ។ ទុល្លភោ ភិក្ខវេ វុឌ្ឍបព្វជិតោ និបុណោ ទុល្លភោ អាកប្បសម្បន្នោ ទុល្លភោ ពហុស្សុតោ ទុល្លភោ ធម្មកថិកោ ទុល្លភោ វិនយធរោ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ទុល្លភោ វុឌ្ឍបព្វជិតោតិ ។

ជាបណ្ឌិតគ្រប់គ្រងផ្ទះ ប្រកបដោយធម៌ ធ្វើអម្ណរឲ្យកើតដល់ពួកញាតិដែលទៅកាន់បរលោក ពួកញាតិដែលកំពុងរស់នៅក្នុងបច្ចុប្បន្ន ពួកសមណៈ ពួកព្រាហ្មណ៍ នឹងពួកទេវតា កុលបុត្តនោះ លុះបានធ្វើអំពើល្អហើយ រមែងជាបុគ្គលគួរបូជា គួរសរសើរ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវកុលបុត្តនោះ ក្នុងលោកនេះឯង កុលបុត្តនោះលុះលះលោកនេះទៅហើយ រមែងត្រេកអរ ក្នុងស្ថានសួគ៌ ។

(៤៩) ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត (អ្នកបួសខាងចាស់) ប្រកបដោយធម៌ ៥ យ៉ាង រកបានដោយក្រ ។ វុឌ្ឍបព្វជិត ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ជាអ្នកមានបញ្ញាល្អិតល្អ រកបានដោយក្រ ១ ជាអ្នកបរិបូណ៌ដោយមារយាទល្អ រកបានដោយក្រ ១ ជាអ្នកចេះដឹងច្រើន រកបានដោយក្រ ១ ជាអ្នកចេះសំដែងធម៌ រកបានដោយក្រ ១ ជាអ្នកទ្រទ្រង់វិន័យ រកបានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត (អ្នកបួសខាងចាស់) ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រកបានដោយក្រ ។

(៦០) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ទុល្លភោ វុឌ្ឍបព្វជិតោ ។ កតមេហិ បញ្ចហិ ។ ទុល្លភោ ភិក្ខវេ វុឌ្ឍបព្វជិតោ សុវចោ ទុល្លភោ សុគ្គហិតគ្គាហី ទុល្លភោ បទក្ខិណគ្គាហី ទុល្លភោ ធម្មកថិកោ ទុល្លភោ វិនយធរោ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ទុល្លភោ វុឌ្ឍបព្វជិតោតិ ។

នីវរណវគ្គោ បឋមោ ។

## តស្សុទ្ទានំ

អាវរណំ រាសិ អង្គានិ
សមយំ មាតុបុត្តិកា
ឧបជ្ឈាឋានកុមារា
លិច្ឆវី អបរេ ទុវេតិ ។

[៦០] ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត (អ្នកបួសឯចាស់) ប្រកប ដោយធម៌ ៥ យ៉ាង រកបានដោយក្រ ។ វុឌ្ឍបព្វជិត ប្រកប ដោយធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ដែលប្រដៅងាយ រកបានដោយក្រ ១ ជាអ្នកប្រកាន់ល្អ រកបាន ដោយក្រ ១ ជាអ្នកទទួលយកនូវខាងស្តាំ រកបានដោយក្រ ១ ជា អ្នកចេះសំដែងធម៌ រកបានដោយក្រ ១ ជាអ្នកទ្រទ្រង់វិន័យ រកបាន ដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍបព្វជិត ប្រកប ដោយធម៌ ៥ យ៉ាងនេះឯង រកបានដោយក្រ ។

ចប់ និវរណវគ្គ ទី ១ ។

## ឧទ្ទាននៃនិវរណវគ្គនោះ គឺ

និយាយអំពីអាវរណធម៌ ១ គំនរអកុសល ១ អង្គនៃបធាន ១ សម័យដើម្បីព្យាយាម ១ ភិក្ខុនី ជាមាតានឹងភិក្ខុ ជាបុត្រ ១ ភិក្ខុ ១ រូបអផ្សុកប្រាប់ហេតុដល់ឧបជ្ឈាយ៍ ១ ស្ថាន ៥ យ៉ាង ដែលគួរពិចារណារឿយ ៗ ១ លិច្ឆវិកុមារ ១ វុឌ្ឍបព្វជិត ប្រកបដោយធម៌ ៥ យ៉ាង ដទៃទៀត ពីរលើក រកបាន ដោយក្រ ១ ។

# សញ្ញាវគ្គោ

(៦១) បញ្ចិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា បញ្ច ។ អសុភសញ្ញា មរណសញ្ញា អាទីនវសញ្ញា(១) អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា ។ ឥមា ខោ ភិក្ខវេ បញ្ច សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

(៦២) បញ្ចិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា បញ្ច ។ អនិច្ចសញ្ញា

---

១ អនិច្ចសញ្ញា អនត្តសញ្ញា មរណសញ្ញាតិបិ បាឋោ ។

# សញ្ញាវគ្គ

[៦១] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះ ដែលបុគ្គលចំរើន ធ្វើឲ្យច្រើន ៗ ហើយមានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៥ យ៉ាង តើដូចម្តេច ។ គឺអសុភសញ្ញា (សេចក្តីសំគាល់ថាមិនល្អ) ១ មរណសញ្ញា (សេចក្តីសំគាល់នូវសេចក្តីស្លាប់) ១ អាទីនវសញ្ញា (សេចក្តីសំគាល់ថាជាទោស) ១ អាហារេ បដិកូលសញ្ញា (សេចក្តីសំគាល់នូវអាហារថាជាបដិកូល) ១ សព្វលោកេ អនភិរតសញ្ញា (សេចក្តីសំគាល់ថាមិនគួរត្រេកត្រអាលនូវលោកទាំងពួង) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយមានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។

[៦២] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៥ យ៉ាង តើដូចម្តេច ។ គឺ អនិច្ចសញ្ញា (សេចក្តីសំគាល់ថាមិនទៀង) ១

អនត្តសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា ។ ឥមា ខោ ភិក្ខវេ បញ្ច សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

(៦៣) បញ្ចហិ ភិក្ខវេ វឌ្ឍីហិ វឌ្ឍមានោ អរិយសាវកោ អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយី ច ហោតិ វរាទាយី ច កាយស្ស ។ កតមាហិ បញ្ចហិ ។ សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ សុតេន វឌ្ឍតិ ចាគេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ ឥមាហិ ខោ ភិក្ខវេ បញ្ចហិ វឌ្ឍីហិ វឌ្ឍមានោ អរិយសាវកោ អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយី ច ហោតិ វរាទាយី ច កាយស្សាតិ ។

អនត្តសញ្ញា (សេចក្តីសំគាល់ថាមិនមែនខ្លួន)១ មរណសញ្ញា (សេចក្តីសំគាល់ក្នុងសេចក្តីស្លាប់)១ អាហារេ បដិកូលសញ្ញា (សេចក្តីសំគាល់ក្នុងអាហារថាជាបដិកូល)១ សព្វលោកេ អនភិរតសញ្ញា (សេចក្តីសំគាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង)១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ មានផលច្រើន មានអានិសង្សច្រើន មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាទីបំផុត ។

(៦៣) ម្នាលភិក្ខុទាំងឡាយ អរិយសាវក កាលចំរើន ដោយសេចក្តីចំរើន៥យ៉ាង ឈ្មោះថា ចំរើន ដោយសេចក្តីចំរើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់កាយ ។ អរិយសាវក ចំរើនដោយសេចក្តីចំរើន ៥ យ៉ាង តើដូចម្តេច ។ គឺចំរើនដោយសទ្ធា១ ចំរើនដោយសីល១ ចំរើនដោយសុតៈ១ ចំរើនដោយចាគៈ១ ចំរើនដោយបញ្ញា១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក កាលចំរើនដោយសេចក្តីចំរើន៥យ៉ាងនេះឯង ឈ្មោះថា ចំរើនដោយសេចក្តីចំរើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់កាយ ។

សទ្ធាយ សីលេន ច យោ បវឌ្ឍតិ
បញ្ញាយ ចាគេន សុតេន ចូភយំ
សោ តាទិសោ សប្បុរិសោ វិចក្ខណោ
អាទីយតិ សារមិធេវ អត្តនោ ។

(៦៤) បញ្ចហិ ភិក្ខវេ វឌ្ឍីហិ វឌ្ឍមានា អរិយសាវិកា អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទា-យិនី ច ហោតិ វរាទាយិនី ច កាយស្ស ។ កតមាហិ បញ្ចហិ ។ សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ សុតេន វឌ្ឍតិ ចាគេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ ឥមាហិ ខោ ភិក្ខវេ បញ្ចហិ វឌ្ឍីហិ វឌ្ឍមានា អរិយសាវិកា អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយិនី ច ហោតិ វរាទាយិនី ច កាយស្សាតិ ។

បុគ្គលណា ចំរើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ ដោយបញ្ញា បុគ្គលប្រាកដដូច្នោះនោះ ឈ្មោះថាជា សប្បុរសមានប្រាជ្ញាជាគ្រឿងពិចារណា រមែងកាន់យកនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍មានខ្លឹម និងប្រយោជន៍ដ៏ឧត្តមដល់ខ្លួនក្នុងលោកនេះបាន ។

[៦៤] ម្នាលភិក្ខុទាំងឡាយ អរិយសាវិកា កាលចំរើនដោយសេចក្តីចំរើន ៥ យ៉ាង ឈ្មោះថា ចំរើនដោយសេចក្តីចំរើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់កាយ ។ អរិយសាវិកា ចំរើនដោយសេចក្តីចំរើន ៥ យ៉ាង តើដូចម្តេច ។ គឺចំរើនដោយសទ្ធា ១ ចំរើនដោយសីល ១ ចំរើនដោយសុតៈ ១ ចំរើនដោយចាគៈ ១ ចំរើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវិកា ចំរើនដោយសេចក្តីចំរើន ៥ យ៉ាងនេះឯង ឈ្មោះថា ចំរើនដោយសេចក្តីចំរើនដ៏ប្រសើរ ទាំងឈ្មោះថា កាន់យកនូវប្រយោជន៍មានខ្លឹម ព្រមទាំងកាន់យកនូវប្រយោជន៍ដ៏ឧត្តមដល់កាយ ។

សទ្ធាយ សីលេន ច យា បវឌ្ឍតិ
បញ្ញាយ ចាគេន សុតេន ចូភយំ
សា តាទិសី សីលវតី ឧបាសិកា
អាទីយតិ សារមិធេវ អត្តនោតិ ។

(៦៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាកច្ឆោ សព្រហ្មចារីនំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ.

ស្ត្រីណា ចំរើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ ដោយបញ្ញា ស្ត្រីប្រាកដដូច្នោះនោះ ឈ្មោះថា ជាឧបាសិកាមានសីល រមែងកាន់យកនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍មានខ្លឹម និងប្រយោជន៍ដ៏ឧត្តមដល់ខ្លួនក្នុងលោកនេះបាន ។

(៦៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា គួរដល់ការសាកសួររបស់សព្រហ្មចារីទាំងឡាយ ។ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមក ក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមក ក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយប្រាជ្ញាដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមក ក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមក ក្នុងវិមុត្តិសម្បទាកថា ១

អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញាណទស្សនសម្បទាកថាយ ច អាគតំ បញ្ហំ ព្យាកត្តា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាកច្ឆោ សព្រហ្មចារីនន្តិ ។

(៦៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាជីវោ សព្រហ្មចារីនំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញាណទស្សនសម្បទាកថាយ ច កតំ បញ្ហំ ព្យាកត្តា ហោតិ ។

បរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ ដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលមានមក គឺវិមុត្តិញ្ញាណទស្សនកថា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា គួរដល់ការសាកសួររបស់សព្រហ្មចារីទាំងឡាយ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរដល់សាជីវៈ (ការសួរប្រស្នានិងការដោះប្រស្នា) របស់សព្រហ្មចារីទាំងឡាយបាន ។ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនគាត់តែងទុក គឺសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិដោយខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលខ្លួនគាត់តែងទុក គឺសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនគាត់តែងទុក គឺបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនគាត់តែងទុក គឺវិមុត្តិសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈដោយខ្លួនឯង ទាំងបានព្យាករនូវប្រស្នាដែលខ្លួនគាត់តែងទុក គឺវិមុត្តិញ្ញាណទស្សនសម្បទាកថា ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំសាជីវោ សព្រហ្មចារីនន្តិ ។

(៦៧) យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា បញ្ច ធម្មេ ភាវេតិ បញ្ច ធម្មេ ពហុលីករោតិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិ- ចិត្តសមាធិ- វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឧស្សោឡ្ហិញ្ញេវ បញ្ចមី ។ យោ ហិ កោចិ ភិក្ខវេ ភិក្ខុ វា ភិក្ខុនី វា ឥមេ បញ្ច ធម្មេ ភាវេតិ ឥមេ បញ្ច ធម្មេ ពហុលីករោតិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៩ នេះឯង ទើបគួររស់សាជីវៈរបស់សព្រហ្មចារីទាំងឡាយបាន ។

(៦៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុ ភិក្ខុនី ចំរើនធម៌ ៩ យ៉ាង ធ្វើឲ្យច្រើន ៗ នូវធម៌ ៩ យ៉ាង បណ្ដាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេច ដល់បុគ្គលនោះ គឺជានឹងបានសម្រេចនូវការៈ ជាព្រះអរហន្ត ក្នុងបច្ចុប្បន្ន ទាន់ភ្នែក ពុំនោះសោត បើមានឧបាទិសេសៈសល់នៅ ក៏គង់នឹងបានសម្រេចនូវការៈជាអនាគាមិបុគ្គលពុំខានឡើយ ។ ធម៌ ៩ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ - ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ទាំងប្រឹងចំរើននូវការព្យាយាមដ៏លើសលុបជាគំរប់ ៩ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុ ភិក្ខុនី ចំរើនធម៌ ៩ យ៉ាងនេះ ធ្វើឲ្យច្រើន ៗ នូវធម៌ ៩ យ៉ាងនេះ បណ្ដាផលទាំងពីរ ផលណាមួយ

បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

(៦៨) បុព្វាហំ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ បញ្ច ធម្មេ ភាវេសឹ បញ្ច ធម្មេ ពហុលិមកាសឹ ។ កតមេ បញ្ច ។ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេសឹ វីរិយសមាធិ- ចិត្តសមាធិ- វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេសឹ ឧស្សោឡ្ហិញ្ញេវ បញ្ចមឹ ។ សោ ខោ អហំ ភិក្ខវេ ឥមេសំ ឧស្សោឡ្ហិបញ្ចមានំ ធម្មានំ ភាវិតត្តា ពហុលីកតត្តា យស្ស យស្ស អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេសឹ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណឹ សតិ សតិ អាយតនេ ។

គង់នឹងបានសម្រេច ដល់បុគ្គលនោះ គឺថានឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្លក ពុំនោះសោត បើមានឧបាទិសេសៈសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គលពុំខានឡើយ ។

(៦៨) ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន អំពីកាលត្រាស់ដឹង តថាគតនៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ បានចំរើននូវធម៌ ៤ យ៉ាង បានធ្វើឲ្យរឿយៗ នូវធម៌ ៤ យ៉ាង ។ ធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺតថាគតបានចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចំរើននូវឥទ្ធិបាទប្រកបដោយវីរិយសមាធិ - ចិត្តសមាធិ-វីមំសាសមាធិ និងបធានសង្ខារ ទាំងប្រឹងចំរើននូវការព្យាយាមដ៏លើសលុបជាគំរប់ ៤ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតបានចំរើន បានធ្វើឲ្យរឿយៗ នូវធម៌ដែលមានការព្យាយាមដ៏លើសលុបជាគំរប់ ៤ នេះ ទើបតថាគតនោះ បានបង្អោនចិត្តទៅដើម្បីធម៌ណាៗ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម កាលបើហេតុមាន ក៏បានដល់នូវភាវៈជាបន្ទាល់ ក្នុងការធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមក្នុងធម៌នោះៗ ឯង ។

សោ សចេ អាកង្ខី អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ។បេ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខី ។បេ។ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេតិ ។

(៦៩) បញ្ចិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា

បើតថាគតនោះ ប្រាថ្នាថា សូមឲ្យតថាគត បាននូវការតាក់តែងឫទ្ធិជាច្រើនប្រការ ។បេ។ ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោក កាលបើហេតុមាន តថាគតក៏បានដល់នូវភាវៈជាបន្ទាល់ ក្នុងការតាក់តែងឫទ្ធិនោះៗ ។ បើតថាគតនោះប្រាថ្នាថា ។បេ។ សូមឲ្យតថាគត បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ កាលបើហេតុមាន តថាគតក៏បានដល់នូវភាវៈជាបន្ទាល់ ក្នុងការបានសម្រេចនូវគុណវិសេសនោះៗ ។

(៦៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្ដីរលត់ដោយមិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ធម៌ ៥ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយៗថា មិនស្អាតក្នុងកាយ ១ សំគាល់ថា គួរខ្ពើមក្នុងអាហារ ១ សំគាល់ថា មិនគួរត្រេកត្រអាល ក្នុងលោកទាំងពួង ១ ឃើញរឿយៗ ថា មិនទៀងក្នុងសង្ខារទាំងពួង ១ ទាំងមរណសញ្ញា

ខោ បនស្ស អជ្ឈត្តំ សូបដ្ឋិតា ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

[៧០] បញ្ចិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សូបដ្ឋិតា ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តន្តីតិ ។

សញ្ញាវគ្គោ ទុតិយោ ។

ក៏ប្រាកដឡើងខាងក្នុងចិត្តរបស់ភិក្ខុនោះ ដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់មិនសល់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

[៧០] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ដែលភិក្ខុបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយ ៗ ថា មិនស្អាតក្នុងកាយ ១ សំគាល់ថា គួរខ្ពើមក្នុងអាហារ ១ សំគាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង ១ ឃើញរឿយ ៗ ថា មិនទៀងក្នុងសង្ខារទាំងពួង ១ ទាំងមរណសញ្ញា ក៏ប្រាកដឡើង ខាងក្នុងចិត្តរបស់ភិក្ខុនោះ ដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលភិក្ខុបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ចប់ សញ្ញាវគ្គទី ២ ។

## តស្សុទ្ទានំ

ទ្វេ ច សញ្ញា ទ្វេ វឌ្ឍី ច
សាកច្ឆេន ច សាជីវំ
ឥទ្ធិបាទា ច ទ្វេ វុត្តា
និព្វិទា ចាសវក្ខយាតិ ។

# ឧទ្ទាននៃសញ្ញាវគ្គនោះគឺ

និយាយអំពីសញ្ញាពីរលើក ១ សេចក្តីចំរើនពីរលើក ១ កិច្ចគួរដល់ការសាកសួរ ១ កិច្ចគួរដល់សាជីវៈ ១ ឥទ្ធិបាទដែលបានពោលពីរលើក ១ ធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ១ ធម៌ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈ ១ ។

# យោធាជីវវគ្គោ

(៧១) បញ្ចិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា ចេតោវិមុត្តិផលា ច ហោន្តិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោន្តិ បញ្ញាវិមុត្តិផលានិសំសា ច ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី(១) វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សូបដ្ឋិតា ហោតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា ភាវិតា ពហុលីកតា ចេតោវិមុត្តិផលា ច ហោន្តិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោន្តិ បញ្ញាវិមុត្តិផលានិសំសា ច ។ យតោ ខោ ភិក្ខវេ ភិក្ខុ ចេតោវិមុត្តោ ច ហោតិ បញ្ញាវិមុត្តោ ច អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ឥតិបិ សង្កិណ្ណបរិក្ខោ ឥតិបិ

---

១ ឱ. ម. ឯត្ថន្តរេ កាយេតិ ទិស្សតិ ។

# យោធាជីវវគ្គ

(៧១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងមានចេតោវិមុត្តិ ជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិសង្សផង ។ ធម៌ទាំង ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ ថា មិនស្អាត (ក្នុងរូបកាយ) ១ មានសេចក្តីសំគាល់ថាជាបដិកូល ក្នុងអាហារ ១ មានសេចក្តីសំគាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង ១ ពិចារណាឃើញរឿយ ៗ ថា មិនទៀងក្នុងសង្ខារទាំងពួង ១ សេចក្តីសំគាល់ក្នុងមរណៈ ភិក្ខុនោះក៏បានដំកល់ទុកដោយប្រពៃ ខាងក្នុងសន្តាន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងមានចេតោវិមុត្តិ ជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិសង្សផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុបានចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ខលឹកឡើងនូវដើងគុលគឺអវិជ្ជាដូច្នេះខ្លះ ថា បំផ្លបបំផ្លាញនូវគូគឺសង្សារវដ្តដូច្នេះខ្លះ

អព្វូឡ្ហេសិកោ ឥតិបិ និរគ្គឡោ ឥតិបិ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ឥតិបិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អវិជ្ជា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹ អនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ បោនោព្ភវិកោ ជាតិសំសារោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹ អនុប្បាទធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។

ថា ដកឡើងនូវសសរគឺតណ្ហាដូច្នេះខ្លះ ថា បើកនូវសន្ទះទ្វារគឺនីវរណៈដូច្នេះខ្លះ ថា ប្រាសចាកសត្រូវ រំលើងនូវទង់គឺមានះ ទំលាក់នូវភារៈ ប្រាសចាកវដ្តៈដូច្នេះខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលហៅថា លើកឡើងនូវដើមគល់គឺអវិជ្ជា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជាចោលចេញហើយ បានកាត់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលើកឡើងនូវដើមគល់គឺអវិជ្ជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបំផ្លេចបំផ្លាញនូវគូ គឺសង្សារវដ្ត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិនិងសង្សារ ដែលសម្រាប់កាត់តែងនូវភពថ្មីទៀតចោលចេញហើយ បានកាត់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបំផ្លេចបំផ្លាញនូវគូ គឺសង្សារវដ្ត យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដកឡើងនូវសសរគឺតណ្ហា តើដូចម្ដេច ។

កថញ្ច ភិក្ខវេ ភិក្ខុ អព្វូឡ្ហេសិកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អព្វូឡ្ហេសិកោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវំ កតានិ អាយតឹអនុប្បាទធម្មានិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់តណ្ហាចោលចេញអស់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យទៅសល់តែទីទៅ ដូចជាទីទៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដកឡើងនូវសសរ គឺតណ្ហា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបើកនូវសន្ទះទ្វារគឺនីវរណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ចោលចេញហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យទៅសល់តែទីទៅ ដូចជាទីទៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបើកនូវសន្ទះទ្វារគឺនីវរណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រាសចាកសត្រូវជាក់ចុះនូវទង់គឺមានះ ទំលាក់ចោលនូវភារៈ ប្រាសចាកវដ្ដៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអស្មិមានះចោលចេញអស់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យទៅសល់តែទីទៅ ដូចជាទីទៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតីតិ ។

(៧២) បញ្ចិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា ចេតោវិមុត្តិផលា ច ហោន្តិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោន្តិ បញ្ញាវិមុត្តិផលានិសំសា ច ។ កតមេ បញ្ច ។ អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា ភាវិតា ពហុលីកតា ចេតោវិមុត្តិផលា ច ហោន្តិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោន្តិ បញ្ញាវិមុត្តិផលានិសំសា ច ។ យតោ ខោ ភិក្ខវេ ភិក្ខុ ចេតោវិមុត្តោ ច ហោតិ បញ្ញាវិមុត្តោ ច អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ឥតិបិ សង្កិណ្ណបរិក្ខោ ឥតិបិ អព្វូឡ្ហេសិកោ ឥតិបិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់គឺមានះ ទំលាក់ចោលនូវភារៈ ប្រាសចាកវដ្ដៈ យ៉ាងនេះឯង ។

(៧២) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងមានចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិសង្សផង ។ ធម៌ទាំង ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសេចក្ដីសំគាល់ថាជារបស់មិនទៀង ១ សេចក្ដីសំគាល់ថា ជាទុក្ខក្នុងរបស់ដែលមិនទៀង ១ សេចក្ដីសំគាល់ថាមិនមែនខ្លួន ក្នុងរបស់ដែលជាទុក្ខ ១ សេចក្ដីសំគាល់ក្នុងការលះបង់ ១ សេចក្ដីសំគាល់ក្នុងការប្រាសចាករាគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងមានចេតោវិមុត្តិជាផលផង មានចេតោវិមុត្តិផល ជាអានិសង្សផង មានបញ្ញាវិមុត្តិ ជាផលផង មានបញ្ញាវិមុត្តិផល ជាអានិសង្សផង ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុបានចេតោវិមុត្តិ ទាំងបញ្ញាវិមុត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា លើកឡើងនូវជើងគុលគឺអវិជ្ជាដូច្នេះខ្លះ ថា បំផុតបំផ្លាញនូវគូគឺសង្សារវដ្ដដូច្នេះខ្លះ ថា ដកឡើងនូវសសរគឺតណ្ហាដូច្នេះខ្លះ

និរគ្គឡោ ឥតិបិ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ឥតិបិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អវិជ្ជា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹ-អនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឧក្ខិត្តបលិឃោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ពោនោព្ភវិកោ ជាតិសំសារោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលា-វត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សង្កិណ្ណបរិក្ខោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អព្ពូឡ្ហេសិកោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា

ថា បើកនូវសន្ទះទ្វារគឺនីវរណៈដូច្នេះ ថា ប្រាសចាកសត្រូវ ដាក់ចុះនូវទង់គឺមានះទំលាក់នូវភារៈប្រាសចាកវដ្ដៈដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកលើកឡើងនូវដើងគុលគឺអវិជ្ជា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជាចោលចេញហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលើកឡើងនូវដើងគុលគឺអវិជ្ជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបំផ្លេចបំផ្លាញនូវគូគឺសង្សារវដ្ដ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិទឹងសង្សារ ដែលសម្រាប់គាត់តែងនូវភពថ្មីទៀតចោលចេញហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបំផ្លេចបំផ្លាញនូវគូគឺសង្សារវដ្ដ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដកឡើងនូវសសរគឺតណ្ហា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់តណ្ហា ចោលចេញហើយ បានគាស់រំលើងឫសគល់អស់ហើយ

តាលាវត្ថុកតា អនភាវំកតា អាយតឹអនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អព្ពុឡ្ហេសិកោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ឥធ ភិក្ខវេ ភិក្ខុនោ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវំកតានិ អាយតឹ អនុប្បាទធម្មានិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ និរគ្គឡោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំកតោ អាយតឹ អនុប្បាទធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ ហោតីតិ ។

បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដកឡើងនូវសសរគឺតណ្ហា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបើកនូវសន្ទះទ្វារគឺនីវរណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ចោលចេញហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់គឺមានះ ទំលាក់នូវភារៈ ប្រាសចាកវដ្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអស្មិមានះចោលចេញអស់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាសចាកសត្រូវ ដាក់ចុះនូវទង់គឺមានះ ទំលាក់នូវភារៈ ប្រាសចាកវដ្តៈ យ៉ាងនេះឯង ។

(៧៣) អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មវិហារី ធម្មវិហារីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ(១) ធម្មវិហារី ហោតីតិ ។ ឥធ ភិក្ខុ(២) ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ។ សោ តាយ ធម្មបរិយត្តិយា ទិវសំ អតិនាមេតិ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ ។ អយំ វុច្ចតិ ភិក្ខុ បរិយត្តិពហុលោ នោ ធម្មវិហារី ។ បុន ចបរំ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ ។ សោ តាយ ធម្មប្បញ្ញត្តិយា ទិវសំ អតិនាមេតិ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ ។

---

១ ឱ. ម. ភន្តេ ភិក្ខុ ។ ២ ឱ. ឥធ ភិក្ខុ ភិក្ខុ ។

(៧៣) គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះញ៉ាំងថ្ងៃឲ្យកន្លងទៅ ដោយការរៀននូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកមានប្រក្រតីនៅដោយធម៌ទេ ។ មួយទៀត ភិក្ខុសំដែងធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដល់បុគ្គលទាំងឡាយដទៃ ដោយសេចក្តីពិស្តារ ភិក្ខុនោះញ៉ាំងថ្ងៃឲ្យកន្លងទៅ ដោយការបញ្ញត្តិនូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។

អយំ វុច្ចតិ ភិក្ខុ បញ្ញត្តិពហុលោ នោ ធម្មវិហារី ។ បុន ចបរំ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ ។ សោ តេន សជ្ឈាយេន ទិវសំ អតិនាមេតិ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ ។ អយំ វុច្ចតិ ភិក្ខុ សជ្ឈាយពហុលោ នោ ធម្មវិហារី ។ បុន ចបរំ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ ។ សោ តេហិ ធម្មវិតក្កេហិ ទិវសំ អតិនាមេតិ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោ-សមថំ ។ អយំ វុច្ចតិ ភិក្ខុ វិតក្កពហុលោ នោ ធម្មវិហារី ។ ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ។ សោ តាយ ធម្មបរិយត្តិយា ន ទិវសំ អតិនាមេតិ ន រិញ្ចតិ បដិសល្លានំ អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ ។

ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបញ្ញត្តិ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។ មួយទៀត ភិក្ខុធ្វើនូវការស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដោយសេចក្តីពិស្តារ ។ ភិក្ខុនោះ ញុំាងថ្ងៃឲ្យកន្លងទៅ ដោយការស្វាធ្យាយនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយការស្វាធ្យាយ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។ មួយទៀត ភិក្ខុត្រិះរិះពិចារណាដោយចិត្ត ដញ្ជឹងដោយចិត្ត ចំពោះធម៌តាមទំនង ដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ។ ភិក្ខុនោះ ញុំាងថ្ងៃឲ្យកន្លងទៅ ដោយការត្រិះរិះនូវធម៌ទាំងនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយសេចក្តីត្រិះរិះនូវធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ភិក្ខុនោះ មិនបានញុំាងថ្ងៃឲ្យកន្លងទៅ ដោយការរៀននូវធម៌នោះ មិនលះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ ប្រកបរឿយ ៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។

ឯវំ ខោ ភិក្ខុ ធម្មវិហារី ហោតិ ។ ឥតិ ខោ ភិក្ខុ ទេសិតោ មយា បរិយត្តិពហុលោ ទេសិតោ បញ្ញត្តិ-ពហុលោ ទេសិតោ សជ្ឈាយពហុលោ ទេសិតោ វិតក្កពហុលោ ទេសិតោ ធម្មវិហារី ។ យំ ភិក្ខុ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខុ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថ ភិក្ខុ មា បមាទត្ថ មា បច្ឆា វិប្បដិ-សារិនោ អហុវត្ថ អយំ វោ អម្ហាកំ អនុសាសនីតិ ។

ភិក្ខុជាអ្នកនៅដោយធម៌យ៉ាងនេះឯង ។ ភិក្ខុជាអ្នកច្រើនដោយការរៀន តថាគតបានសំដែងហើយ អ្នកច្រើនដោយការបញ្ញត្តិ តថាគតបានសំដែងហើយ អ្នកច្រើនដោយការស្វាធ្យាយ តថាគតបានសំដែងហើយ អ្នកច្រើនដោយការត្រិះរិះ តថាគតបានសំដែងហើយ អ្នកមានប្រក្រតីនៅដោយធម៌ តថាគតបានសំដែងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុ អំពើណាដែលសាស្តា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គួរធ្វើដល់សាវកទាំងឡាយ អំពើនោះតថាគតក៏បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុ ទី+នុះ ជារុក្ខមូលសេនាសនៈ ទី+នុះជាសុញ្ញាគារសេនាសនៈ ។ អ្នកទាំងឡាយចូរចំរើន (នូវសមថៈនិងវិបស្សនា) អ្នកទាំងឡាយចូរកុំប្រមាទ អ្នកទាំងឡាយ ចូរកុំមានសេចក្តីក្តៅក្រហាយ(១) ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។

---

១ កាលពីដើមខ្លួននៅក្មេង ពុំទាន់មានរោគមកបៀតបៀន ច្រើនតែសប្បាយភ្លេចខ្លួន ដោយការស៊ីផឹក ទោះបានជួបនឹងព្រះសាស្តាជាម្ចាស់ ក៏មិនបានយកចិត្តទុកដាក់ ចូលចិត្តតែខាងដេកទាំងយប់ទាំងថ្ងៃឲ្យសង្កើចខាំឥតអំពើ ច្រើនធ្វេសប្រហែស (ឥតបាននឹកនាត្រង់ការកុសលណាមួយសោះ) លុះវេលាខាងក្រោយមក ខ្លួនមានវ័យកាន់តែថយទៅ ៗ ចាស់ជរាគ្រាំគ្រា ទាំងរោគក៏មករួបរឹតរាងកាយ ទើបបាននឹកក្តៅក្រហាយស្តាយក្រោយ ។ អដ្ឋកថា ។

(៧៤) អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មវិហារី ធម្មវិហារីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធម្មវិហារី ហោតីតិ ។ ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ... វេទល្លំ ឧត្តរិញ្ចស្ស បញ្ញាយ អត្ថំ នប្បជានាតិ ។ អយំ វុច្ចតិ ភិក្ខុ បរិយត្តិពហុលោ នោ ធម្មវិហារី ។ បេ ។ ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ... វេទល្លំ ឧត្តរិញ្ចស្ស បញ្ញាយ អត្ថំ បជានាតិ ។ ឯវំ ខោ ភិក្ខុ ធម្មវិហារី ហោតិ ។ ឥតិ ខោ ភិក្ខុ ។ បេ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។

(៧៤) គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺ សុត្ត: ... វេទល្ល: តែភិក្ខុនោះមិនដឹងច្បាស់នូវអត្ថដ៏លើសលុបរបស់ធម៌នោះ ដោយបញ្ញាឡើយ ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។បេ។ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺសុត្ត: ... វេទល្ល: តែភិក្ខុនោះដឹងច្បាស់នូវអត្ថដ៏លើសលុបរបស់ធម៌នោះដោយបញ្ញា ។ ភិក្ខុជាអ្នកមានប្រក្រតីនៅដោយធម៌ យ៉ាងនេះឯង ។ ភិក្ខុ ។បេ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។

(៧៩) បញ្ចិមេ ភិក្ខវេ យោធាជីវា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ឯកច្ចោ យោធាជីវោ រជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ បឋមោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ សហតិ រជគ្គំ អបិច ខោ ធជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ ទុតិយោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ អបិច ខោ ឧស្សារណញ្ញេវ[១] ទិស្វា

---

១ ឱ. ឧស្សាទនំ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ (អ្នករស់នៅដោយឋានៈជាទាហាន) នេះមាន ៥ ពួក តែងមានប្រាកដក្នុងលោក ។ យោធាជីវៈទាំង ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ពួកខ្លះក្នុងលោកនេះ គ្រាន់តែបានឃើញនូវផង់ធូលីដែលហុយឡើង (អំពីផែនដី) ប៉ុណ្ណោះ ក៏រួញរា ថប់ចិត្ត មិនរឹងប៉ឹង មិនអាច ដើម្បីនឹងចុះកាន់សង្គ្រាមបាន ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ១ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ ទោះអត់ទ្រាំនូវផង់ធូលី ដែលហុយឡើងបាន តែថា លុះបានឃើញចុងនៃទង់ជ័យប៉ុណ្ណោះ ក៏រួញរា ថប់ចិត្ត មិនរឹងប៉ឹង មិនអាច ដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ ទោះអត់ទ្រាំនូវផង់ធូលី ដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន តែថា លុះបានឮសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលប៉ុណ្ណោះ

សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ តតិយោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ អបិច ខោ សម្បហារេ ហញ្ញតិ ព្យាបជ្ជតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ សហតិ សម្បហារំ សោ តំ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ តមេវ សង្គាមសីសំ អជ្ឈាវសតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ

ក៏រួញរា ថប់ចិត្ត មិនរឹងប៉ឹង មិនអាច ដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះ ជាយោធាជីវៈទី ៣ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលី ដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវពួកពលបាន តែថា ភាន់ភាំងស្រឡាំងកាំង ក្នុងការប្រយុទ្ធគ្នា ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ រមែងមានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះ ជាយោធាជីវៈទី ៤ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ ចេះអត់ទ្រាំនូវផង់ធូលី ដែលហុយឡើងបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវរបស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះហើយ ឈ្មោះថាជាអ្នកឈ្នះសង្គ្រាម តែងបាននៅគ្រប់គ្រងនៅជាប្រធាន លើសង្គ្រាមនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង

អយំ ភិក្ខវេ បញ្ចមោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ ឥមេ ខោ ភិក្ខវេ បញ្ច យោធាជីវា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ យោធាជីវូបមា បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសុ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ រជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ កិមស្ស រជគ្គស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ សុណាតិ អមុកស្មឹ នាម គាមេ វា និគមេ វា ឥត្ថី វា កុមារី វា អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតាតិ ។ សោ តំ សុត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥទមស្ស រជគ្គស្មឹ ។

ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈទាំង ៥ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈនេះ មាន ៥ ពួក តែងមានប្រាកដក្នុងពួកភិក្ខុ ក៏យ៉ាងនោះដែរ ។ បុគ្គល ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញនូវផង់ធូលី គឺលំអ របស់មាតុគ្រាម ក៏លិចចុះទៅ ក្នុងមិច្ឆាវិតក្កៈ ជប់ចិត្ត មិនរឹងប៉ឹង មិនអាច ដើម្បីនឹងគប់គងព្រហ្មចរិយៈបានឡើយ ប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយថាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ដើម្បីភេទថោកទាបវិញ ។ អ្វីជាផង់ធូលី របស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឮដំណឹងថា ស្រីឬកុមារីក្នុងស្រុកឬនិគមឈ្មោះឯណោះ មានរូបល្អ គួរមើលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេក ។ ភិក្ខុនោះ លុះឮដំណឹងនោះហើយ ក៏លិចចុះទៅ ក្នុងមិច្ឆាវិតក្កៈ ជប់ចិត្ត មិនរឹងប៉ឹង មិនអាច ដើម្បីនឹងគប់គងព្រហ្មចរិយៈបានឡើយ ប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយថាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ ដើម្បីភេទថោកទាបវិញ ។ នេះជាផង់ធូលីរបស់បុគ្គលនោះ ។

សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ រជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ បឋមោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សហតិ រជគ្គំ អបិច ខោ ធជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ កិមស្ស ធជគ្គស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ សុណាតិ អមុកស្មឹ គាមេ វា និគមេ វា ឥត្ថី វា កុមារី វា អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតាតិ អបិច ខោ សាមំ បស្សតិ ឥត្ថឹ វា កុមារឹ វា អភិរូបំ ទស្សនីយំ បាសាទិកំ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតំ សោ តំ ទិស្វា សំសីទតិ

ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ គ្រាន់តែបានឃើញនូវផង់ធូលីប៉ុណ្ណោះហើយ ក៏ញ្ញេក ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបាន មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឧបមាដូចយោធាជីវៈទី ១ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអត់ទ្រាំនូវផង់ធូលីបាន ប៉ុន្តែលុះបានឃើញនូវចុងនៃទង់ជ័យប៉ុណ្ណោះ ក៏ញ្ញេក ជប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់ ដើម្បីភេទថោកទាបវិញ ។ អ្វីជាទង់ជ័យ របស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានឮដំណឹងថា ស្ត្រី ឬ កុមារី ក្នុងស្រុក ឬ និគមឈ្មោះឯណោះ មានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេកទេ ប៉ុន្តែបើឃើញនូវស្ត្រីឬកុមារីដែលមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃពេកដោយខ្លួនឯង លុះភិក្ខុនោះ បានឃើញនូវស្ត្រីនោះហើយ ក៏លិចចុះទៅក្នុងមិច្ឆាវិតក្កៈ

វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្តានេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥទមស្ស ធជគ្គស្មឹ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ សហតិ រជគ្គំ អបិច ខោ ធជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ ទុតិយោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សហតិ រជគ្គំ សហតិ ធជគ្គំ អបិច ខោ ឧស្សារណញ្ញេវ សុត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្តានេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ កិមស្ស ឧស្សារណាយ ។

ថប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់ ដើម្បីភេទថោកទាបវិញ ។ នេះជាចុងនៃទង់ជ័យរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន ប៉ុន្តែលុះបានឃើញនូវចុងនៃទង់ជ័យប៉ុណ្ណោះហើយ ក៏រួញរា ថប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងចុះកាន់សង្គ្រាមបានឡើយ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឧបមាដូចជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអត់ទ្រាំនូវផង់ធូលីបាន ជាអ្នកអត់ទ្រាំនូវចុងនៃទង់ជ័យបាន ប៉ុន្តែលុះបានឮសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពល មកដល់ប៉ុណ្ណោះហើយ ក៏រួញរា ថប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ អ្វីជាសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលនៃបុគ្គលនោះ ។

ឥធ ភិក្ខវេ ភិក្ខុំ អរញ្ញគតំ វា រុក្ខមូលគតំ វា សុញ្ញាគារគតំ វា មាតុគ្គាមោ ឧបសង្កមិត្វា ឩហសតិ(១) ឧល្លបតិ ឧជ្ជគ្ឃតិ(១) ឧប្បណ្ឌេតិ ។ សោ មាតុគ្គាមេន ឩហសិយមានោ ឧល្លបិយមានោ ឧជ្ជគ្ឃិយមានោ ឧប្បណ្ឌិយមានោ សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្ពល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥទមស្ស ឧស្សារណាយ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ អបិច ខោ ឧស្សារណញ្ញេវ សុត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ ។ អយំ ភិក្ខវេ តតិយោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។

---

១ ម. ឧជ្ឈគ្គតិ ។

ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បានចូលទៅរកភិក្ខុ ក្នុងសាសនានេះ ដែលជាអ្នកអាស្រ័យនៅក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ក៏ញញឹម និយាយរក សើចក្អាកក្អាយ ចំអកចំអន់លេង ៗ ភិក្ខុនោះ កាលបើមាតុគ្រាម ញញឹម និយាយរក សើចក្អាកក្អាយ ចំអកចំអន់លេង ក៏រួញរា ផប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីទឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ ក៏ស្រាប់តែប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ៗ នេះជាសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលនៃបុគ្គលនោះ ៗ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន ប៉ុន្តែថាលុះបានឮសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលមកដល់ប៉ុណ្ណោះហើយ ក៏រួញរា ផប់ចិត្ត មិនរឹងប៉ឹង មិនអាចដើម្បីចុះកាន់សង្គ្រាមបានឡើយ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឧបមាដូចជាយោធាជីវៈទី ៣ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ៗ

បុន ចបរំ ភិក្ខវេ ភិក្ខុ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ អបិច ខោ សម្បហារេ ហញ្ញតិ ព្យាបជ្ជតិ ។ កិមស្ស សម្បហារស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុំ អរញ្ញគតំ វា រុក្ខមូលគតំ វា សុញ្ញាគារគតំ វា មាតុគ្គាមោ ឧបសង្កមិត្វា អភិនិសីទតិ អភិនិបជ្ជតិ អជ្ឈោត្ថរតិ ។ សោ មាតុគ្គាមេន អភិនិសីទិយមានោ អភិនិបជ្ជិយមានោ អជ្ឈោត្ថរិយមានោ សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវតិ ។ ឥទមស្ស សម្បហារស្មឹ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ អបិច ខោ សម្បហារេ ហញ្ញតិ ព្យាបជ្ជតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហោកញ្ជ្រៀវ របស់ពួកពលបាន ទាស់តែនៅកាន់កាំងស្រឡាំងកាំង ក្នុងការប្រយុទ្ធគ្នា ។ អ្វីជាការប្រយុទ្ធគ្នា របស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបានចូលទៅរកភិក្ខុ ក្នុងសាសនានេះ ដែលជាអ្នកនៅអាស្រ័យក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ចូលទៅអង្គុយជិត ដេកជិត ឱបរឹត ។ ភិក្ខុនោះកាលបើមាតុគ្រាម អង្គុយជិត ដេកជិត ឱបរឹត ក៏មិនបានពោលលានូវសិក្ខា មិនបានប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយហើយ ក៏សេពនូវមេថុនធម្ម ។ នេះជាការប្រយុទ្ធគ្នា របស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហោកញ្ជ្រៀវ របស់ពួកពលបាន ទាស់តែនៅកាន់កាំងស្រឡាំងកាំង ក្នុងការប្រយុទ្ធគ្នា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឧបមាដូចយោធាជីវៈទី ៤ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុ

សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ
សហតិ សម្បហារំ សោ តំ សង្គាមំ អភិវិជិនិត្វា
វិជិតសង្គាមោ តមេវ សង្គាមសីសំ អជ្ឈាវសតិ ។
កិមស្ស សង្គាមវិជយស្ស ។ ឥធ ភិក្ខវេ ភិក្ខុំ
អរញ្ញគតំ វា រុក្ខមូលគតំ វា សុញ្ញាគារគតំ វា
មាតុគ្គាមោ ឧបសង្កមិត្វា អភិនិសីទតិ អភិនិបជ្ជតិ
អជ្ឈោត្ថរតិ ។ សោ មាតុគ្គាមេន អភិនិសីទិយមានោ
អភិនិបជ្ជិយមានោ អជ្ឈោត្ថរិយមានោ វិនិវេឋេត្វា
វិនិមោចេត្វា យេន កាមំ បក្កមតិ ។ សោ វិវិត្តំ
សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ
គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។
សោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ
វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ
បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ
បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ
ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ
អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី

អត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងទង់ជ័យបាន អត់ទ្រាំនូវសំឡេងហ៊ោកញ្ជ្រៀវ របស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន ភិក្ខុនោះ បានឈ្នះនូវសង្គ្រាមនោះហើយ ឈ្មោះថាជាអ្នកឈ្នះនូវសង្គ្រាម តែងនៅគ្រប់គ្រង នៅជាប្រធានលើកងទ័ពនោះឯង ។ អ្វីជាការឈ្នះសង្គ្រាម របស់បុគ្គលនោះ ។ មាលភិក្ខុទាំងឡាយ មាតុគ្រាម បានចូលទៅរកភិក្ខុ ក្នុងសាសនានេះ ដែលជាអ្នកអាស្រ័យនៅក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី អង្គុយជិត ដេកជិត ឧបតែ ។ ភិក្ខុនោះ កាលបើមាតុគ្រាម ទៅអង្គុយជិត ដេកជិត ឧបតែ ក៏រលៀកខ្លួនចេញបាន ដោះខ្លួនចេញរួចហើយ ក៏ចៀសចេញទៅតាមប្រាថ្នា ។ ភិក្ខុនោះតែងគប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល ទីងគំនរចំបើង ។ ភិក្ខុនោះ ជាអ្នកនៅអាស្រ័យក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ លះបង់អភិជ្ឈា ក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់ព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះសត្វទាំងពួង ដោយប្រយោជន៍

ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ

ដម្រះចិត្តឲ្យស្អាតចាកព្យាបាទ ជាគ្រឿងប្រទូស្ត លះបង់ថីនមិទ្ធៈ មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្ដីសំគាល់ច្បាស់ក្នុងពន្លឺ មានស្មារតិ មានសម្បជញ្ញៈ ដម្រះចិត្តចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មានចិត្តមិនរវើរវាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុង ដម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា មានចិត្តឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្ដីងឿងឆ្ងល់ក្នុងកុសលធម៌ ដម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះ លះនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យថយកម្លាំង ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ក៏បានដល់នូវចតុត្ថជ្ឈាន ។ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវធម៌ដែលធ្វើនូវអាសវៈឲ្យអស់ទៅ ។ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ

អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទមស្ស សង្គាមវិជយស្មឹ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ សហតិ សម្បហារំ សោ តំ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ

ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់នៃអាសវៈ ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរួចចាកកាមាសវៈផង ចិត្តរួចចាកភវាសវៈផង ចិត្តរួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចផុតស្រឡះ (ចាកកាមាសវៈជាដើមហើយ) សេចក្តីដឹង ក៏កើតឡើងប្រាកដថា ចិត្តរួចស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ នេះជាជ័យជំនះក្នុងសង្គ្រាម របស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ អត់ទ្រាំនូវផង់ធូលីបាន អត់ទ្រាំនូវចុងនៃទង់ជ័យបាន អត់ទ្រាំនូវសំឡេងហោកញ្ជ្រៀវ របស់ពួកពលបាន អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន យោធាជីវៈនោះ បានឈ្នះនូវសង្គ្រាមនោះហើយ ឈ្មោះថាជាអ្នកឈ្នះនូវសង្គ្រាម

តមេវ សង្គាមសីសំ អជ្ឈាវសតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ បញ្ចមោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ ឥមេ ខោ ភិក្ខវេ បញ្ច យោធាជីវូបមា បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសូតិ ។

[៧៦] បញ្ចិមេ ភិក្ខវេ យោធាជីវា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ឯកច្ចោ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ ។ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាទាបេន្តិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ បឋមោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។

តែងនៅគ្របគ្រង នៅជាប្រធានលើសង្គ្រាមនោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយ មានឧបមាដូចជាពួកយោធាជីវៈទាំង ៥ នេះឯង តែងមានប្រាកដក្នុងភិក្ខុទាំងឡាយ ។

(៧៦) ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ៥ ពួកនេះ តែងមានប្រាកដក្នុងលោក ។ យោធាជីវៈ ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាម ដែលកំពុងប្រយុទ្ធគៀកគ្នា ។ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏បៀតបៀន សង្កត់សង្កិន នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្នះខ្នែងបាន ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ១ តែងមានប្រាកដក្នុងលោក ។

បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ ។ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ នេន្តិ ។ សោ ញាតកេហិ នីយមានោ អប្បត្វា ញាតកេ អន្តរាមគ្គេ កាលំ ករោតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ ទុតិយោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ ។ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ នេន្តិ តមេនំ ញាតកា ឧបដ្ឋហន្តិ បរិចរន្តិ ។ សោ ញាតកេហិ ឧបដ្ឋហិយមានោ បរិចរិយមានោ តេនេវ អាពាធេន កាលំ ករោតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញហើយចុះកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា ៗ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្នះខ្នែង ចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ៗ យោធាជីវៈនោះ កាលពួកញាតិដែលកំពុងនាំទៅ មិនទាន់ដល់ផ្ទះរបស់ខ្លួន ឬសំណាក់របស់ពួកញាតិ ក៏ធ្វើនូវមរណកាល ក្នុងពាក់កណ្ដាលផ្លូវទៅ ៗ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ២ តែងមានប្រាកដក្នុងលោក ៗ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា ៗ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្នះខ្នែង បានចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកនូវយោធាជីវៈនោះទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ពួកញាតិក៏ទំនុកបំរុង បម្រើ ក៏ធ្វើនូវមរណកាល ដោយអាពាធនោះទៅ ៗ

ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ តតិយោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ ។ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ នេន្តិ តមេនំ ញាតកា ឧបដ្ឋហន្តិ បរិចរន្តិ ។ សោ ញាតកេហិ ឧបដ្ឋហិយមានោ បរិចរិយមានោ វុដ្ឋាតិ តម្ហា អាពាធា ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ ។ សោ តំ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ

ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៣ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា ។ យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្នះខ្នែង បានចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ពួកញាតិក៏ទំនុកបំរុង បម្រើនូវយោធាជីវៈនោះ ។ យោធាជីវៈនោះ កាលបើពួកញាតិ ទំនុកបំរុង បម្រើ ក៏បានជាសះស្បើយចាកអាពាធនោះទៅ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៤ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត យោធាជីវៈពួកខ្លះ ក្នុងលោកនេះ កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា ។ យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះហើយ ឈ្មោះថា ជាអ្នកឈ្នះសង្គ្រាម

តមេវ សង្គាមសីសំ អជ្ឈាវសតិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ យោធាជីវោ ហោតិ អយំ ភិក្ខវេ បញ្ចមោ យោធាជីវោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ ឥមេ ខោ ភិក្ខវេ បញ្ច យោធាជីវា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ យោធាជីវូបមា បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសុ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ សោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ ។ សោ តត្ថ បស្សតិ មាតុគាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគាមំ ទិស្វា ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ ។ សោ រាគានុទ្ធំសេន ចិត្តេន សិក្ខំ អបច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវតិ ។

តែងបាននៅគ្រប់គ្រង នៅជាប្រធានលើសង្គ្រាមនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាយោធាជីវៈទី ៥ តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈទាំង ៥ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈនេះមាន ៥ ពួក តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ក៏យ៉ាងនេះដែរ ។ បុគ្គល ៥ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅពឹងពាក់អាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រនឹងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនបានដម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះ ឃើញមាតុគ្រាម ក្នុងស្រុក ឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ រាគៈក៏អុបអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាមដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ ។ ភិក្ខុនោះកាលបើមានចិត្តត្រូវរាគៈអុបអាលហើយ ក៏មិនបានពោលលានូវសិក្ខា មិនបានប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយ ហើយក៏សេពនូវមេថុនធម្ម ។

សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ អសិចម្មំ
គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ
ឱតរតិ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ
តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ហនន្តិ បរិយាទា-
ទេន្តិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។
ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ
អយំ ភិក្ខវេ បឋមោ យោធាជីវូបមោ បុគ្គលោ
សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ
ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា
ឧបនិស្សាយ វិហរតិ ។ សោ បុព្វណ្ហសមយំ
និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា និគមំ
វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន
អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិ-
តាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ ។ សោ
តត្ថ បស្សតិ មាតុគ្គាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា

ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវនិងខែល សៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏បៀតបៀន ចាប់ទុកនូវយោធាជីវៈនោះ ដែលកំពុងខំព្យាយាម ខ្នះខ្នែង មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈ ទី ១ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនូវស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅកាន់ស្រុកឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនដម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះឃើញមាតុគ្រាម ក្នុងស្រុកឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ

តស្ស មាតុគ្គាមំ ទិស្វា ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ ។ សោ រាគានុទ្ធំសេន ចិត្តេន បរិឡយ្ហតេវ កាយេន បរិឡយ្ហតិ ចេតសា ។ តស្ស ឯវំ ហោតិ យន្នូនាហំ អារាមំ គន្ត្វា ភិក្ខូនំ អារោចេយ្យំ រាគាយិតោម្ហិ[១] អាវុសោ រាគបរេតោ ន សក្កោមិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ សោ អារាមំ គច្ឆន្តោ អប្បត្វាវ អារាមំ អន្តរាមគ្គេ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ សោ តស្មឹ សង្គាមេ ឧស្សហតិ

---

១ ឱ. ម. រាគបរិយុដ្ឋិតោម្ហិ ។

រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាម ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ ។ ភិក្ខុនោះកាលបើមានចិត្តត្រូវរាគៈអុចអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាម ហើយគប្បីប្រាប់ (សេចក្ដីនេះ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណា ត្រូវរាគៈរោលរាលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងនៅគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ នឹងពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏ទៅកាន់អារាម តែទៅមិនទាន់ដល់អារាមនៅឡើយ ក៏ប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាប ក្នុងដំណើរពាក់កណ្ដាលផ្លូវ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវនឹងខែល ស៊ៀតធ្នូនឹងបំពង់ព្រួញហើយ ចុះកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ

វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ នេន្តិ សោ ញាតកេហិ នីយមានោ អប្បត្វាវ ញាតកេ អន្តរាមគ្គេ កាលំ ករោតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ ទុតិយោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ សោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ ។ សោ តត្ថ បស្សតិ មាតុគ្គាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគ្គាមំ ទិស្វា ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ ។

ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែខំព្យាយាម ខ្វះខ្វែង បានហើយ ចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ យោធាជីវៈនោះ កាលបើពួកញាតិនាំយកទៅ មិនទាន់ដល់សំណាក់ញាតិទាំងឡាយ ក៏ធ្វើនូវមរណកាល ក្នុងដំណើរពាក់កណ្តាលផ្លូវទៅ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈ ទី ២ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនូវស្រុកឬនិគមណាមួយ ។ ភិក្ខុនោះ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនដម្កល់ស្មារតី មិនសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះ បានឃើញមាតុគ្រាម ក្នុងស្រុកឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ រាគៈក៏អុបអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាម ដែលស្លៀកពាក់មិនល្អ ឬដណ្តប់មិនល្អ ។

សោ រាគានុទ្ធំសេន ចិត្តេន បរិឌយ្ហតេវ កាយេន
បរិឌយ្ហតិ ចេតសា ។ តស្ស ឯវំ ហោតិ យន្នូនាហំ
អារាមំ គន្ត្វា ភិក្ខូនំ អារោចេយ្យំ រាគាយិតោម្ហិ
អាវុសោ រាគបរេតោ ន សក្កោមិ ព្រហ្មចរិយំ
សន្តានេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ
ហីនាយាវត្តិស្សាមីតិ ។ សោ អារាមំ គន្ត្វា ភិក្ខូនំ
អារោចេតិ រាគាយិតោម្ហិ អាវុសោ រាគបរេតោ ន
សក្កោមិ ព្រហ្មចរិយំ សន្តានេតុំ សិក្ខាទុព្វល្យំ
អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។
តមេនំ សព្រហ្មចារី ឱវទន្តិ អនុសាសន្តិ
អប្បស្សាទា អាវុសោ កាមា វុត្តា ភគវតា
ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។

ភិក្ខុនោះមានចិត្តត្រូវរាគៈអុបអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះមានចិត្តត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាម ហើយគប្បីប្រាប់ (សេចក្តីនេះ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណា ត្រូវរាគៈពេលពលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីទឹងនៅគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏បានទៅកាន់អារាមហើយប្រាប់ (សេចក្តីនោះ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណា ត្រូវរាគៈពេលពលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីទឹងនៅគ្រប់គ្រងព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ ពួកសព្រហ្មចារី ក៏ទូន្មានប្រៀនប្រដៅភិក្ខុនោះថា ម្នាលអាវុសោ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។

អដ្ឋិកង្កលូបមា[១] កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ មំសបេសូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ តិណុក្កូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ អង្គារកាសូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ សុបិនកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ យាចិតកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ រុក្ខផលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា

---

១ ឱ. អដ្ឋិសង្ខលូបមា ។

កាមទាំងឡាយ មានឧបមាដូចជាកង់ឆ្អឹង មាកទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាដុំសាច់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមានច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចគប់ភ្លើងស្មៅ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាគំនររងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចការយល់សប្តិ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជារបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាបនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាផ្លែឈើ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ

អាទីនវោ ឯត្ថ ភិយ្យោ ។ អសិសូនូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ សត្តិសូលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ សប្បសិរូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ អភិរមតុ អាយស្មា ព្រហ្មចរិយេ មា អាយស្មា សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តីតិ ។ សោ សព្រហ្មចារីហិ ឯវំ ឱវទិយមានោ ឯវំ អនុសាសិយមានោ ឯវមាហ កិញ្ចាបិ អាវុសោ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ

ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ៗ កាមទាំងឡាយ មានឧបមាដូចជាកាំបិតនឹងជ្រញ់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ៗ កាមទាំងឡាយ មានឧបមាដូចជាចុងលំពែង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ៗ កាមទាំងឡាយ មានឧបមាដូចជាក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ៗ លោកដ៏មានអាយុ ចូរត្រេកអរក្នុងព្រហ្មចរិយធម៌ចុះ លោកដ៏មានអាយុ កុំប្រកាសនូវភាពនៃខ្លួនជាអ្នកមានកម្លាំងថយ ចាកសិក្ខា ពោលលានូវសិក្ខា វិលត្រឡប់មកដើម្បីភេទថោកទាបឡើយ ៗ ភិក្ខុនោះ កាលសព្រហ្មចារីបុគ្គលទាំងឡាយ ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏ពោលយ៉ាងនេះថា ម្នាលអាវុសោ កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ក៏ពិតមែន

អជ្ឈោ នេវាហំ សក្កោមិ [ព្រហ្មចរិយំ សន្តានេតុំ សិក្ខាទុព្ពល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ សោ សិក្ខាទុព្ពល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ សោ តស្មឹ សង្គាមេ ឧស្សហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ នេន្តិ តមេនំ ញាតកា ឧបដ្ឋហន្តិ បរិចរន្តិ សោ ញាតកេហិ ឧបដ្ឋហិយមានោ បរិចរិយមានោ តេនេវ អាពាធេន កាលំ ករោតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ អយំ ភិក្ខវេ តតិយោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ បុន ចបរំ ភិក្ខវេ

តែថា ខ្ញុំករុណាមិនអាចដើម្បីគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏បានប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវនឹងខែល ស៊ៀតធ្នូនឹងបំពង់ព្រួញ ហើយចូលកាន់សង្គ្រាមដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះ ព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃក៏ចាក់នូវយោធាជីវៈនោះ ដែលកំពុងតែព្យាយាម ខ្នះខ្នែងបាន ចាប់យកនូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ពួកញាតិ ញាតិទាំងឡាយក៏ទំនុកបំរុង បម្រើនូវយោធាជីវៈនោះ យោធាជីវៈនោះ កាលបើពួកញាតិទំនុកបំរុង បម្រើ ក៏ធ្វើកាលកិរិយាដោយអាពាធនោះទៅ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ មានឧបមាដូចជាយោធាជីវៈទី ៣ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ សោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ ។ សោ តត្ថ បស្សតិ មាតុគាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគាមំ ទិស្វា ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ ។ សោ រាគានុទ្ធំសេន ចិត្តេន បរិឡយ្ហតេវ កាយេន បរិឡយ្ហតិ ចេតសា ។ តស្ស ឯវំ ហោតិ យន្នូនាហំ អារាមំ គន្ត្វា ភិក្ខូនំ អារោចេយ្យំ រាគាយិតោម្ហិ អាវុសោ រាគបរេតោ ន សក្កោមិ ព្រហ្មចរិយំ សន្តានេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ សោ អារាមំ គន្ត្វា ភិក្ខូនំ អារោចេតិ រាគាយិតោម្ហិ អាវុសោ រាគបរេតោ ន សក្កោមិ

ភិក្ខុចូលទៅពឹងពាក់អាស្រ័យនៅ នឹងស្រុកឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនឹងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកឬនិគមនោះឯង ដើម្បីបិណ្ឌបាត មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនតម្កល់ស្មារតី មិនបានសង្រួមឥន្ទ្រិយ ។ ភិក្ខុនោះបានឃើញមាតុគ្រាម ក្នុងស្រុកឬនិគមនោះ ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ រាគៈក៏អុចអាលចិត្តរបស់ភិក្ខុនោះ ព្រោះឃើញនូវមាតុគ្រាម ដែលស្លៀកពាក់មិនល្អ ឬដណ្ដប់មិនល្អ ។ ភិក្ខុនោះមានចិត្តត្រូវរាគៈអុចអាលហើយ ក៏ក្រហល់ក្រហាយដោយកាយ ក្រហល់ក្រហាយដោយចិត្ត ។ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់អារាម ហើយគប្បីប្រាប់ (សេចក្ដីនេះ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំករុណាត្រូវរាគៈពេលពលហើយ ត្រូវរាគៈគ្របសង្កត់ហើយ មិនអាចដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញ ។ ភិក្ខុនោះក៏ទៅកាន់អារាមហើយប្រាប់ (សេចក្ដីនោះ) ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ខ្ញុំករុណាត្រូវរាគៈពេលពលហើយ ត្រូវរាគៈគ្របសង្កត់ហើយ ខ្ញុំករុណាមិនអាច

ព្រហ្មចរិយំ សន្ធារេតុំ សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ តមេនំ សព្រហ្មចារី ឱវទន្តិ អនុសាសន្តិ អប្បស្សាទា អាវុសោ កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ មំសបេសូបមា កាមា វុត្តា ភគវតា... តិណុក្កូបមា កាមា វុត្តា ភគវតា... អង្គារកាសូបមា កាមា វុត្តា ភគវតា... សុបិនកូបមា កាមា វុត្តា ភគវតា... យាចិតកូបមា កាមា វុត្តា ភគវតា... រុក្ខផលូបមា កាមា វុត្តា ភគវតា...

ដើម្បីនឹងគ្រប់គ្រងនូវព្រហ្មចរិយៈបានទេ ខ្ញុំករុណានឹងប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខាហើយ ពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទដ៏ថោកទាបវិញ ។ សព្រហ្មចារីបុគ្គលទាំងឡាយ ក៏ចូទនា ប្រៀនប្រដៅនូវភិក្ខុនោះថា ម្នាលអាវុសោ កាមទាំងឡាយ មានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចកងឆ្អឹង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ កាមទាំងឡាយ មានឧបមាដូចជាដុំសាច់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ... កាមទាំងឡាយ មានឧបមាដូចជាគប់ភ្លើងស្មៅ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ... កាមទាំងឡាយ មានឧបមាដូចជាគំនររងើកភ្លើង ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ... កាមទាំងឡាយ មានឧបមាដូចជាយល់សប្តិ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ... កាមទាំងឡាយ មានឧបមាដូចជារបស់ខ្ចីគេ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ... កាមទាំងឡាយ មានឧបមាដូចជាផ្លែឈើ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ...

អសិសូនូបមា កាមា វុត្តា ភគវតា... សត្តិ-
សូលូបមា កាមា វុត្តា ភគវតា... សប្បសិរូបមា
កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា
អាទីនវោ ឯត្ថ ភិយ្យោ ។ អភិរមតុ អាយស្មា
ព្រហ្មចរិយេ មា អាយស្មា សិក្ខាទុព្វល្យំ អាវិកត្វា
សិក្ខំ បច្ចក្ខាយ ហីនាយាវត្តីតិ ។ សោ សព្រហ្ម-
ចារីហិ ឯវំ ឱវទិយមានោ ឯវំ អនុសាសិយមានោ
ឯវមាហ ឧស្សហិស្សាមិ អាវុសោ ធារយិស្សាមិ
អាវុសោ អភិរមិស្សាមិ អាវុសោ ន ទានាហំ អាវុសោ
សិក្ខាទុព្វល្យំ អាវិកត្វា សិក្ខំ បច្ចក្ខាយ ហីនាយា-
វត្តិស្សាមីតិ ។ សេយ្យថាបិ សោ ភិក្ខវេ យោធា-
ជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា

កាមទាំងឡាយ មានឧបមាដូចជាកាំបិតនឹងជ្រញ់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ .. កាមទាំងឡាយ មានឧបមាដូចជាចុងលំពែង ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ. កាមទាំងឡាយ មានឧបមាដូចជាក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានប្រមាណច្រើនណាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ។ លោកដ៏មានអាយុ ចូរត្រេកអរក្នុងព្រហ្មចរិយធម៌ចុះ លោកដ៏មានអាយុ កុំប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញឡើយ ។ ភិក្ខុនោះកាលសព្រហ្មចារីបុគ្គលទាំងឡាយ ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏ពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំករុណានឹងព្យាយាម ម្នាលអាវុសោ ខ្ញុំករុណានឹងទ្រទ្រង់ ម្នាលអាវុសោ ខ្ញុំករុណានឹងត្រេកអរ ម្នាលអាវុសោ ឥឡូវនេះ ខ្ញុំករុណាមិនទាន់ប្រកាសនូវភាពនៃខ្លួន ជាអ្នកមានកម្លាំងថយចាកសិក្ខា ហើយពោលលានូវសិក្ខា វិលត្រឡប់មក ដើម្បីភេទថោកទាបវិញទេ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវនឹងខែល សៀតនូវធនូនឹងបំពង់ព្រួញហើយ

វិយូឡ្ហំ សង្គាមំ ឱតរតិ សោ តស្មឹ សង្គាមេ ឧស្ស-
ហតិ វាយមតិ តមេនំ ឧស្សហន្តំ វាយមន្តំ បរេ
ឧបលិក្ខន្តិ តមេនំ អបនេន្តិ អបនេត្វា ញាតកានំ
នេន្តិ តមេនំ ញាតកា ឧបដ្ឋហន្តិ បរិចរន្តិ ។
សោ ញាតកេហិ ឧបដ្ឋហិយមានោ បរិចរិយមានោ
វុដ្ឋាតិ តម្ហា អាពាធា ឥធូបមាហំ ភិក្ខវេ ឥមំ
បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ
បុគ្គលោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ យោធាជីវូ-
បមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។
បុន ចបរំ ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា
ឧបនិស្សាយ វិហរតិ ។ សោ បុព្វណ្ហសមយំ
និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា
និគមំ វា បិណ្ឌាយ បវិសតិ រក្ខិតេនេវ
កាយេន រក្ខិតាយ វាចាយ រក្ខិតេន ចិត្តេន
ឧបដ្ឋិតាយ សតិយា សំវុតេហិ ឥន្ទ្រិយេហិ ។
សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ

ចូលកាន់សង្គ្រាម ដែលប្រយុទ្ធគ្នា យោធាជីវៈនោះ ខំព្យាយាម ខ្នះខ្នែង ក្នុងសង្គ្រាមនោះ ពួកយោធាជីវៈដទៃ ក៏ចាក់នូវយោធាជីវៈនោះឯង ដែលកំពុងតែខំព្យាយាម ខ្នះខ្នែងបាន ក៏ចាប់នូវយោធាជីវៈនោះទៅ លុះចាប់យកទៅហើយ ក៏នាំយកទៅឲ្យដល់ញាតិទាំងឡាយ ពួកញាតិក៏ទំនុកបំរុង បម្រើនូវយោធាជីវៈនោះ យោធាជីវៈនោះ កាលបើពួកញាតិ ទំនុកបំរុង បម្រើ ក៏បានសុះស្បើយចាកអាពាធនោះទៅ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ឧបមាដូចជាយោធាជីវៈទី ៤ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចូលទៅពឹងពាក់អាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ភិក្ខុនោះស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកឬនិគមនោះ ដើម្បីបិណ្ឌបាត បានរក្សាកាយ រក្សាវាចា រក្សាចិត្ត ដម្កល់ស្មារតី សង្រួមឥន្ទ្រិយ ។ ភិក្ខុនោះ ឃើញនូវរូបដោយចក្ខុហើយ តែមិនបានកួចកាន់នូវនិមិត្ត

នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជីវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា.. មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា

មិនបានក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈាទីនទោមនស្សដែលជាអកុសល-ធម៌ដ៏លាមក តែងជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុ មិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក . . . បានធុំក្លិនដោយច្រមុះ . . . បានទទួលរសដោយអណ្តាត . . . បានពាល់ត្រូវនូវផ្សព្វដោយកាយ . . . បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែមិនបានក្តោបកាន់នូវនិមិត្ត មិនបានក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈាទីនទោមនស្ស ដែលជាអកុសលធម៌ ដ៏លាមក តែងជាប់តាមនូវបុគ្គល ដែលមិនសង្រួមនូវមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ លុះត្រឡប់មកពីបិណ្ឌបាតក្នុងវេលាក្រោយភត្តហើយ តែងគប់រកនូវសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល ទីគំនរចំបើងឬស្លឹកឈើ ។ ភិក្ខុនោះ ជាអ្នកអាស្រ័យនៅក្នុងព្រៃក្តី ក្រោមម្លប់ឈើក្តី ក្នុងផ្ទះដ៏ស្ងាត់ក្តី ក៏អង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះ (ទៅកាន់ព្រះកម្មដ្ឋាន)

សោ អភិជ្ឈំ លោកេ បហាយ ។ បេ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សេយ្យថាបិ សោ ភិក្ខវេ យោធាជីវោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា វិយូឡ្ហំ សង្គាមំ ឱតរតិ សោ តំ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ តមេវ សង្គាមសីសំ អជ្ឈាវសតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ហោតិ

ភិក្ខុនោះក៏លះបង់នូវអភិជ្ឈា ក្នុងលោក ។បេ។ ភិក្ខុនោះ ក៏លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសនៃចិត្ត អាចធ្វើបញ្ញាឲ្យមានកម្លាំងថយ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានចូលកាន់ចតុត្ថជ្ឈាន ។ កាលដែលចិត្តខាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ។ ភិក្ខុនោះ ក៏ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ភិក្ខុនោះដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ច នេះទៀតមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈនោះ កាន់ដាវនិងខែល សៀតធ្នូនិងបំពង់ព្រួញ ហើយចូលកាន់សង្គ្រាម ដែលប្រយុទ្ធកៀកគ្នា យោធាជីវៈនោះ បានឈ្នះសង្គ្រាមនោះហើយ ក៏ឈ្មោះថាជាអ្នកឈ្នះសង្គ្រាម នៅគ្រប់គ្រង នៅជាប្រធានលើសង្គ្រាម នោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវបុគ្គលនេះ ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង

អយំ ភិក្ខវេ បញ្ចមោ យោធាជីវូបមោ បុគ្គលោ សន្តោ សំវិជ្ជមានោ ភិក្ខូសុ ។ ឥមេ ខោ ភិក្ខវេ បញ្ច យោធាជីវូបមា បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសូតិ ។

(៧៧) បញ្ចិមានិ ភិក្ខវេ អនាគតភយានិ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ អារញ្ញកោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ឯកកោ អរញ្ញេ វិហរាមិ ឯកកំ ខោ បន អរញ្ញេ វិហរន្តំ អហិ វា មំ ឌំសេយ្យ វិច្ឆិកា វា មំ ឌំសេយ្យ សតបទី វា មំ ឌំសេយ្យ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ។ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះមានឧបមាដូចជាយោធាជីវៈទី ៥ តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានឧបមាដូចជាយោធាជីវៈទាំង ៥ នេះឯង តែងមានប្រាកដ ក្នុងភិក្ខុទាំងឡាយ ។

[៧៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង ពស់គប្បីចឹកអាត្មាអញក្តី ខ្ទួយគប្បីទិចអាត្មាអញក្តី ក្អែបគប្បីខាំអាត្មាអញក្តី ដែលនៅក្នុងព្រៃតែម្នាក់ឯង កាលកិរិយាគប្បីមានដល់អាត្មាអញដោយហេតុនោះ អន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

ឥទំ ភិក្ខវេ បឋមំ អនាគតភយំ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ អារញ្ញកោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ឯកកោ អរញ្ញេ វិហរាមិ ឯកកោ ខោ បនាហំ អរញ្ញេ វិហរន្តោ ឧបក្ខលិត្វា វា បបតេយ្យំ ភត្តំ វា មេ ភុត្តំ ព្យាបជ្ជេយ្យ បិត្តំ វា មេ កុប្បេយ្យ សេម្ហំ វា មេ កុប្បេយ្យ សត្ថកា វា មេ វាតា កុប្បេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ។ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយាតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ១ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង កាលដែលអាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង គប្បីភ្លាត់ដួលទៅក្តី ភត្តដែលអាត្មាអញបរិភោគហើយ គប្បីឲ្យទោសក្តី ប្រមាត់របស់អាត្មាអញ គប្បីកំរើកឡើងក្តី ស្លេស្មរបស់អាត្មាអញ គប្បីកំរើកឡើងក្តី ខ្យល់ទាំងឡាយ ដែលមានមុខមុតដូចជាកាំបិត គប្បីកំរើកឡើងក្តី កាលកិរិយាគប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះគប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

ឥទំ ភិក្ខវេ ទុតិយំ អនាគតភយំ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ អារញ្ញកោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ឯកកោ អរញ្ញេ វិហរាមិ ឯកកោ ខោ បនាហំ អរញ្ញេ វិហរន្តោ វាឡេហិ សមាគច្ឆេយ្យំ សីហេន វា ព្យគ្ឃេន វា ទីបិនា វា អច្ឆេន វា តរច្ឆេន វា តេ មំ ជីវិតា វោរោបេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ។ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង ក៏កាលដែលអាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងម្រឹគសាហាវទាំងឡាយ គឺ រាជសីហ៍ក្តី ខ្លាធំក្តី ខ្លាដម្បងក្តី ខ្លាឃ្មុំក្តី ខ្លាត្រីក្តី ម្រឹគសាហាវទាំងនោះ គប្បីផ្តាច់បង់អាត្មាអញចាកជីវិត កាលកិរិយា គប្បីមានដល់អាត្មាអញដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

ឥទំ ភិក្ខវេ តតិយំ អនាគតភយំ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ អារញ្ញកោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ឯកកោ អរញ្ញេ វិហរាមិ ឯកកោ ខោ បនាហំ អរញ្ញេ វិហរន្តោ មាណវេហិ សមាគច្ឆេយ្យំ កតកម្មេហិ វា អកតកម្មេហិ វា តេ មំ ជីវិតា វោរោបេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ។ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។ ឥទំ ភិក្ខវេ ចតុត្ថំ អនាគតភយំ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៣ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាម ញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាច ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង ក៏កាលដែលអាត្មាអញនៅ ក្នុងព្រៃតែម្នាក់ឯង គប្បីជួបប្រទះនឹងពួកចោរ ដែលធ្វើចោរកម្មហើយក្តី ដែលមិនទាន់បានធ្វើចោរកម្មក្តី ចោរទាំងនោះគប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយា គប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណ-វិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៤ នេះហើយ

អប្បមត្តេន អាតាបិនា បហិតត្តេន វិហរតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ អារញ្ញកោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ឯកកោ អរញ្ញេ វិហរាមិ សន្តិ ខោ បនារញ្ញេ វាឡា អមនុស្សា តេ មំ ជីវិតា វោរោបេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ។ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។ ឥទំ ភិក្ខវេ បញ្ចមំ អនាគតភយំ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរតុំ អប្បត្តស្ស បត្តិយា

ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុអ្នកនៅព្រៃ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្នុងព្រៃតែម្នាក់ឯង ប្រសិនបើមានអមនុស្សកំណាចនៅក្នុងព្រៃ អមនុស្សកំណាចទាំងនោះ គប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតទៅ កាលកិរិយា គប្បីមានដល់អាត្មាអញ ដោយហេតុនោះ សេចក្តីអន្តរាយនោះ គប្បីមានដល់អាត្មាអញមិនខាន ។ បើដូច្នោះ អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទី ៥ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់

អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អនាគតភយានិ សម្បស្សមានេន អលមេវ អារញ្ញកេន ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

[៧៨] បញ្ចិមានិ ភិក្ខវេ អនាគតភយានិ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ ឯតរហិ ទហរោ យុវា សុសុ កាឡកេសោ

ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅព្រៃ កាលបើពិចារណាឃើញនូវអនាគតភ័យទាំង ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណ-វិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញនៅក្មេង កំឡោះ ជំទង់ មានសក់ខ្មៅស្រិល

ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា ហោតិ ខោ បន សោ សមយោ យំ ឥមំ កាយំ ជរា ផុសតិ ជិណ្ណេន ខោ បន ជរាយ អភិភូតេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ន សុករានិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ បុរា មំ សោ ធម្មោ អាគច្ឆតិ អនិដ្ឋោ អកន្តោ អមនាបោ ហន្ទាហំ បដិកច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ យេនាហំ ធម្មេន សមន្នាគតោ ជិណ្ណកោបិ ផាសុំ(១) វិហរិស្សាមីតិ ។ ឥទំ ភិក្ខវេ បឋមំ អនាគតភយំ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។

---

១ ឱ. ម. ផាសុ ។

ប្រកបដោយវ័យចំរើន គឺបឋមវ័យនៅឡើយ សម័យដែលជរាមកប៉ះពាល់នូវកាយនេះ រមែងមានដោយពិត ក៏កាយដែលចាស់គ្រាំគ្រា ត្រូវជរាមកគ្របសង្កត់ហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកនូវសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះអាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុនវិញ ដើម្បីដល់នូវគុណ-វិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញ ជាអ្នកប្រកបព្រមដោយធម៌ណាសូម្បីខ្លួនចាស់ជរាហើយ ក៏នឹងនៅជាសុខដោយធម៌នោះ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើពិចារណាឃើញនូវអនាគតភ័យទី ១ នេះហើយជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ៗ

បុន ចបរំ ភិក្ខវេ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ
ឯតរហិ អប្បាពាធោ អប្បាតង្កោ សមវេបាកិនិយា
គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ
មជ្ឈិមាយ បធានក្ខមាយ ហោតិ ខោ បន សោ
សមយោ យំ ឥមំ កាយំ ព្យាធិ ផុសតិ ព្យាធិតេន ខោ
បន ព្យាធិនា អភិភូតេន ន សុករំ ពុទ្ធានំ សាសនំ
មនសិកាតុំ ន សុករានិ អរញ្ញវនបត្ថានិ បន្តានិ
សេនាសនានិ បដិសេវិតុំ បុរា មំ សោ ធម្មោ
អាគច្ឆតិ អនិដ្ឋោ អកន្តោ អមនាបោ ហន្ទាហំ
បដិកច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិ-
គតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ
យេនាហំ ធម្មេន សមន្នាគតោ ព្យាធិតោបិ ផាសុំ
វិហរិស្សាមីតិ ។ ឥទំ ភិក្ខវេ ទុតិយំ អនាគតភយំ
សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន
អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ អាត្មាអញមានអាពាធតិច មានទុក្ខតិច ប្រកបដោយភ្លើងធាតុដែលដុតកំដៅស្មើគ្នា មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម សម័យដែលព្យាធិមក ប៉ះពាល់នូវកាយនេះ រមែងមានដោយពិត ក៏កាយដែលមានព្យាធិ ត្រូវព្យាធិមកគ្របសង្កត់ហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកនូវសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីមានព្យាធិក៏នឹងនៅជាសុខដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើពិចារណាឃើញនូវអនាគតភ័យទី ២ នេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកានព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់បានដល់

អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិ-
កិរិយាយ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ឥតិ
បដិសញ្ចិក្ខតិ ឯតរហិ ខោ[១] សុសស្សំ សុលភ-
បិណ្ឌំ សុករំ ឧញ្ឆេន បគ្គហេន យាបេតុំ ហោតិ
ខោ បន សោ សមយោ យំ ទុព្ភិក្ខំ ហោតិ
ទុស្សស្សំ ទុល្លភបិណ្ឌំ ន សុករំ ឧញ្ឆេន បគ្គហេន
យាបេតុំ ទុព្ភិក្ខេ ខោ បន មនុស្សា យេន សុភិក្ខំ
តេន សង្កមន្តិ តត្ថ សង្គណិកាវិហារោ ហោតិ
អាកិណ្ណវិហារោ សង្គណិកាវិហារេ ខោ បន សតិ
អាកិណ្ណវិហារេ ន សុករំ ពុទ្ធានំ សាសនំ មន-
សិកាតុំ ន សុករំ អរញ្ញវនបត្ថានិ បន្តានិ
សេនាសនានិ បដិសេវិតុំ បុរ មំ សោ ធម្មោ អាគច្ឆតិ
អនិដ្ឋោ អកន្តោ អមនាបោ ហន្ទាហំ បដិកច្ចេវ វិរិយំ
អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ

---

១ ឱ. ម. ឯតរហិ ខោ សុភិក្ខំ សុសស្សំ ។

ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ សំទូងល្អ បិណ្ឌបាតបានងាយ ស្រួលដើម្បីនឹងព្យាយាម ស្វែងរកមកចិញ្ចឹមជីវិតបានងាយ ក៏សម័យដែលមានទុរភិក្ស សំទូង មិនល្អ បិណ្ឌបាតបានដោយក្រ មិនងាយដើម្បីនឹងព្យាយាម ស្វែងរកមកចិញ្ចឹមជីវិតបានឡើយ មនុស្សទាំងឡាយ ក៏តែងទៅកាន់ទីដែលមានភិក្ខាងាយ ក្នុងវេលាដែលស្រុកកើតមានទុរភិក្ស ការនៅច្រឡូកច្រឡំ ការនៅដេរដាសក្នុងទីដែលមានភិក្ខាងាយនោះ រមែងមាន កាលបើការនៅច្រឡូកច្រឡំការនៅដេរដាសមានហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធបានទេ មិនងាយនឹងគប់រកសេនាសនៈស្ងាត់គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន

អសច្ឆិកតស្ស សច្ឆិកិរិយាយ យេនាហំ ធម្មេន សមន្នាគតោ ទុព្ភិក្ខេបិ ផាសុំ វិហរិស្សាមីតិ ។ ឥទំ ភិក្ខវេ តតិយំ អនាគតភយំ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ ឯតរហិ ខោ មនុស្សា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ ហោតិ ខោ បន សោ សមយោ យំ ភយំ ហោតិ អដវីសង្កោបោ ចក្កសមារូឡ្ហា ជានបទា បរិយាយន្តិ ភយេ ខោ បន សតិ មនុស្សា យេន ខេមំ តេន សង្កមន្តិ តត្ថ សង្គណិកវិហារោ ហោតិ អាកិណ្ណវិហារោ សង្គណិកវិហារេ ខោ បន សតិ អាកិណ្ណវិហារេ

ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីកងទ័ពកិលេសម័យក៏ទឹងនៅសប្បាយដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៣ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ មនុស្សទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយដោយទឹក ក្រឡេកមើលគ្នាទឹងគ្នា ដោយចក្ខុជាទីស្រឡាញ់ ក៏សម័យដែលមានភ័យ គឺពោរកម្រើក កងជងព្រៃហើយ ពួកអ្នកជនបទ ក៏នាំគ្នាឡើងកាន់ចក្កយានហើយបរទៅ (កាន់ទិសផ្សេងៗ) ក៏កាលបើភ័យមានហើយ មនុស្សទាំងឡាយតែងទៅកាន់ទីដ៏ក្សេមក្សាន្ត ការនៅច្រឡូកច្រឡំ ការនៅដេរដាស កងទីនោះរមែងមាន កាលបើការនៅច្រឡូកច្រឡំគ្នា ការនៅដេរដាសមានហើយ

ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ន សុករានិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ បុរ មំ សោ ធម្មោ អាគច្ឆតិ អនិដ្ឋោ អកន្តោ អមនាបោ ហន្ទាហំ បដិកច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិ-គមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ យេនាហំ ធម្មេន សមន្នាគតោ ភយេបិ ផាសុំ វិហរិស្សាមីតិ ។ ឥទំ ភិក្ខវេ ចតុត្ថំ អនាគតភយំ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន អាតាបិនា បហិ-តត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ ឯតរហិ ខោ សង្ឃោ សមគ្គោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុំ វិហរតិ ហោតិ

មិនងាយនឹងធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា សូម្បីក្នុងវេលាមានភ័យ ក៏នឹងនៅសប្បាយដោយធម៌នោះ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៤ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុពិចារណាឃើញដូច្នេះថា ឥឡូវនេះ សង្ឃជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅសប្បាយ

ខោ បន សោ សមយោ យំ សង្ឃោ ភិជ្ជតិ សង្ឃេ ខោ បន ភិន្នេ ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ន សុករានិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ បុរា ម៌ សោ ធម្មោ អាគច្ឆតិ អនិដ្ឋោ អកន្តោ អមនាបោ ហន្ទាហំ បដិកច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ យេនាហំ ធម្មេន សមន្នាគតោ ភិន្នេបិ សង្ឃេ ផាសុំ វិហរិស្សាមីតិ ។ ឥទំ ភិក្ខវេ បញ្ចមំ អនាគតភយំ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អនាគតភយានិ សម្បស្សមានេន អលមេវ ភិក្ខុនា អប្បមត្តេន

សម័យដែលសង្ឃបែកបាក់គ្នា រមែងមានដោយពិត កាលបើសង្ឃបែកបាក់គ្នាហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធបាន មិនងាយនឹងគប់រកសេនាសនៈស្ងាត់ គឺដងព្រៃបានឡើយ ធម៌ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តនោះ រមែងមកដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុនវិញ ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ អាត្មាអញប្រកបដោយធម៌ណា កាលបើសង្ឃបែកបាក់គ្នាហើយ ក៏នឹងនៅសប្បាយដោយធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យទី ៥ នេះ ជាអ្នកមិនប្រមាទ មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពិចារណាឃើញនូវអនាគតភ័យ ៥ យ៉ាងនេះឯង ជាអ្នកមិនប្រមាទ

អាតាបិនា បហិតត្តេន វិហរិតុំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

(៧៩) បញ្ចិមានិ ភិក្ខវេ អនាគតភយានិ ឯតរហិ អសមុប្បន្នានិ អាយតឹ សមុប្បជ្ជិស្សន្តិ តានិ វោ បដិពុជ្ឈិតព្វានិ បដិពុជ្ឈិត្វា ច តេសំ បហានាយ វាយមិតព្វំ ។ កតមានិ បញ្ច ។ ភវិស្សន្តិ ភិក្ខវេ ភិក្ខូ អនាគតមទ្ធានំ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា អញ្ញេ ឧបសម្បាទេស្សន្តិ តេបិ ន សក្ខិស្សន្តិ វិនេតុំ អធិសីលេ អធិចិត្តេ អធិបញ្ញាយ តេបិ ភវិស្សន្តិ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា

មានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបអាចដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ អនាគតភ័យនេះ មាន ៥ យ៉ាង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅ ក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យទាំងនោះចេញ ។ អនាគតភ័យ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយនឹងមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាទេ បើភិក្ខុទាំងនោះ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាហើយ នឹងញុំាងបុគ្គលដទៃឲ្យឧបសម្បទ ភិក្ខុទាំងនោះឯងនឹងមិនអាចដើម្បីទូន្មាន ក្នុងអធិសីល អធិចិត្តនឹងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះនឹងមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញា កាលបើភិក្ខុទាំងនោះមិនបានចំរើនកាយ

អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា អញ្ញេ ឧបសម្បាទេស្សន្តិ តេបិ ន សក្ខិស្សន្តិ វិនេតុំ អធិសីលេ អធិចិត្តេ អធិបញ្ញាយ តេបិ ភវិស្សន្តិ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា ។ ឥតិ ខោ ភិក្ខវេ ធម្មសន្ទោសា វិនយសន្ទោសោ វិនយសន្ទោសា ធម្មសន្ទោសោ ។ ឥទំ ភិក្ខវេ បឋមំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា អញ្ញេសំ និស្សយំ ទស្សន្តិ តេបិ ន សក្ខិស្សន្តិ វិនេតុំ អធិសីលេ អធិចិត្តេ អធិបញ្ញាយ តេបិ ភវិស្សន្តិ អភាវិតកាយា

មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញា ហើយនឹងញុំាងបុគ្គលដទៃឲ្យឧបសម្បទ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មាន ក្នុងអធិសីល អធិចិត្ត នឹងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះមុខជានឹងមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យ ព្រោះខូចធម៌ ការខូចធម៌ ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យ ទី ១ មិនទាន់កើតឡើងក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយគួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចោលចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយនឹងមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាទេ បើភិក្ខុទាំងនោះមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯង ក៏មិនអាចដើម្បីនឹងទូន្មាន ក្នុងអធិសីល អធិចិត្ត នឹងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះនឹងមិនបានចំរើនកាយ

អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា អញ្ញេសំ និស្សយំ ទស្សន្តិ តេបិ ន សក្ខិស្សន្តិ វិនេតុំ អធិសីលេ អធិចិត្តេ អធិបញ្ញាយ តេបិ ភវិស្សន្តិ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា ។ ឥតិ ខោ ភិក្ខវេ ធម្មសន្ទោសា វិនយសន្ទោសោ វិនយសន្ទោសា ធម្មសន្ទោសោ ។ ឥទំ ភិក្ខវេ ទុតិយំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា អភិធម្មកថំ វេទល្លកថំ កថេន្តា កណ្ហំ ធម្មំ ឱក្កមមានា ន ពុជ្ឈិស្សន្តិ ។

មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញា កាលបើភិក្ខុទាំងនោះ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាហើយ ឲ្យនិស្ស័យដល់ភិក្ខុទាំងឡាយដទៃ ភិក្ខុទាំងនោះឯង នឹងមិនអាចដើម្បីទូន្មាន ក្នុងអធិសីល អធិចិត្តនឹងអធិបញ្ញាបានឡើយ ភិក្ខុទាំងនោះ មុខជានឹងមិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាដែរ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យ ព្រោះខូចធម៌ ការខូចធម៌ ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ២ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញា ហើយសំដែងនូវអភិធម្មកថា នឹងវេទល្លកថា ឈានចុះទៅកាន់ធម៌ខ្មៅ ក៏មិនដឹងខ្លួន ។

ឥតិ ខោ ភិក្ខវេ ធម្មសន្ទោសា វិនយសន្ទោសោ វិនយសន្ទោសា ធម្មសន្ទោសោ ។ ឥទំ ភិក្ខវេ តតិយំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា យេ តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតាបដិសំយុត្តា តេសុ ភញ្ញមានេសុ ន សុស្សូសន្តិ ន សោតំ ឱទហិស្សន្តិ ន អញ្ញាចិត្តំ ឧបដ្ឋាបេស្សន្តិ ន ច តេ ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញិស្សន្តិ យេ បន តេ សុត្តន្តា កវិកតា កាវេយ្យា ចិត្តក្ខរា ចិត្តព្យញ្ជនា ពាហិរកា

ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យ ព្រោះខូចធម៌ ការខូចធម៌ ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៣ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត ភិក្ខុទាំងឡាយ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាហើយ ពួកព្រះសូត្រណា ដែលជា តថាគតភាសិត ជ្រាលជ្រៅ (ដោយបាលី) ជ្រាលជ្រៅដោយអត្ថ ជាលោកុត្តរធម៌ ប្រកបដោយការៈសោះសូន្យ កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល (ជនដទៃ) ក៏មិនប្រាថ្នាដើម្បីស្តាប់ មិនផ្ទៀងត្រចៀកប្រុងស្តាប់ មិនតាំងចិត្តដើម្បីចងដឹងសោះ ទាំងមិនសំគាល់នូវកិច្ចដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះឡើយ បើពួកព្រះសូត្រណា ដែលកវីតាក់តែង ជាពាក្យកាព្យឃ្លោង មានអក្ខរៈដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រ ជាពាក្យខាងក្រៅ

សាវកភាសិតា តេសុ ភញ្ញមានេសុ សុស្សូសន្តិ សោតំ ឱទហិស្សន្តិ អញ្ញាចិត្តំ ឧបដ្ឋាបេស្សន្តិ តេ ច ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញិស្សន្តិ ។ ឥតិ ខោ ភិក្ខវេ ធម្មសន្ទោសា វិនយសន្ទោសោ វិនយសន្ទោសា ធម្មសន្ទោសោ ។ ឥទំ ភិក្ខវេ ចតុត្ថំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេ អភាវិតកាយា សមានា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា ថេរា ភិក្ខូ ពាហុលិកា ភវិស្សន្តិ សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វិរិយំ អារភិស្សន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ

ជាភាសិតរបស់សាវកខាងក្រៅ កាលបើព្រះសូត្រទាំងនោះ ដែលភិក្ខុកំពុងពោល (ទើបពួកជនដទៃ) នឹងប្រាថ្នាចង់ស្តាប់ ផ្ទៀងត្រចៀកប្រុងស្តាប់ តាំងចិត្ត ដើម្បីចង់ដឹង ទាំងសំគាល់នូវកិច្ចដែលខ្លួនត្រូវរៀន ត្រូវទន្ទេញយកធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យ ព្រោះខូចធម៌ ការខូចធម៌ ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៤ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងកាលដ៏យូរអង្វែងទៅក្នុងអនាគត ភិក្ខុទាំងឡាយ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាទេ កាលបើភិក្ខុទាំងនោះ មិនបានចំរើនកាយ មិនបានចំរើនសីល មិនបានចំរើនចិត្ត មិនបានចំរើនបញ្ញាហើយ ភិក្ខុទាំងឡាយជាថេរៈ នឹងមានសេចក្តីល្មោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធាន ក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រារព្ធសេចក្តីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន

អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជិស្សតិ សាបិ ភវិស្សតិ ពាហុល្លិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភិស្សតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ ឥតិ ខោ ភិក្ខវេ ធម្មសន្ទោសា វិនយសន្ទោសោ វិនយសន្ទោសា ធម្មសន្ទោសោ ។ ឥទំ ភិក្ខវេ បញ្ចមំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អនាគតភយានិ ឯតរហិ អសមុប្បន្នានិ

ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ នឹងដល់នូវទិដ្ឋានុគតិ តាមពួកភិក្ខុដែលជាអ្នកលោភច្រើននោះ សូម្បីប្រជុំជនដែលកើតខាងក្រោយនោះទៀត ក៏នឹងមានសេចក្ដីលោភច្រើន ជាអ្នកបន្ធូរបន្ថយ ជាប្រធាន ក្នុងការបន្ធូរបន្ថយ ជាអ្នកលះបង់ធុរៈក្នុងវិវេក នឹងមិនប្រារព្ធសេចក្ដីព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណ-វិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ការខូចវិន័យ ព្រោះខូចធម៌ ការខូចធម៌ ព្រោះខូចវិន័យ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៥ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ អនាគតភ័យទាំង៥ យ៉ាងនេះឯង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ

អាយតឹ សមុប្បជ្ជិស្សន្តិ តានិ វោ បដិពុជ្ឈិតព្វានិ បដិពុជ្ឈិត្វា ច តេសំ បហានាយ វាយមិតព្វន្តិ ។

(៨០) បញ្ចិមានិ ភិក្ខវេ អនាគតភយានិ ឯតរហិ អសមុប្បន្នានិ អាយតឹ សមុប្បជ្ជិស្សន្តិ តានិ វោ បដិពុជ្ឈិតព្វានិ បដិពុជ្ឈិត្វា ច តេសំ បហានាយ វាយមិតព្វំ ។ កតមានិ បញ្ច ។ ភវិស្សន្តិ ភិក្ខវេ ភិក្ខូ អនាគតមទ្ធានំ ចីវរេ កល្យាណកាមា តេ ចីវរេ កល្យាណកាមា សមានា រិញ្ចិស្សន្តិ បំសុកូលិកត្តំ រិញ្ចិស្សន្តិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ គាមនិគមរាជធានីសុ ឱសរិត្វា វាសំ កប្បិស្សន្តិ ចីវរហេតុ ច អនេកវិហិតំ អនេសនំ អប្បតិរូបំ អាបជ្ជិស្សន្តិ ។ ឥទំ ភិក្ខវេ បឋមំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ

នឹងកើតឡើងទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាម ដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។

(៨០) ម្នាលភិក្ខុទាំងឡាយ អនាគតភ័យនេះ មាន ៤ យ៉ាង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យទាំងនោះចេញ ។ អនាគតភ័យ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត នឹងមានពួកភិក្ខុអ្នកប្រាថ្នាល្អក្នុងចីវរ កាលបើភិក្ខុទាំងនោះ ប្រាថ្នាល្អក្នុងចីវរហើយ មុខជានឹងលះបង់នូវបង្សុកូលិកង្គ នឹងលះបង់នូវសេនាសនៈស្ងាត់គឺដងព្រៃ នឹងចូលទៅសម្រេចការនៅ ក្នុងស្រុក ក្នុងនិគមក្នុងព្រះរាជធានីទាំងឡាយ មួយយ៉ាងទៀត នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗ ព្រោះហេតុតែចីវរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ១ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ

បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។
បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ
បិណ្ឌបាតេ កល្យាណកាមា តេ បិណ្ឌបាតេ
កល្យាណកាមា សមានា រិញ្ចិស្សន្តិ បិណ្ឌបាតិកត្តំ
រិញ្ចិស្សន្តិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ
គាមនិគមរាជធានីសុ ឱសរិត្វា វាសំ កប្បិស្សន្តិ
ជីវ្ហគ្គេន រសគ្គានិ បរិយេសមានា បិណ្ឌបាតហេតុ ច
អនេកវិហិតំ អនេសនំ អប្បដិរូបំ អាបជ្ជិស្សន្តិ ។
ឥទំ ភិក្ខវេ ទុតិយំ អនាគតភយំ ឯតរហិ អសមុប្បន្នំ
អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ
បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។
បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ
សេនាសនេ កល្យាណកាមា តេ សេនាសនេ
កល្យាណកាមា សមានា រិញ្ចិស្សន្តិ អារញ្ញកត្តំ
រិញ្ចិស្សន្តិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ
គាមនិគមរាជធានីសុ ឱសរិត្វា វាសំ កប្បិស្សន្តិ

លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត នឹងមានពួកភិក្ខុអ្នកប្រាថ្នាល្អ ក្នុងបិណ្ឌបាត កាលបើភិក្ខុទាំងនោះ ប្រាថ្នាល្អក្នុងបិណ្ឌបាតហើយ មុខជានឹងលះបង់បិណ្ឌបាតិកធុតង្គ នឹងលះបង់នូវសេនាសនៈស្ងាត់ គឺដងព្រៃហាលចេញ ហើយនឹងចូលទៅសម្រេចការនៅ ក្នុងស្រុកប្តូនិគមប្តូក្នុងព្រះរាជធានីទាំងឡាយ មួយយ៉ាងទៀត (ភិក្ខុទាំងនោះ) ស្វែងរកនូវរសទាំងឡាយដ៏ប្រសើរ ដោយចុងអណ្តាតហើយ នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗ ព្រោះហេតុតែបិណ្ឌបាត ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ២ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត នឹងមានពួកភិក្ខុអ្នកប្រាថ្នាល្អ ក្នុងសេនាសនៈ កាលបើភិក្ខុទាំងនោះប្រាថ្នាល្អ ក្នុងសេនាសនៈហើយ មុខជានឹងលះបង់នូវអារញ្ញិកធុតង្គ នឹងលះបង់នូវសេនាសនៈស្ងាត់គឺដងព្រៃ ហើយនឹងចូលទៅសម្រេចការនៅ ក្នុងស្រុកប្តូនិគមប្តូក្នុងព្រះរាជធានីទាំងឡាយ

សេនាសនហេតុ ច អនេកវិហិតំ អនេសនំ អប្ប-ដិរូបំ អាបជ្ជិស្សន្តិ ។ ឥទំ ភិក្ខវេ តតិយំ អនាគត-ភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ ភិក្ខុនីសិក្ខមានា-សមណុទ្ទេសេហិ សំសដ្ឋា វិហរិស្សន្តិ ភិក្ខុនី-សិក្ខមានាសមណុទ្ទេសេហិ សំសដ្ឋេ ខោ បន ភិក្ខវេ សតិ ឯតំ បាដិកង្ខំ អនភិរតា វា ព្រហ្មចរិយំ ចរិស្សន្តិ អញ្ញតរំ វា សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជិស្សន្តិ សិក្ខំ វា បច្ចក្ខាយ ហីនាយាវត្តិស្សន្តិ ។ ឥទំ ភិក្ខវេ ចតុត្ថំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។

មួយយ៉ាងទៀត នឹងដល់នូវការស្វែងរកដ៏មិនសមគួរ មានប្រការផ្សេងៗ ព្រោះហេតុតែសេនាសនៈ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនា-គតភ័យទី ៣ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត នឹងមានពួកភិក្ខុនៅច្រឡូកច្រឡំគ្នា ដោយពួកភិក្ខុនី សិក្ខមានា នឹងសមណុទ្ទេសៈ ម្នាលភិក្ខុទាំងឡាយ កាលបើការនៅច្រឡូកច្រឡំ ដោយពួកភិក្ខុនី សិក្ខមានានឹងសមណុទ្ទេសៈមានហើយ អំពើនេះ នឹងប្រាកដឡើងគឺថា ពួកភិក្ខុមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈផង នឹងត្រូវអាបត្តិដែលសៅហ្មងឯណាទីមួយផង នឹងពោលលានូវសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញផង ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៤ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។

បុន ចបរំ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ អារាមិកសមណុទ្ទេសេហិ សំសដ្ឋា វិហរិស្សន្តិ អារាមិកសមណុទ្ទេសេហិ សំសគ្គេ ខោ បន ភិក្ខវេ សតិ ឯតំ បាដិកង្ខំ អនេកវិហិតំ សន្និធិការក-បរិភោគំ អនុយុត្តា វិហរិស្សន្តិ ឱឡារិកំបិ និមិត្តំ ករិស្សន្តិ បថវិយាបិ ហរិតគ្គេបិ ។ ឥទំ ភិក្ខវេ បញ្ចមំ អនាគតភយំ ឯតរហិ អសមុប្បន្នំ អាយតឹ សមុប្បជ្ជិស្សតិ តំ វោ បដិពុជ្ឈិតព្វំ បដិពុជ្ឈិត្វា ច តស្ស បហានាយ វាយមិតព្វំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អនាគតភយានិ ឯតរហិ អសមុប្បន្នានិ អាយតឹ សមុប្បជ្ជិស្សន្តិ តានិ វោ បដិពុជ្ឈិតព្វានិ បដិពុជ្ឈិត្វា ច តេសំ បហានាយ វាយមិតព្វន្តិ ។

យោធាជីវវគ្គោ តតិយោ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងកាលដ៏យូរអង្វែងទៅ ក្នុងអនាគត នឹងមានពួកភិក្ខុនៅច្រឡូកច្រឡំ ដោយពួកអាពមិកជននឹងសមណុទ្ទេសៈ ម្នាលភិក្ខុទាំងឡាយ កាលបើការនៅច្រឡូកច្រឡំ ដោយពួកអាពមិកជននឹងសមណុទ្ទេសៈមានហើយ អំពើនេះនឹងប្រាកដឡើង គឺថា ពួកភិក្ខុនឹងប្រកបរឿយ ៗ នូវការបរិភោគនូវវត្ថុដែលខ្លួនសន្សំទុក មានប្រការផ្សេង ៗ ទាំងធ្វើនូវនិមិត្ត(១) ដ៏ជ្រោកជ្រោក ដោយផែនដីខ្លះ ដោយចុងស្មៅខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអនាគតភ័យទី ៤ មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ អនាគតភ័យ ៥ យ៉ាងនេះឯង មិនទាន់កើតឡើង ក្នុងកាលឥឡូវនេះទេ នឹងកើតឡើងតទៅក្នុងខាងមុខ អ្នកទាំងឡាយ គួរដឹងច្បាស់នូវអនាគតភ័យទាំងនោះ លុះដឹងច្បាស់ហើយ គួរព្យាយាមដើម្បីលះបង់នូវអនាគតភ័យទាំងនោះចោលចេញ ។

ចប់ យោធាជីវវគ្គទី ៣ ។

---

១ ភិក្ខុជីកដីដោយខ្លួនឯងក្តី ប្រើគេឲ្យជីកក្តី កាត់ស្មៅ ដើមឈើ មែកឈើ ស្លឹកឈើស្រស់ដោយខ្លួនឯងក្តី ប្រើគេឲ្យកាត់ក្តី នេះហៅថា ធ្វើនូវនិមិត្តដ៏ជ្រោកជ្រាក ។ អដ្ឋកថា ។

## តស្សុទ្ទានំ

ទុវេ ចេតោវិមុត្តី(១) ច

ទ្វេ ច ធម្មវិហារិនោ

យោធាជីវា ច ទ្វេ វុត្តា

ចត្តារោ ច អនាគតាតិ ។

---

១ ឱ. ម. ទ្វេ ចេតោវិមុត្តិផលា ។

## ឧទ្ទាននៃយោធាជីវវគ្គនោះគឺ ៖

និយាយអំពីចេតោវិមុត្តិ ២ លើក ធម្មវិហារិបុគ្គល ២ លើក

ពួកយោធាជីវៈ ២ លើក នឹងអនាគតភ័យ ៤ លើក ។

# ថេរវគ្គោ

(៨១) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ រជនីយេ រជ្ជតិ ទុស្សនីយេ ទុស្សតិ មោហនីយេ មុយ្ហតិ កុប្បនីយេ កុប្បតិ មទនីយេ មជ្ជតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ រជនីយេ ន រជ្ជតិ ទុស្សនីយេ ន ទុស្សតិ មោហនីយេ ន មុយ្ហតិ កុប្បនីយេ ន កុប្បតិ

# ថេរវគ្គ

(៨១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុត្រេកអរ ក្នុងអារម្មណ៍ជាទីត្រេកអរ ១ ប្រទូស្តក្នុងអារម្មណ៍ជាទីប្រទូស្ត ១ ភ័ន្តវង្វេង ក្នុងអារម្មណ៍ជាទីភ័ន្តវង្វេង ១ ញាប់ញ័រ ក្នុងអារម្មណ៍ជាទីញាប់ញ័រ ១ ស្រវឹង ក្នុងអារម្មណ៍ជាទីស្រវឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុមិនត្រេកអរ ក្នុងអារម្មណ៍ជាទីត្រេកអរ ១ មិនប្រទូស្ត ក្នុងអារម្មណ៍ជាទីប្រទូស្ត ១ មិនភ័ន្តវង្វេង ក្នុងអារម្មណ៍ជាទីភ័ន្តវង្វេង ១ មិនញាប់ញ័រ ក្នុងអារម្មណ៍ជាទីញាប់ញ័រ ១

មទនីយេ ន មជ្ជតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។

(៨២) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ អវីតរាគោ ហោតិ អវីតទោសោ ហោតិ អវីតមោហោ ហោតិ មក្ខី ច បឡាសី ច ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ វីតរាគោ ហោតិ វីតទោសោ ហោតិ វីតមោហោ ហោតិ អមក្ខី ច អបឡាសី ច ។ ឥមេហិ ខោ ។បេ ។

មិនស្រវឹង ក្នុងអារម្មណ៍ជាទីស្រវឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។

(៨២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនទាន់ប្រាសចាករាគៈ ១ មិនទាន់ប្រាសចាកទោសៈ ១ មិនទាន់ប្រាសចាកមោហៈ ១ ជាអ្នកលុបគុណគេ ១ ប្រណាំងប្រជែងគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកប្រាសចាករាគៈ ១ ប្រាសចាកទោសៈ ១ ប្រាសចាកមោហៈ ១ មិនលុបគុណគេ ១ មិនប្រណាំងប្រជែងគ្នា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។

(៨៣) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ កុហកោ ច ហោតិ លបកោ ច និមិត្តិកោ ច និប្បេសិកោ ច លាភេន លាភំ និជ្ជិគីសិតា ច ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ ន ច កុហកោ ហោតិ ន ច លបកោ ន ច និមិត្តិកោ ន ច និប្បេសិកោ ន ច លាភេន លាភំ និជ្ជិគីសិតា ។ ឥមេហិ ខោ ។ បេ ។

(៨៤) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ

(៨៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកប្រើកិរិយាបំភ័ន្ត ១ ជាអ្នកស្រូតរ៉ា ១ ជាអ្នកនិយាយឲ្យទំនង ១ ជាអ្នកមានកលល្បិច ១ ជាអ្នកស្វែងលាភដោយលាភ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកមិនប្រើកិរិយាបំភ័ន្ត ១ ជាអ្នកមិនស្រូតរ៉ា ១ ជាអ្នកមិននិយាយឲ្យទំនង ១ ជាអ្នកមិនមានកលល្បិច ១ ជាអ្នកមិនស្វែងលាភដោយលាភ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនជឿកម្មនិងផល ១ មិនខ្មាសបាប ១

អនោត្តប្បី ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ។ បេ ។

(៨៥) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ អក្ខមោ ហោតិ រូបានំ អក្ខមោ សទ្ទានំ អក្ខមោ គន្ធានំ អក្ខមោ រសានំ អក្ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ។ បេ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ ខមោ ហោតិ រូបានំ

មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ អប្បឥតប្រាជ្ញា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកជឿកម្មផល ១ ខ្មាសបាប ១ ខ្លាចបាប ១ ប្រឹងព្យាយាម ១ មានប្រាជ្ញា ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។

(៨៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយទេ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផោដ្ឋព្វៈ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកអត់ទ្រាំនឹងរូប ១

ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ។ ឥមេហិ ខោ ។ បេ ។

[៨៦] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ អត្ថប្បដិសម្ភិទាបត្តោ ហោតិ ធម្មប្បដិសម្ភិទាបត្តោ ហោតិ និរុត្តិប្បដិសម្ភិទាបត្តោ ហោតិ បដិភាណប្បដិសម្ភិទាបត្តោ ហោតិ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។ ឥមេហិ ខោ ។ បេ ។

[៨៧] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ បញ្ចហិ ។ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ

អត់ទ្រាំនឹងសំឡេង ១ អត់ទ្រាំនឹងក្លិន ១ អត់ទ្រាំនឹងរស ១ អត់ទ្រាំនឹងផោដ្ឋព្វៈ ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកបានអត្ថប្បដិសម្ភិទា ១ បានធម្មប្បដិសម្ភិទា ១ បាននិរុត្តិប្បដិសម្ភិទា ១ បានបដិភាណប្បដិសម្ភិទា ១ ជាអ្នកឧស្សាហ៍មិនខ្ជិល ក្នុងកិច្ចដែលត្រូវធ្វើអ្វីៗ នោះបីតូចធំ របស់ពួកសព្រហ្មចារី ទាំងប្រកបដោយប្រាជ្ញាឈ្លាសវៃ ក្នុងកិច្ចការនោះល្មមធ្វើបាន ចាត់ចែងបាន ១ ។ ធម៌ ៥ យ៉ាងនេះឯង ។ បេ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុមានសីល ជាអ្នកសង្រួមដោយការសង្រួម ក្នុងបាតិមោក្ខ ប្រកបដោយអាចារៈនិងគោចរៈ តែងឃើញភ័យ ក្នុងទោសទាំងឡាយ នោះបីតិចតួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១

ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

ជាអ្នកស្តាប់ច្រើន ចាំរបស់ដែលស្តាប់ហើយ ចេះចាំលែងភ្លេច នូវរបស់ដែលស្តាប់ហើយ ពួកធម៌ណា មានលំអត្រង់ខាងដើម មានលំអត្រង់កណ្តាល មានលំអត្រង់ខាងចុង ប្រកាសព្រហ្មចារ្យព្រមទាំងអត្ថ ទាំងព្យញ្ជនៈ បរិបូណ៌គ្រប់គ្រាន់ ដ៏បរិសុទ្ធ ភិក្ខុនោះបានស្តាប់ធម៌ មានសភាពយ៉ាងនោះច្រើន ជាអ្នកស្ទាត់រត់មាត់ នឹកឃើញដោយចិត្តបាន ចាក់ធ្លុះល្អដោយប្រាជ្ញាបាន ១ ជាអ្នកមានសំដីពីរោះ គឺកកងល្អ ប្រកបដោយសំដីអ្នកក្រុង ហូរមិនពាក់ មិនខុស ច្បាស់ បានសេចក្តី ១ ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានទូលាយនូវឈានទាំង ៤ ជាឈានអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ របស់សព្រហ្មចារីទាំងឡាយ ។

(៨៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ កតមេហិ បញ្ចហិ ។ ថេរោ ហោតិ រត្តញ្ញូ ចិរបព្វជិតោ ញាតោ ហោតិ យសស្សី សគហដ្ឋបព្វជិតានំ ពហុជនបរិវារោ លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ ។បេ។ ទិដ្ឋិយា សុប្បដិវិទ្ធា មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ សោ ពហុជនំ សទ្ធម្មា វុដ្ឋាបេត្វា អសទ្ធម្មេ បតិដ្ឋាបេតិ ថេរោ ភិក្ខុ រត្តញ្ញូ ចិរបព្វជិតោ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ ញាតោ ថេរោ ភិក្ខុ យសស្សី សគហដ្ឋបព្វជិតានំ ពហុជនបរិវារោ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ លាភី ថេរោ ភិក្ខុ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ

(៨៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកប្រតិបត្តិ មិនបានជាគុណ ដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រី បួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត ១ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងច្បាស់ច្រើន ទាំរបស់ដែលឮហើយ ទាំងលែងភ្លេចនូវរបស់ដែលឮហើយ ។ បេ ។ ចាក់ធ្លុះល្អដោយប្រាជ្ញា ១ តែជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិត ១ ភិក្ខុនោះញុាំងជនច្រើន ឲ្យឃ្លាតចាកព្រះសទ្ធម្ម ឲ្យដម្កល់នៅក្នុងអសទ្ធម្ម ភិក្ខុដទៃដល់នូវទិដ្ឋានុគតិ[1] របស់ភិក្ខុនោះថា ភិក្ខុនោះជាថេរៈ ដឹងរាត្រី បួសយូរខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់ច្រើន ជាអ្នកមានយស មានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា

---

១ យកគម្រាប់តាម ។

ពហុស្សុតោ ថេរោ ភិក្ខុ សុតធរោ សុតសន្និចយោ
ឥតិបិស្ស ទិដ្ឋានុគតិំ អាបជ្ជន្តិ ។ ឥមេហិ ខោ
ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ
ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនា-
សុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ
ទុក្ខាយ ទេវមនុស្សានំ ។ បញ្ចហិ ភិក្ខវេ ធម្មេហិ
សមន្នាគតោ ថេរោ ភិក្ខុ ពហុជនហិតាយ បដិ-
បន្នោ ហោតិ ពហុជនសុខាយ ពហុនោ ជនស្ស
អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កត-
មេហិ បញ្ចហិ ។ ថេរោ ហោតិ រត្តញ្ញូ ចិរបព្វជិតោ
ញាតោ ហោតិ យសស្សី សគហដ្ឋបព្វជិតានំ
ពហុជនបរិវារោ លាភី ហោតិ ចីវរបិណ្ឌបាតសេនាស-
នគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ពហុស្សុតោ ហោតិ
សុតធរោ សុតសន្និចយោ ។ បេ ។ ទិដ្ឋិយា សុប្ប-
ដិវិទ្ធា សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ សោ
ពហុជនំ អសទ្ធម្មា វុដ្ឋាបេត្វា សទ្ធម្មេ បតិដ្ឋាបេតិ

ភិក្ខុនោះជាថេរៈ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៤ យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីមិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនប្រយោជន៍ដល់ជនច្រើន មិនមែនជាគុណទេ ជាទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៤ យ៉ាង ជាអ្នកប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីគុណនឹងសេចក្តីសុខដល់ទេវតានឹងមនុស្សទាំងឡាយ ។ ធម៌ ៤ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រី បួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត ១ ជាអ្នកសម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ។បេ។ ចាក់ធ្លុះ ដោយប្រាជ្ញា ១ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិត ១ ភិក្ខុនោះញុំាងជនច្រើនឲ្យឃ្លាតចាកអសទ្ធម្ម ឲ្យដម្កល់នៅក្នុងព្រះសទ្ធម្ម

ថេរោ ភិក្ខុ រត្តញ្ញូ ចិរប្បព្វជិតោ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ ញាតោ ថេរោ ភិក្ខុ យសស្សី សគហដ្ឋប្បព្វជិតានំ ពហុជនបរិវារោ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ លាភី ថេរោ ភិក្ខុ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ ពហុស្សុតោ ថេរោ ភិក្ខុ សុតធរោ សុតសន្និចយោ ឥតិបិស្ស ទិដ្ឋានុគតឹ អាបជ្ជន្តិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ ពហុជនហិតាយ បដិបន្នោ ហោតិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

(៨៩) បញ្ចិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ ។

ពួកភិក្ខុដទៃដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ដឹងរាត្រី បួសយូរខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈគេដឹង ស្គាល់ច្រើន មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជ-បរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នក ដឹងច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាងនេះ ឯង ឈ្មោះថាប្រតិបត្តិ ដើម្បីគុណដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីគុណ ដើម្បីសេចក្តី សុខដល់ទេវតានិងមនុស្សទាំងឡាយ ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បី សេចក្តីសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តី ត្រេកអរនឹងការងារ ១ សេចក្តីត្រេកអរនឹងតិរច្ឆានកថា ១ សេចក្តី ត្រេកអរនឹងកិរិយាដេកលក់ ១ សេចក្តីត្រេកអរនឹងការប្រឡូកប្រឡំដោយ ពួក ១ មិនពិចារណាចិត្តដែលផុត ( ចាកកិលេស ) យ៉ាងណា ១ ។

ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា ន សង្គណិការាមតា យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

(៩០) បញ្ចិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ សេក្ខោ ភិក្ខុ ពហុកិច្ចោ ហោតិ ពហុករណីយោ អព្យត្តោ កឹករណីយេសុ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ បឋមោ ធម្មោ សេក្ខស្ស ភិក្ខុនោ បរិហា-នាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ អប្បមត្តកេន កម្មេន ទិវសំ អតិនាមេតិ

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនត្រេកអរនឹងការងារ ១ សេចក្តីមិនត្រេកអរនឹងតិរច្ឆានកថា ១ សេចក្តីមិនត្រេកអរនឹងកិរិយាដេកលក់ ១ សេចក្តីមិនត្រេកអរនឹងការនៅច្រឡូកច្រឡំដោយពួក ១ ពិចារណាចិត្តដែលផុត (ចាកកិលេស) យ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

[៩០] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅជាសេក្ខៈ តែមានកិច្ចច្រើន មានការងារច្រើន មិនឈ្លាសវៃ កន្លងកិច្ចដែលត្រូវធ្វើអ្វីៗ វៀរចាកការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបដោយចេតោសមថៈ (សេចក្តីរម្ងាប់ចិត្ត) ខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ ញុំាងថ្ងៃឲ្យកន្លងទៅដោយការងារបន្តិចបន្តួច

រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ ទុតិយោ ធម្មោ សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ សំសដ្ឋោ វិហរតិ សគហដ្ឋបព្វជិតេហិ អននុលោមិកេន គិហិសំសគ្គេន រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ តតិយោ ធម្មោ សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ អកាលេន គាមំ បវិសតិ អតិទិវា បដិក្កមតិ រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា

ព្រោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនៅជាសេក្ខៈ ហើយច្រឡូកច្រឡំ ដោយគ្រហស្ថនឹងបព្វជិត ដោយការជាប់ចំពាក់នឹងគ្រហស្ថ ដ៏មិនសមគួរ ព្រោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ ចូលទៅកាន់ស្រុកពីព្រឹកពេក ចេញមកវិញថ្ងៃពេក ព្រោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោ-សមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាសេក្ខៈ មិនបានតាមសេចក្តីប្រាថ្នា បានលំបាក បានដោយក្រនូវពាក្យដែលជាគ្រឿងជុសខាត់កិលេស ជាទីសប្បាយដល់ធម៌ ជាគ្រឿងបើកចិត្ត គឺពាក្យនាំឲ្យកើតសេចក្តីប្រាថ្នាតិច ពាក្យនាំឲ្យកើតសន្តោស ពាក្យនាំឲ្យស្ងប់ស្ងាត់ ពាក្យមិននាំឲ្យច្រឡូកច្រឡំ (ដោយពួកគណៈ) ពាក្យនាំឲ្យប្រារព្ធសេចក្តីព្យាយាម ពាក្យនាំឲ្យកើតសីល ពាក្យនាំឲ្យកើតសមាធិ ពាក្យនាំឲ្យកើតបញ្ញា

វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឯវរូបិយា កថាយ ន និកាមលាភី ហោតិ កិច្ឆលាភី កសិរលាភី រិញ្ចតិ បដិសល្លានំ នានុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ បញ្ចមោ ធម្មោ សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ បញ្ចិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ សេក្ខោ ភិក្ខុ ន ពហុកិច្ចោ ហោតិ ន ពហុករណីយោ ព្យត្តោ កឹករណីយេសុ ន រិញ្ចតិ បដិសល្លានំ អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ បឋមោ ធម្មោ សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ ន អប្បមត្ត-កេន កម្មេន ទិវសំ អតិនាមេតិ ន រិញ្ចតិ បដិសល្លានំ អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ

វាចានាំឲ្យកើតវិមុត្តិ វាចានាំឲ្យកើតវិមុត្តិញាណទស្សនៈ មានសភាពដូច្នោះ បោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន មិនប្រកបចេតោសមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី៥ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅជាសេក្ខៈ មិនមានកិច្ចច្រើន មិនមានការងារច្រើន ឈ្លាសវៃក្នុងកិច្ចដែលត្រូវធ្វើផ្សេងៗ មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន ប្រកបចេតោ-សមថៈខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិនញុំាងថ្ងៃឲ្យកន្លងទៅ ដោយការងារបន្តិចបន្តួច មិនបោះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបធម៌ជាគ្រឿងស្ងប់ចិត្តខាងក្នុង

អយំ ភិក្ខវេ ទុតិយោ ធម្មោ សេក្ខស្ស ភិក្ខុនោ
អបរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ
ភិក្ខុ អសំសដ្ឋោ វិហរតិ សគ្គហដ្ឋបព្វជិតេហិ អននុ-
លោមិកេន គិហិសំសគ្គេន ន រិញ្ចតិ បដិសល្លានំ
អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ
តតិយោ ធម្មោ សេក្ខស្ស ភិក្ខុនោ អបរិហានាយ
សំវត្តតិ ។ បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ ន
អតិកាលេន គាមំ បវិសតិ នាតិទិវា បដិក្កមតិ ន
រិញ្ចតិ បដិសល្លានំ អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ
អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សេក្ខស្ស ភិក្ខុនោ
អបរិហានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ
សេក្ខោ ភិក្ខុ យាយំ កថា អភិសល្លេខិកា
ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា
សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា
សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិននៅប្រឡូកប្រឡំ ដោយពួកគ្រហស្ថនិងបព្វជិត ដោយការជាប់ជំពាក់នឹងគ្រហស្ថមិនសមគួរ មិនបោះបង់ការពួនសម្ងំ ក្នុងកម្មដ្ឋាន តែងប្រកបសេចក្តីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ មិនចូលទៅកាន់ស្រុកពីព្រឹកពេក មិនចេញមកវិញថ្ងៃពេក មិនបោះបង់ការពួនសម្ងំ ក្នុងកម្មដ្ឋាន តែងប្រកបសេចក្តីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខៈ បានតាមសេចក្តីប្រាថ្នា មិនបានលំបាក បានទូលាយនូវកថា ជាគ្រឿងផុសខាត់កិលេស ជាទីសប្បាយដល់ធម៌ ជាគ្រឿងបើកចិត្ត គឺកថានាំឲ្យមានប្រាថ្នាតិច កថានាំឲ្យសន្តោស កថានាំឲ្យស្ងប់ស្ងាត់ កថាមិននាំឲ្យប្រឡូកប្រឡំដោយពួក កថានាំឲ្យប្រារព្ធព្យាយាម កថានាំឲ្យកើតសីល កថានាំឲ្យកើតសមាធិ កថានាំឲ្យកើតបញ្ញា កថានាំឲ្យកើតវិមុត្តិ

វិមុត្តិញាណទស្សនកថា ឯវរូបិយា កថាយ និកាម-លាភី ហោតិ អកិច្ឆលាភី អកសិរលាភី ន វិញ្ចតិ បដិសល្លានំ អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ អយំ ភិក្ខវេ បញ្ចមោ ធម្មោ សេក្ខស្ស ភិក្ខុនោ អបរិហា-នាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

ថេរវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

រជនីយំ វីតរាគោ
កុហកោ សទ្ធអក្ខមោ
បដិសម្ភិទា ច សីលេន
ថេរោ សេខាបរេ ទុវេតិ ។

វាចានាំឲ្យកើតវិមុត្តិញាណទស្សនៈ មានសភាពដូច្នោះ មិនលះបង់ការពួនសម្ងំក្នុងកម្មដ្ឋាន តែងប្រកបសេចក្តីស្ងប់ចិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។

ចប់ ថេរវគ្គ ទី ៤ ។

## ឧទ្ទាននៃថេរវគ្គនោះ គឺ

និយាយពីអារម្មណ៍ជាទីរីករាយ ១ ពីភិក្ខុប្រាសចាករាគៈ ១ ពីភិក្ខុប្រើកិរិយាបំភ័ន្ត ១ ពីភិក្ខុជឿកម្មផល ១ ពីភិក្ខុមិនអត់ធន់ ១ ពីបដិសម្ភិទា ១ ពីសីល ១ ពីភិក្ខុជាថេរៈ ១ នឹងភិក្ខុជាសេក្ខៈដទៃ ពីរលើកទៀត ។

# កកុធវគ្គោ

(៩១) បញ្ចិមា ភិក្ខវេ សម្បទា ។ កតមា បញ្ច ។ សទ្ធាសម្បទា សីលសម្បទា សុតសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ ឥមា ខោ ភិក្ខវេ បញ្ច សម្បទាតិ ។

(៩២) បញ្ចិមា ភិក្ខវេ សម្បទា ។ កតមា បញ្ច ។ សីលសម្បទា សមាធិសម្បទា បញ្ញាសម្បទា វិមុត្តិសម្បទា វិមុត្តិញាណទស្សនសម្បទា ។ ឥមា ខោ ភិក្ខវេ បញ្ច សម្បទាតិ ។

(៩៣) បញ្ចិមានិ ភិក្ខវេ អញ្ញាព្យាករណានិ ។ កតមានិ បញ្ច ។ មន្ទត្តា មោមូហត្តា អញ្ញំ ព្យាករោតិ បាបិច្ឆោ ឥច្ឆាបកតោ អញ្ញំ ព្យាករោតិ ឧម្មាទា ចិត្តក្ខេបា អញ្ញំ ព្យាករោតិ អធិមានេន អញ្ញំ ព្យាករោតិ សម្មទេវ អញ្ញំ ព្យាករោតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច អញ្ញាព្យាករណានីតិ ។

# កកុធវគ្គ

(៩១) ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៥ យ៉ាង ។ សម្បទា ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ សុតសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សម្បទា ៥ យ៉ាង ។

(៩២) ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន៥ យ៉ាង ។ សម្បទា ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសីលសម្បទា១ សមាធិសម្បទា ១ បញ្ញាសម្បទា ១ វិមុត្តិសម្បទា ១ វិមុត្តិញាណទស្សនសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សម្បទា ៥ យ៉ាង ។

(៩៣) ម្នាលភិក្ខុទាំងឡាយ ការព្យាករណ៍ (អួត) អរហត្តផលនេះមាន ៥ យ៉ាង ។ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុព្យាករអរហត្តផល ព្រោះតែខ្លួនល្ងង់ វង្វេង ១ ភិក្ខុអ្នកមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ហើយព្យាករអរហត្តផល ១ ភិក្ខុព្យាករអរហត្តផល ព្រោះតែឆ្កួត ព្រោះចិត្តរវើរវាយ ១ ភិក្ខុព្យាករអរហត្តផល ដោយសំគាល់ថាខ្លួនបាន ១ ភិក្ខុព្យាករអរហត្តផល តាមត្រឹមត្រូវមែន ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ការព្យាករណ៍អរហត្តផល ៥ យ៉ាង ។

(៩៨) បញ្ចិមេ ភិក្ខវេ ផាសុវិហារា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច ផាសុវិហារាតិ ។

(៩៩) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ អកុប្បំ បដិវិជ្ឈតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អត្ថប្បដិសម្ភិទាបត្តោ ហោតិ ធម្មប្បដិសម្ភិទាបត្តោ ហោតិ និរុត្តិប្បដិសម្ភិទាបត្តោ ហោតិ បដិភាណប្បដិសម្ភិទាបត្តោ ហោតិ យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។

(៩៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានការនៅសប្បាយនេះ មាន ៥ ពួក ។ ភិក្ខុនៅសប្បាយ ៥ ពួក គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈាន ១ ព្រោះរម្ងាប់វិតក្កវិចារៈ ។ បេ ។ បានដល់ទុតិយជ្ឈាន ១ ព្រោះប្រាសចាកបីតិ ។ បេ ។ បានដល់តតិយជ្ឈាន ១ ព្រោះលះបង់សុខផង ។ បេ ។ បានដល់ចតុត្ថជ្ឈាន ១ បានសម្រេចចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យច្បាស់លាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ភិក្ខុមានការនៅសប្បាយ ៥ ពួក ។

(៩៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងត្រាស់ដឹងនូវធម៌មិនកម្រើក (អរហត្ត) យ៉ាងឆាប់រហ័ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបានដល់អត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ពិចារណាចិត្តដែលផុតហើយយ៉ាងណា ១ ។

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ អកុប្បំ បដិវិជ្ឈតីតិ ។

(៩៦) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អានាបានស្សតឹ អាសេវន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អប្បដ្ឋោ ហោតិ អប្បកិច្ចោ សុភរោ សុសន្តោសោ ជីវិតបរិក្ខារេសុ អប្បាហារោ ហោតិ អនោទរិកត្តំ អនុយុត្តោ អប្បមិទ្ធោ ហោតិ ជាគរិយំ អនុយុត្តោ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងបាន ត្រាស់ដឹងធម៌មិនកម្រើក យ៉ាងឆាប់រហ័ស ។

(៩៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង កាល បើធ្វើឲ្យច្រើន បានចំរើននូវអានាបានស្សតិ រមែងបានត្រាស់ដឹងធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ សន្តោសល្អ ក្នុងបរិក្ខារជាគ្រឿងចិញ្ចឹមជីវិតទាំងឡាយ ១ ជាអ្នកមានអាហារតិច ប្រកបរឿយ ៗ នូវភាពជាអ្នកមានអាហារតិចក្នុង ពោះ (មិនល្មោភតែស៊ី) ១ ជាអ្នកដេកលក់តិច ប្រកបការភ្ញាក់រលឹក ១ ជា អ្នកស្តាប់ច្រើន ចាំរបស់ដែលឮហើយ ចាំមិនភ្លេចនូវរបស់ដែលឮហើយ ពួកធម៌ណា មានលំអត្រង់ខាងដើម មានលំអត្រង់កណ្តាល មានលំអ ត្រង់ខាងចុង ប្រកាសព្រហ្មចារ្យ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ បរិសុទ្ធ ពេញលេញអស់ដើង ធម៌មានសភាពដូច្នោះ ភិក្ខុនោះបានស្តាប់ធម៌មាន សភាពយ៉ាងនោះច្រើន ចាំស្ទាត់ រត់មាត់ យល់ច្បាស់ដោយចិត្ត ចាក់ធ្លុះ ល្អដោយប្រាជ្ញា ១ បានពិចារណាចិត្ត ដែលផុតស្រឡះហើយយ៉ាង ណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង

អានាបានស្សតឹ អាសេវន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតីតិ ។

(៩៧) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អានាបានស្សតឹ ភាវេន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អប្បដ្ឋោ ហោតិ អប្បកិច្ចោ សុភរោ សុសន្តោសោ ជីវិតបរិក្ខារេសុ អប្បាហារោ ហោតិ អនោទរិកត្តំ អនុយុត្តោ អប្បមិទ្ធោ ហោតិ ជាគរិយំ អនុយុត្តោ យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឯវរូបិយា កថាយ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។

កាលបើធ្វើឲ្យច្រើននូវអានាបានស្សតិហើយ រមែងត្រាស់ដឹងនូវធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។

(៩៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌៥ យ៉ាង កាលបើធ្វើឲ្យច្រើននូវអានាបានស្សតិ រមែងត្រាស់ដឹងធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។ ធម៌៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ មានសន្តោសល្អក្នុងបរិក្ខារគ្រឿងចិញ្ចឹមជីវិត១ ជាអ្នកមានអាហារតិច ប្រកបរឿយៗ នូវភាពជាអ្នកមានអាហារតិច ក្នុងពោះ១ ជាអ្នកដេកលក់តិច ប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក១ បានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានទូលាយនូវកថា ដែលជាគ្រឿងជុសខាត់កិលេសដ៏ប្រសើរ ជាទីសប្បាយដល់ធម៌ជាគ្រឿងបើកចិត្ត គឺកថានាំឲ្យប្រាថ្នាតិច កថានាំឲ្យសន្តោស កថានាំឲ្យស្ងប់ស្ងាត់ កថាមិននាំឲ្យប្រឡូកប្រឡំដោយពួក (គណៈ) កថានាំឲ្យប្រារព្ធសេចក្តីព្យាយាម កថានាំឲ្យកើតសីល កថានាំឲ្យកើតសមាធិ កថានាំឲ្យកើតបញ្ញា កថានាំឲ្យកើតវិមុត្តិ កថានាំឲ្យកើតវិមុត្តិញាណ-ទស្សនៈ មានសភាពដូច្នោះ១ ពិចារណានូវចិត្តដែលផុតស្រឡះហើយយ៉ាងណា១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង

ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អានាបានស្សតឹ ភាវេន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតីតិ ។

(៩៨) បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អានាបានស្សតឹ ពហុលីករោន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតិ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ អប្បដ្ឋោ ហោតិ អប្បកិច្ចោ សុភរោ សុសន្តោសោ ជីវិតបរិក្ខារេសុ អប្បាហារោ ហោតិ អនោទរិកត្តំ អនុយុត្តោ អប្បមិទ្ធោ ហោតិ ជាគរិយំ អនុយុត្តោ អារញ្ញកោ ហោតិ បន្តសេនាសនោ យថាវិមុត្តំ ចិត្តំ បច្ចវេក្ខតិ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អានាបានស្សតឹ ពហុលីករោន្តោ នចិរស្សេវ អកុប្បំ បដិវិជ្ឈតីតិ ។

(៩៩) សីហោ ភិក្ខវេ មិគរាជា សាយណ្ហសមយំ អាសយា និក្ខមតិ អាសយា និក្ខមិត្វា វិជម្ភតិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេតិ

កាលបើធ្វើឲ្យច្រើននូវអានាបានស្សតិ រមែងបានត្រាស់ដឹងនូវធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។

(៩៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង កាលបើបានធ្វើអានាបានស្សតិឲ្យច្រើន រមែងបានត្រាស់ដឹងធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកខ្វល់ខ្វាយតិច មានកិច្ចតិច គេចិញ្ចឹមងាយ មានសន្តោសល្អ ក្នុងបរិក្ខារគ្រឿងចិញ្ចឹមជីវិត ១ ជាអ្នកមានអាហារតិច ប្រកបរឿយៗ នូវភាពជាអ្នកមានអាហារតិចក្នុងពោះ ១ ជាអ្នកដេកលក់តិច ប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក ១ ជាអ្នកនៅក្នុងព្រៃ មានសេនាសនៈដ៏ស្ងាត់ ១ ពិចារណាចិត្តដែលផុតស្រឡះហើយ យ៉ាងណា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលបើបានធ្វើអានាបានស្សតិឲ្យច្រើន រមែងបានត្រាស់ដឹងធម៌ មិនកម្រើក យ៉ាងឆាប់រហ័ស ។

(៩៩) ម្នាលភិក្ខុទាំងឡាយ សត្វសីហៈជាស្តេចម្រឹគ តែងចេញអំពីទីអាស្រ័យ ក្នុងសម័យរសៀល លុះចេញពីទីអាស្រ័យហើយក៏ម៉ឹតពត់ខ្លួន លុះម៉ឹតពត់ខ្លួនរួចហើយ ក៏ក្រឡេកមើលទិសទាំង ៤ជុំវិញ

សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទតិ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមតិ ។ សោ ហត្ថិស្ស ចេបិ បហារំ ទេតិ សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ មហីសស្ស ចេបិ បហារំ ទេតិ សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ គវស្ស ចេបិ បហារំ ទេតិ សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ ទីបិស្ស ចេបិ បហារំ ទេតិ សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ ខុទ្ទកានញ្ចេបិ បាណានំ បហារំ ទេតិ អន្តមសោ សសពិឡារានំបិ សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ ។ តំ កិស្ស ហេតុ ។ មា មេ យោគ្គបថោ នស្សាតិ ។ សីហោតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ យំ ខោ ភិក្ខវេ តថាគតោ បរិសាយ ធម្មំ ទេសេតិ ឥទមស្ស ហោតិ សីហនាទស្មឹ ភិក្ខូនញ្ចេបិ ភិក្ខវេ តថាគតោ ធម្មំ ទេសេតិ សក្កច្ចញ្ញេវ

លុះក្រឡេកមើលទៅទិសទាំង ៤ ជុំវិញខ្លួនហើយ ក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងរួចហើយ ក៏ដើរចេញទៅស្វែងរកចំណី ។ សត្វសីហៈនោះ កាលបើប្រហារដំរី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារក្របី ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារគោ ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារខ្លាដម្បង ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ បើប្រហារពួកសត្វតូចៗ ដូចទន្សាយនិងឆ្មាជាទីបំផុត ក៏ប្រហារយ៉ាងប្រយ័ត្ន មិនមែនប្រហារខ្ជីខ្ជាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះសត្វសីហៈគិតថា ផ្លូវព្យាយាមរបស់អញកុំវិនាសឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា សត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតសំដែងធម៌ចំពោះបរិសទ្យដោយពាក្យណា នេះជាសីហនាទរបស់ព្រះតថាគតនោះ ម្នាលភិក្ខុទាំងឡាយ បើតថាគតសំដែងធម៌ចំពោះពួកភិក្ខុ តថាគត តែងសំដែងធម៌ដោយប្រយ័ត្នណាស់

តថាគតោ ធម្មំ ទេសេតិ នោ អសក្កច្ចំ ភិក្ខុនី-
នញ្ចេបិ ភិក្ខវេ តថាគតោ ធម្មំ ទេសេតិ សក្ក-
ច្ចញ្ញេវ តថាគតោ ធម្មំ ទេសេតិ នោ អសក្កច្ចំ
ឧបាសិកានញ្ចេបិ ភិក្ខវេ តថាគតោ ធម្មំ ទេសេតិ
សក្កច្ចញ្ញេវ តថាគតោ ធម្មំ ទេសេតិ នោ
អសក្កច្ចំ ឧបាសិកានញ្ចេបិ ភិក្ខវេ តថាគតោ ធម្មំ
ទេសេតិ សក្កច្ចញ្ញេវ តថាគតោ ធម្មំ ទេសេតិ
នោ អសក្កច្ចំ បុថុជ្ជនានញ្ចេបិ ភិក្ខវេ តថាគតោ
ធម្មំ ទេសេតិ អន្តមសោ អន្នភារនេសាទានំបិ
សក្កច្ចញ្ញេវ តថាគតោ ធម្មំ ទេសេតិ នោ
អសក្កច្ចំ ។ តំ កិស្ស ហេតុ ។ ធម្មគរុ ភិក្ខវេ
តថាគតោ ធម្មគារវោតិ ។

[១០០] ឯកំ សមយំ ភគវា កោសម្ពិយំ
វិហរតិ ឃោសិតារាមេ ។ តេន ខោ បន
សមយេន កកុធោ នាម កោលិយបុត្តោ
អាយស្មតោ មហាមោគ្គល្លានស្ស ឧបដ្ឋាកោ អធុនា
កាលកតោ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ

មិនមែនសំដែងទាំងខ្ញីខ្ញាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគត សំដែងធម៌ចំពោះពួកភិក្ខុនី ក៏តថាគត តែងសំដែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសំដែងទាំងខ្ញីខ្ញាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគត សំដែងធម៌ចំពោះពួកឧបាសក ក៏តថាគត តែងសំដែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសំដែងទាំងខ្ញីខ្ញាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគត សំដែងធម៌ចំពោះពួកឧបាសិកា ក៏តថាគត តែងសំដែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសំដែងទាំងខ្ញីខ្ញាទេ ម្នាលភិក្ខុទាំងឡាយ បើតថាគត សំដែងធម៌ចំពោះពួកបុថុជ្ជន ដោយហោចទៅ សូម្បីពួកអ្នកនាំបាយនឹងពួកអ្នកនេសាទ ក៏តថាគត តែងសំដែងធម៌ដោយប្រយ័ត្នណាស់ មិនមែនសំដែងទាំងខ្ញីខ្ញាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតមានធម៌ជាទីគោរព ជាអ្នកគោរពធម៌ ។

[១០០] សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង កូនអ្នកស្រុកកោលិយៈម្នាក់ ឈ្មោះកកុធៈ ជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ទើបនឹងស្លាប់ភ្លាម បានទៅកើតក្នុងពួកទេវតាមួយរូប ដែលសម្រេចដោយចិត្ត

តស្ស ឯវរូបោ អត្តភាវប្បដិលាភោ ហោតិ សេយ្យ-
ថាបិ នាម ទ្វេ វា តីណិ វា មាគធកានិ(១)
គាមក្ខេត្តានិ ។ សោ តេន អត្តភាវប្បដិលាភេន
នេវ អត្តានំ ព្យាពាធេតិ នោ បរំ ព្យាពាធេតិ ។
អថខោ កកុធោ ទេវបុត្តោ យេនាយស្មា មហា-
មោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ
មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។
ឯកមន្តំ ឋិតោ ខោ កកុធោ ទេវបុត្តោ
អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ទេវទត្តស្ស
ភន្តេ ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ ភិក្ខុសង្ឃំ
បរិហរិស្សាមីតិ សហ ចិត្តុប្បាទា ច ភន្តេ ទេវទត្តោ
តស្សា ឥទ្ធិយា បរិហីនោតិ ឥទមវោច កកុធោ
ទេវបុត្តោ ឥទំ វត្វា អាយស្មន្តំ មហាមោគ្គល្លានំ
អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ
អាយស្មា មហាមោគ្គល្លានោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

---

១ ឱ. ម. មាគធិកានិ ។

ទេវបុត្តនោះបានអត្តភាព មានសភាពយ៉ាងនេះ ប្រហែលប៉ុនគាមក្ខេត្ត
របស់អ្នកស្រុកមគធៈពីរ ឬបី ។ ទេវបុត្តនោះ មិនទើសខ្លួនឯង មិន
ទើសអ្នកដទៃ ព្រោះតែការបានអត្តភាពនោះឡើយ ។ គ្រានោះ កកុធ-
ទេវបុត្ត ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់
ហើយ ទើបថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឈរក្នុងទី
សមគួរ ។ លុះកកុធទេវបុត្ត ឈរក្នុងទីសមគួរហើយ បានទូលព្រះមហា-
មោគ្គល្លានដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ទេវទត្តកើតចិត្ត
លុះក្នុងសេចក្តីប្រាថ្នាមានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃ
ដូច្នេះ បពិត្រលោកម្ចាស់ ទេវទត្តក៏សាបសូន្យចាកឫទ្ធិនោះ ដំណាល
គ្នានឹងចិត្តដែលកើតឡើង ។ កកុធទេវបុត្ត បានថ្លែងពាក្យនេះ លុះថ្លែង
ពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហាមោគ្គល្លានដ៏មានអាយុធ្វើ
ប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះឯង ។ លំដាប់នោះ ព្រះមហា-
មោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅ
ដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច កកុធោ នាម ភន្តេ កោលិយបុត្តោ មំ ឧបដ្ឋាកោ អធុនា កាលកតោ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ តស្ស ឯវរូបោ អត្តភាវប្បដិលាភោ សេយ្យថាបិ នាម ទ្វេ វា តីណិ វា មាគធកានិ គាមក្ខេត្តានិ ។ សោ តេន អត្តភាវប្បដិលាភេន នេវ អត្តានំ ព្យាពាធេតិ នោ បរំ ព្យាពាធេតិ ។ អថខោ ភន្តេ កកុធោ ទេវបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ភន្តេ កកុធោ ទេវបុត្តោ មំ ឯតទវោច ទេវទត្តស្ស ភន្តេ ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ សហ ចិត្តុប្បាទា ច ភន្តេ ទេវទត្តោ តស្សា ឥទ្ធិយា បរិហីនោតិ ឥទមវោច ភន្តេ កកុធោ ទេវបុត្តោ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

លុះព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន មានកូនអ្នកស្រុកកោលិយៈម្នាក់ឈ្មោះកកុធៈ ជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គទើបនឹងស្លាប់ថ្មីៗ បានទៅកើតក្នុងពួកទេវតាមួយរូប ដែលសម្រេចដោយចិត្ត ទេវបុត្តនោះបានអត្តភាពយ៉ាងនេះ ប្រហែលប៉ុនគាមក្ខេត្តរបស់អ្នកស្រុកមគធៈពីរឬបី ។ ទេវបុត្តនោះ មិនទើសខ្លួនឯង ទឹងទើសអ្នកដទៃ ព្រោះការបានអត្តភាពនោះទេ ។ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ កកុធទេវបុត្ត ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ ថ្វាយបង្គំខ្ញុំព្រះអង្គ រួចឈរក្នុងទីដ៏សមគួរ ។ លុះកកុធទេវបុត្តនោះ ឈរក្នុងទីដ៏សមគួរហើយ បានថ្លែងពាក្យនេះ នឹងខ្ញុំព្រះអង្គថា បពិត្រលោកម្ចាស់ ទេវទត្តកើតចិត្ត លុះក្នុងសេចក្តីប្រាថ្នា មានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ដំណាលគ្នានឹងចិត្តដែលកើតឡើង បពិត្រព្រះអង្គដ៏ចំរើន កកុធទេវបុត្ត បានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ក្រាបថ្វាយបង្គំលាខ្ញុំព្រះអង្គ ធ្វើប្រទក្សិណហើយ ក៏បាត់ក្នុងទីនោះឯង ។

កឹ បន តេ មោគ្គល្លាន កកុធោ ទេវបុត្តោ ចេតសា ចេតោ បរិច្ច វិទិតោ យំ កិញ្ចិ កកុធោ ទេវបុត្តោ ភាសតិ សព្វន្តំ តថេវ ហោតិ នោ អញ្ញថាតិ ។ ចេតសា ចេតោ បរិច្ច វិទិតោ មេ ភន្តេ កកុធោ ទេវបុត្តោ យំ កិញ្ចិ កកុធោ ទេវបុត្តោ ភាសតិ សព្វន្តំ តថេវ ហោតិ នោ អញ្ញថាតិ ។ រក្ខស្សេតំ មោគ្គល្លាន វាចំ ឥទានិ សោ មោឃបុរិសោ អត្តនាវ អត្តានំ បាតុករិស្សតិ ។ បញ្ចិមេ មោគ្គល្លាន សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ បញ្ច ។ ឥធ មោគ្គល្លាន ឯកច្ចោ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ មយញ្ចេវ ខោ បន គិហីនំ អារោចេស្សាម[១]

---

១ ឱ. ម. អារោចេយ្យាម ។

ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលមោគ្គល្លាន អ្នកបានកំណត់ដឹងច្បាស់នូវចិត្តរបស់កកុធទេវបុត្ត ដោយចិត្ត ហើយថា កកុធទេវបុត្ត និយាយពាក្យណាមួយ ពាក្យទាំងនោះជាពាក្យពិត មិនមែនផ្តេសផ្តាសទៅដែរឬ ។ ព្រះមហាមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គកំណត់ដឹងចិត្តដោយចិត្តច្បាស់ថា កកុធទេវបុត្ត និយាយពាក្យណាមួយ ពាក្យទាំងនោះជាពាក្យពិត មិនមែនផ្តេសផ្តាសទេ ។ ព្រះអង្គត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នករក្សាទុកនូវសំដីនេះ ដ្បិតឥឡូវនេះ មោឃបុរសនោះ ធ្វើខ្លួនឲ្យល្បីដោយខ្លួនឯង ។ ម្នាលមោគ្គល្លាន គ្រូក្នុងលោកនេះ មាន៤ពួក ។ គ្រូ៤ពួក តើដូចម្តេចខ្លះ ។ ម្នាលមោគ្គល្លាន គ្រូពួកមួយ ក្នុងលោកនេះ មានសីលមិនបរិសុទ្ធទេ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធ សីលរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ។ សាវកទាំងឡាយ តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធទេ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធ សីលរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថាបើយើងប្រាប់ដល់ពួកគ្រហស្ថ

នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថំ នុ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា សីលតោ រក្ខន្តិ ឯវរូបោ ច បន សត្ថា សាវកេហិ សីលតោ រក្ខំ បច្ចាសីសតិ ។ បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាតិ បរិសុទ្ធោ មេ អាជីវោ បរិយោទាតោ អសង្កិលិដ្ឋោតិ ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាតិ បរិសុទ្ធោ មេ អាជីវោ បរិយោទាតោ អសង្កិលិដ្ឋោតិ មយញ្ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថំ នុ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន

គង់លោកមិនគាប់ចិត្តទេ ក៏វៀរណា មិនគាប់ចិត្តដល់លោក រវល់អ្វី យើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងតែទំនុកបំរុង ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា លោកគង់នឹងឮខ្ចរខ្ចាយ ព្រោះតែកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវកទាំងឡាយ តែងរក្សាទុកនូវគ្រូបែបនេះ ដោយសីល ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថា ទឹកសង្ឃឹមនូវការរក្សាអំពីពួកសាវក ដោយសីល ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយ ក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធ អាជីវៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវក ដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើន មានអាជីវៈមិនបរិសុទ្ធទេ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធ អាជីវៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថាបើយើងប្រាប់ដល់ពួកគ្រហស្ថគង់លោកមិនគាប់ចិត្តទេ បើវៀរណា មិនគាប់ចិត្តដល់លោក រវល់អ្វី យើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងតែពប់អាន ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ

យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា អាជីវតោ រក្ខន្តិ ឯវរូបោ ច បន សត្ថា សាវកេហិ អាជីវតោ រក្ខំ បច្ចាសីសតិ ។ បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោម្ហីតិ បដិជានាតិ បរិសុទ្ធា មេ ធម្មទេសនា បរិយោទាតា អសង្កិលិដ្ឋាតិ ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោម្ហីតិ បដិជានាតិ បរិសុទ្ធា មេ ធម្មទេសនា បរិយោទាតា អសង្កិលិដ្ឋាតិ មយញ្ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថំ នុ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។

លោកនឹងធ្វើកម្មណា គង់លោកនឹងឮខ្ចរខ្ចាយ ព្រោះតែកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវកទាំងឡាយ តែងរក្សាទុកនូវគ្រូបែបនេះ ដោយអាជីវៈ ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថា ទុកសង្ឃឹមនូវការរក្សា អំពីពួកសាវកដោយអាជីវៈ ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយ ក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ។ ពួកសាវកតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានធម្មទេសនា មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ដូច្នេះ តែថាបើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្ត បើរឿងណា មិនគាប់ចិត្តដល់លោក រវល់អ្វី យើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងរាប់អានយើង ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងឮខ្ចរខ្ចាយ ព្រោះតែកម្មនោះមិនខានទេ ។

ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា ធម្មទេសនតោ រក្ខន្តិ ឯវរូបោ ច បន សត្ថា សាវកេហិ ធម្មទេសនតោ រក្ខំ បច្ចាសីសតិ ។ បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធវេយ្យាករណោ សមានោ បរិសុទ្ធវេ-យ្យាករណោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធវេយ្យាករណោ សមានោ បរិសុទ្ធវេយ្យាករណោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ មយញ្ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថំ នុ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌ-បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្ស-តីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា វេយ្យាករណតោ រក្ខន្តិ ឯវរូបោ ច បន សត្ថា សាវកេហិ វេយ្យាករណតោ រក្ខំ បច្ចាសីសតិ ។

ម្នាលមោគ្គល្លាន ពួកសាវកតែងរក្សាទុកនូវគ្រូបែបនេះ ដោយធម្ម-ទេសនា ឯគ្រូបែបនេះសោត ឈ្មោះថា ទឹកសង្ឃឹមនូវការរក្សាអំពីពួកសាវកដោយធម្មទេសនា ។ ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយក្នុងលោកនេះ មានវេយ្យាករណ៍ មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធ វេយ្យាករណ៍របស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មងទេ ។ ពួកសាវកតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានវេយ្យាករណ៍ មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យា-ករណ៍បរិសុទ្ធ វេយ្យាករណ៍របស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ដូច្នេះ បើយើងប្រាប់ដល់គ្រហស្ថ គង់លោកមិនគាប់ចិត្តទេ បើរឿងណា មិនគាប់ចិត្តដល់លោក រវល់អ្វី យើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងកប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកធ្វើអំពើណា គង់គេដឹងនូវរឿងលោកនោះមិនខានឡើយ ។ ម្នាលមោគ្គល្លាន ពួកសាវកតែងរក្សាទុកនូវគ្រូបែបនេះ ដោយវេយ្យាករណ៍ ចំណែកគ្រូមានសភាពយ៉ាងនោះ ឈ្មោះថា ទឹកសង្ឃឹមនូវការរក្សាអំពីពួកសាវក ដោយវេយ្យាករណ៍ ។

បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា
អបរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញា-
ណទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណ-
ទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ។ តមេនំ
សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អប-
រិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្ស-
នោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ
បរិយោទាតំ អសង្កិលិដ្ឋន្តិ មយញ្ចេវ ខោ បន
គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ
បនស្ស អមនាបំ កថំ នុ មយំ តេន សមុទា-
ចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាត-
សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ
ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។
ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា
ញាណទស្សនតោ រក្ខន្តិ ឯវរូបោ ច បន សត្ថា
សាវកេហិ ញាណទស្សនតោ រក្ខំ បច្ចាសីសតិ ។

ម្នាលមោគ្គល្លាន មួយទៀត គ្រូពួកមួយ ក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវ័ក តែងដឹងគ្រូនោះ យ៉ាងនេះថា គ្រូដ៏ចំរើននេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់អញបរិសុទ្ធ ផូរផង់ មិនសៅហ្មង ដូច្នេះ បើយើងប្រាប់ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ បើរឿងណាមិនគាប់ចិត្តដល់លោក រវល់អ្វី យើងនឹងសើរើរឿងនោះ ព្រោះលោកកំពុងកាប់កាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកធ្វើអំពើណា គង់លោកត្កល្បី ព្រោះអំពើនោះមិនខានឡើយ ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាទុកនូវគ្រូបែបនេះ ដោយញាណទស្សនៈ ឯគ្រូមានសភាពយ៉ាងនេះ ឈ្មោះថា នឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័ក ដោយញាណទស្សនៈ ។

ឥមេ ខោ មោគ្គល្លាន បញ្ច សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ អហំ ខោ មោគ្គល្លាន បរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ។ ន ច មំ សាវកា សីលតោ រក្ខន្តិ ន ចាហំ សាវកេហិ សីលតោ រក្ខំ បច្ចាសីសាមិ ។ បរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាមិ បរិសុទ្ធោ មេ អាជីវោ បរិយោទាតោ អសង្កិលិដ្ឋោតិ ។ ន ច មំ សាវកា អាជីវតោ រក្ខន្តិ ន ចាហំ សាវកេហិ អាជីវតោ រក្ខំ បច្ចាសីសាមិ ។ បរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោម្ហីតិ បដិជានាមិ បរិសុទ្ធា មេ ធម្មទេសនា បរិយោទាតា អសង្កិលិដ្ឋាតិ ។ ន ច មំ សាវកា ធម្មទេសនតោ រក្ខន្តិ ន ចាហំ សាវកេហិ ធម្មទេសនតោ រក្ខំ បច្ចាសីសាមិ ។ បរិសុទ្ធវេយ្យាករណោ សមានោ បរិសុទ្ធវេយ្យាករណោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ។

ម្នាលមោគ្គល្លាន គ្រូ ៥ ពួកនេះឯង តែងមានក្នុងលោក ។ ម្នាលមោគ្គល្លាន ចំណែកតថាគត ជាបុគ្គលមានសីលបរិសុទ្ធ ប្តេជ្ញាថា តថាគតមានសីលបរិសុទ្ធ សីលរបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវក មិនបាច់រក្សាទុកនូវតថាគត ដោយសីលទេ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយសីលទេ ។ តថាគត ជាបុគ្គលមានអាជីវៈបរិសុទ្ធ ប្តេជ្ញាថា តថាគតមានអាជីវៈបរិសុទ្ធ អាជីវៈរបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវក មិនបាច់រក្សាតថាគតដោយអាជីវៈទេ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយអាជីវៈទេ ។ តថាគត ជាបុគ្គលមានធម្មទេសនាបរិសុទ្ធ ប្តេជ្ញាថា តថាគតមានធម្មទេសនាបរិសុទ្ធ ធម្មទេសនារបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវក មិនបាច់រក្សាតថាគត ដោយធម្មទេសនាឡើយ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយធម្មទេសនាទេ ។ តថាគត ជាបុគ្គលមានវេយ្យាករណ៍បរិសុទ្ធ ប្តេជ្ញាថា តថាគតមានវេយ្យាករណ៍បរិសុទ្ធ វេយ្យាករណ៍របស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។

ន ច មំ សាវកា វេយ្យាករណតោ រក្ខន្តិ ន ចាហំ
សាវកេហិ វេយ្យាករណតោ រក្ខំ បច្ចាសីសាមិ ។
បរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណ-
ទស្សនោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ ញាណទស្សនំ
បរិយោទាតំ អសង្កិលិដ្ឋន្តិ ។ ន ច មំ សាវកា
ញាណទស្សនតោ រក្ខន្តិ ន ចាហំ សាវកេហិ
ញាណទស្សនតោ រក្ខំ បច្ចាសីសាមីតិ ។

កកុធវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

ទ្វេ សម្បទា ព្យាករណំ
ផាសុកុប្បេន បញ្ចមំ
សុតំ កថញ្ច អរញ្ញំ
សីហាកកុធេន តេ ទសាតិ ។

ទុតិយោ បណ្ណាសកោ សមត្តោ ។

ពួកសាវក មិនបាច់រក្សាតថាគត ដោយវេយ្យាករណ៍ឡើយ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយវេយ្យាករណ៍ទេ ។ តថាគត ជាបុគ្គលមានញាណទស្សនៈបរិសុទ្ធ ប្ដេជ្ញាថា តថាគតមានញាណទស្សនៈបរិសុទ្ធ ញាណទស្សនៈរបស់តថាគតបរិសុទ្ធ ផូរផង់ មិនសៅហ្មង ។ ពួកសាវក មិនបាច់រក្សាតថាគត ដោយញាណទស្សនៈឡើយ តថាគតសោត ក៏មិនបាច់សង្ឃឹមការរក្សាអំពីពួកសាវក ដោយញាណទស្សនៈទេ ។

ចប់ កកុធវគ្គ ទី ៥ ។

## ឧទ្ទាននៃកកុធវគ្គនោះ គឺ

សម្បទា ២ លើក ការព្យាករណ៍អរហត្តផល ១ ការនៅសប្បាយ ១ ជាគំរប់ ៥ នឹងអកុប្បធម៌ រឿងភិក្ខុបានស្ដាប់ច្រើន ១ កថាវត្ថុ ១ ភិក្ខុនៅព្រៃ ១ សត្វសីហៈ ១ ជាគំរប់ ១០ នឹងរឿងកកុធទេវបុត្ត ។

ចប់ បណ្ណាសក ទី ២ ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស បញ្ចកនិបាតោ

# បញ្ចមោ ភាគោ

---

## បឋមបណ្ណាសកោ

## មាតិកា


| | | | អង្កេ |
|---|---|---|---|
| បឋមបណ្ណាសកេ | សេក្ខពលវគ្គោ | បឋមោ ...... | ១ |
| | ពលវគ្គោ | ទុតិយោ ...... | ១៨ |
| | បញ្ចង្គិកវគ្គោ | តតិយោ ..... | ២៨ |
| | សុមនវគ្គោ | ចតុត្ថោ ....... | ៦៣ |
| | មុណ្ឌរាជវគ្គោ | បញ្ចមោ ....... | ៨៩ |
| ទុតិយបណ្ណាសកេ | នីវរណវគ្គោ | បឋមោ ...... | ១៣០ |
| | សញ្ញាវគ្គោ | ទុតិយោ ....... | ១៦៤ |
| | យោធាជីវវគ្គោ | តតិយោ ...... | ១៧៤ |
| | ថេរវគ្គោ | ចតុត្ថោ ....... | ២៣៤ |
| | កកុធវគ្គោ | បញ្ចមោ ....... | ២៤៦ |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ បញ្ចកនិបាត

# បញ្ចមភាគ

---

## បឋមបណ្ណាសក

## មាតិកា


| | | | | លេខទំព័រ |
|---|---|---|---|---|
| បឋមបណ្ណាសក | សេក្ខពលវគ្គ | ទី | ១ | ១ |
| | ពលវគ្គ | ទី | ២ | ១៨ |
| | បញ្ចង្គិកវគ្គ | ទី | ៣ | ២៨ |
| | សុមនវគ្គ | ទី | ៤ | ៦៣ |
| | មុណ្ឌរាជវគ្គ | ទី | ៥ | ៨៩ |
| ទុតិយបណ្ណាសក | នីវរណវគ្គ | ទី | ១ | ១៣០ |
| | សញ្ញាវគ្គ | ទី | ២ | ១៦២ |
| | យោធាជីវវគ្គ | ទី | ៣ | ១៧២ |
| | ថេរវគ្គ | ទី | ៤ | ២៣២ |
| | កកុធវគ្គ | ទី | ៥ | ២៤៦ |


---

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE